សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ កក្កដា ឆ្នាំ ២០១៧

# លីអាហូណា



## ដើម្បីធ្វើជាពួកបរិសុទ្ធថ្ងៃចុងក្រោយគឺត្រូវតែធ្វើជាអ្នកត្រួសត្រាយ
ទំព័រ ២៤, ៣០, ៥៦, ៦៤

គោលការណ៍ប្រាំមួយយ៉ាងដើម្បីជួយពួកយើងឲ្យក្លាយជាគ្រូបង្រៀនដែលសង្គ្រោះដល់ព្រលឹង ទំព័រ ៨

កងទ័ពជំរំសីយ៉ូន ៖ មេរៀនស្ដីពីការរៀនសូត្រ និងការធ្វើតាមពួកបងប្អូនប្រុស ទំព័រ ១៤

អ្វីដែលខ្ញុំបានរៀនអំពីការសាកល្បងមកពីការធ្វើជាឪពុកម្ដាយ ទំព័រ ៣៤




*ការជួបជុំគ្នានៅក្រោមបដាដែលសរសេរថា « ពួកអ្នកត្រួសត្រាយឆ្នាំ ១៨៤៧ » បុរស និងស្ត្រី ដែលបានចូលទៅជ្រលងភ្នំ សលត៍ លេក ក្នុងឆ្នាំ ១៨៤៧ បានជួបជុំគ្នាសម្រាប់ការប្រារព្ធកម្មវិធីថ្ងៃទី ២៤ ខែ កក្កដា ក្នុងឆ្នាំ ១៩០៥ ។*

ប្រថតទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពី បណ្ណាល័យប្រវត្តិសាសនាចក្រ

# លីអាហូណា ខែ កក្កដា ឆ្នាំ ២០១៧





## សារលិខិត

**៤ សារលិខិតគណៈប្រធានទីមួយ ៖ រង្វាន់នៃការស៊ូទ្រាំដោយហ្មត់ចត់**
ដោយ ប្រធាន ហិនរី ប៊ី អាវរីង

**៧ សារលិខិតបង្រៀនសួរសុខទុក្ខ ៖ ដើម្បីឲ្យគេបានរួមគ្នាតែមួយ**

## អត្ថបទពិសេសៗ

**១២ អព្ភូតហេតុដ៏ពិត**
ដោយ ដុន អែល. សៀរល៍
*ការជាសះស្បើយរបស់ ប៉ោឡា គឺជាអព្ភូតហេតុមួយ ប៉ុន្តែអព្ភូតហេតុដែលកាន់តែអស្ចារ្យជាងនេះទៅទៀតនោះគឺ របៀបដែលព្រះអង្គសង្គ្រោះបានផ្លាស់ប្ដូរដួងចិត្តរបស់គ្រួសារគាត់ ។*

**១៤ នៅខាងព្រះអម្ចាស់ ៖ មេរៀនមកពីកងទ័ពដំរសីយ៉ូន**
ដោយ អែលឌើរ ដាវីឌ អេ បែដណា
*មេរៀនដ៏មានតម្លៃនានាមកពីក្រុមនេះដែលបានធ្វើដំណើរចម្ងាយ ១៤៥០ គីឡូម៉ែត្រ ដើម្បីជួយពួកបរិសុទ្ធដែលជាបងប្អូនរបស់ពួកគេ ។*

**២៤ ការរៀនស្ដាប់ ៖ សាខាដែលមានពូជសាសន៍ចម្រុះដំបូងគេនៅអាហ្វ្រិកខាងត្បូង**
ដោយ ម៉ាត ម៉ាកប្រ៊ីដ និង ជេមស៍ ហ្គោលបើក
*អំឡុងពេលនៃការបំបែកពូជសាសន៍ ពួកបរិសុទ្ធទាំងនេះបានរៀនស្រឡាញ់គ្នា នៅពេលពួកគេបានចាប់ផ្ដើមស្ដាប់ យល់ និងរាប់អានគ្នាទៅវិញទៅមក ។*

**២៨ ការផ្សះផ្សាប្រទេសដ៏ជាទីស្រឡាញ់ ៖ សេចក្ដីជំនឿរបស់ ជូលៀ ម៉ាវីមបេឡា**
ដោយ ម៉ាថាយ ខេ ហៀស
*ទោះបីជាមានសោកនាកម្មនៅក្នុងជីវិតគាត់ក្ដី នៅទីបំផុត ជូលៀ ម៉ាវីមបេឡា បានរកឃើញនូវភាពសុខសាន្ត ។*

**៣០ ដេសុីឌើរៀ យ៉ាញ៉េស្ស ៖ អ្នកត្រួសត្រាយក្នុងចំណោមពួកស្ត្រី**
ដោយ ក្លីនតុន ឌី គ្រីស្ទីនសិន
*តាមរយៈការធ្វើតាមសុបិន និងការបំផុសគំនិត ដេសុីឌើរៀ យ៉ាញ៉េស្ស បានរកឃើញទ្រព្យសម្បត្តិដ៏មានតម្លៃបំផុតរបស់គាត់ ។*

**៣៤ ការចិញ្ចឹមបីបាច់កូនប្រុសរបស់យើងក្នុងភាពជាដៃគូជាមួយព្រះ**
ដោយ ខាមី ក្រូកស្តុន
*ការមើលថែទាំកូនប្រុសរបស់ខ្ញុំដែលមានជំងឺ ADHD ធ្ងន់ធ្ងរ ហាក់បីដូចជាការសាកល្បងមួយដែលមិនចេះចប់មិនចេះហើយ ។ តើខ្ញុំត្រូវរៀនអ្វីអំពីរឿងនេះ ?*

## ផ្នែកនានា

**៨ ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ ៖ គ្រូបង្រៀនដែលជួយសង្គ្រោះព្រលឹង**
ដោយ ប្រាយអិន ហេនប្រូវ

**៣៨ ការបង្ហាញអំពីសេចក្ដីជំនឿ ៖ ម៉ើរីឡូ វីសិនធេ លីធេ រីបៀរ៉ូ**

**៤០ សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**៨០ លុះត្រាជួបទៀត ៖ ពួកគេគឺជាក្រុមរទេះចុងក្រោយគេ**
ដោយប្រធាន ជេ រ៉ូប៊ីន ក្លាក ជុញ៉រ




**នៅលើក្របមុខ**
រូបថតរបស់គ្រួសារអ្នកត្រួសត្រាយនៅក្នុងប្រទេស បូលីវី ដោយ ឡេសលី និលសុន ។

## យុវមជ្ឈិមវ័យ





**៤៤ ដំណឹងតែមួយគត់ដែលបានសង្គ្រោះខ្ញុំ**
ដោយ ស្ស៊ូហូ តាកាយ៉ាម៉ា បានប្រាប់ដល់ អាណា លីសា ក្លាក ម៉ូឡិន
*ខ្ញុំមានការបាក់ទឹកចិត្ត និងឯកោ ។ តើខ្ញុំអាចរកបានកល្យាណមិត្តដែរឬទេ ?*

**៤៨ ការដើរតួក្នុងឈុតដ៏សំខាន់បំផុត**
ដោយ អាននី ម៉ាក់ខរមីក បូននើរ
*ខ្ញុំមានចិត្តរំភើបដើម្បីដើរតួដ៏សំខាន់នៅក្នុងល្ខោន — រហូតដល់ខ្ញុំបានអានអត្ថបទសាច់រឿងនោះ ។*




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ សូមមើលនៅក្បែរដើមឈើ ។***

## យុវវ័យ


**៥០ រឹងប៉ឹងពេញមួយសប្ដាហ៍**
*តើពិធីសាក្រាម៉ង់មានអត្ថន័យបែបណាចំពោះអ្នក ?*

**៥៤ ចម្លើយមកពីថ្នាក់ដឹកនាំនៃសាសនាចក្រ : របៀបទទួលបានទីបន្ទាល់**
ដោយ អែលឌើរ ដាល្លិន អេក អូក

**៥៥ ចំទៅនឹងគោលដៅ**
*តើយើងវិនិច្ឆ័យដោយសុចរិតតាមរបៀបណា ? តើត្រូវនិយាយអំពីការណ៍អាសគ្រាមជាមួយប៊ីស្សពរបស់ខ្ញុំឬ ?*

**៥៦ ដំណើរត្រួសត្រាយរបស់អ្នក — ដំណើរពិតប្រាកដពុំមែនប្រឌិតឡើយ**
ដោយ អើរ៉ុន អិល វ៉េស
*ពួកអ្នកត្រួសត្រាយបច្ចុប្បន្ននេះធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។*

**៦០ ចម្រៀងមួយបទសម្រាប់ម៉ាណុន**
ដោយ រីឆាឌ អិម រ៉មនី
*ម៉ាណុនឈឺហើយពុំអាចសម្ដែងបានឡើយ ប៉ុន្តែមិត្តភក្តិរបស់នាងពុំបានបំភ្លេចនាងឡើយ ។*

**៦៣ ប័ណ្ណប្រកាស : ចូរឡើងឲ្យកាន់តែខ្ពស់**





## កុមារ





**៦៤ ផ្លូវទៅកាន់ស៊ីយ៉ូន**
ដោយ ជេស៊ីកា ឡសិន
*ម៉ារីត្រូវនាំគ្រួសារនាងទៅរហូតដល់ជ្រលងភ្នំសលត៍ លេក ដោយខ្លួននាងផ្ទាល់ ។ តើនាងអាចធ្វើវាបានដែរឬទេ ?*

**៦៨ តមអាហារសម្រាប់ព្យាការី**
ដោយ រ៉េបេកា ជេ ខាលសុន
*ស៊ីលីអូទី ឃ្លាន ប៉ុន្តែនាងចង់តមអាហារសម្រាប់ប្រធាន ឃីមបឺល ។*

**៧០ ជ្រុងមួយនៃសំណួរ : តើខ្ញុំដឹងថា ខ្ញុំធំល្មមនឹងចាប់ផ្ដើមតមអាហារបានដោយរបៀបណា ?**

**៧១ ការបញ្ចាំងពន្លឺរបស់អ្នក**
ដោយ អែលឌើរ ឡារី អេស ខាធើរ
*អ្នកអាចធ្វើគំរូអំពីព្រះគ្រីស្ទ មិនថាអ្នកនៅក្មេងឡើយ ។*

**៧២ កាបូបលុយវេទមន្ត**
ដោយ អាម៉ានដា វ៉ៃតធើរ
*តើការយកកាបូបលុយត្រឡប់ទៅវិញពិតជាធ្វើឲ្យមានការផ្លាស់ប្ដូរដ៏ធំមួយឬ ?*

**៧៤ ចម្លើយមកពីសាវក : តើក្រុមប្រឹក្សាគ្រួសារជាអ្វី ?**
ដោយ អែលឌើរ អិម រ័សុល បាឡឺដ

**៧៥ រូបភាពប្រវត្តិសាសនាចក្រ : ទីក្រុង ខឺតឡង់ និងច្បាប់ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ**

**៧៦ រឿងអំពីព្រះយេស៊ូវ : ព្រះយេស៊ូវបានប្រទានអាហារដល់មនុស្សជាច្រើន**
ដោយ គីម វិប រៀដ

**៧៩ ទំព័រផាត់ពណ៌ : ខ្ញុំចូលចិត្តអានព្រះគម្ពីរ**

# យោបល់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ពីរ ។*



**« កាបូបលុយវេទមន្ត »** ទំព័រ ៧២ ៖ អ្នកអាចចាប់ផ្ដើមរាត្រីជួបជុំក្រុមគ្រួសារដោយច្រៀងបទ « ជ្រើសផ្លូវត្រូវ » ( *ទំនុកតម្កើង* លេខ ១៤៨ ) អ្នកអាចដើរតួក្នុងស្ថានភាពដើម្បីជ្រើសផ្លូវត្រូវជាមួយគ្រួសាររបស់អ្នក ។ ឧទាហរណ៍ តើអ្នកនឹងធ្វើដូចម្ដេច ប្រសិនបើអ្នកត្រូវបានល្បួងឲ្យលួចចម្លងពេលប្រឡង ឬជកនរណាម្នាក់មិនឲ្យចូលរួមក្នុងសកម្មភាពអ្វីមួយនោះ ? សូមធ្វើឲ្យស្ថានភាពទាំងនោះដូចជារឿងផ្ទាល់ខ្លួន ដើម្បីត្រូវនឹងស្ថានភាពរបស់គ្រួសារអ្នក ។

**« តើក្រុមប្រឹក្សាគ្រួសារជាអ្វី ? »** ទំព័រ ៧៤ ៖ ដើម្បីរៀបចំសម្រាប់ក្រុមប្រឹក្សាគ្រួសាររបស់អ្នកផ្ទាល់ អ្នកអាចបង្កើតច្បាប់ ឬគោលដៅសម្រាប់ក្រុមប្រឹក្សាគ្រួសារ ។ សូមឲ្យសមាជិកក្នុងគ្រួសារចែកចាយយោបល់របស់ពួកគេ ។ ច្បាប់ និងគោលដៅអាចរួមមាន ការបិទឧបករណ៍អេឡិចត្រូនិច ការស្ដាប់គ្នា ការនិយាយអំពីព្រឹត្តិការណ៍ដែលនឹងកើតមានឡើង និងការដាក់គោលដៅយូរអង្វែងសម្រាប់គ្រួសារ ។ សូមធ្វើឲ្យក្រុមប្រឹក្សាគ្រួសាររបស់អ្នកក្លាយជារឿងផ្ទាល់ខ្លួន ហើយធ្វើវាឲ្យមានភាពរីករាយ ប្រយោជន៍ឲ្យសមាជិកគ្រួសារនឹងទន្ទឹងរង់ចាំដើម្បីធ្វើក្រុមប្រឹក្សាគ្រួសារ ។

## មានធនធានជាច្រើនទៀតនៅលើអ៊ិនធើរណែត

សូមអាន ចែកចាយ និងស្វែងរកតាមអ៊ិនធើរណែតនៅគេហទំព័រ **liahona.lds.org** ។

សូមផ្ញើមតិកែលម្អទៅកាន់ **liahona@ldschurch.org** ។

សូមស្វែងរកសារលិខិតបំផុសគំនិតនៅគេហទំព័រ **facebook.com/liahona.magazine** ( មានជាភាសា អង់គ្លេស ព័រទុយហ្គាយ និង អេស្ប៉ាញ ) ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**

*លេខទាំងឡាយគឺ តំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*


**កងទ័ពជំរំស៊ីយ៉ូន,** *១៤*
**ការគោរពប្រតិបត្តិ,** *៤, ១៤*
**ការតមអាហារ,** *៦៨, ៧៩*
**ការធ្វើជាឪពុកម្ដាយ,** *៣៤*
**ការបង្រៀន,** *៨*
**ការបង្រៀនតាមផ្ទះ,** *៤៣*
**ការបន្ទាបខ្លួន,** *១៤*
**ការបម្រើ,** *៤, ៤៣, ៦០*
**ការប្រែចិត្ត,** *១២, ៥៥*
**ការប្រែចិត្តជឿ,** *១២, ៤៤*
**ការយល់ចិត្ត,** *២៤, ២៨*
**ការស៊ូទ្រាំ,** *៤, ៣០, ៣៤, ៦០, ៨០*
**ការអប់រំ,** *៤០*
**ការអភ័យទោស,** *២៨*
**កិច្ចការផ្សព្វផ្សាយសាសនា,** *១២, ២៨, ៣០, ៤២, ៤៤, ៧១*
**ក្រុមគ្រួសារ,** *១២, ៣៤, ៧៤*
**គំរូ,** *៥៥, ៧១*
**ថ្ងៃឈប់សម្រាក,** *៣៨, ៥០*
**ទីបន្ទាល់,** *៥៤*
**ទុក្ខវេទនា,** *៤, ១៤, ៤១, ៤៤*
**ទេពកោសល្យ,** *៤៨*
**ប្រវត្តិសាសនាចក្រ,** *១៤, ២៤, ៣០, ៦៤, ៧៥*
**ពង្សប្រវត្តិ,** *៤១*
**ពិធីសាក្រាម៉ង់,** *៥០, ៥៤*
**ព្រះគម្ពីរ,** *៧៩*
**ព្រះយេស៊ូវគ្រីស្ទ,** *៧, ៨, ៤១, ៥៦, ៦៣, ៧៦, ៨០*
**ភាពក្លាហាន,** *៦៤, ៧២*
**ភាពជាសិស្ស,** *១៤, ៤៨, ៥៦, ៦៣, ៨០*
**ភាពទៀងត្រង់,** *៧២*
**មិត្តភាព,** *៤៤, ៦០, ៧១*
**សាមគ្គីភាព,** *៧, ២៤, ៦០*
**សេចក្ដីជំនឿ,** *៤, ៤០, ៦០, ៦៤, ៦៨*
**ស្ត្រី,** *២៨, ៣០, ៦៤*
**អព្ភូតហេតុ,** *១២*
**អាពាហ៍ពិពាហ៍,** *៤០*
**អ្នកត្រួសត្រាយ,** *១៤, ២៤, ២៨, ៣០, ៥៦, ៦៤*



**ខែ កក្កដា ឆ្នាំ ២០១៧ វ៉ុល ៤១ លេខ ៧**
**លីអាហូណា 14447 258**
ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ



**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អិម. រ័សុល បាឡឺដ, រ៉ូបឺត ឌី ហែល, ជែហ្វ្រី អ័រ ហូឡិន, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវ៉ែនសុន, ឌែល ជី រេនឡាន់

**និពន្ធនាយក ៖** យ៉ូសែប ដបុលយូ. ស៊ីតាទី
**ជំនួយការនិពន្ធនាយក ៖** រ៉េនដល យេ បិនណ្ណិត, ខារ៉ូ អេហ្វ ម៉ាកខន់ឃី
**អ្នកប្រឹក្សា ៖** ប្រែន ខេ អាស្តុន, ជីន ប៊ី ប៊ីងហាំ, ឡឺហ្វ្រង់ ឬ ខឺធីស ជុញ្ញ័រ, គ្រីស្តូហ្វែល ហ្វូលឌិន, ដូហ្គ្លាស ឌី ហូលមែស, អ៊ីរិក ដុបយូរ កូពីស្កេ, លែរី អរ ឡរិន, ខារ៉ូល អិម ស្ទេហ្វិន

**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយបិហ្គ
**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់
**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រដាម ស៊ី អូស្ទុន
**ជំនួយការ ការគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ាយអិន ខារ
**ជំនួយការបោះពុម្ព ៖** មេហ្គេន ស៊ីត
**និពន្ធ និងកែសម្រួលដោយ ៖** ម៉ារីសា ខែននី, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាធ្យូ ឌី ហ្វីតុន, ឡារី ហូលើរ, ហ្គាប៉េត អេច ហ្គាហ្វ, ឡាប៉េន ផតទើរ ហ្គាន, ចុន រ៉ាយអេន ជែនសិន, ឆាលទ្បុត ឡាកាបាល់, មែឃល អរ ម៉ូរីស, អ៊ីរីក ប៊ី ម៉ដុក សាលី ចនសុន អូដេឃីក, យ៉ូស្វេ ជេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉ូមនី, មីនឌី អាន សេលូ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ថេដ អ័រ ភីធើរសុន
**រចនាប្លង់ដោយ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, ស៊ី ឃីមបឹល បុត, ថូម៉ាស ឆាល, ដេវីឌ ហ្គ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡហ្វ្គីន, ស្កត អិម ម៉ូយ, ម៉ាក ដប៉ុលយូ រ៉ូប៊ីសុន, រ៉ាជែល ស្មីធ, ប្រាត ធៀរ, យេ នីកូល វ៉ែកឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នែបេឃើ អាននី
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ហ្គែន អាឌៀ, ខនី បិរទួប ប្រ៊ីច, ជូលី ប៊ីដេត, ថូម៉ាស ជី គ្រូនីន, ខេទី ដានខាន, ប្រៃអិន ដប៉ុលយូ ជីជី, ជីនី ជេ និលសុន, ហ្គែល ធេត រ៉ាហ្វីជី
**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស

**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ធី លេវីស
**នាយកចែកចាយ ៖** ត្រយ ខេ វេលីនហ្គា



ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬសាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និង សំណួរនានា** តាមអ៊ិនធើណែតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាម៉ៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ៊្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, នរវេ, ប៉ូឡូញ, ព័រទុយហ្គាយ, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។

( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។



© 2017 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

ព័ត៌មានអំពីកម្មសិទ្ធិបញ្ញា ៖ លុះត្រាមានការបញ្ជាក់ បុគ្គលម្នាក់ៗអាចថតចម្លងឯកសារចេញពី*លីអាហូណា*នេះសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬ ពុំមែនដើម្បីធ្វើអាជីវកម្ម ( រួមទាំងការហៅបម្រើក្នុងសាសនាចក្រ ) ។ សិទ្ធិនេះអាចត្រូវបានលុបចោលវិញគ្រប់ពេល ។ រូបភាពពុំអាចថតចម្លងបានឡើយ ប្រសិនបើឃើញមានការដាក់បម្រាមបង្ហាញនៅក្នុងជួរបន្ទាត់នៃការដកស្រង់នៃរូបភាពនោះ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., FL 13, Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។



**For Readers in the United States and Canada:**
July 2017 Vol. 16 No. 4. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $10.00 per year; Canada, $12.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.



**ដោយប្រធាន**
**ហិនរី ប៊ី អាវរិង**
ទីប្រឹក្សាទីមួយក្នុង
គណៈប្រធានទីមួយ

# រង្វាន់នៃ ការស៊ូទ្រាំ ដោយហ្មត់ចត់

កាលខ្ញុំនៅជាយុវជន ខ្ញុំបានបម្រើនៅក្នុងសាសនាចក្រជាទីប្រឹក្សារបស់ប្រធានមណ្ឌលដ៏វាងវៃមួយរូប ។ គាត់បានព្យាយាមបង្រៀនខ្ញុំជានិច្ច ។ ខ្ញុំចាំថាមានគ្រាមួយនោះ គាត់បានផ្ដល់ដំបូន្មានដល់ខ្ញុំថា ៖ « កាលណាអ្នកជួបនរណាម្នាក់ សូមប្រព្រឹត្តនឹងពួកគេ ដូចពួកគេកំពុងមានបញ្ហាធ្ងន់ធ្ងរ ហើយអ្នកនឹងធ្វើរឿងត្រឹមត្រូវបានដល់ជាងពាក់កណ្ដាលទៅហើយ » ។ កាលនោះខ្ញុំគិតថាគាត់មានភាពទុទិដ្ឋិនិយមណាស់ ។ ឥឡូវនេះវាជាង ៥០ឆ្នាំហើយ ខ្ញុំអាចឃើញថាគាត់យល់ដឹងពីពិភពលោក និងជីវិតនេះបានយ៉ាងច្បាស់ ។

យើងទាំងអស់គ្នាប្រឈមមុខនឹងការសាកល្បងនានា — ជួនកាលវាពិតជាលំបាកហួសប្រមាណ ។ យើងដឹងថាព្រះអម្ចាស់ទុកឲ្យយើងហែលឆ្លងកាត់ការសាកល្បងនានា ដើម្បីឲ្យយើងអាចដុសខាត់ខ្លួនយើងឲ្យប្រសើរឡើង និងឲ្យបានល្អឥតខ្ចោះ ប្រយោជន៍ឲ្យយើងអាចរស់នៅជាមួយទ្រង់ជារៀងរហូត ។

ព្រះអម្ចាស់បានបង្រៀនព្យាការី យ៉ូសែប ស៊្មីធ នៅក្នុងគុកលីបើធីថា រង្វាន់សម្រាប់ការស៊ូទ្រាំដោយហ្មត់ចត់ទៅនឹងការសាកល្បងរបស់លោក នឹងជួយលោកឲ្យមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជីវិតអស់កល្បជានិច្ច ៖

« បុត្រយើងអើយ ចូរមានសេចក្ដីសុខសាន្តដល់ព្រលឹងបុត្រចុះ សេចក្ដីទំនាស់ និងសេចក្ដីលំបាករបស់អ្នកនោះគ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ

ហើយខណៈនោះ បើសិនជាអ្នកស៊ូទ្រាំការណ៍នោះដោយហ្មត់ចត់ នោះព្រះទ្រង់នឹងតម្កើងអ្នកឡើងនៅស្ថានខ្ពស់ » ( គ. និង ស. ១២១:៧–៨ ) ។

យើងជួបប្រទះរឿងជាច្រើននៅក្នុងជីវិតនេះ ដែលវាហាក់បីដូចជាលំបាកឲ្យយើងស៊ូទ្រាំដោយហ្មត់ចត់បាន ។ វាប្រៀបដូចទៅនឹងគ្រួសារមួយដែលពឹងផ្អែកលើការដាំដុះពេលគ្មានភ្លៀងធ្លាក់អញ្ចឹងដែរ ។ ពួកគេអាចឆ្ងល់ថា « តើយើងអាចស៊ូទ្រាំបានយូរប៉ុណ្ណាទៅ ? » វាប្រៀបដូចទៅនឹងយុវជនម្នាក់ដែលបានប្រឈមមុខទប់ទល់នឹងទង្វើស្មោកគ្រោក និងការល្បួងដែលកំពុងតែកើនឡើង ។ វាប្រៀបដូចទៅនឹងយុវជនម្នាក់ដែលកំពុងពុះពារទទួលការអប់រំ ឬការបំពាក់បំប៉ននានា ដែលគាត់ត្រូវការសម្រាប់ការងារមួយ ដើម្បីឧបត្ថម្ភភរិយា និងគ្រួសារ ។ វាប្រៀបដូចទៅនឹងមនុស្សម្នាក់ដែលពុំអាចរកការងារធ្វើបាន ឬបុគ្គលម្នាក់ដែលបាត់បង់ការងារជាច្រើនខណៈដែលអាជីវកម្មនានាត្រូវបានបិទទ្វារឈប់ដំណើរការ ។ វាប្រៀបដូចទៅនឹងអស់អ្នកដែលប្រឈមមុខជាមួយនឹង ការទ្រុឌទ្រោមនៃសុខភាព និងកម្លាំងរូបកាយដែលវាអាចកើតទាំងក្នុងវ័យក្មេង ឬវ័យចំណាស់របស់ពួកគេ ឬដល់អស់អ្នកដែលពួកគេស្រឡាញ់ ។

ប៉ុន្តែព្រះដែលពេញដោយក្ដីស្រឡាញ់ ពុំបានដាក់ការសាកល្បងបែបនោះនៅចំពោះមុខយើង ដើម្បីគ្រាន់តែដឹងថាតើយើងអាចស៊ូទ្រាំនឹងការលំបាកនោះបាន ឬអត់នោះឡើយ ផ្ទុយទៅវិញគឺដើម្បីមើលថាតើយើងអាចស៊ូទ្រាំនឹងការលំបាកទាំងនោះបានហ្មត់ចត់ប៉ុណ្ណា ហើយប្រែកាន់តែប្រសើរឡើង ។

គណៈប្រធានទីមួយបានបង្រៀនអែលឌើរ ប៉ាលី ភី ប្រាត្ត ( ១៨០៧–៥៧ ) ពេលលោកត្រូវបានហៅឲ្យធ្វើជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ថ្មីថ្មោងដូចនេះ ៖ « អ្នកត្រូវបានជ្រើសឲ្យបម្រើនៅក្នុងបុព្វហេតុមួយដែលតម្រូវឲ្យអ្នកមានការផ្ដោតចិត្តទុកដាក់ទាំងស្រុង . . . ក្លាយជាតួព្រួញដែលខាត់រំលីង ។ . . . អ្នកត្រូវតែស៊ូទ្រាំនឹងការលំបាក ការធ្វើកិច្ចការ និងការសាកល្បងជាច្រើនដើម្បីត្រូវបានដុសខាត់ឲ្យបានល្អឥតខ្ចោះ ។ . . . ព្រះវរបិតាសួគ៌របស់អ្នកតម្រូវនូវអ្វីៗទាំងនេះ វាលស្រែគឺជារបស់ផងទ្រង់ កិច្ចការនេះគឺជារបស់ផងទ្រង់ ហើយទ្រង់នឹង . . . ធ្វើឲ្យចិត្តអ្នករីករាយឡើង . . . ហើយទ្រង់នឹងគាំទ្រអ្នក » ។[១]

នៅក្នុងគម្ពីរហេព្រើរ ប៉ុលនិយាយអំពីផលផ្លែនៃការស៊ូទ្រាំដោយហ្មត់ចត់ដូចនេះ ៖ « កាលណាយើងត្រូវសេចក្ដីផ្ចាញ់ផ្ចាល នោះមើលទៅដូចជាព្រួយណាស់ មិនមែនសប្បាយទេ តែក្រោយមក នោះទើបបង្កើតផលដ៏សុខសាន្ត នៃសេចក្ដីសុចរិតដល់អស់អ្នកណាដែលត្រូវរងទ្រាំនោះវិញ » ( ហេព្រើរ ១២:១១ ) ។

ការសាកល្បង និងទុក្ខលំបាករបស់យើងផ្ដល់ឱកាសឲ្យយើងរៀន និងរីកចម្រើន ហើយវាអាចផ្លាស់ប្ដូរលក្ខណៈរបស់យើងបាន ។ ប្រសិនបើយើងអាចបែរទៅរកព្រះអង្គសង្គ្រោះ អំឡុងពេលនៃការសាកល្បងដ៏លំបាករបស់យើង នោះព្រលឹងយើងអាចត្រូវបានដុសខាត់ នៅពេលយើងស៊ូទ្រាំ ។



ហេតុដូច្នោះហើយ កិច្ចការដំបូងដែលត្រូវចងចាំនោះគឺអធិស្ឋានជានិច្ច ( សូមមើល គ. និង ស. ១០:៥; អាលម៉ា ៣៤:១៩–២៩ ) ។

ទីពីរត្រូវព្យាយាមបន្តគោរពព្រះបញ្ញត្តិ — ទោះបីជាមានការជំទាស់ ការល្បួង ឬបញ្ហាស្មុគស្មាញនៅជុំវិញយើងក្តី ( សូមមើល ម៉ូសាយ ៤:៣០ ) ។

រឿងសំខាន់ទីបីដែលត្រូវធ្វើនោះគឺបម្រើព្រះអម្ចាស់ ( សូមមើល គ. និង ស. ៤:២; ២០:៣១ ) ។

នៅក្នុងការបម្រើរបស់លោកថៅហ្វាយ យើងបានស្គាល់ ហើយស្រឡាញ់ទ្រង់កាន់តែខ្លាំង ។ យើងនឹងចាប់ផ្តើមទទួលស្គាល់ឥទ្ធិពលរបស់ព្រះអង្គសង្គ្រោះ និងឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតយើង ប្រសិនបើយើងព្យាយាមក្នុងការអធិស្ឋាន និងការបម្រើដោយស្មោះត្រង់ ។ ពួកយើងជាច្រើននាក់ធ្លាប់ទទួលឱកាសបម្រើទាំងនោះ ហើយទទួលអារម្មណ៍នៃភាពជាគូកននោះ ។ ប្រសិនបើអ្នកត្រឡប់ទៅគិតអំពីគ្រានោះវិញ នោះអ្នកនឹងចាំថាអ្នកមានការផ្លាស់ប្តូរ ។ ការល្បួងឲ្យធ្វើអាក្រក់ហាក់ដូចជាមានតិចតួច ។ បំណងប្រាថ្នាធ្វើល្អបានកើនឡើង ។ អស់អ្នកដែលស្គាល់អ្នកច្បាស់ជាងគេ និងអស់អ្នកដែលស្រឡាញ់អ្នកអាចនិយាយដូចនេះ ៖ « អ្នកមានចិត្តសប្បុរស ហើយមានការអត់ធ្មត់ច្រើន ។ អ្នកហាក់ដូចជាពុំមែនជាមនុស្សដូចកាលពីមុន » ។

អ្នកពុំមែនជាមនុស្សដូចកាលពីមុនឡើយ ។ អ្នកត្រូវបានផ្លាស់ប្តូរតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដោយសារអ្នកពឹងផ្អែកលើទ្រង់ នៅក្នុងគ្រានៃការសាកល្បងរបស់អ្នក ។

ខ្ញុំសន្យានឹងអ្នកថា ព្រះអម្ចាស់នឹងជួយអ្នកក្នុងការសាកល្បងនានា ប្រសិនបើអ្នកស្វែងរក ហើយបម្រើទ្រង់ ហើយព្រលឹងអ្នកនឹងត្រូវបានដុសខាត់នៅក្នុងដំណើរការនោះ ។ ខ្ញុំសូមអញ្ជើញអ្នកឲ្យដាក់ទីទុកចិត្តរបស់អ្នកលើទ្រង់ នូវគ្រប់ទាំងសេចក្តីលំបាករបស់អ្នក ។

ខ្ញុំដឹងថា ព្រះជាព្រះវរបិតាមានព្រះជន្មរស់ ហើយទ្រង់ព្រះសណ្តាប់ និងឆ្លើយតបគ្រប់ការអធិស្ឋានរបស់យើង ។ ខ្ញុំដឹងថា ព្រះរាជបុត្រាទ្រង់ព្រះយេស៊ូវគ្រីស្ទបានបង់ថ្លៃសម្រាប់អំពើបាបរបស់យើងគ្រប់គ្នា ហើយថាទ្រង់សព្វព្រះទ័យឲ្យយើងមករកទ្រង់ ។ ខ្ញុំដឹងថាព្រះវរបិតា និងព្រះរាជបុត្រាមើលថែពួកយើង ហើយបានរៀបចំផ្លូវសម្រាប់យើងឲ្យស៊ូទ្រាំដោយហ្មត់ចត់ និងត្រឡប់ទៅផ្ទះវិញ ។ ■

កំណត់ចំណាំ

១. *Autobiography of Parley Parker Pratt* បានបោះពុម្ព Parley P. Pratt Jr. ( ឆ្នាំ ១៩៧៩ ) ទំព័រ ១២០ ។

**ការបង្រៀនចេញពីសារលិខិតនេះ**

យើងទាំងអស់គ្នាមានឧបសគ្គដែលសាកល្បងសេចក្តីជំនឿ និងសមត្ថភាពក្នុងការស៊ូទ្រាំរបស់យើង ។ សូមពិចារណាអំពីតម្រូវការ និងឧបសគ្គនានារបស់អស់អ្នកទាំងឡាយណាដែលអ្នកបង្រៀន ។ ពីមុនការសួរសុខទុក្ខ អ្នកអាចអធិស្ឋានសូមការណែនាំ ឲ្យដឹងអំពីរបៀបជួយពួកគេឲ្យស៊ូទ្រាំដោយហ្មត់ចត់បានកាន់តែប្រសើរឡើង ។ អ្នកអាចគិតអំពីការពិភាក្សាទាំងគោលការណ៍ និងខគម្ពីរនានាដែលប្រធាន អារីង បានថ្លែង រួមទាំងការអធិស្ឋាន ការបម្រើ និងការគោរពព្រះបញ្ញត្តិ ។ អ្នកក៏អាចចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន អំពីរបៀបដែលអ្នកបានទទួលពរក្នុងរបៀបមួយដែលបានជួយអ្នកឲ្យស៊ូទ្រាំដោយហ្មត់ចត់ ។



## យុវវ័យ

*អ្នកអាចទាញយកបទ « សូមគង់នឹងខ្ញុំយប់យន់រាត្រី » នៅគេហទំព័រ lds.org/go/7176 ។*

# នៅពេលមិត្តរបស់ខ្ញុំបានស្លាប់

ដោយ សាមែនថា លីនតុន

អំឡុងពេលរៀននៅវិទ្យាល័យ មិត្តភក្តិម្នាក់របស់ខ្ញុំមានជំងឺប៉ោងសសៃឈាមក្នុងខួរក្បាល ហើយបានស្លាប់នៅថ្ងៃបន្ទាប់ ។ ទោះបីខ្ញុំជាសមាជិកសាសនាចក្រក្តី ខ្ញុំនៅតែមានការលំបាកក្នុងចិត្ត ។ ខ្ញុំត្រូវបានបង្រៀនពេញមួយជីវិតរបស់ខ្ញុំថា ខ្ញុំអាចងាកទៅរកព្រះវរបិតាសួគ៌ា និងព្រះអង្គសង្គ្រោះសម្រាប់រឿងគ្រប់យ៉ាង ប៉ុន្តែខ្ញុំពុំធ្លាប់ឆ្លងកាត់រឿងបែបនេះពីមុនឡើយ ។

ខ្ញុំបានយំអស់ពេលជាច្រើនម៉ោង ដោយព្យាយាមស្វែងរកអ្វីមួយ — អ្វីក៏បាន — ដែលផ្តល់ភាពសុខសាន្តដល់ខ្ញុំ ។ នៅយប់បន្ទាប់ពីថ្ងៃដែលគាត់ស្លាប់នោះ ខ្ញុំបានបើកសៀវភៅទំនុកតម្កើង ។ នៅពេលខ្ញុំបើកទំព័រសៀវភៅនោះ ខ្ញុំបានបើកទៅបទ « សូមគង់នឹងខ្ញុំ យប់យន់រាត្រី » ( *ទំនុកតម្កើង* ទំព័រ ៩៧ ) ។ ខ្ញុំចាប់អារម្មណ៍នឹងវគ្គទីបី ៖

*សូមគង់នឹងខ្ញុំយប់យន់រាត្រី*
*រាត្រីនឹងប្រែងកោ*
*បើខ្ញុំមិនអាចប្រាស័យនឹងទ្រង់*
*ឬទ្រង់មិនបានបំភ្លឺ*
*ខ្ញុំខ្លាចភាពងងឹតនៃលោកិយ*
*គ្របដណ្តប់លើផ្ទះខ្ញុំ ។*
*ឱ! ព្រះអង្គគង់នឹងខ្ញុំយប់នេះ*
*មើលហ្ន៎ យប់យន់ដល់ហើយ ។*

វគ្គនេះបានធ្វើឲ្យចិត្តខ្ញុំសុខសាន្តជាខ្លាំង ។ ក្រោយមកខ្ញុំដឹងថា ព្រះអង្គសង្គ្រោះមិនត្រឹមតែអាចគង់នៅជាមួយខ្ញុំនាយប់នោះប៉ុណ្ណោះទេ ទ្រង់ថែមទាំងជ្រាបដឹងយ៉ាងច្បាស់អំពីអារម្មណ៍របស់ខ្ញុំ ។ ខ្ញុំដឹងថាសេចក្តីស្រឡាញ់ដែលខ្ញុំមានតាមរយៈទំនុកតម្កើង មិនគ្រាន់តែជួយខ្ញុំឲ្យឆ្លងកាត់ការលំបាកនាយប់នោះប៉ុណ្ណោះទេ តែថែមទាំងជួយខ្ញុំឲ្យឆ្លងកាត់ការសាកល្បងផ្សេងៗជាច្រើនដែលខ្ញុំបានស៊ូទ្រាំ ។

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

## កុមារ

# ផ្តោតចិត្តទុកដាក់ទៅលើព្រះយេស៊ូវ

ពេលយើងផ្តោតចិត្តទុកដាក់លើព្រះយេស៊ូវ នោះទ្រង់អាចជួយយើងឲ្យទប់ទល់នឹងរឿងលំបាកៗក្នុងជីវិត ។ ការស្រឡាញ់អ្នកដទៃ ការគោរពព្រះបញ្ញត្តិ និងការអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ទាំងនេះគឺជារបៀបផ្តោតចិត្តទុកដាក់ទៅលើព្រះយេស៊ូវ ។

សូមគូររូបភាពនៅក្នុងចន្លោះទំនេរាងការ៉េទាំងនោះ ដើម្បីឲ្យជួរដេក និងជួរឈរនីមួយៗមានរូបភាពនៃសេចក្តីស្រឡាញ់ ការអធិស្ឋាន និងការបទបញ្ញត្តិ ។



រចនារូបភាពដោយ តេអា ម៉រលើ

សារលិខិតបង្រៀនសួរសុខទុក្ខ

# ដើម្បីឲ្យគេបានរួមគ្នាតែមួយ

*សូមសិក្សាអត្ថបទនេះប្រកបដោយការអធិស្ឋាន និងស្វែងរកការបំផុសគំនិត ដើម្បីដឹងពីអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងអំពីគោលបំណងនៃសមាគមសង្គ្រោះ នឹងរៀបចំបុត្រីទាំងឡាយរបស់ព្រះឲ្យទទួលបានពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ច យ៉ាងដូចម្ដេច ?*



*សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ*

អែលឌើ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « ព្រះយេស៊ូវបានសម្រេចនូវការរួបរួមយ៉ាងឥតខ្ចោះជាមួយនឹងព្រះវរបិតា ដោយការចុះចូលអង្គទ្រង់ទាំងខាងសាច់ឈាម និងខាងវិញ្ញាណទៅតាមព្រះឆន្ទៈរបស់ព្រះវរបិតា ។

. . . ប្រាកដណាស់ យើងនឹងមិនមែនតែមួយជាមួយព្រះ និងព្រះគ្រីស្ទទេ រហូតទាល់តែយើងធ្វើឲ្យព្រះឆន្ទៈ និងចំណាប់អារម្មណ៍របស់ទ្រង់ក្លាយជាបំណងប្រាថ្នាដ៏ខ្លាំងបំផុតរបស់យើងសិន ។ ការចុះចូលបែបនេះពុំអាចសម្រេចបានក្នុងពេលមួយថ្ងៃនោះឡើយ ប៉ុន្តែតាមរយៈព្រះវិញ្ញាណបរិសុទ្ធ និង ដំណើរការនៃពេលវេលា នោះព្រះអម្ចាស់នឹងណែនាំយើងរហូតទាល់តែអាចនិយាយបានយ៉ាងប្រាកដថា ទ្រង់គឺនៅក្នុងយើង ដូចជាព្រះវរបិតានៅក្នុងទ្រង់ដែរ » ។[១]

លីនដា ខេ បើតុន ប្រធានសមាគមសង្គ្រោះទូទៅបានបង្រៀនអំពីរបៀបធ្វើការដើម្បីឆ្ពោះទៅរកសាមគ្គីភាពនេះ ៖ « ការចុះ និងការរក្សាសេចក្ដីសញ្ញារបស់យើង គឺជាការបង្ហាញនូវការតាំងចិត្តរបស់យើង ដើម្បីក្លាយដូចព្រះអង្គសង្គ្រោះ ។ ឧត្តមគតិនោះគឺត្រូវព្យាយាមឲ្យមានអាកប្បកិរិយា ដែលបានបង្ហាញយ៉ាងល្អបំផុតក្នុងឃ្លាមួយចំនួននៃទំនុកតម្កើងដ៏គួរឲ្យពេញចិត្តដូចនេះ ៖ ‹ ខ្ញុំនឹងទៅដែល *ទ្រង់* ឲ្យខ្ញុំទៅ ។ . . . ខ្ញុំនឹងថាដែល *ទ្រង់* ឲ្យខ្ញុំថា ។ . . . ខ្ញុំនឹងធ្វើដែល *ទ្រង់* ឲ្យខ្ញុំធ្វើ › » ។[២]

អែលឌើរ គ្រីស្តូហ្វឺសិន ក៏បានរំឭកយើងផងដែរថា « នៅពេលយើងខិតខំពីមួយថ្ងៃទៅមួយថ្ងៃ និងពីមួយសប្ដាហ៍ទៅមួយសប្ដាហ៍ ដើម្បីដើរតាមមាគ៌ារបស់ព្រះគ្រីស្ទ លំដាប់នោះវិញ្ញាណរបស់យើងបង្ហាញឧត្តមភាពរបស់ខ្លួន ហើយចម្បាំងដ៏ឥតស្រាកស្រាន្ត និងការល្បួងទាំងឡាយនឹងលែងជាបញ្ហាទៀតហើយ » ។[៣]

នីល អែហ្វ ម៉ារ៉ែត ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានយុវនារីទូទៅថ្លែងទីបន្ទាល់អំពីពរជ័យនៃការព្យាយាមសម្របឆន្ទៈរបស់យើងជាមួយនឹងព្រះទ័យរបស់ព្រះដូចនេះ ៖ « ខ្ញុំបានពុះពារលុបបំបាត់បំណងប្រាថ្នា ដែលចង់ធ្វើអ្វីគ្រប់យ៉ាងតាមរបៀប *របស់ខ្ញុំ* នៅទីបំផុតខ្ញុំទទួលស្គាល់ថា របៀបរបស់ខ្ញុំគឺខ្វះចន្លោះ មានដែនកំណត់ និងទាបជាងរបៀបរបស់ព្រះយេស៊ូវគ្រីស្ទ ។ ‹ របៀប [ របស់ព្រះវរបិតាសួគ៌ ] គឺជាមាគ៌ានាំទៅរកសុភមង្គលក្នុងជីវិតនេះ និងជីវិតអស់កល្បជានិច្ចក្នុងពិភពខាងមុខ › » ។[៤] ចូរយើងព្យាយាមដោយរាបសាដើម្បីបានរួមគ្នាតែមួយជាមួយព្រះវរបិតាសួគ៌យើង និងព្រះរាជបុត្រាទ្រង់ព្រះយេស៊ូវគ្រីស្ទ ។

**ខគម្ពីរ និង ព័ត៌មានបន្ថែម**
យ៉ូហាន ១៧:២០–២១; អេភេសូរ ៤:១៣; គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២៧; reliefsociety.lds.org

**កំណត់ចំណាំ**

១. ឌី ថត គ្រីស្តូហ្វឺសិន « That They May Be One in Us » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០២ ទំព័រ ៧២, ៧៣ ។
២. លីនដា ខេ បើតុន « The Power, Joy, and Love of Covenant Keeping » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ១១១ ។
៣. ឌី ថត គ្រីស្តូហ្វឺសិន « That They May Be One in Us » ទំព័រ ៧១ ។
៤. នីល អែហ្វ ម៉ារ៉ែត « Yielding Our Hearts to God » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៣២ ។

សូមពិចារណាអំពីសំណួរនេះ

តើការធ្វើតាមព្រះហឫទ័យរបស់ព្រះអាចជួយយើងឲ្យប្រែក្លាយកាន់តែដូចទ្រង់យ៉ាងដូចម្ដេច ?

# គ្រូបង្រៀនដែលជួយសង្គ្រោះព្រលឹង

**ដោយ ប្រាយអិន ហេនប្រូវ**
*ការអភិវឌ្ឍន៍កម្មវិធីសិក្សារបស់សាសនាចក្រ*

មូលហេតុ *ដែលព្រះអង្គសង្គ្រោះបានបង្រៀន ផ្ដល់អត្ថន័យដល់* របៀប *ដែលទ្រង់បានបង្រៀន ។ តើគោលបំណងរបស់យើងមានផ្សេងពីនេះឬ ?*

ខ្ញុំសារភាពថា នៅពេលខ្ញុំគិតអំពីការបង្រៀនតាមរបៀបរបស់ព្រះអង្គ សង្គ្រោះ នោះខ្ញុំមានទំនោរផ្ដោតទៅលើ *របៀប* ដែលទ្រង់បានបង្រៀន ។ តើទ្រង់បានធ្វើអ្វីខ្លះ ? តើទ្រង់បានប្រាស្រ័យទាក់ទងជាមួយនឹងមនុស្សទូទៅយ៉ាងដូចម្ដេច ? លើសពីនោះទៀត ទ្រង់គឺជាគ្រូបង្រៀនដ៏ឆ្នើម ! ប៉ុន្តែប្រសិនបើយើងចង់បង្រៀនដូចជាទ្រង់ វាជារឿងចាំបាច់ត្រូវយល់អំពី *មូលហេតុ* ដែលទ្រង់បានបង្រៀន ។ ទីបំផុត « មូលហេតុ » នោះនឹងធ្វើឲ្យយើង និងអស់អ្នកដែលយើងបង្រៀនមានការផ្លាស់ប្ដូរ ។

នៅពេលព្រះអង្គសង្គ្រោះបង្រៀន ព្រះរាជបំណងរបស់ទ្រង់ពុំមែនគ្រាន់តែបំពេញតែម៉ោង ឬជាការកម្សាន្ត ឬ ចែកចាយព័ត៌មានដ៏ច្រើនសន្ធឹកសន្ធាប់នោះទេ ។ អ្វីគ្រប់យ៉ាងដែលទ្រង់ធ្វើ — រួមទាំងការបង្រៀន — គឺមានព្រះទ័យដឹកនាំមនុស្សដទៃទៅកាន់ព្រះវរបិតាទ្រង់ ។ ព្រះរាជបំណងប្រាថ្នា និង បេសកកម្មទាំងស្រុងរបស់ព្រះអង្គសង្គ្រោះគឺដើម្បីសង្គ្រោះកូនចៅរបស់ព្រះវរបិតាសួគ៌ ( សូមមើល នីហ្វៃទី ២ ២៦:២៤ ) ។ នៅក្នុងការប៉ុនប៉ងរបស់យើងដើម្បីបង្រៀនដូចទ្រង់បានបង្រៀន នោះយើងអាចរៀនដើម្បីបានការជំរុញទឹកចិត្ត មកពីគោលបំណងដូចគ្នាដែលបានជំរុញព្រះទ័យរបស់ទ្រង់ផងដែរ ។

និយាយម្យ៉ាងទៀតគឺថា ដើម្បីបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះគឺត្រូវធ្វើជាគ្រូបង្រៀនដែលមានគោលបំណងដើម្បីជួយសង្គ្រោះដល់ព្រលឹង ។

**បំណងប្រាថ្នាដើម្បីសង្គ្រោះអ្នកដទៃ**

ដំណើររឿងមួយដែលខ្ញុំពេញចិត្តនៅក្នុងព្រះគម្ពីរមរមន ប្រាប់អំពីបុត្រារបស់ស្ដេចម៉ូសាយ បោះបង់នគរនៃសាសន៍នីហ្វៃ ដើម្បីពួកទ្រង់អាចស្ថាបនានគរព្រះនៅក្នុងចំណោមពួកសាសន៍លេមិន ។ ពួកគេបានបោះបង់នគរនៅលើផែនដីដើម្បីយកនគរស្ថានសួគ៌ ។ ពួកទ្រង់បោះបង់សុវត្ថិភាព និងសន្តិសុខដ៏ស្រណុកសុខស្រួលនៅក្នុងចំណោមពួកសាសន៍នីហ្វៃ ដើម្បីទៅក្នុងចំណោមពួកសត្រូវរបស់ពួកទ្រង់គឺសាសន៍លេមិន ដើម្បីពួកទ្រង់ « អាចសង្គ្រោះព្រលឹងពួកគេបានខ្លះ » ( អាលម៉ា ២៦:២៦ ) ។



តើមានអ្វីខ្លះទៅដែលបានជំរុញទឹកចិត្ត ពួកអ្នកបម្រើរបស់ព្រះទាំងនេះ ? « ពួកគេពុំអាចទ្រាំឲ្យព្រលឹងមនុស្សណាម្នាក់ត្រូវវិនាសឡើយ មែនហើយ ទោះបីគ្រាន់តែគិតថា ព្រលឹងមនុស្សណាម្នាក់ត្រូវស៊ូទ្រាំនូវសេចក្ដីទុក្ខវេទនាដ៏មិនចេះចប់មិនចេះហើយ ក៏ធ្វើឲ្យពួកគេញាក់ និងញ័រទៅហើយ » ( ម៉ូសាយ ២៨:៣ ) ។ ការជំរុញចិត្តនោះបានបណ្ដាលឲ្យពួកគេស៊ូទ្រាំ « ការវេទនាជាច្រើន » ( អាលម៉ា ១៧:៥, ១៤ ) ។

ជារឿយៗ រឿងនេះបានបំផុសគំនិតឲ្យខ្ញុំគិតថា តើខ្ញុំកំពុងតែធ្វើអ្វីដែលខ្ញុំអាចនាំអ្នកដទៃមកកាន់ព្រះគ្រីស្ទឬទេ ? តើខ្ញុំបានផ្ដោតយកចិត្តទុកដាក់គ្រប់គ្រាន់ទៅលើការសង្គ្រោះព្រលឹងដែរឬទេ ?

### ការក្លាយជាគ្រូបង្រៀនដែលជួយសង្គ្រោះព្រលឹង

នៅពេលយើងមានបំណងប្រាថ្នាបង្រៀន ដោយមានមូលហេតុដូចជាព្រះអង្គសង្គ្រោះបានបង្រៀន នោះគោលការណ៍នៃ *របៀប* ដែលទ្រង់បង្រៀនកាន់តែមានអត្ថន័យអស្ចារ្យឡើង ។ វាមានន័យលើសពីបច្ចេកទេសបង្រៀនទៅទៀត វាគឺជាលំនាំសម្រាប់ការប្រែក្លាយដូចជាទ្រង់ ។ នៅពេលយើងបន្តអនុវត្តយោបល់ដូចតទៅនេះ និងយោបល់ផ្សេងៗទៀតដែលមាននៅក្នុងសៀវភៅ *ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ* នោះយើងមិនគ្រាន់តែអាច *បង្រៀន* កាន់តែដូចទ្រង់ប៉ុណ្ណោះទេ យើងថែមទាំង *ក្លាយ* កាន់តែដូចទ្រង់ទៀតផង ។

#### *ស្វែងរកវិវរណៈជាមុន*

ដើម្បីជួយក្នុងកិច្ចការនៃការសង្គ្រោះព្រលឹង នោះយើងត្រូវការវិវរណៈ ។ វិវរណៈកើតមានឡើង « មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ ឯណេះបន្តិច ឯណោះបន្តិច » ( នីហ្វៃទី២ ២៨:៣០ ) — ហើយវាត្រូវការចំណាយពេលច្រើន ។ ដូច្នេះយើងចាប់ផ្ដើមរៀបចំជាមុន ហើយយើងស្វែងរកវិវរណៈឲ្យបានញឹកញាប់ ។

#### *ស្រឡាញ់មនុស្ស*

សេចក្ដីស្រឡាញ់អាចជាវិធីដ៏មានឥទ្ធិពលបំផុតដែលគ្រូបង្រៀនអាចជួយសង្គ្រោះព្រលឹង ។ វាអាចជា





កិច្ចការសាមញ្ញៗ ដូចជាការស្គាល់ឈ្មោះសមាជិកម្នាក់ៗក្នុងថ្នាក់ សួរពួកគេអំពីជីវិតពួកគេក្នុងសប្ដាហ៍នោះ ប្រាប់ពួកគេអំពីការទៀងនិយាយដ៏ល្អដែលពួកគេបាននិយាយ ឬសាទរពួកគេចំពោះភាពរីកចម្រើន ឬស្នាដៃរបស់ពួកគេ ។ ការបង្ហាញអំពីចំណាប់អារម្មណ៍ និងក្ដីស្រឡាញ់បើកដួងចិត្ត និងជួយអស់អ្នកដែលយើងបង្រៀនឲ្យទទួលការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ ។

***រៀបចំបង្រៀនដោយគិតអំពីតម្រូវការរបស់អ្នករៀននៅក្នុងគំនិត***

គ្រូបង្រៀនដែលជួយសង្គ្រោះព្រលឹងផ្ដោតចិត្តទុកដាក់ទៅលើអ្នករៀន ។ នៅពេលយើងរំឭកមាតិកានៅក្នុងមេរៀនឡើងវិញ យើងផ្ដោតចិត្តទុកដាក់លើអ្វី ដែលនឹងបំពេញតម្រូវការរបស់ពួកគេបានច្រើនបំផុត ដែលពុំមែនជាតម្រូវការរបស់យើងឡើយ ។ នោះយើងនឹងភ្លេចអំពីការបង្រៀនគ្រាន់តែបំពេញម៉ោង ហើយផ្ដោតចិត្តទុកដាក់ទៅលើការបំពេញដួងចិត្ត និងគំនិតវិញ ។ យើងមិនគ្រាន់តែគិតអំពីអ្វីដែលយើងនឹងនិយាយ និងធ្វើឡើយ ប៉ុន្តែយើងនឹងគិតអំពីអ្វីដែលអ្នករៀននឹងនិយាយ និងធ្វើវិញ ។ យើងចង់ឲ្យពួកគេចែកចាយយោបល់របស់ពួកគេ ដោយសារវាបង្កើតឲ្យមានសាមគ្គីភាព បើកដួងចិត្តរបស់ពួកគេ ហើយជួយពួកគេឲ្យអនុវត្តសេចក្ដីជំនឿ ។

***បន្តផ្ដោតចិត្តទុកដាក់លើគោលលទ្ធិ***

វាជារឿងធម្មតាដែលគ្រូបង្រៀន វាយតម្លៃទៅលើប្រសិទ្ធិភាពនៃការបង្រៀនរបស់ខ្លួន តាមរយៈចំនួននៃសិស្សដែលចូលរួម ប៉ុន្តែនោះគឺគ្រាន់តែជាធាតុមួយនៃបទពិសោធន៍នេះប៉ុណ្ណោះ ។ ប្រសិនបើសិស្សនៅក្នុងថ្នាក់យើងមានការចែកចាយជាច្រើន ប៉ុន្តែមានគោលលទ្ធិតែបន្តិចបន្តួច នោះយើងបានផ្ដល់នូវអ្វីដែលអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានហៅថា « ចំណីខាងសាសនាដែលខ្វះរសជាតិ » ។ យើងបានផ្ដល់នូវអ្វីដែលមានរសជាតិឆ្ងាញ់ ប៉ុន្តែយើងពុំបានចិញ្ចឹមបីបាច់សមាជិកថ្នាក់របស់យើងនូវអនុភាពដែលទ្រទ្រង់គោលលទ្ធិឡើយ ។

ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា « មនុស្សម្នាក់មិនត្រូវបានសង្គ្រោះ លឿនជាងចំណេះដឹង

ដែលគាត់ទទួលបានឡើយ » ។[១] យើងត្រូវជួយអស់អ្នកដែលយើងបង្រៀនឲ្យទទួលបានចំណេះដឹងមួយបែបដែលសំខាន់បំផុតគឺ — គោលលទ្ធិនៃព្រះយេស៊ូវគ្រីស្ទ ។

នៅពេលយើង និងសមាជិកក្នុងថ្នាក់ចែកចាយគំនិត និងអារម្មណ៍របស់យើង នោះយើងគប្បីភ្ជាប់ការចែកចាយទាំងនោះត្រឡប់ទៅរកបទគម្ពីរ និងប្រសាសន៍របស់ពួកព្យាការីថ្ងៃចុងក្រោយវិញជានិច្ច ។ ថ្មីៗនេះបងប្រុស ថាត អរ ខាលីស្នើរ ប្រធានសាលាថ្ងៃអាទិត្យទូទៅ បានបង្រៀនថា ៖ « គ្រូបង្រៀនដែលមានឧត្តមគតិព្យាយាមភ្ជាប់យោបល់នានារបស់សិស្សទៅនឹងគោលលទ្ធិជាប់ជានិច្ច ។ ឧទាហរណ៍ គ្រូបង្រៀនអាចនិយាយថា ‹ បទពិសោធន៍ដែលអ្នកចែកចាយរំឭកខ្ញុំអំពីខគម្ពីរមួយ › ។ ឬ ‹ តើសេចក្ដីពិតនៃដំណឹងល្អអ្វីខ្លះដែលយើងរៀនមកពីយោបល់ដែលយើងបានស្ដាប់ឮនេះ ? › ឬ ‹ តើមាននរណាម្នាក់ចង់ថ្លែងទីបន្ទាល់អំពីអនុភាពនៃសេចក្ដីពិតនោះ ដែលយើងបានពិភាក្សាដែរឬទេ ? › »[២]

***យាងព្រះវិញ្ញាណបរិសុទ្ធឲ្យថ្លែងទីបន្ទាល់***

គ្រូបង្រៀនដែលជួយសង្គ្រោះព្រលឹងយល់ថា អ្វីដែលយើងនិយាយ និងធ្វើក្នុងនាមជាគ្រូបង្រៀនគឺមានចេតនាយាងព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធមកកាន់ជីវិតអ្នកដទៃ ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាគ្រូបង្រៀន ។ តួនាទីមួយរបស់ព្រះវិញ្ញាណបរិសុទ្ធគឺថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ជាពិសេសអំពីព្រះវរបិតា និងព្រះរាជបុត្រា ។ ដូច្នេះនៅពេលយើងបង្រៀនអំពីពួកទ្រង់ និងដំណឹងល្អរបស់ពួកទ្រង់ យើងយាងព្រះវិញ្ញាណបរិសុទ្ធឲ្យថ្លែងទីបន្ទាល់ដល់សមាជិកក្នុងថ្នាក់ ។ ព្រះចេស្ដារបស់ទ្រង់ពង្រឹងទីបន្ទាល់ ហើយផ្លាស់ប្ដូរដួងចិត្តរបស់ពួកគេ ទៅតាមកម្រិតនៃបំណងក្នុងដួងចិត្តរបស់ពួកគេ ។ សាក្សីរបស់ទ្រង់មានព្រះចេស្ដាជាងមតិយោបល់ទៅទៀត ។[៣]

***អញ្ជើញអ្នករៀនឲ្យរៀន ហើយអនុវត្តសម្រាប់ខ្លួនពួកគេ***

ថ្មីៗនេះ ខ្ញុំបានចូលរួមនៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ ដែលមានគ្រូបង្រៀនបានចាប់ផ្ដើមថ្នាក់ ដោយសូមឲ្យសមាជិកក្នុងថ្នាក់ចែកចាយអ្វីដែលមានន័យពិសេសចំពោះពួកគេ នៅពេលពួកគេអានកិច្ចការប្រចាំសប្ដាហ៍ ចេញពីខគម្ពីរ និងរបៀបដែលពួកគេបានអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ ។ ការណ៍នេះបាននាំឲ្យមានការពិភាក្សាដ៏មានឥទ្ធិពលអំពីការយល់ដឹង និងការរកឃើញនានា ដែលពួកគេបានជួបផ្ទាល់ ។ វាគឺជារឿងធម្មតាចំពោះគ្រូបង្រៀន ដើម្បីបញ្ចូលបន្ថែមទៅលើការសន្ទនានេះអំពីចំណុចនៃគោលលទ្ធិដែលគាត់បានរៀបចំបង្រៀន ។ អ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍នោះគឺអំពីរបៀបដែលគាត់ផ្ដោតចិត្តទុកដាក់លើការលើកទឹកចិត្តសមាជិកក្នុងថ្នាក់របស់គាត់ ឲ្យដកពិសោធន៍នូវព្រះចេស្ដានៃព្រះបន្ទូលព្រះដោយខ្លួនពួកគេផ្ទាល់ ។

គោលដៅរបស់យើងក្នុងនាមជាគ្រូបង្រៀន ពុំមែនគ្រាន់តែមានបទពិសោធន៍អស្ចារ្យនៅក្នុងថ្នាក់រៀន ឬគ្រាន់តែបំពេញម៉ោងបង្រៀន ឬផ្ដល់មេរៀនដ៏ល្អនោះទេ ។ គោលដៅពិតប្រាកដនោះគឺត្រូវដើរជាមួយអ្នកដទៃ នៅលើដំណើររបស់ពួកគេ ដើម្បីត្រឡប់ទៅកាន់ព្រះវរបិតាសួគ៌របស់យើង និងព្រះយេស៊ូវគ្រីស្ទវិញ ។ គោលដៅរបស់យើងគឺប្រែក្លាយជាគ្រូបង្រៀនដែលជួយសង្គ្រោះព្រលឹង ។ ■



*សូមចូលទៅគេហទំព័រ teaching.lds.org ដើម្បីរៀនបន្ថែមទៀតអំពីរបៀប បង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ និងការប្រជុំក្រុមប្រឹក្សាគ្រូបង្រៀន អាចផ្លាស់ប្ដូររបៀបដែលយើងរៀន និងបង្រៀន ។*

កំណត់ចំណាំ

១. *Teachings of Presidents of the Church: Joseph Smith* ( ឆ្នាំ ២០០៧ ) ទំព័រ ២៦៦ ។
២. ថាត អរ ខាលីស្នើរ « Sunday School 'Discussion Is a Means, Not an End' » *Church News* ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៦ គេហទំព័រ deseretnews.com ។
៣. សូមមើល *Teachings of Presidents of the Church: Harold B. Lee* ( ឆ្នាំ ២០០០ ) ទំព័រ ៣៩ ។

# អព្ភូតហេតុដ៏ពិត

*ព្រះចេស្ដារបស់ព្រះអម្ចាស់ពុំគ្រាន់តែបានបង្ហាញនៅក្នុងការជាសះស្បើយរបស់ ប៉ោឡា ប៉ុណ្ណោះទេ ថែមទាំងបានបង្ហាញនៅក្នុងការប្រែចិត្តជឿលើដំណឹងល្អរបស់ឪពុកនាងផងដែរ ។*

ដោយ ដុន អែល សៀរល៍

វេជ្ជបណ្ឌិតបាននិយាយថា អ្វីដែលបានកើតឡើងចំពោះ ប៉ោឡា យ៉ាញេស្ស គឺជាអព្ភូតហេតុនៃការព្យាបាល ។ ស្ថានភាពជំងឺរបស់ក្មេងជំទង់ម្នាក់នៅ គីតូ អេក្វាទ័រ បានប្រសើរឡើងភ្លាមៗ ពេលឪពុករបស់នាងបានបរិច្ចាគតម្រងនោមម្ខាងឲ្យទៅនាង ការវះកាត់ប្ដូរសរីរាង្គនោះបានទទួលជោគជ័យ ហើយនាងមានឱកាសរស់ជាថ្មីម្ដងទៀត ។

ប៉ុន្តែឪពុករបស់នាងគឺ ម៉ាកូ យ៉ាញេស្ស និយាយថាអ្វីដែលបានកើតឡើងចំពោះគាត់នោះគឺជារឿងអស្ចារ្យដូចគ្នា ។ គាត់បានរកឃើញដំណឹងល្អ ហើយដំណឹងល្អក៏បានផ្លាស់ប្ដូរជីវិតគាត់ ដំណឹងល្អបានផ្ដល់ឱកាសជាលើកទីពីរដល់រូបគាត់ផងដែរ ។

ជំងឺរលាកតម្រងនោមតាំងពីកុមារភាព បានបំផ្លាញតម្រង់នោមទាំងសងខាងរបស់ ប៉ោឡា ប៉ុន្តែការប្រើឱថសបានជួយនាងឲ្យមានជីវិតរស់នៅ ។ ទោះជាយ៉ាងណាក្ដី ពេលនាងអាយុ ១៥ ឆ្នាំស្ថានភាពជំងឺរបស់នាងប្រែកាន់តែធ្ងន់ធ្ងរឡើងៗ ។ តម្រងនោមម្ខាងបានខូច ហើយម្ខាងទៀតកំពុងតែខូចយ៉ាងឆាប់រហ័ស ។ ទោះបីជាបានទទួលការព្យាបាលដោយការលាងឈាមក្ដី ប៉ោឡានឹងឈានទៅរកសេចក្ដីស្លាប់ដោយសន្សឹមៗ ។ នាងត្រូវបានអនុញ្ញាតឲ្យផឹកបានតែទឹកមួយកែវប៉ុណ្ណោះក្នុងមួយថ្ងៃ ហើយនាងត្រូវបានដាក់កំហិតយ៉ាងតឹងរឹងពុំឲ្យធ្វើសកម្មភាពផ្សេងៗឡើយ ដោយសារសួត លំពែង និងបេះដូងរបស់នាងបានទទួលរងការប៉ះពាល់ផងដែរ ។

វាពុំអាចធ្វើទៅបានឡើយ ដើម្បីយកគាត់ទៅសហរដ្ឋ ឬប្រទេសគុយបា ដើម្បីវះកាត់ប្ដូរសរីរាង្គ — នាងត្រូវស្វែងរកអ្នកបរិច្ចាគសរីរាង្គម្នាក់ដែលនៅអេក្វាទ័រ ។ ការធ្វើតេស្ដបានបង្ហាញថា ឪពុករបស់គាត់ពុំអាចធ្វើជាអ្នកបរិច្ចាគសរីរាង្គនោះបានឡើយ ។ ម្ដាយរបស់នាងអាចធ្វើជាអ្នកបរិច្ចាគបាន ប៉ុន្តែក្រោយមកវេជ្ជបណ្ឌិតបានរកឃើញថា ការលាងឈាមបានបន្សល់ទុកនូវកម្រិតថ្នាំអង់ទីប៊ីយ៉ូទិកក្នុងខ្លួនរបស់ ប៉ោឡា ខ្ពស់ ដែលពុំអាចធ្វើការវះកាត់ប្ដូរសរីរាង្គបានទេ ។ ប៉ោឡា បានអធិស្ឋានសូមឲ្យមានរបៀបណាមួយ ដែលឲ្យនាងមានជីវិតរស់នៅបន្តទៀត ។

នៅគ្រានោះ ក្នុងខែមិថុនា ឆ្នាំ ១៩៨៨ អ្នកផ្សព្វផ្សាយសាសនានៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានគោះទ្វារផ្ទះរបស់គ្រួសារ យ៉ាញេស្ស ។ ខាមែន ម្ដាយរបស់ ប៉ោឡា បាននិយាយថា គាត់បានអញ្ជើញពួកគេឲ្យចូលផ្ទះ ដើម្បីគាត់អាចប្រមាថមើលងាយដល់ពួកគេ ។ នៅពេលពួកគេ



បានប្រាប់គាត់ថា ពួកគេមានសារលិខិតដែលអាចជួយគាត់បាន នោះគាត់បាននិយាយទាំងខឹងសម្បារថា « តើអ្នកអាចជួយខ្ញុំបានតាមរបៀបណា ខណៈដែលកូនស្រីរបស់ខ្ញុំខិតទៅរកសេចក្តីស្លាប់ទៅហើយនោះ ? ខ្ញុំពុំជឿថាមានព្រះឡើយ ! »

ទោះបីជាមានការជំទាស់ជាលើកដំបូងពី ខាមែន ក្តី អ្នកផ្សព្វផ្សាយសាសនានៅតែបន្តទៅសួរសុខទុក្ខគ្រួសាររបស់គាត់ ។ ដំបូង ម៉ាកូ មានអារម្មណ៍ថាគាត់ហាក់ដូចជាយកចិត្តទុកដាក់ខ្លាំងក្នុងការមើលថែកូនស្រីរបស់គាត់ ដោយពុំបានខ្វល់ចំពោះអ្នកផ្សព្វផ្សាយសាសនាឡើយ ។ ប៉ុន្តែទីបំផុតគាត់បានស្តាប់ ដោយសារគាត់ចង់ដឹងជាខ្លាំង ។ គាត់បានឃើញថា ពួកគេមានចម្លើយចំពោះសំណួរដែលគាត់មានអំពីគោលបំណងនៃជីវិតនេះ ។

ម៉ាកូ ពុំជឿថាព្រះជាព្រះដែលមានព្រះកាយអ្វីឡើយ ។ សម្រាប់គាត់ ព្រះគឺជាប្រភពដ៏មានឥទ្ធិពលជាសកលមួយ ឬជាតួអង្គដ៏អស្ចារ្យ ជាតួអង្គដែលគ្មានទំនាក់ទំនងជាមួយមនុស្សឡើយ ។ ប៉ុន្តែពេលស្ថានភាពជំងឺកូនស្រីរបស់គាត់កាន់តែធ្ងន់ធ្ងរទៅៗ នោះគាត់បានអធិស្ឋានដោយទូលសូមព្រះឲ្យព្យាបាលកូនស្រីដែលកំពុងរងទុក្ខរបស់គាត់ ឬក៏ឆក់យកជីវិតរបស់នាងទៅ ។ គាត់បានអធិស្ឋានថា « ប្រសិនបើទ្រង់មានមែន សូមបង្ហាញទូលបង្គំមក ។ សូមប្រទានជីវិតដល់កូនស្រីទូលបង្គំមក » ។

បន្ទាប់ពីការអធិស្ឋានរបស់គាត់ ម៉ាកូទទួលអារម្មណ៍យ៉ាងខ្លាំងថាស្ថានភាពជំងឺរបស់ ប៉ោឡា នឹងផ្លាស់ប្តូរ ។ គាត់បានសូមឲ្យវេជ្ជបណ្ឌិតធ្វើតេស្តគាត់ និងកូនស្រីគាត់ម្តងទៀត ។ ពួកគេបានប្រាប់គាត់ថាការធ្វើតេស្តនោះនឹងចំណាយពេលឥតប្រយោជន៍ហើយ ប៉ុន្តែពួកគេយល់ព្រមធ្វើតេស្តនោះ ។

ពួកគេបានរកឃើញថា ម៉ាកូ *គឺ* ពិតជាអ្នកបរិច្ចាគដ៏ត្រឹមត្រូវ — ហើយថាស្ថានភាពជំងឺរបស់ ប៉ោឡា បានប្រសើរឡើងគ្រប់គ្រាន់ ដែលធ្វើឲ្យនាងអាចទទួលការវះកាត់ប្តូរសរីរាង្គបាន !

នៅមុនថ្ងៃវះកាត់ ម៉ាកូ និង ប៉ោឡា បានទទួលយកការប្រសិទ្ធពរនៃបព្វជិតភាពពីអ្នកផ្សព្វផ្សាយសាសនា ។

ទាំង ម៉ាកូ និង ប៉ោឡា បានរំពឹងថានឹងជាសះស្បើយក្នុងរយៈពេលមួយនៅក្នុងមន្ទីរពេទ្យ បន្ទាប់ពីការវះកាត់របស់ពួកគេ ។ ប៉ុន្តែ ម៉ាកូ អាចចេញពីមន្ទីរពេទ្យក្នុងរយៈពេលប្រាំថ្ងៃក្រោយមក ហើយ ប៉ោឡា វិញ រំពឹងទុកជាមុនថាត្រូវបន្តស្នាក់នៅមន្ទីរពេទ្យរយៈពេលពីរខែ ប៉ុន្តែបានចេញពីមន្ទីរពេទ្យក្នុងរយៈពេលតែ ១៣ ថ្ងៃក្រោយប៉ុណ្ណោះ ។ ម៉ាកូ បាននិយាយដោយអាងហេតុផលថា ការជាសះស្បើយយ៉ាងលឿនរបស់ពួកគេ នោះគឺបានមកពីការប្រសិទ្ធពរនៃបព្វជិតភាព ហើយគាត់បានដឹងថា គាត់ត្រូវតែរៀនសារលិខិតរបស់អ្នកផ្សព្វផ្សាយសាសនាដោយហ្មត់ចត់ ។

ម៉ាកូ និង ខាមែន យ៉ាញេស្ស បានទទួលបុណ្យជ្រមុជទឹកនៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៨៨ ។ ប៉ោឡា ដែលបានស្តាប់ឮការបង្រៀននានារបស់អ្នកផ្សព្វផ្សាយសាសនាពីមុនការវះកាត់ និងប្អូនស្រីរបស់នាង ប៉ាទ្រីសៀ បានទទួលបុណ្យជ្រមុជទឹកនៅថ្ងៃទី ៣ ខែ វិច្ឆិកា ។ នៅគ្រានោះឪពុករបស់ពួកគេបានទទួលបព្វជិតភាពអើរ៉ុន ហើយបានធ្វើបុណ្យជ្រមុជទឹកឲ្យពួកគេ ។

បងប្រុស យ៉ាញេស្ស ជឿថាព្រះអម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់គាត់ ហើយបានធ្វើឲ្យគាត់ក្លាយជាអ្នកបរិច្ចាគសរីរាង្គឲ្យដល់ ប៉ោឡា ដើម្បីឲ្យគាត់ផ្លាស់ប្តូរដួងចិត្តរបស់គាត់ ។ គាត់និយាយថា « ប្រសិនបើពួកគេវះកាត់ប្រពន្ធរបស់ខ្ញុំជំនួសរូបខ្ញុំ នោះខ្ញុំជឿថាខ្ញុំនឹងបន្តរស់នៅក្នុងជីវិតដដែលនោះជាក់ជាមិនខានឡើយ » ។ វាពុំមែនជាជីវិតដែលគាត់មានមោទនភាពចំពោះ — ការផឹក ការជក់ និងការលេងល្បែងនោះទេ ។ គាត់និយាយថា គាត់យកឈ្នះលើការញៀនរបស់គាត់ដោយសារចម្លើយដែលគាត់បានទទួលមកពីការអធិស្ឋានរបស់គាត់ ។ ប៉ុន្តែវាមានការលំបាកយ៉ាងខ្លាំង ដែលគាត់ត្រូវទទួលស្គាល់ថា មានតែព្រះប៉ុណ្ណោះដែលអាចជួយគាត់ឲ្យផ្លាស់ប្តូរបាន ។

បងប្រុស យ៉ាញេស្ស និយាយថា ឥឡូវនេះគាត់មានទីបន្ទាល់យ៉ាងរឹងមាំអំពីច្បាប់ពាក្យសម្តីនៃប្រាជ្ញាវាងវៃ និង ច្បាប់ដង្វាយមួយភាគក្នុងដប់ ។ កាលអ្នកផ្សព្វផ្សាយសាសនាបង្រៀនគាត់ គាត់បន្តបើកអាជីវកម្មរបស់គាត់រយៈពេលប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ដើម្បីបង់ថ្លៃការព្យាបាលរបស់ ប៉ោឡា ១000 ដុល្លារ ក្នុងមួយខែ ។ គាត់និយាយថា ច្បាប់ដង្វាយមួយភាគក្នុងដប់ « ពិបាកឲ្យខ្ញុំទទួលយកណាស់ » ប៉ុន្តែគាត់បានសម្រេចចិត្តរក្សាថ្ងៃឈប់សម្រាកទុកជាបរិសុទ្ធ ហើយល្បងលនឹងការសន្យានៅក្នុង ម៉ាឡាគី ៣:១០ ដោយការថ្វាយដង្វាយមួយភាគក្នុងដប់ ។ ពេលគាត់បិទហាងលក់ទំនិញរបស់គាត់នៅថ្ងៃអាទិត្យ គាត់និយាយថា « អស់អ្នកដែលទិញទំនិញនៅថ្ងៃអាទិត្យ បានទិញទំនិញនៅថ្ងៃសៅរ៍វិញ — ហើយពួកគេបានទិញច្រើនទៀតផង » ។ សព្វថ្ងៃនេះគាត់មានហិរញ្ញវត្ថុប្រសើរច្រើនជាង កាលគាត់បើកអាជីវកម្មរបស់គាត់ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ទៅទៀត ។

នៅពេល ម៉ាកូ យ៉ាញេស្ស គិតរឿងទាំងនោះឡើងវិញ គាត់មានក្តីរំភើបចំពោះការផ្លាស់ប្តូរនៅក្នុងខ្លួនគាត់ ។ គាត់ទទួលស្គាល់ថា ការទូលអង្វររបស់គាត់ សូមជីវិតកូនស្រីគាត់នោះ បាននាំគ្រួសារទាំងមូលឈានទៅដល់កម្រិតនៃជីវភាពខាងវិញ្ញាណមួយ ដែលគាត់ពុំធ្លាប់សម្រេចថានឹងអាចកើតឡើងបានឡើយ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

រចនារូបភាពដោយ នី យេត ឡាសុន

# នៅខាង



**ដោយអែលឌើរ**
**ដាវីឌ អេ បែដណា**
ក្នុងកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

បេសកកម្មកងទ័ពជំរំស៊ីយ៉ូនដែលបានដឹកនាំដោយព្យាការី យ៉ូសែប ស្ម៊ីធ ក្នុងឆ្នាំ ១៨៣៤ គឺជាគំរូដ៏អស្ចារ្យមួយអំពី ការជ្រើសរើសដើម្បីនៅខាងព្រះអម្ចាស់ ។ ការរំឭកឡើងវិញអំពីប្រវត្តិនៃកងទ័ពជំរំស៊ីយ៉ូន អាចជួយយើងឲ្យរៀនអំពីមេរៀនដ៏មានតម្លៃ និងដែលពុំប្រែប្រួល មកពីប្រព្រឹត្តិការណ៍សំខាន់ៗនៅក្នុងប្រវត្តិសាសនាចក្រដែលអនុវត្តចំពោះជីវិត និងកាលៈទេសៈរបស់យើងសព្វថ្ងៃនេះ ។

## តើកងទ័ពជំរំស៊ីយ៉ូនគឺជាអ្វី ?

ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយនៅក្នុងឆ្នាំ ១៨៣១ ឲ្យជ្រើសរើសយកទីក្រុង អ៊ីនឌីពែនឌែនស៍ ឃុំចាកសុន រដ្ឋមិសសួរី ជាទីតាំងនៃស៊ីយ៉ូន ជាទីតាំងកណ្តាលនៃការប្រមូលពួកបរិសុទ្ធថ្ងៃចុងក្រោយ និងជាទីតាំងសម្រាប់ទីក្រុងយេរូសាឡិមថ្មី ដែលអាចរកឃើញនៅក្នុងទាំងព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមន ( សូមមើល គ. និង ស. ៥៧:១–៣ សូមមើលផងដែរ វិវរណៈ ២១:១–២; អេធើរ ១៣:៤–៦ ) ។ នៅរដូវក្តៅឆ្នាំ ១៨៣៣ អ្នកតាំងទីលំនៅនៃពួកមរមនមានប្រមាណជាមួយភាគបីនៃប្រជាជននៅក្នុងឃុំ ចាកសុន ។ ការកើនឡើងយ៉ាងលឿននៃពួកអ្នកតាំងទីលំនៅ ឥទ្ធិពលនៃនយោបាយដ៏មានសក្តានុពល ព្រមទាំងជំនឿលើសាសនា និងនយោបាយផ្សេងៗគ្នា របស់ពួកអ្នកចំណូលថ្មីទាំងនេះ បានបណ្តាលឲ្យមានការខ្វល់ខ្វាយដល់អ្នកតាំងទីលំនៅផ្សេងទៀតនៅក្នុងតំបន់នោះ ដែលក្រោយមកពួកគេបានទាមទារឲ្យសមាជិកសាសនាចក្រចាកចេញពីផ្ទះសំបែង និងទ្រព្យសម្បត្តិរបស់ពួកគេ ។ នៅពេលការទាមទារនេះពុំត្រូវបានអនុវត្ត នោះពួកប្រជាជនរដ្ឋមិសសួរី បានវាយប្រហារទីលំនៅទាំងនោះ ក្នុងខែវិច្ឆិកា ឆ្នាំ ១៨៣៣ ហើយបានបង្ខំឲ្យពួកបរិសុទ្ធចាកចេញ ។




# ព្រះអម្ចាស់
## មេរៀនមកពីកងទ័ពជំរំស៊ីយ៉ូន





នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៨៣៣ ពួកប្រជាជនរដ្ឋមិសសួរី បានវាយប្រហារទីលំនៅពួកមរមននៅក្នុងឃុំ ចាកសុន រដ្ឋមិសសួរី ហើយបានបង្ខំឲ្យពួកបរិសុទ្ធចាកចេញ ។

ការបង្កើតកងទ័ពជំរំស៊ីយ៉ូន ត្រូវបានបញ្ជាដោយវិវរណៈនៅក្នុងខែកុម្ភៈឆ្នាំ ១៨៣៤ ( សូមមើល គ. និង ស. ១០៣ ) ។ គោលបំណងចម្បងនៃកងទ័ពរបស់ព្រះអម្ចាស់នេះគឺ ដើម្បីការពារពួកមរមននៅក្នុងឃុំ ចាកសុនពីការវាយប្រហារបន្ថែម — បន្ទាប់ពីកងទ័ពពួកមិសសួរី បានបំពេញកាតព្វកិច្ចខ្លួន ក្នុងការអមដំណើរពួកអ្នកតាំងទីលំនៅទាំងនោះដោយសុវត្ថិភាពឲ្យត្រឡប់ទៅផ្ទះសំបែង និងទឹកដីរបស់ពួកគេវិញ ។ ក្រុមនោះក៏បាននាំយកប្រាក់ គ្រឿងសម្ភារផ្គត់ផ្គង់នានា ព្រមទាំងការគាំទ្រផ្នែកសីលធម៌ដល់ពួកបរិសុទ្ធដែលក្រខ្សត់ ។ ដូច្នេះហើយ អំឡុង ខែ ឧសភា និង មិថុនា ឆ្នាំ ១៨៣៤ មនុស្សមួយក្រុមដែលមានពួកបរិសុទ្ធស្ម័គ្រចិត្តជាង ២០០ នាក់ដែលដឹកនាំដោយព្យាការី យ៉ូសែប ស្ម៊ីធ បានធ្វើដំណើរចម្ងាយប្រហែលជា ១៤៥០ គីឡូម៉ែត្រពីទីក្រុង ខឺតឡង់ រដ្ឋអូហៃអូ ទៅឃុំ ក្លេ រដ្ឋមិសសួរី ។ ហៃរុម ស្ម៊ីធ និង ឡាយមិន វ៉ាយ ក៏បានកែនទ័ពនៃពួកអ្នកស្ម័គ្រចិត្តមួយក្រុមតូចមកពីដែនដីមីឈីហ្គេន ហើយបានជួបជាមួយក្រុមកងទ័ពរបស់ព្យាការីនៅក្នុងរដ្ឋមិសសួរី ។ អ្នកចូលរួមនៅក្នុងកងទ័ពជំរំស៊ីយ៉ូននោះរួមមាន ព្រិកហាំ យ៉ង់, ហ៊ីប៊ើរ ស៊ី ឃិមបឹល, វិលហ្វូឌ វូឌ្រុហ្វ, ប៉ាលី ភី ប្រាត្ត, អ្សុន ហៃឌ និង មនុស្សល្បីៗជាច្រើននាក់ទៀតក្នុងប្រវត្តិសាស្ត្រសាសនាចក្រ ។

គោលបំណងរបស់ខ្ញុំពុំមែនពិពណ៌នាអំពីព័ត៌មានលម្អិតនៃ ការធ្វើដំណើរដ៏លំបាកនេះ ឬដំណាលប្រាប់អំពីប្រព្រឹត្តិការណ៍ខាងវិញ្ញាណសំខាន់ៗទាំងអស់ ដែលបានកើតឡើងនោះឡើយ ។ ខ្ញុំគ្រាន់តែសង្ខេបអំពីប្រព្រឹត្តិការណ៍សំខាន់ៗពីរបីអំពីបេសកកម្មនៃកងទ័ពជំរំស៊ីយ៉ូននេះ ៖

- អភិបាលរដ្ឋមិសសួរី លោក ដានីយ៉ែល ដាក់គ្លីន ពុំបានផ្ដល់ជំនួយកងទ័ពដ៏ចាំបាច់ដូចបានសន្យា ដល់ពួកអ្នកតាំងទីលំនៅមរមន ដើម្បីតាំងឡើងវិញនូវដែនដីរបស់ពួកគេឡើយ ។
- ការចរចារដែលបានធ្វើឡើងរវាងថ្នាក់ដឹកនាំសាសនាចក្រ ពួកមន្ត្រីរដ្ឋមិសសួរី និងប្រជាពលរដ្ឋនៃឃុំចាកសុន ដើម្បីចៀសវាងទំនាស់ប្រើប្រាស់អាវុធ និងការដោះស្រាយជម្លោះដីធ្លី ពុំបានធ្វើទៅតាមកិច្ចព្រមព្រៀងគ្នានោះឡើយ ។
- ទីបំផុត ព្រះអម្ចាស់បានដឹកនាំ យ៉ូសែប ស្ម៊ីធ ឲ្យបំបែកពួកកងទ័ពជំរំស៊ីយ៉ូន និងបង្ហាញអំពីមូលហេតុដែលកងទ័ពរបស់ព្រះអម្ចាស់ពុំបានសម្រេចនូវគោលបំណងដែលខ្លួនមាន ( សូមមើល គ. និង ស. ១០៥:៦–១៣, ១៩ ) ។
- ព្រះអម្ចាស់បានដឹកនាំពួកបរិសុទ្ធឲ្យបង្កើតនូវសេចក្ដីសប្បុរសនៅក្នុងតំបន់នោះ ដើម្បីរៀបចំសម្រាប់គ្រាដែលស្ថានភាពនៃក្រុងស៊ីយ៉ូននឹងទទួលបានសិទ្ធិមកវិញតាមផ្លូវច្បាប់ ជាងតាមការប្រើកងទ័ព ( សូមមើល គ. និង ស. ១០៥:២៣–២៦, ៣៨–៤១ ) ។

កងទ័ពស៊ីយ៉ូនបានបំបែកគ្នាជាក្រុមតូចៗនៅចុងខែមិថុនាឆ្នាំ ១៨៣៤ ហើយទីបំផុតសំបុត្ររំសាយកងទ័ពបានចេញទៅនៅពីរបីថ្ងៃដំបូងនៃ ខែ កក្កដា ឆ្នាំ ១៨៣៤ នោះ ។ ពួកអ្នកស្ម័គ្រចិត្តភាគច្រើនបានត្រឡប់ទៅរដ្ឋអូហៃអូ វិញ ។

# តើមេរៀនអ្វីខ្លះ ដែលយើងអាចរៀនពីកងទ័ពជំរំស៊ីយ៉ូន ?

ដោយសារតែការខកខានពុំបានស្ដាបនាពួកបរិសុទ្ធនៅលើទឹកដីរបស់ពួកគេវិញ នៅក្នុងឃុំចាកសុន នោះមនុស្សមួយចំនួនបានចាត់ទុកកងព័ទជំរំស៊ីយ៉ូនថា ជាការខំប្រឹងមួយដែលបរាជ័យ និងគ្មានប្រយោជន៍ ។ បងប្រុសម្នាក់នៅទីក្រុង ខឺតឡង់ — ជាមនុស្សម្នាក់ដែលខ្វះសេចក្ដីជំនឿក្នុងការស្ម័គ្រចិត្តទៅជាមួយពួកក្រុមកងទ័ពនោះ — បានជួប ព្រិកហាំ យ៉ង់ ពេលលោកត្រឡប់មកពីរដ្ឋមិសសួរីវិញ ហើយបានសួរលោកថា « ‹ តើអ្នកបានទទួលអ្វីពីដំណើរដ៏ឥតប្រយោជន៍ទៅកាន់រដ្ឋ មិសសួរី ជាមួយ យ៉ូសែប ស្ម៊ីធ នេះ ? › ព្រិកហាំ យ៉ង់ បានតបវិញភ្លាមថា ‹ អ្វីៗទាំងអស់ដែលយើងបានសម្រេចនោះ ខ្ញុំនឹងមិនប្ដូរបទពិសោធន៍ ដែលខ្ញុំបានទទួលនៅក្នុងបេសកកម្មនោះជាមួយនឹងទ្រព្យសម្បត្តិនៃឃុំ ហ្គូហ្គាឡើយ › » ដែលកាលនោះទីក្រុង ខឺតឡង់ មានទីតាំងនៅឃុំនោះ ។[១]

ខ្ញុំអញ្ជើញអ្នកគិតឲ្យបានល្អិតល្អន់អំពីចម្លើយរបស់ ព្រិកហាំ យ៉ង់ ៖ « អ្វីៗទាំងអស់ដែលយើងបានសម្រេច» ។ តើមានគន្លឹះរៀនសូត្រសំខាន់អ្វីខ្លះ ដែលយើងអាចរៀនចេញពីការទទួលខុសត្រូវនេះ ដែលពុំបានបំពេញតាមគោលបំណងដែលបានចែង ប៉ុន្តែបានផ្ដល់ដល់ពួកបរិសុទ្ធកាលពីជំនាន់មុនទាំងនោះ ហើយអាចផ្ដល់ពរជ័យដល់ជីវិតយើង ?



ខ្ញុំជឿថា យ៉ាងហោចណាស់មានមេរៀនដែលគួរឲ្យយល់ដឹងពីរ ដែលមាននៅក្នុងចម្លើយរបស់បងប្រុស ព្រិកហាំ ចំពោះសំណួរចំអកឡកឡឺយនោះ ៖ ( ១ ) មេរៀននៃការសាកល្បង ការរែងរកមើល និងការរៀបចំ និង ( ២ ) មេរៀននៃការគោរពប្រតិបត្តិ ការរៀនសូត្រ និងការធ្វើតាមពួកបងប្អូនប្រុស ។ ខ្ញុំសូមគូសបញ្ជាក់ថាមេរៀនទាំងនេះមានសារៈសំខាន់ចំពោះពួកយើងដើម្បីរៀន ហើយអនុវត្តក្នុងពេលបច្ចុប្បន្ននេះដូចវាសំខាន់ចំពោះអ្នកស្ម័គ្រចិត្តនៃកងទ័ពជំរំស៊ីយ៉ូនកាលពីជាង ១៨០ ឆ្នាំមុនដែរ ។

**មេរៀននៃការសាកល្បង ការរែងរកមើល និងការរៀបចំ**

ពួកបរិសុទ្ធដ៏អង់អាចក្លាហាន ដែលបានធ្វើដំណើរក្នុងកងទ័ពរបស់ព្រះអម្ចាស់ត្រូវបានសាកល្បង ។ ដូចព្រះអម្ចាស់បានប្រកាសថា « យើងបានឮបទអធិស្ឋានទាំងឡាយរបស់ពួកគេហើយ ហើយព្រមទទួលដង្វាយរបស់ពួកគេ ហើយគឺជាការចាំបាច់ដល់យើង ដែលពួកគេត្រូវបាននាំមកដល់ទីនេះ សម្រាប់ការសាកល្បងសេចក្ដីជំនឿនៃពួកគេ » ( គ. និង ស. ១០៥:១៩ ) ។

និយាយឲ្យត្រង់ទៅ ការអញ្ជើញទាំងខាងរូបកាយ និងខាងវិញ្ញាណនៃពួកកងទ័ពជំរំស៊ីយ៉ូន បានបង្កើតឲ្យមានការរែងស្រូវសាលី ចេញពីស្រងែ ( សូមមើល ម៉ាថាយ ១៣:២៥, ២៩–៣០; គ. និង ស. ១០១:៦៥ ) ជាការញែកចៀមចេញពីពពែ ( សូមមើល ម៉ាថាយ ២៥:៣២–៣៣ ) ជាការញែកចេញរវាងអ្នកមានភាពរឹងមាំខាងវិញ្ញាណពីអ្នកដែលខ្សោយខាងវិញ្ញាណ ។ ដូច្នេះបុរស និងស្ត្រីម្នាក់ៗដែលបានចូលបម្រើនៅក្នុងកងទ័ពរបស់ព្រះអម្ចាស់ បានប្រឈមមុខ ហើយឆ្លើយសំណួរដ៏មុឹងម៉ាត់ដែលថា « តើនរណានៅខាងព្រះអម្ចាស់ ? »[២]

នៅពេល វិលហ្វឺឌ វូឌ្រុហ្វ កំពុងរៀបចំកិច្ចការជំនួញរបស់លោក ហើយរៀបចំខ្លួនចូលរួមកងទ័ពជំរំស៊ីយ៉ូន មិត្តភក្តិ និងអ្នកជិតខាងរបស់លោក បានព្រមានលោក កុំឲ្យធ្វើដំណើរដ៏គ្រោះថ្នាក់នោះឡើយ ។ ពួកគេបានផ្ដល់យោបល់ថា « កុំទៅឡើយ ប្រសិនបើអ្នកទៅនោះអ្នកនឹងស្លាប់បាត់បង់ជីវិតហើយ » ។ លោកបានតបវិញថា « ប្រសិនបើខ្ញុំដឹងថាខ្ញុំនឹងត្រូវគេបាញ់ទម្លុះបេះដូង នៅជំហានដំបូងដែលខ្ញុំឈានជើងដើរនៅលើរដ្ឋមិសសួរីក្ដី ក៏ខ្ញុំនឹងទៅដែរ » ។[៣] វិលហ្វឺឌ វូឌ្រុហ្វ បានដឹងថាមិនត្រូវភ័យខ្លាចនឹងលទ្ធផលអាក្រក់ដែលកើតមានឡើយ ដរាបណាគាត់នៅស្មោះត្រង់ ហើយគោរពប្រតិបត្តិនោះ ។ គាត់ពិតជានៅខាងព្រះអម្ចាស់ហើយ !

ប្រាកដណាស់នេះជា « ពេលដែលត្រូវបង្ហាញ »[៤] ពីបុរស និងស្ត្រីស្មោះត្រង់នាដូវក្ដៅក្នុងឆ្នាំ ១៨៣៤ ទាំងនោះ ។ ប៉ុន្តែការសម្រេចចិត្តដើម្បីធ្វើដំណើរជាមួយព្យាការី យ៉ូសែប ទៅរដ្ឋមិសសួរី ពុំមែនជាការឆ្លើយតបចាំបាច់តែម្ដងឬរួមគ្នាទាំងអស់ ឬចម្លើយតបភ្លាមៗទៅនឹងសំណួរថា « តើនរណានៅខាងព្រះអម្ចាស់ ? » ឡើយ ។ ពេលដែលត្រូវបង្ហាញដោយពួកបរិសុទ្ធទាំងនោះបានកើតឡើងជារឿយៗ ហើយដដែលៗ តាមរយៈការហត់នឿយខាងផ្លូវចិត្ត និងរូបកាយ តាមរយៈពងបែកនៅលើជើងរបស់ពួកគេ តាមរយៈការខ្វះខាតអាហារ និងទឹកមិនស្អាត តាមរយៈការខកចិត្តជាច្រើន តាមរយៈការបែកបាក់គ្នា និងការបះបោរនៅក្នុងក្រុម និងតាមរយៈការគំរាមកំហែងពីសំណាក់ពួកមារសត្រូវខាងក្រៅដ៏កាចសាហាវ ។

ពេលដែលត្រូវបង្ហាញកើតមានឡើងនៅក្នុងបទពិសោធន៍ និងការលំបាកនានាដែលមានរៀងរាល់ម៉ោង រាល់ថ្ងៃ និងរាល់សប្ដាហ៍ ។ វាគឺជាការរួមផ្គុំគ្នា



« យើងមានមនុស្សជាច្រើនដែលពួកគេមានអារម្មណ៍ថា ពួកគេជាមនុស្សល្អ ប៉ុន្តែពួកគេត្រូវតែជាមនុស្សល្អចំពោះរឿងមួយចំនួន » ។

ដ៏ធំសម្បើមនៃជម្រើស និងទង្វើជាច្រើនដែលហាក់ដូចជាតូចតាច នៅក្នុងជីវិតនៃពួកបរិសុទ្ធដ៏មានភក្តីភាពទាំងនោះ ដែលបានផ្តល់ចម្លើយយ៉ាងពិតប្រាកដចំពោះសំណួរថា « តើនរណានៅខាងព្រះអម្ចាស់ ? »

តើការសាកល្បង និងការរែងរកមើល ដែលបានកើតឡើងនៅក្នុងជីវិតនៃអស់អ្នក ដែលចូលរួមនឹងកងទ័ពជំរំស៊ីយ៉ូននេះជួយក្នុងការរៀបចំខ្លួនដោយរបៀបណា ? គួរឲ្យចាប់អារម្មណ៍ណាស់ មានបងប្អូនប្រុសចំនួនប្រាំបីរូបត្រូវបានហៅឲ្យបម្រើនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ក្នុងឆ្នាំ ១៨៣៥ ព្រមទាំងពួកចិតសិបនាក់ទាំងអស់ក៏ត្រូវបានហៅនាពេលដដែរនោះ សុទ្ធតែជាពួកទាហានជើងចាស់មកពីកងទ័ពជំរំស៊ីយ៉ូននោះ ។ នៅក្នុងការប្រជុំមួយបន្ទាប់ពីការហៅពួកចិតសិបនាក់មក ព្យាការី យ៉ូសែប ស្ម៊ីធ បានប្រកាសថា ៖

« បងប្អូនប្រុសអើយ មានបងប្អូនមួយចំនួនខឹងនឹងរូបខ្ញុំ ដោយសារបងប្អូនពុំបានធ្វើចម្បាំងនៅក្នុងរដ្ឋមិសសួរី ប៉ុន្តែខ្ញុំសូមប្រាប់បងប្អូនថា ព្រះពុំចង់ឲ្យបងប្អូនធ្វើចម្បាំងឡើយ ។ ទ្រង់ពុំអាចស្ថាបនានគរទ្រង់ឡើង ដោយមានតែបុរសដប់ពីរនាក់បើកទ្វារនៃដំណឹងល្អឲ្យជាតិសាសន៍ទាំងអស់នៅលើផែនដី និងពួកចិតសិបនាក់ទៀត ដែលស្ថិតក្រោមការដឹកនាំរបស់ពួកគេដើម្បីបន្តកិច្ចការបានឡើយ លើកលែងតែទ្រង់ចម្រាញ់ពួកគេចេញមកពី ក្រុមបុរសដែលបានថ្វាយជីវិតខ្លួន និង ដែលបានលះបង់យ៉ាងធំធេងដូចដែលអ័ប្រាហាំបានធ្វើប៉ុណ្ណោះ ។

ឥឡូវនេះព្រះអម្ចាស់បានមានពួកដប់ពីរនាក់ និងពួកចិតសិបនាក់របស់ទ្រង់ហើយ ហើយនឹងមានកូរ៉ុមនៃពួកចិតសិបនាក់ផ្សេងទៀតនឹងត្រូវបានហៅ » ។[៥]

ប្រាកដណាស់ និយាយរួមកងទ័ពជំរំស៊ីយ៉ូនគឺជាភ្លើងរបស់ជាងសំរង សម្រាប់អស់អ្នកដែលស្ម័គ្រចិត្តទាំងអស់ ហើយជាពិសេសសម្រាប់អនាគតថ្នាក់ដឹកនាំជាច្រើននាក់របស់សាសនាចក្រ ។

បទពិសោធន៍ដែលអ្នកស្ម័គ្រចិត្តទាំងនោះទទួលបាននៅក្នុងកងទ័ពរបស់ព្រះអម្ចាស់ ក៏ជាការរៀបចំសម្រាប់ការធ្វើអន្តោប្រវេសន៍ដ៏ធំនាពេលខាងមុខរបស់សមាជិកសាសនាចក្រផងដែរ ។ អ្នកចូលរួមជាង ២០ នាក់នៅក្នុងកងទ័ពជំរំស៊ីយ៉ូននោះបានក្លាយជាមេបញ្ជាការ និងអនុសេនីយ៍ត្រីនៅក្នុងការធ្វើដំណើរដ៏ធំៗចំនួនពីរ — លើកទីមួយគឺបួនឆ្នាំក្រោយមកទាក់ទងនឹងការផ្លាស់ទីលំនៅរបស់ប្រជាជនពី ៨០០០ នាក់ ទៅ ១០០០០ នាក់ពីរដ្ឋមិសសួរី ទៅរដ្ឋអិលលីណោយ[៦] និងលើកទីពីរ ១២ ឆ្នាំក្រោយមក គឺការប្តូរទីលំនៅដ៏ធំទៅទិសខាងលិចនៃពួកបរិសុទ្ធថ្ងៃចុងក្រោយប្រមាណជា ១៥០០០ នាក់ពីរដ្ឋអិលលីណោយ ទៅជ្រលងភ្នំ សលត៍ លេក និងជ្រលងភ្នំរ៉ុកគី ។ អំឡុងពេលការរៀបចំបំពាក់បំប៉ន កងទ័ពជំរំស៊ីយ៉ូនមានតម្លៃខ្លាំងបំផុតសម្រាប់សាសនាចក្រ ។ ឆ្នាំ ១៨៣៤ គឺជាពេលដែលត្រូវបង្ហាញ — ហើយដើម្បីរៀបចំសម្រាប់ឆ្នាំ ១៨៣៨ និង ឆ្នាំ ១៨៤៦ ។

ក្នុងនាមជាបុគ្គលម្នាក់ៗ និងក្រុមគ្រួសារ យើងក៏នឹងទទួលការសាកល្បង ការរែងរកមើល និងការរៀបចំ ដូចជាសមាជិកនៃកងទ័ពជំរំស៊ីយ៉ូនដែរ ។ ព្រះគម្ពីរ និងការបង្រៀនរបស់ពួកបងប្អូនប្រុសពោរពេញដោយការសន្យាថា សេចក្តីជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ការចុះ ការគោរព និងការចងចាំអំពីសេចក្តីសញ្ញាពិសិដ្ឋរបស់យើង និងការគោរពប្រតិបត្តិតាមបទបញ្ញត្តិរបស់ព្រះ នឹងពង្រឹងយើងឲ្យរៀបចំ

ខ្លួនដើម្បីប្រឈមមុខ ដើម្បីយកឈ្នះ និងដើម្បីរៀនពីការសាកល្បង និងការល្បងលនៃជីវិតមេងស្លាប់នេះ ។

ពួកអ្នកដឹកនាំសាសនាចក្ររបស់ព្រះអម្ចាស់ពីជំនាន់មុនៗ បានរកឃើញនូវការសាកល្បងរួម ឬការសាកល្បងទូទៅមួយចំនួន ដែលយើងអាចរំពឹងទុកជាមុនថានឹងជួបប្រទះនៅក្នុងជីវិត និងជំនាន់របស់យើង ។ ក្នុងនាមជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ក្នុងឆ្នាំ ១៩៧៧ ប្រធាន អ៊ែសរ៉ា ថាហ្វ បែនសឹន ( ១៨៩៩–១៩៩៤ ) បានមានប្រសាសន៍ពីសំឡេងនៃការព្រមាន នៅក្នុងការប្រជុំអ្នកតំណាងភូមិភាគ ។ ឥឡូវនេះខ្ញុំសូមដកស្រង់សារលិខិតទាំងស្រុងរបស់ប្រធាន បែនសឹន ហើយអញ្ជើញអ្នកឲ្យផ្តោតចិត្តទុកដាក់លើការទូន្មានរបស់លោកនាកាលគ្រានោះ ៖

« ជំនាន់នីមួយៗមានការសាកល្បង និងឱកាសរៀងៗខ្លួនដើម្បីក្រោកឈរឡើង ហើយបង្ហាញសមត្ថភាពរបស់ខ្លួន ។ តើអ្នកចង់ដឹងអំពីការសាកល្បងដ៏លំបាកបំផុតមួយរបស់ពួកយើងដែរឬទេ ? ដោយស្តាប់ពួការព្រមានរបស់ ព្រិកហាំ យ៉ង់ ‹ ការភ័យខ្លាចដ៏ធំបំផុតដែលខ្ញុំមានអំពីប្រជាជននេះគឺថា ពួកគេនឹងក្លាយជាអ្នកមាននៅក្នុងប្រទេសនេះ ភ្លេចព្រះ និងរាស្ត្ររបស់ទ្រង់ ប្រែជាខ្ជិលច្រអូស ហើយដកខ្លួនឯងចេញពីសាសនាចក្រចូលទៅស្ថាននរក ។ ប្រជាជននេះអាចស៊ូនឹងការវាយប្រហារ ការលួចឆក់ប្លន់ ភាពក្រីក្រ និងការបៀតបៀនគ្រប់រូបភាពបាន ហើយបន្តនៅស្មោះត្រង់ ។ ប៉ុន្តែអ្វីដែលជាសេចក្តីភ័យខ្លាចដ៏ធំបំផុតរបស់ខ្ញុំនោះគឺថា ពួកគេនឹងពុំអាចស៊ូទ្រាំនឹងការមានភោគទ្រព្យសំបូរហូរហៀរឡើយ › » ។

ប្រធាន បែនសឹន ថ្លែងបន្តទៀតថា ៖ « ការសាកល្បងរបស់យើងហាក់ដូចជាលំបាកខ្លាំងបំផុតលើសពីការសាកល្បងទាំងអស់ ដ្បិតអារក្សមានកលល្បិចយ៉ាងប៉ិនប្រសប់ ហើយវាឆ្លាតជាងយើង ។ ការសាកល្បងទាំងនោះហាក់ដូចជាមិនសូវកាចសាហាវ ហើយវាពិបាកមើលឃើញ ។ ខណៈដែលគ្រប់ការសាកល្បងនៃសេចក្តីសុចរិត តំណាងឲ្យការលំបាកមួយ នោះការសាកល្បងបែបនេះហាក់ដូចជាពុំមែនជាការសាកល្បងទេឡើយ គ្មានការលំបាកណា អាចក្លាយជាការបំភាន់ខ្លាំងបំផុតលើសពីការសាកល្បងទាំងអស់ឡើយ ។

« តើអ្នកដឹងទេថាភាពសុខសាន្ត និងភាពចម្រុងចម្រើនអាចផ្តល់អ្វីខ្លះដល់មនុស្ស — វាអាចធ្វើឲ្យពួកគេភ្លេចខ្លួន ។ ព្រះគម្ពីរមរមនបានព្រមានយើងអំពី របៀបដែលសាតាំងនឹងនាំយើងឲ្យធ្លាក់ចុះទៅស្ថាននរកដោយប្រុងប្រយ័ត្ននៅជំនាន់ចុងក្រោយនេះ ។ ព្រះអម្ចាស់បានដាក់អ្នកមានសក្តានុពលដែលរឹងប៉ឹងខាងវិញ្ញាណមួយចំនួនលើផែនដី ជាអស់អ្នកដែលទ្រង់បានរក្សាទុកអស់រយៈពេលប្រាំមួយពាន់ឆ្នាំ ដើម្បីជួយបង្កើតផលដោយជោគជ័យដល់នគរព្រះ ហើយអារក្សកំពុងព្យាយាមធ្វើឲ្យពួកគេភ្លេចខ្លួន ។ មារសត្រូវដឹងថា វាប្រហែលជាមិនសូវទទួលជោគជ័យក្នុងការនាំពួកគេឲ្យប្រព្រឹត្តអំពើបាបធំៗ និងដ៏សែនអាក្រក់នៃការប្រព្រឹត្តកំហុសនោះឡើយ ។ ដូច្នេះវាធ្វើឲ្យពួកគេភ្លេចខ្លួន ដូចជាហ្វូលីជីវ ដោយវាដាក់អន្ទាក់ពួកគេឲ្យជាប់ទៅនឹងអំពើបាបតូចៗទាំងនោះនៃការមិនប្រតិបត្តិតាមវិញ ហើយតើអ្នកដឹកនាំដែលភ្លេចខ្លួន គ្មានប្រសិទ្ធភាព មានចិត្តស្ទាក់ស្ទើរនោះមានអ្វីល្អទៅ ?



« យើងមានអ្នកមានសក្តានុពលដែលរឹងប៉ឹងខាងវិញ្ញាណជាច្រើន ដែលគួរតែលើកស្ទួយគ្រួសារ នគរ និងប្រទេសរបស់ខ្លួនឲ្យបានកាន់តែរឹងមាំឡើង ។ យើងមានមនុស្សជាច្រើនដែលពួកគេមានអារម្មណ៍ថា ពួកគេជាមនុស្សល្អ ប៉ុន្តែពួកគេចាំបាច់ត្រូវតែជាមនុស្សប៉ិនប្រសប់ចំពោះរឿងមួយចំនួនដូចជា — អយ្យកោរឹងមាំ អ្នកផ្សព្វផ្សាយសាសនាមានចិត្តក្លាហាន អ្នកធ្វើការដ៏អង់អាចក្នុងកិច្ចការពង្សប្រវត្តិ និងព្រះវិហារបរិសុទ្ធ អ្នកស្នេហាជាតិចេះលះបង់ សមាជិកកូរ៉ុមដែលមានភក្តីភាព ។ សរុបទៅ យើងត្រូវតែគេចខ្លួន និងដាស់ខ្លួនយើងចេញពីការលង់លក់ខាងវិញ្ញាណ » ។[៧]

ចូរពិចារណាអំពីភោគទ្រព្យដ៏សំបូរហូរហៀរ ភាពចម្រុងចម្រើន និងភាពងាយស្រួលនោះ ដែលវាអាចក្លាយជាការសាកល្បងនៅក្នុងជំនាន់របស់យើង ដែលមានទំហំស្មើ ឬខ្លាំងជាងការបៀតបៀន និងការលំបាកខាងរូបកាយ ដែលពួកបរិសុទ្ធស្ម័គ្រចិត្តធ្វើដំណើរជាមួយកងទ័ពដំរីសីយ៉ូនទាំងនោះបានស៊ូទ្រាំ ។ ដូចព្យាការីមរមនបានពិពណ៌នានៅក្នុងការសង្ខេបដ៏អស្ចារ្យរបស់លោកអំពីវដ្តនៃភាពឆ្មើងឆ្មៃ ដែលមាននៅក្នុង ហេលេមិន ១២ ៖

« ម្លោះហើយ យើងអាចឃើញថា ចិត្តនៃកូនចៅមនុស្សខុសឆ្គង ហើយគ្មានភាពនឹងនយ៉ាងណា មែនហើយ យើងអាចឃើញថា ព្រះអម្ចាស់នៅក្នុងសេចក្តីល្អមហិមាដ៏និរន្តរ៍របស់ទ្រង់ ប្រទានពរ ហើយធ្វើឲ្យចម្រើនឡើងដល់អស់អ្នកណា ដែលដាក់ទីទុកចិត្តរបស់គេទៅលើទ្រង់ ។

« មែនហើយ ហើយយើងអាចឃើញថា នៅពេលដែលទ្រង់ធ្វើឲ្យរាស្ត្រទ្រង់បានចម្រើនឡើង មែនហើយ គឺក្នុងការបង្កើនស្រែចម្ការរបស់គេ ហ្វូងចៀមរបស់គេ និងហ្វូងសត្វរបស់គេ ហើយមាស និងប្រាក់ និងវត្ថុមានតម្លៃសព្វសារពើ និងវត្ថុសិល្បៈ លើកលែងជីវិតឲ្យគេ ហើយដោះលែងពួកគេឲ្យរួចផុតពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវរបស់គេ បន្ទន់ចិត្តនៃពួកខ្មាំងសត្រូវរបស់គេដើម្បីកុំឲ្យពួកវាធ្វើសង្គ្រាមនឹងពួកគេ មែនហើយ ហើយសរុបសេចក្តីមក ធ្វើនូវគ្រប់ការណ៍ទាំងអស់ ដើម្បីសុខមាលភាព និងសុភមង្គលរបស់រាស្ត្រទ្រង់ មែនហើយ នៅពេលនោះហើយដែលពួកគេធ្វើចិត្តរឹងរូស ហើយបំភ្លេចព្រះអម្ចាស់ជាព្រះរបស់គេ ហើយជាន់ឈ្លីនៅក្រោមជើងរបស់គេនូវព្រះដ៏បរិសុទ្ធ — មែនហើយ ហើយនេះគឺមកពីការងាយស្រួល និងការចម្រើនឡើងដ៏ធំហួសប្រមាណរបស់គេ » ( ហេលេមិន ១២:១–២ ) ។

ជាពិសេសខ្ញុំសូមអញ្ជើញអ្នកឲ្យកត់សម្គាល់អំពីឃ្លាចុងក្រោយនៅក្នុងខគម្ពីរចុងក្រោយនោះ ៖ « ហើយនេះគឺមកពីការងាយស្រួល និងការចម្រើនឡើងដ៏ធំហួសប្រមាណរបស់គេ » ។

ប្រធាន ហារ៉ូល ប៊ី លី ( ១៨៩៩–១៩៧៣ ) ក៏បានបង្រៀនដូចនេះផងដែរ អំពីការសាកល្បងជារួមនៃភាពងាយស្រួល ដែលយើងជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងថា ៖ « យើងត្រូវបានសាកល្បង យើងត្រូវបានល្បងល យើងកំពុងហែលឆ្លងកាត់ការសាកល្បងដ៏លំបាកបំផុតមួយចំនួននាសព្វថ្ងៃនេះ ហើយយើងប្រហែលជាពុំដឹងអំពីទំហំដ៏ធ្ងន់ធ្ងរនៃការសាកល្បងទាំងនោះដែលយើងកំពុងឆ្លងកាត់ឡើយ ។ នៅជំនាន់នោះ មានអំពើឃាតកម្ម មានការបៀតបៀនពីមនុស្សអាក្រក់ មានការបណ្ដេញចេញពីទីលំនៅ ។ ពួកគេត្រូវបានបណ្ដេញចេញឲ្យចូលទៅក្នុងវាលរហោស្ថាន ពួកគេមានការស្រេកឃ្លាន ហើយពួកគេអាក្រាតគ្មានសម្លៀកបំពាក់ ហើយពួកគេរងារ ។ ពួកគេបានមកដល់ទីនេះដែលជាដែនដីដ៏សំណព្វចិត្ត ។ ពួកយើងគឺជាអ្នកទទួលមរតកនៃអ្វីដែលពួកគេបានផ្ដល់ដល់យើង ។ ប៉ុន្តែតើយើងកំពុងធ្វើអ្វីខ្លះជាមួយនឹងមរតកទាំងនោះ ? សព្វថ្ងៃនេះយើងរីករាយនឹងជីវិតបែបទំនើប ជាជីវិតដែលយើងពុំធ្លាប់បានឃើញពីមុន នៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោក ។ វាទំនងថានេះប្រហែលជាការសាកល្បងដ៏ខ្លាំងបំផុតនៃការសាកល្បងនានា ដែលយើងធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រនៃសាសនាចក្រនេះ » ។ [៨]

ការបង្រៀនទាំងនេះមកពីពួកព្យាការីសម័យទំនើប និងបុរាណអំពីការល្បងល និងការសាកល្បងនាថ្ងៃចុងក្រោយនេះគឺមានភាពស្រគត់ស្រគំ និងសំខាន់ណាស់ ។ ប៉ុន្តែការបង្រៀនទាំងនោះពុំគួរបំបាក់ទឹកចិត្តយើងឡើយ ហើយយើងពុំគួរភ័យខ្លាចផងដែរ ។ ដ្បិតអស់អ្នកមានភ្នែកដែលមើលឃើញ ហើយមានត្រចៀកដែលស្ដាប់ឮ នោះការព្រមានខាងវិញ្ញាណដឹកនាំទៅរកការប្រុងប្រយ័ត្នកាន់តែខ្លាំងឡើង ។ បងប្អូន និងរូបខ្ញុំរស់នៅក្នុង « ថ្ងៃនៃការព្រមាន » ( គ. និង ស. ៦៣:៥៨ ) ។ ដូចសាវកប៉ុលបានទូន្មាន ហើយដោយសារយើងធ្លាប់ និងត្រូវបានព្រមាន នោះយើងត្រូវ « ចាំយាម . . . នូវគ្រប់ទាំងសេចក្ដីខ្ជាប់ខ្ជួន » ( អេភេសូរ ៦:១៨ ) ។ នៅពេលយើងប្រុងប្រយ័ត្ន ហើយរៀបចំខ្លួន ប្រាកដណាស់យើងពុំត្រូវភ័យខ្លាចឡើយ ( សូមមើល គ. និង ស. ៣៨:៣០ ) ។

តើនរណានៅខាងព្រះអម្ចាស់ ? ឥឡូវនេះគឺជាពេលដែលត្រូវបង្ហាញថា យើងមានចិត្តគំនិត ដែលទទួលយក ហើយនឹងឆ្លើយតបទៅនឹងការព្រមានដ៏បំផុសគំនិតទាំងនេះ ។ ឥឡូវនេះគឺជាពេលដែលត្រូវបង្ហាញថា យើងកំពុងប្រុងប្រយ័ត្ន ហើយរៀបចំខ្លួនទប់ទល់នឹងការសាកល្បងនៃភាពចម្រុងចម្រើន និងភាពឆ្មើងឆ្មៃ ភោគទ្រព្យសំបូរហូរហៀរ និងភាពងាយស្រួល និងភាពរឹងរូសនៃចិត្ត និងការបំភ្លេចព្រះអម្ចាស់ជាព្រះរបស់យើងនាជំនាន់ថ្ងៃចុងក្រោយនេះ ។ ឥឡូវនេះគឺជាពេលដែលត្រូវបង្ហាញថា យើងនឹងបន្តស្មោះត្រង់គ្រប់ពេលវេលា ទោះនៅក្នុងកិច្ចការណាក៏ដោយ ដែលយើងទទួលមកពីព្រះវរបិតាសួគ៌របស់យើង និងបុត្រាដ៏ជាទីស្រឡាញ់របស់ទ្រង់ — ហើយថាយើងនឹងកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយដើរដោយស្មោះត្រង់នៅចំពោះទ្រង់ ( សូមមើល អាលម៉ា ៥៣:២០–២១ ) ។

**មេរៀននៃការគោរពប្រតិបត្តិ ការរៀនសូត្រ និងការធ្វើតាមពួកបងប្អូនប្រុស**

ពួកបរិសុទ្ធដ៏មានចិត្តអង់អាចក្លាហាននៅក្នុងកងទ័ពរបស់ព្រះអម្ចាស់បានទទួលពរ ក្នុងការគោរពប្រតិបត្តិ ការរៀនសូត្រ និងការធ្វើតាមពួកបងប្អូនប្រុស ។ ហើយពួកយើងសព្វថ្ងៃនេះអាចទទួលបានអត្ថប្រយោជន៍យ៉ាងធំធេងមកពីគំរូ និងភាពស្មោះត្រង់របស់សមាជិកនៃកងទ័ពជំរំស៊ីយ៉ូនដ៏មានភក្ដីភាពទាំងនោះ ។

ក្នុងការឆ្លើយតបទៅនឹងការទូន្មានរបស់ ប៉ាលី ភី ប្រាត្ត នោះ វិលហ្វូឌ វូឌដ្រុព្វ បានធ្វើដំណើរទៅទីក្រុង ខឺតឡង់ រដ្ឋអូហៃអូ នៅក្នុងខែមេសា ឆ្នាំ ១៨៣៤ ទៅចូលរួមនឹងកងទ័ពជំរំស៊ីយ៉ូន ។ ដំណើររឿងរបស់បងប្រុស វូឌដ្រុព្វ អំពីការការប្រជុំជាមួយព្យាការី យ៉ូសែប ស៊្មីធ គឺមានប្រយោជន៍សម្រាប់ពួកយើងទាំងអស់គ្នា ៖

« នេះគឺជាលើកដំបូងក្នុងជីវិតខ្ញុំ ដែលខ្ញុំបានជួប និងបានសម្ភាសជាមួយព្យាការី យ៉ូសែប ស៊្មីធ ជាទីស្រឡាញ់របស់យើង គាត់ជាបុរសដែលព្រះបានជ្រើសរើស ឲ្យនាំយកនូវវិវរណៈរបស់ទ្រង់មកកាន់ជំនាន់ថ្ងៃចុងក្រោយនេះ ។ ការណែនាំខ្លួនខ្ញុំលើកដំបូងឲ្យលោកស្គាល់ ពុំមែនជាអ្វីមួយគាប់ចិត្តមនុស្សដែលកាន់សាសនាធ្លាប់បានសន្មត់ទុកជាមុនទាក់ទងនឹងអត្តចរិតរបស់ព្យាការី និងរូបរាងរបស់លោកឡើយ ។ វាអាចធ្វើឲ្យសេចក្ដីជំនឿរបស់មនុស្សមួយចំនួនរង្គោះរង្គើរ ។ ខ្ញុំបានជួបលោក និងបងប្រុសរបស់លោក ហៃរុម នៅខាងក្រៅផ្ទះកំពុងកាន់កាំភ្លើងពីរដើមបាញ់ទៅលើផ្ទាំងសីប ។ ពេលពួកលោកឈប់បាញ់កាំភ្លើង ខ្ញុំបានណែនាំខ្លួនឲ្យបងប្រុស យ៉ូសែប ស្គាល់ ហើយលោកបានចាប់ដៃខ្ញុំដោយដួងចិត្តរីករាយបំផុត ។ លោកបានអញ្ជើញខ្ញុំឲ្យចាត់ទុកផ្ទះរបស់លោកដូចជាផ្ទះរបស់ខ្ញុំ អំឡុងពេលខ្ញុំស្នាក់នៅទីក្រុងខឺតឡង់ ។ ខ្ញុំបានទទួលយកការអញ្ជើញនេះដោយរីករាយបំផុត ហើយខ្ញុំត្រូវបានស្គាងឡើង និងមានសេចក្ដីមនោរម្យឥតឧបមាអំឡុងពេលខ្ញុំស្នាក់នៅជាមួយលោក » ។[៩]

ខ្ញុំយល់ឃើញថា វាជាប្រយោជន៍ដ៏ធំមួយ ដែលបងប្រុស វូឌដ្រុព្វ បានស្នាក់នៅមួយរយៈពេលនៅក្នុងផ្ទះរបស់ព្យាការី ហើយមានឱកាសអស្ចារ្យបំផុត ដើម្បីសង្កេតមើលលោកនៅក្នុងការរស់នៅប្រចាំថ្ងៃ ហើយបានទទួលពរឲ្យមានភ្នែកដែលមើលឃើញហួសពី « គំនិតដែលមនុស្សកាន់សាសនាធ្លាប់បានសន្មត់ទុកជាមុនទាក់ទងនឹងអត្តចរិតរបស់ព្យាការី និងរូបរាងរបស់លោក » ។ គំនិតខុសឆ្គងទាំងនោះបានធ្វើឲ្យមនុស្សជាច្រើននៅក្នុងពិភពលោកបច្ចុប្បន្ននេះ ទាំងនៅក្នុង និងក្រៅសាសនាចក្ររបស់ព្រះអម្ចាស់ ដែលស្ដារឡើងវិញនេះ មានទស្សនយល់ខុស ។

ជាលទ្ធផលនៃការហៅបម្រើរបស់ខ្ញុំក្នុងឆ្នាំ ២០០៤ ដើម្បីបម្រើនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នោះខ្ញុំមានទស្សនវិស័យផ្ទាល់ខ្លួនមួយយ៉ាងជាក់ច្បាស់ អំពីអត្ថន័យនៃការគោរពប្រតិបត្តិ ការរៀនសូត្រ និងការធ្វើតាមពួកបងប្អូនប្រុស ។ ឥឡូវនេះខ្ញុំមើលឃើញជាប្រចាំនូវចរិតលក្ខណៈ ចំណង់ចំណូលចិត្តផ្សេងៗគ្នា និងចរិតដ៏

ថតរូប © DESERET NEWS



វាជារឿងសំខាន់សម្រាប់ពួកយើងទាំងអស់គ្នាដើម្បីចងចាំថា យើងអាចរៀនពីការបង្រៀនរបស់ពួកបងប្អូនប្រុស និងរៀនពីគំរូនៃជីវិតរបស់ពួកលោក ។

ថ្លៃថ្នូររបស់ពួកលោកម្នាក់ៗ ដែលជាអ្នកដឹកនាំក្នុងសាសនាចក្រនេះ ។ មនុស្សមួយចំនួនបានរាប់ថាការខ្វះខាត និងភាពមិនល្អឥតខ្ចោះរបស់បងប្អូនប្រុសទាំងនេះគឺជាបញ្ហា ហើយធ្វើឲ្យសេចក្ដីជំនឿថយចុះ ។ សម្រាប់ខ្ញុំ ភាពទន់ខ្សោយទាំងនោះគឺជាការលើកកម្ពស់សេចក្ដីជំនឿទៅវិញ ។ គំរូបើកបង្ហាញរបស់ព្រះអម្ចាស់អំពីការគ្រប់គ្រងនៅក្នុងសាសនាចក្ររបស់ទ្រង់ ផ្ដល់ការគាំទ្រ និងកាត់បន្ថយឥទ្ធិពលនៃភាពទន់ខ្សោយរបស់មនុស្ស ។ វាពិតជាអព្ភូតហេតុសម្រាប់ខ្ញុំ ក្នុងការមើលឃើញថា ព្រះអម្ចាស់សម្រេចបាននូវព្រះហឫទ័យទ្រង់ តាមរយៈអ្នកបម្រើទ្រង់ទោះបីជាថ្នាក់ដឹកនាំដែលទ្រង់បានជ្រើសរើសនោះមានកំហុសឆ្គង និងភាពទន់ខ្សោយក្ដី ។ ពួកបុរសទាំងនេះពុំធ្លាប់ប្រកាសអះអាងថា ពួកលោកល្អឥតខ្ចោះ ហើយពួកលោកក៏មិនល្អឥតខ្ចោះផងដែរ ប៉ុន្តែព្រះបានហៅពួកលោកជាប្រាកដ ។

នៅពេលលោកដើរចូរទៅក្នុងរដ្ឋមិសស្សូរីជាមួយកងទ័ពព្រះអម្ចាស់ក្នុងនាមជាសង្ឃ នោះ វិលហ្វូឌ វូឌដ្រុព្វ បានប្រកាសនៅពេលក្រោយមកទៀត អំឡុងពេលបម្រើជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ថា ៖ « យើងបានទទួលបទពិសោធន៍មួយ ដែលយើងពុំអាចទទួលវាបានតាមរបៀបណាផ្សេងទៀតឡើយ ។ យើងមានឯកសិទ្ធិក្នុងការ . . . ធ្វើដំណើរអស់រាប់ពាន់គីឡូជាមួយ [ ព្យាការី ] ហើយមើលឃើញកិច្ចការនៃព្រះវិញ្ញាណរបស់ព្រះនៅគង់ជាមួយនឹងលោក ព្រមទាំងវិវរណៈនៃព្រះយេស៊ូវគ្រីស្ទប្រទានមកដល់លោក និងការបំពេញនូវវិវរណៈទាំងនោះ ។ . . . ប្រសិនបើខ្ញុំពុំបានមកជាមួយនឹងកងទ័ពជំរំស៊ីយ៉ូនទេនោះ ខ្ញុំពុំអាចមានវត្តមាននៅទីនេះនាថ្ងៃនេះឡើយ » ។[១០]

នៅថ្ងៃអាទិត្យចុងក្រោយក្នុងខែមេសា ឆ្នាំ ១៨៣៤ យ៉ូសែប ស្ម៊ីធ បានអញ្ជើញថ្នាក់ដឹកនាំមួយចំនួនរបស់សាសនាចក្រ ឲ្យដឹកនាំប្រមូលពួកកងទ័ពជំរំស៊ីយ៉ូនចូលទៅក្នុងសាលារៀនមួយ ។ បន្ទាប់ពីពួកបងប្អូនប្រុសបានបញ្ចប់សារលិខិតរបស់ពួកលោកហើយ ព្យាការីបានក្រោកឈរឡើង ហើយបង្ហាញថាលោកត្រូវបានស្អាងឡើងដោយការណែនាំមួយ ។ បន្ទាប់មកលោកបានព្យាករថា ៖

« ខ្ញុំចង់និយាយទៅកាន់បងប្អូននៅចំពោះព្រះភក្ត្រព្រះអម្ចាស់ថា បងប្អូនពុំដឹងអ្វីផ្សេងទៀតអំពីជោគវាសនានៃសាសនាចក្រ និងនគរនេះច្រើនជាងទារកដែលនៅលើភ្លៅម្ដាយឡើយ ។ បងប្អូនពុំអាចយល់វាបានទេ ។ . . . នៅយប់នេះ បងប្អូនឃើញមានអ្នកកាន់បព្វជិតភាពតែបន្តិចទេ ប៉ុន្តែសាសនាចក្រនេះនឹងមានពាសពេញនៅអាមេរិកខាងជើង និងខាងត្បូង — វានឹងមានពេញផែនដីទាំងមូល » ។[១១]

បុរសទាំងនោះដូចជា ព្រិកហាំ យ៉ង់, ហ៊ីប៊ើរ ស៊ី ឃិមបឹល ,អ្លរសុន ប្រាត្ត និង វិលហ្វូឌ វូឌដ្រុព្វ បានស្ដាប់តាម ហើយបានរៀនច្រើនពីព្យាការីនាយប់នោះ — ហើយជាច្រើនឆ្នាំក្រោយមក ពួកគេបានជួយបំពេញនូវការព្យាករដែលបានប្រកាសនោះ ។ ឱ វាជាឱកាសដ៏រុងរឿងអ្វីម្ល៉េះ ដែលបុរសទាំងនេះមានក្នុងការគោរពប្រតិបត្តិការរៀនសូត្រ និងការធ្វើតាមព្យាការី ។

វាជារឿងសំខាន់សម្រាប់ពួកយើងទាំងអស់គ្នាដើម្បីចងចាំថា យើងអាចរៀនពីការបង្រៀនរបស់ពួកបងប្អូនប្រុស និងរៀនពីគំរូនៃជីវិតរបស់ពួកលោក ។ ព្យាការីយ៉ូសែប ស្ម៊ីធ បានពិពណ៌នាអំពីទស្សនវិស័យដ៏វិសេសវិសាលអំពីការរីកចម្រើន



« តើនរណានៅខាងព្រះអម្ចាស់ ? » ឥឡូវនេះគឺជាពេលដែលត្រូវបង្ហាញតាមរយៈការស្ដាប់ និងស្ដាប់ដោយយកចិត្តទុកដាក់ លើដំបូន្មានរបស់ពួកសាវក និងព្យាការីដែលកំពុងរស់នៅដែលព្រះបានហៅ ។

របស់សាសនាចក្រនាពេលអនាគត ឥឡូវនេះសូមពិចារណាអំពីឥទ្ធិពលនៃគំរូផ្ទាល់ខ្លួនរបស់លោក នៅក្នុងការធ្វើកិច្ចការប្រចាំថ្ងៃ និងសាមញ្ញៗ ប៉ុន្តែជាកិច្ចការចាំបាច់ ។ ចច អេ ស្ម៊ីធ បានពិពណ៌នានៅក្នុងទិនានុប្បវត្តិរបស់លោក អំពីប្រតិកម្មរបស់ព្យាការីទៅនឹងឧបសគ្គប្រចាំថ្ងៃ ក្នុងការធ្វើធ្វើដំណើរទៅកាន់រដ្ឋមិសស៊ូរី ។

« ព្យាការី យ៉ូសែប ស្ម៊ីធ មានការនឿយហត់ដូចជាបុរសដទៃទៀតក្នុងអំឡុងពេលនៃការធ្វើដំណើរនោះ ។ ក្រៅពីការមើលថែក្នុងការផ្គត់ផ្គង់ និងការគ្រប់គ្រងកងទ័ពនោះភាគច្រើនលោកបានដើរ ហើយមានដំបៅពងបែក ហូរឈាម និងការឈឺចាប់នៅជើង ។ . . . ប៉ុន្តែអំឡុងពេលនៃការធ្វើដំណើរនោះទាំងមូល លោកពុំរអ៊ូរទាំ ឬត្អូញត្អែរទាល់តែសោះ ខណៈដែលមនុស្សស្ទើរតែទាំងអស់ក្នុងកងទ័ពនោះ បានត្អូញត្អែរដាក់គាត់អំពីការឈឺមេជើង ពងបែកនៅជើង ធ្វើដំណើរផ្លូវឆ្ងាយ ស្បៀងអាហារមានតិចតួច អាហារគ្មានឱជារស នំពោតមិនល្អ បើរដែលកខ្វក់ ទឹកឃ្មុំខាប់ សាច់ប៊ែកខន់ និងឈីសមានដង្កូវ ជាដើម សូម្បីតែសត្វឆ្កែក៏រអ៊ូរទាំដាក់ យ៉ូសែប ដែរ ។ ប្រសិនបើពួកគេត្រូវធ្វើដំណើរដោយមានទឹកមិនស្អាត នោះវាបណ្ដាលឲ្យមានការបះបោរ ប៉ុន្តែយើងគឺជាកងទ័ពជំរំស៊ីយ៉ូន ហើយពួកយើងជាច្រើននាក់គ្មានការអធិស្ឋាន គ្មានការគិតពិចារណា មិនយកចិត្តទុកដាក់ ពុំស្ដាប់តាមឆ្គួតលីលា ឬកាចសាហាវ ហើយពួកយើងពុំបានដឹងពីវាឡើយ ។ យ៉ូសែប ត្រូវតែស៊ូទ្រាំជាមួយពួកយើង ហើយបង្រៀនពួកយើង ដូចជាកូនក្មេង » ។[១២]

យ៉ូសែបគឺជាគំរូដ៏រឹងមាំមួយអំពីគោលការណ៍ដែលបានបង្រៀនដោយ អាលម៉ា ថា ៖ « ដ្បិតអ្នកផ្សាយសាសនាមិនប្រសើរជាងអ្នកស្ដាប់ទេ ឯគ្រូបង្រៀនក៏មិនប្រសើរជាងអ្នករៀនដែរ . . . ហើយពួកគេបានធ្វើការទាំងអស់គ្នា បុគ្គលគ្រប់រូបតាមកម្លាំងរៀងៗខ្លួន » ( អាលម៉ា ១:២៦ ) ។

ចាប់តាំងពីការហៅបម្រើរបស់ខ្ញុំជាពួកអ្នកមានសិទ្ធិអំណាចទូទៅ ខ្ញុំបានព្យាយាមគោរពប្រតិបត្តិតាម ហើយរៀនដើម្បីក្លាយដូចជាពួកបងប្អូនប្រុសមួយចំនួនរបស់ខ្ញុំ ដែលបានប្រឈមមុខនឹងឥទ្ធិពលនៃភាពចាស់ជរា ឬតម្រូវការឥតឈប់ឈរនៃភាពខ្វះខាតខាងរូបកាយ និងការឈឺចាប់ជាប់ជានិច្ច ។ អ្នកពុំអាច ហើយអ្នកនឹងពុំស្គាល់ពីការរងទុក្ខផ្ទាល់ខ្លួន និងស្នាត់ស្ងៀមរបស់បុរសមួយចំនួននោះបានហែលឆ្លងកាត់ឡើយ នៅពេលពួកគេបម្រើសាធារណជនដោយអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់ពួកគេ ។ ដោយបានបម្រើ និងមើលឃើញប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ១៩១០–២០០៨ ) ប្រធាន ជេមស៍ អ៊ី ហ្វោស្ដ ( ១៩២០–២០០៧ ) អែលឌើរ យ៉ូសែប ប៊ី វ៉ឺតលីន ( ១៩១៧–២០០៨ ) ប្រធាន ប៊យដ៍ ឃេ ផាកកឺ ( ១៩២៤–២០១៥ ) អែលឌើរ អិល ថម ភែរី ( ១៩២២–២០១៥ ) អែលឌើរ រីឆាដ ជី ស្កត ( ១៩២៨–២០១៥ ) និងសមាជិកក្រុមផ្សេងទៀតនៃពួកសាវក ផ្ដល់អំណាចដល់ខ្ញុំឲ្យប្រកាសយ៉ាងច្បាស់ និងអង់អាចថា ពួកបងប្អូនប្រុសដែលខ្ញុំបម្រើជាមួយគឺជាកងទ័ព — ជាកងទ័ពខាងវិញ្ញាណដែលមានត្រកូលខ្ពស់ និងអស្ចារ្យ — នៅក្នុងពាក្យសម្ដីដ៏ទុកចិត្ត និងកោតសរសើរខ្លាំងបំផុត ! ការអត់ធ្មត់ ការតស៊ូ និងភាពក្លាហានរបស់ពួកលោកធ្វើឲ្យពួកលោក « ឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ » ( នីហ្វៃទី ២ ៣១:២០ ) ដែលវាសមនឹងឲ្យយើងយកធ្វើជាគំរូ ។

ប្រធាន លី បានព្រមានអំពីការសាកល្បងទូទៅមួយបន្ថែមទៀត ដែលកំពុងកើនឡើងកាន់តែខ្លាំងទូទាំងសកលលោកនៅក្នុងជំនាន់នេះ ៖ « ឥឡូវនេះយើងកំពុងឆ្លងកាត់នូវការសាកល្បងមួយទៀត — ជារយៈពេលមួយដែលយើងអាចហៅបានថាជាការបំភាន់ ។ នេះគឺជាគ្រាដែលមានមនុស្សឆ្លាតជាច្រើន ដែលគ្មានឆន្ទៈស្ដាប់ព្យាការីដ៏រាបសារបស់ព្រះអម្ចាស់ ។ . . . វាពិតជាការសាកល្បងមួយដែលកាន់តែខ្លាំងឡើង » ។[១៣]

ការសាកល្បងនៃការបំភាន់នេះគឺជាដៃគូនឹងការសាកល្បងនៃភាពចម្រុងចម្រើន និងភាពងាយស្រួល ។ ឱ វាសំខាន់អ្វីម្ល៉េះដល់ពួកយើងម្នាក់ៗ ដើម្បីគោរពប្រតិបត្តិ រៀនសូត្រ និងធ្វើតាមពួកបងប្អូនប្រុស ។

« តើនរណានៅខាងព្រះអម្ចាស់ ? » ឥឡូវនេះគឺជាពេលដែលត្រូវបង្ហាញតាមរយៈការស្ដាប់ និងស្ដាប់ដោយយកចិត្តទុកដាក់ លើដំបូន្មានរបស់ពួកសាវក និងព្យាការីដែលកំពុងរស់នៅ ដែលព្រះបានហៅនៅក្នុងជំនាន់ចុងក្រោយនេះ ដើម្បីមើលថែ និងដឹកនាំកិច្ចការរបស់ទ្រង់នៅលើផែនដីនេះ ។ ឥឡូវនេះគឺជាពេលដែលត្រូវបង្ហាញ ថាយើងជឿថា « ពាក្យរបស់ព្រះនឹងមិនកន្លងបាត់ទៅឡើយ ប៉ុន្តែពាក្យទាំងអស់នឹងបានសម្រេច ទោះជាដោយសំឡេង [ របស់ទ្រង់ ] ផ្ទាល់ ឬក៏ដោយសំឡេងនៃពួកអ្នកបម្រើ [ របស់ទ្រង់ ] ក្ដី គឺដូចតែគ្នា » ( គ. និង ស. ១:៣៨ ) ។ ឥឡូវនេះគឺជាពេលដែលត្រូវបង្ហាញហើយ ។ គឺពេលនេះហើយ !



ចំរូប © DESERET NEWS

## កងទ័ពជំរំស៊ីយ៉ូនផ្ទាល់ខ្លួនរបស់យើង

នៅគ្រាមួយក្នុងជីវិតយើងម្នាក់ៗ យើងនឹងត្រូវបានអញ្ជើញឲ្យធ្វើដំណើរនៅក្នុងកងទ័ពជំរំស៊ីយ៉ូនផ្ទាល់ខ្លួនរបស់យើង ។ ពេលវេលានៃការអញ្ជើញនោះនឹងមានលក្ខណៈខុសៗពីគ្នា ហើយឧបសគ្គនានាដែលយើងអាចជួបប្រទះនៅលើដំណើរនោះក៏ផ្សេងៗពីគ្នាដែរ ។ ប៉ុន្តែការឆ្លើយតបជាបន្តបន្ទាប់ និងជាប់លាប់របស់យើងចំពោះការហៅដ៏ប្រាកដប្រជានេះ ទីបំផុតនឹងផ្ដល់ចម្លើយចំពោះសំណួរដែលថា « តើនរណានៅខាងព្រះអម្ចាស់ ? »

ពេលវេលាដែលត្រូវបង្ហាញគឺនៅពេលនេះ ថ្ងៃនេះ ថ្ងៃស្អែក និងជារៀងរហូតទៅ ។ សូមឲ្យយើងចងចាំពីមេរៀននានាដែលទាក់ទងនឹងការសាកល្បង ការរែងរកមើល និងការរៀបចំខ្លួន ព្រមទាំងការគោរពប្រតិបត្តិ ការរៀនសូត្រ និងការធ្វើតាមពួកបងប្អូនប្រុស ។ ■

*ដកស្រង់ចេញពីសុន្ទរកថាក្នុងការប្រជុំធម្មនិដ្ឋាននៃសប្ដាហ៍ស្ដីពីការអប់រំ ដែលមានចំណងជើងថា « Who's on the Lord's Side ? Now Is the Time to Show » ( « តើនរណានៅខាងព្រះអម្ចាស់ ? ឥឡូវនេះគឺពេលដែលត្រូវបង្ហាញហើយ » ) បានថ្លែងនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់-អៃដាហូ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១០ ។*

**កំណត់ចំណាំ**

១. ព្រិកហាំ យ៉ង់ នៅក្នុង B. H. Roberts *A Comprehensive History of the Church* ១:៣៧០–៧១ ។
២. « Who's on the Lord's Side? » *ទំនុកតម្កើង* លេខ ២៦០ ។
៣. *The Discourses of Wilford Woodruff* ed. G. Homer Durham ( ឆ្នាំ ១៩៤៦ ) ទំព័រ ៣០៦ ។
៤. « Who's on the Lord's Side? » *ទំនុកតម្កើង* លេខ ២៦០ ។
៥. យ៉ូសែប ស្ម៊ីធ នៅក្នុង Joseph Young Sr. *History of the Organization of the Seventies* ( ឆ្នាំ ១៨៧៨ ) ទំព័រ ១៤ សូមមើលផងដែរ *History of the Church* ២:១៨២ ។
៦. សូមមើល Alexander L. Baugh « From High Hopes to Despair: The Missouri Period 1831–39 » *Ensign,* ខែ កក្កដា ឆ្នាំ ២០០១ ទំព័រ ៤៤ ។
៧. អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន « Our Obligation and Challenge » សិក្ខាសាលាអ្នកតំណាងភូមិភាគ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៧ ទំព័រ ២–៣ ឯកសារពុំបានបោះពុម្ព ។
៨. ហារ៉ូល ប៊ី លី « Christmas address to Church employees » ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៧៣ ទំព័រ ៤–៥ ឯកសារពុំបានបោះពុម្ព ។
៩. វិលហ្វូឌ វូឌរ្រុព្វ នៅក្នុង Matthias F. Cowley *Wilford Woodruff: History of His Life and Labors* ( ឆ្នាំ ១៩០៩ ) ទំព័រ ៣៩ ។
១០. វិលហ្វូឌ វូឌរ្រុព្វ នៅក្នុង *The Discourses of Wilford Woodruff* ទំព័រ ៣០៥ ។
១១. យ៉ូសែប ស្ម៊ីធ នៅក្នុង *Teachings of Presidents of the Church: Wilford Woodruff* ( ឆ្នាំ ២០០៤ ) ទំព័រ ២៥–២៦ សូមមើលផងដែរ យ៉ូសែប ស្ម៊ីធ ដែលបានដកស្រង់ដោយ វិលហ្វូឌ វូឌរ្រុព្វ នៅក្នុង Conference Report ខែ មេសា ឆ្នាំ ១៨៩៨ ទំព័រ ៥៧ ។
១២. ចច អេ ស្ម៊ីធ « My Journal » *Instructor* ខែ ឧសភា ឆ្នាំ ១៩៤៦ ទំព័រ ២១៧ ។
១៣. ហារ៉ូល ប៊ី លី « Sweet Are the Uses of Adversity » *Instructor* ខែ មិថុនា ឆ្នាំ ១៩៦៥ ទំព័រ ២១៧ ។

# ការរៀនស្ដាប់ ៖ សាខាដែលមានពូជសាសន៍ចម្រុះដំបូងគេនៅអាហ្វ្រិកខាងត្បូង

**ដោយ ម៉ាត ម៉ាកប្រ៊ីដ និង ជេមស៍ ហ្គោលបើក**
ការិយាល័យប្រវត្តិសាស្ត្ររបស់សាសនាចក្រ

ហ្វ្រង់ លេកខ្វាទី អាយុ ៥៦ ឆ្នាំបានយំ នៅពេលគាត់អង្គុយនៅទល់មុខ អូលៀរ តាំ ដែលជាប្រធានស្តេករបស់គាត់ ។ ប្រធាន តាំ ទើបតែបានសួរយោបល់គាត់អំពីការបង្កើតសាខាមួយរបស់សាសនាចក្រនៅក្នុងស្រុកកំណើតរបស់ ហ្វ្រង់ នៅទីក្រុង សូវ៉េតូ អាហ្វ្រិកខាងត្បូង ។

ប្រធានតាំ បានសួរថា « ហេតុអ្វីបានជាលោកយំ ? តើខ្ញុំបានធ្វើអ្វីឲ្យលោកអាក់អន់ស្រពន់ចិត្តឬ ? »

ហ្វ្រង់ បានតបថា « មិនមែនទេ ។ នេះគឺជាលើកដំបូងហើយនៅអាហ្វ្រិកខាងត្បូង ដែលជនជាតិស្បែក-ស បានសួរយោបល់ពីខ្ញុំមុននឹងធ្វើការសម្រេចចិត្ត » ។




*ខាងលើ ៖ ឆ្នេរសមុទ្រដែលត្រូវបានកំណត់ថាជាតំបន់សម្រាប់តែពួកស្បែក-សប៉ុណ្ណោះ ក្រោមច្បាប់ដ៏តឹងរឹងនៃការបំបែកពូជសាសន៍នៅអាហ្វ្រិកខាងត្បូង ។*
*ខាងស្ដាំ ៖ ក្រុមប្រឆាំងតវ៉ាឆ្នាំ ១៩៥២ នៅក្នុង យ៉ូហាណែស្បើក ស្រែកអំពាវនាវទាមទារសិទ្ធិសេរីភាព និងសមភាព ។*

## ការរស់នៅក្រោមច្បាប់នៃការបំបែកពូជសាសន៍

វាគឺនៅក្នុងឆ្នាំ ១៩៨១ ។ ជាគ្រាដែលប្រជាជនស្បែកខ្មៅ និងស្បែក-ស នៅអាហ្វ្រិកខាងត្បូងត្រូវបានបំបែកចេញ ឲ្យរស់នៅក្រោមប្រព័ន្ធច្បាប់ដែលយើងស្គាល់ថាជាច្បាប់បំបែកពូជសាសន៍ ។ ការបំបែកពូជសាសន៍ស្របច្បាប់នេះ រួមទាំងការរាំងរាំងជាកំហិតរបស់សាសនាចក្រក្នុងការតែងតាំងបព្វជិតភាពដល់បុរសអាហ្វ្រិក





*ប្រធានសមាគមសង្គ្រោះជនជាតិស្បែកខ្មៅដំបូងគេនៅអាហ្វ្រិកខាងត្បូង ជូលី ម៉ាវីមបេឡា ចូលរួមនៅក្នុងពិធីសម្ពោធការសាងសង់អគារសាខាសូវ៉េតូថ្មី នៅក្នុងឆ្នាំ ១៩៩១ ។ ( សូមអានរឿងរបស់គាត់នៅអត្ថបទបន្ទាប់ ) ។*

រូបថតទទួលបានសិទ្ធិអនុញ្ញាតពី ជូលី ម៉ាវីមបេឡា

ស្បែកខ្មៅ នោះមានន័យថា សាសនាចក្រពុំអាចរីកសុះសាយនៅក្នុងចំណោមប្រជាជនអាហ្វ្រិកស្បែកខ្មៅភាគខាងត្បូងឡើយ ។ ស្ថានភាពនោះបានផ្លាស់ប្ដូរនៅក្នុងឆ្នាំ ១៩៧៨ ពេលប្រធាន ស្ពែនស៊ើរ ដបុលយូ឵ ឃឹមបឹល បានទទួលវិវរណៈដែលបានលើកកម្ពស់ដល់ការដាក់កំហិតនៃបព្វជិតភាពនោះ ប៉ុន្តែឧបសគ្គនៃការបំបែកពូជសាសន៍ និងវប្បធម៌ប្រកាន់ពូជសាសន៍នោះនៅបន្តមាន ។

ប្រជាជនស្បែកខ្មៅនៅអាហ្វ្រិកខាងត្បូងភាគច្រើនបំផុត រស់នៅក្នុងទីប្រជុំជនតូចៗ ដែលជាទូទៅមានទីតាំងនៅព្រំប្រទល់នៃទីក្រុងធំៗរបស់ពួកស្បែក-សដូចជាទីក្រុង យ៉ូហាណែស្ប៊ើក ។ ទីក្រុង សូវ៉េតូ មានឈ្មោះពេញថា សោវ៉េស្ទើរ ថោនស៊ីប គឺជាទីក្រុងដ៏ធំបំផុត ។ ពួកស្បែក-សកម្រទៅទីប្រជុំជនទាំងនោះណាស់ ហើយគេចាត់ទុកពួកស្បែកខ្មៅដែលទៅទីក្រុងទាំងនោះ មិនស្មើនឹងពួកស្បែក-សឡើយ ។

ហ្វ្រង់ និងគ្រួសារគាត់គឺជាអ្នកដែលមកពីក្រុមតូចមួយនៅទីក្រុង សូវ៉េតូ បានទទួលយកដំណឹងល្អដែលបានស្ដារឡើងវិញដោយរីករាយ នៅអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ ។ ដំបូងឡើយ ពួកគេចូលរួមនៅក្នុងវួដ យ៉ូហាណែស្ប៊ើក ។ យ៉ូណាសកូនប្រុសរបស់ ហ្វ្រង់ បានចាំពីការក្រោកនៅម៉ោង ៤ ព្រឹកថ្ងៃអាទិត្យ ដើម្បីឲ្យគ្រួសារពួកគេអាចទៅទាន់រថភ្លើងពេលព្រឹក ដែលចេញដំណើរទៅទីក្រុង យ៉ូហាណែស្ប៊ើក បន្ទាប់មកដើរយ៉ាងយូរទៅកាន់សាលាជំនុំពីមុនការប្រជុំចាប់ផ្ដើមនៅម៉ោង ៩ ព្រឹក ។ ក្រុមគ្រួសារនេះតែងតែក្រោកពីព្រលឹមជានិច្ច — ទោះបីជាពេលខ្លះ ក្មេងៗមានការលំបាកក្នុងការទ្រាំកុំឲ្យងងុយគេងនៅក្នុងថ្នាក់បឋមសិក្សាក្ដី !

*« យើងប្រហែលជាខ្វែងគំនិតគ្នាលើរឿងដែលកើតមានឡើងនៅខាងក្រៅសាសនាចក្រ ប៉ុន្តែយើងមូលមតិគ្នាលើគោលលទ្ធិ » ។*

ការធ្វើជាអ្នកត្រួសត្រាយនៃការបង្រួបបង្រួមភាពចម្រុះពូជសាសន៍ ក៏អាចជាឧបសគ្គខាងផ្លូវចិត្តមួយផងដែរ ។ យ៉ូសាយ ម៉ូហាពី បានចាំពីការស្ដាប់ឮដោយចៃដន្យពីក្មេងប្រុសជនជាតិស្បែក-សអាយុប្រាំមួយឆ្នាំម្នាក់ ដែលគាត់បានជួបនៅព្រះវិហារដោយបាននិយាយពាក្យសម្ដីមិនល្អដល់ពួកស្បែកខ្មៅ ។ យ៉ូសាយ បានថ្លែងថា « និយាយតាមត្រង់ ខ្ញុំខឹងដល់កតែម្ដង » ។ ប៉ុន្តែក្រោយមក គាត់បានឮម្ដាយរបស់ក្មេងប្រុសនោះប្រាប់កូនប្រុសគាត់ថា « ព្រះវិហារគឺសម្រាប់មនុស្សគ្រប់គ្នា » ។ ដោយឮពាក្យសម្ដីលួងលោមនោះ យ៉ូសាយបានស្ងប់អារម្មណ៍វិញ ។

**តើបង្កើតសាខាមួយនៅ សូវ៉េតូ ឬ ?**

ប្រធាន តាំ បានដឹងអំពីឧបសគ្គខាងផ្លូវកាយ និងផ្លូវចិត្តដែលសមាជិកស្បែកខ្មៅបានជួបប្រទះ ។ គាត់បានពិចារណាអំពីការចាប់ផ្ដើមសាខាមួយនៅក្នុងទីក្រុង សូវ៉េតូ ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ពួកគេ ប៉ុន្តែពុំចង់ធ្វើឲ្យពួកគេមានអារម្មណ៍ថា ពួកគេមិនត្រូវបានស្វាគមន៍ឲ្យទៅវួដនៅយ៉ូហាណែស្ប៊ើក ឡើយ ។ គាត់សម្រេចចិត្តសម្ភាសសមាជិកនៅទីក្រុង សូវ៉េតូ ដូចជា ហ្វ្រង់ ដើម្បីស្ទង់មើលពីអារម្មណ៍របស់ពួកគេពីមុនធ្វើការសម្រេចចិត្ត ។ ពួកគេបានផ្ដល់ចម្លើយយ៉ាងច្បាស់លាស់ដល់គាត់ថា ៖ « យើងចង់បង្កើតសាសនាចក្រនៅទីក្រុង សូវ៉េតូ » ។

ប្រធាន តាំ បានរកមើលអ្នកដឹកនាំដែលមានបទពិសោធន៍ ជាអ្នកដែលអាចជួយផ្ដល់ដំបូន្មានដល់អ្នកប្រែចិត្តជឿថ្មីៗ ។ គាត់បានសម្ភាសសមាជិកនៅក្នុងទីក្រុងយ៉ូហាណែស្ប៊ើក ជាង ២០០ នាក់ ហើយទីបំផុតសមាជិក ៤០ នាក់ត្រូវបានហៅឲ្យចូលរួមនៅក្នុងសាខាថ្មីនោះយូរល្មម ដើម្បីជួយបង្រៀនក្រុមអ្នកត្រួសត្រាយនៃអ្នកដឹកនាំក្នុងមូលដ្ឋាននោះ ។

ខាងក្រោមខាងឆ្វេង ៖ រូបថតដោយក្ដី KEYSTONE/GETTY IMAGES
ខាងក្រោមខាងស្ដាំ ៖ រូបថតដោយក្ដី POPPERFOTO/GETTY IMAGES

ដោយសារសមាជិកស្បែកខ្មៅ បានចូលទៅទីក្រុង និងវប្បធម៌មួយផ្សេងទៀត ដើម្បីចូលរួមនៅវួដ យ៉ូហាណែស្បើក នោះសមាជិកស្បែក-ស បានសម្របសម្រួលខ្លួនឲ្យត្រូវនឹងបរិយាកាស និងវប្បធម៌ថ្មីនៅពេលពួកគេបម្រើនៅទីក្រុង សូវ៉េតូ ។ រឿងគ្រប់យ៉ាងមិនដំណើរការដោយរលូននោះឡើយ ។ ម៉ូរីន វ៉ាន ស្ស៊ីល សមាជិកស្បែក-សម្នាក់ដែលត្រូវបានហៅបម្រើជាប្រធានថ្នាក់អង្គការបឋមសិក្សា ពុំបានគិតអ្វីអំពីរឿងនោះឡើយ នៅពេលពួកគេបានជ្រើសរើសយកចម្រៀងគោរពទង់ជាតិរបស់ប្រជាជនអាហ្វ្រិកខាងត្បូងនាគ្រានោះដើម្បីច្រៀងបើកនៅក្នុងការប្រជុំថ្នាក់សមាគមសង្គ្រោះនាថ្ងៃអាទិត្យមួយ ។ ប៉ុន្តែក្រោយមក គាត់បានដឹងថា ពួកអាហ្វ្រិកស្បែកខ្មៅភាគខាងត្បូងនោះគិតថាចម្រៀងគោរពទង់ជាតិនោះ គឺជានិមិត្តសញ្ញានៃការបំបែកពូជសាសន៍ ហើយគាត់បានដឹងថា បងប្អូនស្រីស្បែកខ្មៅទាំងនោះបានអន់ចិត្ត ចំពោះការរើសយកបទចម្រៀងនោះ ។

*« យើងអាចប្ដូរគំនិតតាមរយៈបទពិសោធន៍តែប៉ុណ្ណោះ ។ យើងគ្រប់គ្នាត្រូវការបទពិសោធន៍ដែលបានឆ្លងកាត់ទាំងនេះ ដើម្បីនាំឲ្យយើងផ្លាស់ប្ដូរ ។*

សមាជិកទាំងស្បែកខ្មៅ ទាំងស្បែក-ស អាចងាយនឹងបាក់ទឹកចិត្ត ដោយសារការយល់ខុសបែបនោះ ប៉ុន្តែពួកគេបានរើសយកការយល់ខុសទាំងនោះធ្វើជាឱកាសមួយសម្រាប់ការពិភាក្សា និងកែលម្អវាឲ្យបានល្អប្រសើរទៅវិញ ។ ម៉ូរីន បាននិយាយថា « យើងបានចែកចាយនូវរឿងគ្រប់យ៉ាងទាំងអស់ ។ សម្រាប់ពួកស្បែកខ្មៅ ចែកចាយពីអ្វីដែលធ្វើឲ្យពួកគេអាក់អន់ចិត្ត ហើយសម្រាប់ពួកស្បែក-សវិញចែកចាយពីអ្វីដែលពួកគេរកឃើញថាជាការអាក់អន់ចិត្ត ។ របៀបដែលពួកគេធ្វើកិច្ចការ និងរបៀបដែលយើងធ្វើកិច្ចការជាក់លាក់នានា ។ ដូច្នេះនេះវាគឺជាពេលវេលាដ៏អស្ចារ្យដើម្បីរៀនជាមួយគ្នា » ។

នៅពេលសាខានៅទីក្រុង សូវ៉េតូ បានរីកចម្រើន ហើយមានសមាជិកកាន់តែច្រើនឡើង នោះមានសាខាផ្សេងៗបានចាប់ផ្ដើមនៅក្នុងទីប្រជុំជនផ្សេងទៀត ដោយប្រើគំរូដូចគ្នានោះ ។ ឃុមប៉ូឡានី ម៉ាតឡែតស៊ី គឺជាយុវជនម្នាក់រស់នៅទីប្រជុំជន ខ្វាម៉ាស្ស៊ូ ក្បែរទីក្រុង ឌូបាន ។ នៅពេលគាត់ចូលរួមសាសនាចក្រនៅក្នុងឆ្នាំ ១៩៨០ គាត់បាននាំយកគំនិតទូទៅរបស់ពួកស្បែក-សមកកាន់បុរសស្បែកខ្មៅស្ទើរតែគ្រប់រូបនៅអាហ្វ្រិកខាងត្បូងនាគ្រានោះ ។ ប៉ុន្តែបទពិសោធន៍នៃការថ្វាយបង្គំរបស់គាត់នៅក្នុងសាខាដែលមានពូជសាសន៍ចម្រុះនោះ បានផ្លាស់ប្ដូរទស្សនវិស័យរបស់គាត់ ។

**ជំរការដែលបិទភ្ជាប់មនុស្សឲ្យរួមគ្នា**

នៅក្នុងឆ្នាំ ១៩៨២ ឃុមប៉ូឡានី និងយុវជនមួយចំនួនទៀតនៅក្នុងសាខារបស់គាត់ ត្រូវបានអញ្ជើញឲ្យចូលរួមសន្និសីទយុវមជ្ឈិមវ័យនៅលីវ ។ ប្រធានសាខារបស់គាត់ គឺជាជនជាតិស្បែក-ស ឈ្មោះ ចន មែនហ្វត ចង់ឲ្យពួកយុវជនស្លៀកពាក់ស្អាតបាត ប៉ុន្តែអ្នកដែលមានសម្លៀកបំពាក់ស្អាតមានតិចតួចណាស់ ។ គាត់បានយកសម្លៀកបំពាក់ពីទូរបស់គាត់ ហើយចែកខោអាវធំទាំងនោះឲ្យពួកយុវជន ហើយពួកគេបានពាក់វាទៅសន្និសីទ ។ នៅថ្ងៃអាទិត្យបន្ទាប់នោះប្រធានមែនហ្វត បានពាក់ខោអាវធំដែលគាត់បានឲ្យ ឃុមប៉ូឡានី ខ្ចី ។ ឃុមប៉ូឡានីបានថ្លែងថា « ខ្ញុំពុំជឿសោះថា មានមនុស្សស្បែក-ស បានពាក់សម្លៀកបំពាក់ដែលខ្ញុំបានពាក់ហើយសោះប៉ុន្តែគាត់បានពាក់វា ។ គាត់បានចាប់ផ្ដើមជួយខ្ញុំឲ្យយល់



*ទង់ជាតិរបស់អាហ្វ្រិកខាងត្បូងដែលត្រូវបានជ្រើសយកទុកជារបស់ខ្លួនក្នុងឆ្នាំ ១៩៩៤ ទុកជានិមិត្តសញ្ញាសាមគ្គីភាពក្រោយពីច្បាប់ការបំបែកពូជសាសន៍បានបញ្ចប់ ។ ពណ៌ខ្មៅ លឿង និងបៃតងតំណាងឲ្យសមាជជាតិអាហ្វ្រិក ហើយពណ៌ក្រហម ស និងខៀវតំណាងឲ្យ សាធារណរដ្ឋ ប៊ូអើរ ។*




រូបថតព្រះវិហារបរិសុទ្ធ យ៉ូហានណេសប៊ើក អាហ្វ្រិកខាងត្បូង

ឃើញថា មនុស្សស្បែក-ស គឺខុសប្លែកជាងកាលពីមុនដែលខ្ញុំធ្លាប់ជួប » ។

ឥឡូវនេះអែលឌើរ ម៉ាតឡែតសុី ជាពួកចិតសិបនាក់ដែលមានសិទ្ធិអំណាចប្រចាំតំបន់ បានថ្លែងថា « យើងគ្រប់គ្នាត្រូវការបទពិសោធន៍ដែលបានឆ្លងកាត់ទាំងនេះដើម្បីនាំឲ្យយើងផ្លាស់ប្ដូរ » ។

ច្បាប់នៃការបំបែកពូជសាសន៍នៅក្នុងអាហ្វ្រិកខាងត្បូងបានបញ្ចប់ក្នុងឆ្នាំ ១៩៩៤ ។ ខណៈដែលក្រុមជំនុំជាច្រើននាពេលបច្ចុប្បន្ននេះភាគច្រើនមាននៅក្នុងតំបន់ពួកស្បែកខ្មៅ ឬ ពួកស្បែក-ស នោះមានន័យថា សេរីភាពកាន់តែធំធេងបានកើនឡើងនៅក្នុងតំបន់ដែលរួមបញ្ចូលគ្នានោះ ។ ដូចជាអ្នកត្រួសត្រាយនៃសាខាដំបូងៗនៅក្នុងទីប្រជុំជននោះដែរ សមាជិកដែលមានជីវប្រវត្តិផ្សេងៗគ្នា អាចថ្វាយបង្គំ និងធ្វើការរួមគ្នាដើម្បីស្ថាបនានគរព្រះ ។

ថាបូ លេបេថោ ប្រធានស្តេកបច្ចុប្បន្ននៅ សូវ៉េតូ ពិពណ៌នាថា ដំណឹងល្អគឺដូចជាជ័រកាវដែលបិទភ្ជាប់មនុស្សឲ្យរួមគ្នានៅក្នុងគ្រានៃការបំបែកពូជសាសន៍នោះ ។ លោកបានថ្លែងថា « យើងប្រហែលជាខ្វែងគំនិតគ្នាលើរឿងដែលកើតមានឡើងនៅខាងក្រៅសាសនាចក្រ ដូចជារឿងនយោបាយ និងរឿងផ្សេងៗទៀត ប៉ុន្តែយើងបានមូលមតិគ្នាលើគោលលទ្ធិ » ។ ការធ្វើការដោយឈរលើគ្រឹះរួមគ្នានោះ មនុស្សអាចរៀនពីភាពខុសគ្នាទៅវិញទៅមក នៅពេលពួកគេប្រឹក្សាគ្នា ហើយស្ដាប់ដោយយកចិត្តទុកដាក់ខាងវិញ្ញាណ ។ ប្រធាន លេបេថោ ទូន្មានថា « រឿងដ៏សំខាន់បំផុតមួយអំពីភាពជាអ្នកដឹកនាំនោះគឺស្ដាប់មនុស្ស ។ ស្ដាប់ដើម្បីឲ្យអ្នកអាចយល់ ។ ស្ដាប់ដើម្បីឲ្យអ្នកអាចដឹង ។ ស្ដាប់ដើម្បីឲ្យអ្នកអាចទទួលការបំផុសគំនិត » ។

ថូបា ខាល ហាឡា កូនស្រីរបស់ ជូលៀ ម៉ារីមបេឡា ជាសមាជិកនៅសាខាសូវ៉េតូ ពីមុនយល់ស្របថា ការស្ដាប់គ្នាជួយទប់ស្កាត់ជម្លោះដែលចៀសមិនបាននោះកុំឲ្យវាប្រែទៅជាការបែកបាក់ដ៏គួរឲ្យឈឺចាប់ ។ គាត់និយាយថា « ខ្ញុំគួរតែស្ដាប់តាមរបៀបមួយដែលធ្វើឲ្យខ្ញុំយល់ពីការលំបាកអំពីមនុស្សណាម្នាក់ ដែលហាក់ដូចជាធ្វើខុសចំពោះខ្ញុំ » ។

អែលឌើរ ម៉ាតឡែតសុី ជំរុញពួកបរិសុទ្ធអាហ្វ្រិកខាងត្បូងនាបច្ចុប្បន្ននេះឲ្យស្វែងរកភាពរឹងមាំនៅក្នុងភាពទីទៃពីគ្នារបស់ពួកគេ ជាពិសេសនៅក្នុងការប្រជុំក្រុមប្រឹក្សា ។ គាត់បានថ្លែងថា « ព្រះអម្ចាស់សព្វព្រះទ័យ ឲ្យមនុស្សដែលមានលក្ខណៈផ្សេងៗពីគ្នាទាំងនោះ អង្គុយចុះនៅឯតុ ហើយពិភាក្សាគ្នាអំពីបញ្ហានានា » ។ ការអំពាវនាវរបស់គាត់ចំពោះថ្នាក់ដឹកនាំក្នុងមូលដ្ឋានទូទាំងសាសនាចក្រគឺបន្ដលើកស្ទួយដល់ថ្នាក់ដឹកនាំដែលមានជីវប្រវត្តិផ្សេងៗគ្នានោះ គឺដូចជាពួកជំនាន់មុនដែលគាំទ្រដល់គាត់ដែរ ។ នៅពេលព្យាយាមចាប់ផ្ដើមតំបន់ ឬក្រុមថ្មីនោះ គាត់ថ្លែងថា « អ្នកពុំអាចរកបានមនុស្សដែលមានបទពិសោធន៍ឡើយ ។ ប៉ុន្តែអ្នកស្ថាបនាបទពិសោធន៍នៅក្នុងសាសនាចក្រ ។ អ្នកស្ថាបនាបទពិសោធន៍ ដោយនាំមនុស្សម្នាមករួមគ្នា ហើយឲ្យពួកគេធ្វើការរួមគ្នា » ។ ■

*ការដកស្រង់មកពីកិច្ចសម្ភាសធ្វើឡើងដោយអ្នកនិពន្ធ នៅក្នុងឆ្នាំ ២០១៥ ។*

# ការផ្សះផ្សាប្រទេសដ៏ជាទីស្រឡាញ់ ៖ សេចក្តីជំនឿរបស់ ជូលៀ ម៉ាវីមបេឡា

ដោយ ម៉ាថាយ ខេ ហៀស
ការិយាល័យប្រវត្តិសាស្ត្ររបស់សាសនាចក្រ


ជូលៀ បានជួប ហើយរៀបអាពាហ៍ពិពាហ៍ជាមួយ ចន នៅក្នុងឆ្នាំ ១៩៤៦ ។

ជីវិតរបស់ ជូលៀ ម៉ាវីមបេឡា បានផ្លាស់ប្តូរមួយរំពេចនៅក្នុងឆ្នាំ ១៩៥៥ ពេលស្វាមីរបស់គាត់ ចន បានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ។ ភស្តុតាងនៅកន្លែងកើតហេតុ ចង្អុលបង្ហាញថាបុរសស្បែក-សម្នាក់ដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់នោះ បានបើកចូលមកក្នុងផ្លូវរបស់ចន ។ ប៉ុន្តែបុរសនោះពុំត្រូវបានសម្រេចថាមានទោសឡើយ ។ ផ្ទុយទៅវិញ មន្ត្រីប៉ូលីសស្បែក-សទាំងនោះនិយាយថា ពួកស្បែកខ្មៅជាអ្នកបើកឡានមិនល្អ ដូច្នេះ ចនត្រូវទទួលខុសត្រូវចំពោះគ្រោះថ្នាក់បុកគ្នានោះ ។[1]

ជូលៀ អាយុ ៣៧ ឆ្នាំ មានកូនបួននាក់ ហើយកំពុងតែពរពោះកូនមួយទៀត ។ គេថានាងជាអ្នកខុសដោយសារតែការប្រកាន់ពូជសាសន៍ ដោយសារតែប៉ូលីស និងប្រព័ន្ធតុលាការ ។ ប៉ុន្តែទីបំផុតគាត់បានរៀនថា មិនត្រូវបណ្តែតបណ្តោយខ្លួនទៅក្នុងភាពល្វីងជូរចត់ឡើយ ផ្ទុយទៅវិញ គាត់បានចំណាយពេលក្នុងជីវិតគាត់ ព្យាយាមឲ្យបានជាសះស្បើយ ហើយផ្សះផ្សាប្រទេសជាទីស្រឡាញ់របស់គាត់តាមរយៈការបម្រើដូចជាព្រះគ្រីស្ទ ។ ដោយសារតែសេចក្តីស្រឡាញ់របស់គាត់ចំពោះទឹកដី សេចក្តីជំនឿរបស់គាត់លើព្រះ និងភក្តីភាពរបស់គាត់ ដើម្បីរស់នៅតាមគោលការណ៍នៃសេចក្តីជំនឿរបស់គាត់ ទើបធ្វើឲ្យរឿងនេះអាចកើតឡើងបាន ។

ជូលៀ បានកើតនៅក្នុងឆ្នាំ ១៩១៧ ជាកូនពៅគេក្នុងចំណោមកូនទាំងប្រាំនាក់ ។ ឪពុកគាត់បានចែកឋានទៅកាល ជូលៀ អាយុប្រាំឆ្នាំ ។ ដោយបន្សល់ទុកឲ្យម្តាយរបស់គាត់ចិញ្ចឹមកូនៗដោយខ្លួនឯង ដោយធ្វើការជាអ្នកបោកខោអាវ និងអ្នកធ្វើការបម្រើតាមផ្ទះ ។

ម្តាយរបស់ ជូលៀ គឺជាស្ត្រីកាន់សាសនាដែលបានបង្រៀនព្រះគម្ពីរប៊ីបដល់កូនៗរបស់គាត់ ។ ជូលៀ បាននិយាយថា « ម្តាយរបស់ខ្ញុំបានបង្រៀនខ្ញុំឲ្យពុះពារតស៊ូចំពោះរឿងរ៉ាវល្វីងជូរចត់ដែលមានក្នុងជីវិត ហើយបានលើកទឹកចិត្តខ្ញុំកុំឲ្យក្រឡេកមើលអតីតកាលឡើយ ប៉ុន្តែត្រូវសម្លឹងឆ្ពោះទៅអនាគតវិញ » ។ ម្តាយរបស់ ជូលៀ ក៏បានយល់អំពីសារៈសំខាន់នៃការអប់រំផងដែរ ហើយគាត់បានខំខ្នះខ្នែងអស់ពីសមត្ថភាពរបស់គាត់ ដើម្បីឃើញថាកូនៗរបស់គាត់ទទួលបានការអប់រំជាផ្លូវការ ។

ជូលៀ បានទទួលការបំពាក់បំប៉ន និងការអប់រំកាន់តែច្រើនឡើង ហើយបានធ្វើជាគ្រូបង្រៀន និងនាយកសាលា រហូតដល់គាត់បានជួប និងរៀបការជាមួយ ចន ម៉ាវីមបេឡា ក្នុងឆ្នាំ ១៩៤៦ ។ ចន មានហាងលក់គ្រឿងទេស និងលក់សាច់ ។ ជូលៀ បានបោះបង់ការងាររបស់គាត់ដើម្បីទៅធ្វើការនៅទីនោះ ។ ពួកគេបានសាងសង់ផ្ទះ ហើយមានកូនចៅ ។ ថ្វីបើមានភាពតឹងរឹងដោយសារតែការបំបែកពូជសាសន៍ក្តី ក៏ពួកគេមានជីវភាពល្អផងដែរ ។ ប៉ុន្តែអ្វីៗទាំងអស់បានផ្លាស់ប្តូរបន្ទាប់ពី ចន បានចែកឋានទៅ ។

នៅលើផ្នូររបស់ស្វាមីគាត់ ជូលៀ បានសរសេរពាក្យទាំងនេះ ៖

> *ក្នុងការចងចាំដល់សេចក្តីស្រឡាញ់របស់*
> *ចន ហ្វីលីព ខរលី ម៉ាវីមបេឡា ។*
> *តាមរយៈភរិយា និងសាច់ញាតិរបស់គាត់ ។*
> *ប៉ុន្តែភាពល្វីងជូរចត់នៅតែដក់ជាប់ក្នុងចិត្ត ។*
> *សូមឲ្យវិញ្ញាណក្ខន្ធបងបានទៅដល់សុខគតិភព ។*

ដោយពិពណ៌អំពីបន្ទាត់ទីបួននោះ ជូលៀ បាននិយាយថា « នៅពេលសរសេរពាក្យទាំងនេះ ភាពស្មុគស្មាញដែលនៅមាននោះគឺជាការស្អប់ខ្ពើម និងភាពល្វីងជូរចត់ — ចំពោះមនុស្សដែលបង្កអោយមានគ្រោះថ្នាក់ ចំពោះប៉ូលីសដែលកុហក [ និង ] ចំពោះតុលាការដែលបានជឿថាស្វាមីរបស់ខ្ញុំត្រូវទទួលខុសត្រូវចំពោះគ្រោះថ្នាក់ ដែលបានឆក់យកជីវិតគាត់នោះ » ។[2] ការសាកល្បងដ៏ធំធេងបំផុតរបស់គាត់នោះគឺត្រូវយកឈ្នះលើភាពល្វីងជូរចត់ និងកំហឹងនេះ ។

មិនយូរប៉ុន្មានបន្ទាប់ពីស្វាមីគាត់បានចែកឋានទៅ នាពេលយប់មួយដែល « ដេករសាប់រសល់ » នោះ ជូលៀបានសុបិនថា ចន បានបង្ហាញខ្លួនឲ្យគាត់ឃើញ ហើយបានហុចខោអៀមមួយចំនួនឲ្យគាត់ ហើយនិយាយថា « ចូរទៅធ្វើការចុះ » ។ ដោយរៀបរាប់ពីលទ្ធផលនៃសុបិននោះ គាត់បាននិយាយថា « ខ្ញុំបានរកឃើញរបៀបមួយដើម្បីដកខ្លួនខ្ញុំចេញពីកង្វល់នៃអំឡុងឆ្នាំទាំងនោះ ហើយថាខ្ញុំត្រូវចុះប្រឡូកក្នុងកិច្ចការសហគមន៍ » ។

ម្ភៃឆ្នាំក្រោយមក នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៧០ ប្រតិកម្មរបស់ពួកស្បែកខ្មៅទៅនឹងច្បាប់បំបែកពូជសាសន៍ បានប្រែពីការតវ៉ាដោយសន្តិភាពទៅជាការផ្ទុះនូវអំពើហិង្សា ។ កន្លែងមួយដែលអំពើហិង្សានោះកើតមានឡើងគឺនៅទីក្រុងសូវ៉េតូ ជាកន្លែងដែល ជូលៀ រស់នៅ ។ គាត់និយាយថា « សូវ៉េតូ បានក្លាយជាកន្លែងមួយដែលយើងមិនធ្លាប់ស្គាល់ឡើយ — វាបានក្លាយ ដូចជាសមរភូមិប្រយុទ្ធគ្នា » ។

ជូលៀ បារម្ភថា របួសនៃភាពល្វីងជូរចត់របស់គាត់នឹងរើរឡើងវិញ ៖ « វាមានរយៈពេលជាង ២០ ឆ្នាំ ហើយតាំងពី ចន ចែកឋានទៅ ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍ឈឺចាប់អំពីគ្រានោះដដែល » ។ នៅក្នុងកិច្ចខិតខំស្វែងរកការជាសះស្បើយ ទាំងសម្រាប់ខ្លួនគាត់



*ខាងក្រោម ៖ អំឡុងពេលនៃការបំបែកពូជសាសន៍ ជូលៀ បានចាប់ផ្ដើមសួនដំណាំសហគមន៍ដើម្បីបង្រៀនក្មេងៗថា « អ្វីៗគ្រប់យ៉ាងវាមិនបាត់បង់ឡើយ » ។*
*ខាងស្ដាំ ៖ ជូលៀ ស្លៀកសម្លៀកបំពាក់តាមប្រពៃណីស្វាស៊ីលូ ហើយបម្រើនៅក្នុងព្រះវិហារបរិសុទ្ធ យ៉ូហាណែស្បឺក អាហ្វ្រិកខាងត្បូង ។*





និងប្រជាជនរបស់គាត់ ជូលៀ បានគិតថា « ប្រហែលខ្ញុំអាចបង្រៀនក្មេងៗឲ្យស្រឡាញ់ការងារដាំដុះ នោះអ្វីៗទាំងអស់នឹងពុំបាត់បង់ឡើយ » ។ គាត់បានបង្កើតសួនដំណាំសហគមន៍មួយ ដែលជានិមិត្តរូបនៃសេចក្ដីសង្ឃឹមដល់មនុស្សដែលស្គាល់តែភាពភ័យខ្លាចនិងកំហឹង ។

នៅពេលគាត់ធ្វើការជាមួយក្មេងៗនៅក្នុងសួនដំណាំសហគមន៍របស់គាត់ គាត់បានបង្រៀនពួកគេថា ៖ « ចូរយើងជីកយកដីនៃភាពល្វីងជូរចត់ចេញ ហើយបោះគ្រាប់ពូជនៃសេចក្ដីស្រឡាញ់ ហើយមើលថាតើវានឹងផ្ដល់ផ្លែអ្វីដល់យើង ។ . . . សេចក្ដីស្រឡាញ់នឹងពុំអាចកើតមានឡើងដោយគ្មានការអភ័យទោសដល់អ្នកដទៃឡើយ ។

គាត់និយាយថា « ខ្ញុំដឹងដោយអស់ពីចិត្តខ្ញុំថា ខ្ញុំបានបំបែកដីនៃភាពល្វីងជូរចត់របស់ខ្ញុំ នៅពេលខ្ញុំបានអភ័យទោសដល់អ្នកដែលធ្វើឲ្យខ្ញុំឈឺចាប់ » ។ ភាពល្វីងជូរចត់ដែលនៅដក់ជាប់ក្នុងចិត្ត បន្ទាប់ពីមរណភាពរបស់ ចន នោះចាប់ផ្ដើមសាយបាត់ទៅ ។

នៅក្នុងឆ្នាំ ១៩៨១ ជូលៀ ត្រូវបានណែនាំឲ្យស្គាល់សាសនាចក្រ ។ អ្នកផ្សព្វផ្សាយសាសនាធ្វើការបម្រើនៅក្នុងសហគមន៍នៅក្នុងទីក្រុង សូវ៉េតូ បានឃើញថាមជ្ឈមណ្ឌលមួយរបស់ក្មេងប្រុសស្ថិតនៅក្នុងភាពទ្រុឌទ្រោម ដែលចាំបាច់ត្រូវតែជួសជុល ។ អស់ប្អូនប្រាំសប្ដាហ៍ពួកគេបានសម្អាតបរិវេណមជ្ឈមណ្ឌលនោះ ។[3]

ថ្ងៃមួយ ជូលៀ បានសុំទៅបម្រើនៅមជ្ឈមណ្ឌលក្មេងៗនោះដែរ ។ ពេលគាត់ទៅដល់ទីនោះ គាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយឃើញ « យុវជនស្បែក-សពីរនាក់កំពុងប្រើប៉ែលជីកដីក្រម៉ៅនោះ » ។ អ្នកផ្សព្វផ្សាយសាសនាបានសួរប្រសិនបើពួកគេអាចទៅផ្ទះរបស់គាត់ ហើយចែកចាយសារលិខិតដល់គាត់ ។ បីថ្ងៃក្រោយមក អែលឌើរ ដាវីឌ ម៉ាកខុមស៍ និង អែលឌើរ ជូអែល ហៀតុន បានទៅផ្ទះគាត់ ដោយស្លៀកពាក់ឯកសណ្ឋានអ្នកផ្សព្វផ្សាយសាសនា និងពាក់ស្លាកឈ្មោះ ។

ជូលៀ និយាយថា មេរៀនពីដំបូងរបស់អ្នកផ្សព្វផ្សាយសាសនា « បានចូលតាមត្រចៀកម្ខាង ហើយចេញតាមត្រចៀកម្ខាងទៀត » ។ ប៉ុន្តែនៅពេលជួបលើកទីបី អ្នកផ្សព្វផ្សាយសាសនាបានសួរអំពីរូបថតរបស់ ជូលៀ និង ចន ដែលព្យួរនៅលើជញ្ជាំង ។ គាត់បាននិយាយថា ស្វាមីរបស់គាត់បានចែកឋាន ហើយ អ្នកផ្សព្វផ្សាយសាសនាបានទទួលការបំផុសគំនិតឲ្យប្រាប់គាត់អំពីផែនការនៃសេចក្ដីសង្គ្រោះ និងបុណ្យជ្រមុជទឹកដល់មរណជន ។ គាត់បាននិយាយថា « ក្រោយមកខ្ញុំបានចាប់ផ្ដើមផ្ទៀងត្រចៀកស្ដាប់ គឺស្ដាប់ដោយស្មោះអស់ពីចិត្តរបស់ខ្ញុំ ។ . . . នៅពេលអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនខ្ញុំ អំពីគោលការណ៍នៃទំនាក់ទំនងអស់លក្សជានិច្ច នោះខ្ញុំបានមានអារម្មណ៍ថានេះគឺជារបៀបដើម្បីនៅជាមួយឪពុកម្ដាយ និងស្វាមីរបស់ខ្ញុំ » ។ ប្រាំខែក្រោយមក ជូលៀ បានទទួលបុណ្យជ្រមុជទឹក ។

មួយខែក្រោយពីបុណ្យជ្រមុជទឹក ជូលៀ បាននិយាយនៅក្នុងសន្និសីទស្តេក ។ គាត់បាននិយាយថា « នៅពេលខ្ញុំបានដើរទៅកាន់វេទិកា ខ្ញុំគិតថាមនុស្សគ្រប់គ្នាបានភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ វាគឺជាលើកដំបូងរបស់ពួកគេ ដែលឃើញមនុស្សស្បែកខ្មៅ និយាយនៅក្នុងសន្និសីទ — ប្រហែលវាជាលើកដំបូងសម្រាប់មនុស្សមួយចំនួន ដែលស្ដាប់ឮមនុស្សស្បែកខ្មៅថ្លែងទៅកាន់អ្នកស្ដាប់ទាំងនោះ » ។ គាត់ទទួលអារម្មណ៍បំផុសគំនិត ឲ្យនិយាយអំពីមរណភាពរបស់ស្វាមីគាត់ និងការលំបាកដែលគាត់មានរយៈពេលជាច្រើនឆ្នាំនោះ ។ គាត់បានពិពណ៌នាអំពីភាពល្វីងជូរចត់របស់គាត់ និងរបៀបដែលគាត់ « បានរកឃើញសាសនាចក្រ ដែលបានបង្រៀនគាត់ឲ្យចេះអភ័យទោសយ៉ាងពិតប្រាកដ » ។

ប៉ុន្តែ ការពុះពាររបស់គាត់ទាំងការយល់ខុស និងគំនិតប្រកាន់ ពុំបានចប់ឡើយ ទោះបីជាបន្ទាប់ពីការបំបែកពូជសាសន៍នោះត្រូវបានបញ្ចប់នៅក្នុងឆ្នាំ ១៩៩៤ ក្ដី ។

អែលឌើរ ឌេល ជី រេនឡាន់ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅក្នុងសុន្ទរកថាសន្និសីទទូទៅខែមេសា ឆ្នាំ ២០១៥ ដែលមានចំណងជើងថា « ពួកបរិសុទ្ធថ្ងៃចុងក្រោយបន្តការព្យាយាមជានិច្ច » បានប្រាប់អំពីភាពចៃដន្យដែល ជូលៀ និងកូនស្រីរបស់គាត់ ថូបា បានជួបនៅពេលពួកគេ « ត្រូវបានពួកសមាជិកស្បែក-សមួយចំនួនបានប្រព្រឹត្តដាក់ដោយពុំសប្បុរស » ។ ថូបា បានត្អូញត្អែរអំពីការព្យាបាលនោះ ។ ជាអ្វីដែលងាយនឹងក្លាយជារឿងដោះសារដើម្បីចាកចេញពីព្រះវិហារ បានក្លាយជាឱកាសបង្រៀនដែលពុំអាចកាត់ថ្លៃបាន ។ ជូលៀ បានតបថា « ឱ កូន ថូបា អើយសាសនាចក្រគឺដូចជាមន្ទីរពេទ្យធំមួយ ហើយយើងទាំងអស់គ្នាជាអ្នកជំងឺផ្សេងៗគ្នា ។ យើងទៅព្រះវិហារដើម្បីបានជំនួយ » ។[4]

ជូលៀ បានឃើញថា ការព្យាបាលអាចកើតមានឡើងតាមរយៈ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ពុំគ្រាន់តែកើតឡើងចំពោះខ្លួនគាត់ប៉ុណ្ណោះឡើយ តែក៏សម្រាប់ប្រជាជាតិរបស់គាត់ផងដែរ ។ ការបម្រើរបស់គាត់នៅក្នុងព្រះវិហារបរិសុទ្ធ យ៉ូហាណែស្បឺក អាហ្វ្រិកខាងត្បូង បានបង្រៀនគាត់ថា នៅក្នុងព្រះវិហារបរិសុទ្ធ « គ្មានការប្រកាន់ពូជសាសន៍ឡើយ ។ គ្មានភាពខុសគ្នាដោយសារតែការនិយាយភាសាអង់គ្លេសឡើយ ។ គ្មានភាពខុសគ្នាដោយសារតែការនិយាយភាសាស៊ីទូ និង ស្វាលូ ឡើយ ។ អ្នកស្គាល់ពីអារម្មណ៍នៃសាមគ្គីភាពនោះ » ។

ជូលៀ ម៉ាវីមបេឡា បានទទួលមរណភាពនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០០ ។ ■

**កំណត់ចំណាំ**
១. លើកលែងដូចបានកត់សម្គាល់ ការដកស្រង់មកពី Laura Harper « ‹ Mother of Soweto › : Julia Mavimbela, Apartheid Peace-Maker and Latter-day Saint » unpublished manuscript, Church History Library, Salt Lake City ។
២. នៅក្នុងអត្ថបទកំណាព្យ ពាក្យ *lamp* ត្រូវបានប្រើជំនួសដោយពាក្យ *lump* វិញ ។ ប៉ុន្តែ ថូបា បានបញ្ជាក់ថាពាក្យដែលបានឆ្លាក់នៅលើផ្ទាំងនោះគឺជាពាក្យ *lump* ។
៣. ដកស្រង់មកពី ដាវីឌ ឡូរិន ម៉ាខម សម្ភាសជាមួយអ្នកនិពន្ធ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥ ។
៤. ឌេល ជី រេនឡាន់ « Latter-day Saints Keep on Trying » *Liahona*, ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៥៧ ។

រូបថតដោយមានការអនុញ្ញាតពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ
រូបថតដោយមានការអនុញ្ញាតពី ថូបា អេលីសាបែត ម៉ាវីមបេឡា



# ដេសីឌើរៀ យ៉ាញេស្ស៖

## អ្នកត្រួសត្រាយក្នុងចំណោមពួកស្ត្រី

**ដោយ ក្លីនតុន ឌី គ្រីស្ទីនសិន**
ការិយាល័យប្រវត្តិសាស្ត្ររបស់សាសនាចក្រ

*បន្ទាប់ពីសុបិនបានដឹកនាំគាត់ឲ្យស្គាល់ដំណឹងល្អដែលបានស្តារឡើងវិញ ពួកបរិសុទ្ធថ្ងៃចុងក្រោយកាលពីជំនាន់ដើមរូបនេះ មកពីប្រទេស ម៉ិកស៊ិក បានក្លាយជាអ្នកត្រួសត្រាយដ៏ស្មោះត្រង់របស់សាសនាចក្រ ។*

នារាត្រីមួយនៅក្នុងដើមឆ្នាំ ១៨៨០ ដេសីឌើរៀ យ៉ាញេស្ស កំពុងដេកនៅក្នុងផ្ទះមួយដ៏សុខសាន្ត នៅលើទួល ណូផាឡា ដែលមានដើមដំបងយក្សដុះ នៅក្នុងប្រទេស ម៉ិកស៊ិក ។ នៅពេលគាត់សុបិន គាត់បានឃើញកូនសៀវភៅមួយមានចំណងជើងថា Voz de Amonestación ( *សំឡេងនៃការព្រមាន* ) ដែលនឹងផ្លាស់ប្តូរជីវិត និងផ្តល់ជំនួយខាងវិញ្ញាណដល់គាត់ ។ នៅពេលគាត់ដឹងខ្លួនឡើង គាត់បានដឹងថាអ្នកបោះពុម្ពកូនសៀវភៅនោះនៅទីក្រុងម៉ិកស៊ីកូ ។[1] គាត់ក៏បានដឹងផងដែរថា គាត់ពុំអាចធ្វើដំណើរចម្ងាយ ១២០ គីឡូម៉ែត្រ ទៅកាន់ទីក្រុងនោះឡើយ ប៉ុន្តែគាត់បានសម្រេចចិត្តធ្វើតាមការបំផុសគំនិតមកពីសុបិននោះ ហើយស្វែងរកដំណោះស្រាយ ។

### សេចក្តីជំនឿរបស់គ្រួសារមួយ

ដេសីឌើរៀ បានពិភាក្សាអំពីសុបិនរបស់គាត់ជាមួយកូនប្រុសគាត់ ហូសេ ។ កូនប្រុសគាត់បានជឿគាត់ ហើយបានធ្វើដំណើរទៅទីក្រុងម៉ិកស៊ីកូជំនួសគាត់ ។ កូនប្រុសគាត់ បានចាប់ផ្តើមនិយាយជាមួយមនុស្សនៅទីនោះដោយការជ្រួលច្របល់ក្នុងចិត្ត ហើយទីបំផុតបានជួបសមាជិកសាសនាចក្រម្នាក់ឈ្មោះ ផ្លូទីណូ រ៉ូដាកាណាធី ដែលបាននាំកូនប្រុសគាត់ទៅសណ្ឋាគារសាន ខាឡូស ។[2]

នៅឯសណ្ឋាគារ ហូសេបានជួបអែលឌើរ ជេម ស៊្ស៊ី ស្ទូវ៉ែត ធ្វើការកែរឯកសារដែលហៀបនឹងបោះពុម្ពរបស់ ប៉ាលី ភី ប្រាត្ត ដែលមានចំណងជើងថា *Voz de Amonestación* គឺជាកូនសៀវភៅដែល ដេសីឌើរៀ បានឃើញនៅក្នុងសុបិនរបស់គាត់ ។ បន្ទាប់ពីអែលឌើរ ហូសេ និយាយជាមួយអែលឌើរ ស្ទូវ៉ែតអំពីសុបិនរបស់ ដេសីឌើរៀ មក អ្នកផ្សព្វផ្សាយសាសនាបានឲ្យកូនសៀវភៅមួយចំនួនផ្សេងដល់ ហូសេ ដោយសារសៀវភៅ *Voz de Amonestación* ពុំទាន់បានបញ្ចប់នៅឡើយ ហើយអែលឌើរ ស្ទូវ៉ែត បានកត់ត្រាអំពីការសន្ទនាដ៏គួរឲ្យចាប់អារម្មណ៍នោះនៅក្នុងទិនានុប្បវត្តិរបស់គាត់ ។[3]

បន្ទាប់ពីធ្វើដំណើរអស់ជាច្រើនគីឡូម៉ែត្រលើផ្លូវដែលមានដីហុយមក ហូសេ បានមកជួបជុំនឹងម្តាយរបស់គាត់វិញ ។ បន្ទាប់ពីបានរៀនអំពីភាពពិតប្រាកដរបស់កូនសៀវភៅនោះមក ដេសីឌើរៀ បានដឹងថាសុបិននោះគឺជាការពិត ។ គាត់បានសិក្សាកូនសៀវភៅដែល ហូសេបានយកមកឲ្យគាត់នោះដោយយកចិត្តទុកដាក់ ហើយការបង្រៀនជាមូលដ្ឋានគ្រឹះអំពីដំណឹងល្អដែលមាននៅក្នុងសៀវភៅទាំងនោះបានដាស់រំជួលដល់ព្រលឹងគាត់ ។ គាត់មានបំណងទទួលបុណ្យជ្រមុជទឹក ។

រូបគំនូរដោយ ខាធ្លីន ភីធើសិន



**បានជួបពួកអ្នកផ្សព្វផ្សាយសាសនា**

ដោយសារអែលឌើរ ស្ទូវ៉ត នៅបន្តបញ្ចប់សៀវភៅ *Voz de Amonestación* អែលឌើរ មេលីតុន ត្រេហ្វ ជាអ្នកផ្សព្វផ្សាយសាសនាមកពីប្រទេសអេស្ប៉ាញ ត្រូវបានបញ្ជូនឲ្យទៅទីក្រុងណូប៉ាឡា ដើម្បីស្វែងរក ដេស៊ីឌើរៀ និងហូសេ ។ នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៨៨០ អែលឌើរ ត្រេហ្វ បានជ្រមុជទឹក ដេស៊ីឌើរៀ ខ្វីនថាណា ឌើ យ៉ាញ៉េស្ស និង ខាមិន កូនស្រីរបស់ហូសេ ។ ដេស៊ីឌើរៀ គឺជាមនុស្សទី ២២ ដែលបានទទួលបុណ្យជ្រមុជទឹកនៅក្នុងបេសកកម្មម៉ិកស៊ិក ហើយជាស្ត្រីដំបូងគេនៅក្នុងប្រទេសម៉ិកស៊ិកភាគកណ្ដាល ។[៤]

នៅចុងខែនោះ ហូសេ បានទៅលេងទីក្រុងម៉ិកស៊ីកូម្ដងទៀត ហើយបាននាំយកសៀវភៅ *Voz de Amonestación* ចំនួន ១០ ក្បាលទៅផ្ទះផងដែរ ។ ទីបំផុត ដេស៊ីឌើរៀ បានឃើញកូនសៀវភៅដែលគាត់បានឃើញក្នុងសុបិន ។ សម្រាប់គាត់ កូនសៀវភៅនោះគឺជាការំឭកដល់គាត់អំពីព្រះអម្ចាស់ ដែលបានឈោង

ព្រះហស្តទ្រង់ដោយផ្ទាល់ទៅជួយគាត់ ហើយធ្វើឲ្យគាត់ចាប់អារម្មណ៍លើដំណឹងល្អដែលបានស្តារឡើងវិញ ។

**ព្រះគម្ពីរមរមនភាសាអេស្ប៉ាញមុនដំបូងគេបង្អស់**

នៅអាយុ ៧២ ឆ្នាំ ដេសីឌើរៀ បានឃើញថាសុខភាពរបស់គាត់បានចុះទ្រុឌទ្រោម ។ នៅឆ្នាំ ១៨៨៦ គាត់ពុំអាចចាកចេញពីផ្ទះដ៏តូចរបស់គាត់នៅសាន ឡូរ៉ែនសូ ក្បែរទីក្រុង ណូប៉ាឡា បានឡើយ ។ នាល្ងាចដ៏សោកសៅមួយ ពួកចោរបានគាស់ចូលផ្ទះរបស់គាត់ វាយធ្វើបាបគាត់ ហើយបានលួចយកប្រាក់ ៣០០០ ដុល្លារទៅផងដែរ ។[៥] តែ ដេសីឌើរៀ នៅរស់រានមានជីវិត ។ ជាជាងមានក្តីអស់សង្ឃឹម ដេសីឌើរៀ បានរង់ចាំជំនួយរបស់ព្រះអម្ចាស់ដោយសេចក្តីជំនឿ ។ គាត់បានរៀនមកពីសុបិនរបស់គាត់ថា ព្រះអម្ចាស់ជ្រាបដឹងអំពីស្ថានភាពរបស់គាត់ ។

ក្រោយមកនៅខែ តុលា ឆ្នាំ ១៨៨៦ សាវកមួយរូប និងប្រធានបេសកកម្មពីរនាក់បានទៅលេងតំបន់នោះដោយពុំបានព្រៀងទុកឡើយ ។ ហូសេ យ៉ាញេស្ស បានប្រាប់ពួកលោកអំពីការរងទុក្ខរបស់ម្តាយគាត់ ។ ពួកបងប្អូនប្រុសបានប្រញាប់ទៅផ្ទះរបស់ដេសីឌើរៀ ។ ដេសីឌើរៀមានចិត្តរីករាយដោយបានជួបអែលឌើរ អ៊ីរ៉ាស្តុស ស្នូ ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ ហើយបានឲ្យអែលឌើរ អ៊ីរ៉ាស្តុស ស្នូ ដាក់ដៃលើក្បាលគាត់ ផ្តល់ការប្រសិទ្ធពរបព្វជិតភាព ។

អំឡុងពេលពួកបងប្អូនប្រុសសួរសុខទុក្ខគាត់ នោះប្រធានបេសកកម្ម ហូរ៉េស្ស ខូមមីង បានប្រាប់ដំណឹងដ៏រំភើបមួយដល់ ដេសីឌើរៀ ។ អែលឌើរ អ៊ីរ៉ាស្តុស ស្នូ បានប្រាប់គាត់អំពីការបកប្រែដំបូងនៃព្រះគម្ពីរមរមនទាំងមូលជាភាសាអេស្ប៉ាញនៅទីក្រុង សលត៍ លេក ជិតចប់សព្វគ្រប់ហើយ ។ ដេសីឌើរៀ បានស្នើសូមព្រះគម្ពីរដែលនឹងមាននាពេលដ៏ឆាប់ខាងមុខនោះភ្លាម ។

មួយខែក្រោយមកប្រធាន ខូមមីង បានយកព្រះគម្ពីរមរមនមួយក្បាលនោះទៅផ្ទះរបស់ ដេសីឌើរៀ ។ គាត់បានសរសេរអំពីបទពិសោធន៍នេះថា ៖ « ការសួរសុខទុក្ខបងស្រីចំណាស់ យ៉ាញេស្ស ជាអ្នកកំពុងត្រូវការការមើលថែ ខ្ញុំបានជូនព្រះគម្ពីរមរមនបោះពុម្ពរួចនោះទៅគាត់ ដែលខ្ញុំត្រូវបានបញ្ជូនទៅរដ្ឋ យូថាហ៍ ដើម្បីយកវាឲ្យគាត់ ។ វាគឺជាព្រះគម្ពីរដំបូងគេជាភាសាអេស្ប៉ាញដែលបានទទួលនៅក្នុងប្រទេសម៉ិកស៊ិក ។ . . . គាត់ហាក់បីដូចជាពេញចិត្តព្រះគម្ពីរនោះខ្លាំងណាស់ » ។[៦] នេះគឺជាលើកចុងក្រោយនៃការសួរសុខទុក្ខរបស់អ្នកផ្សព្វផ្សាយសាសនាជាមួយ ដេសីឌើរៀ អំឡុងពេលនៃជីវិតរបស់គាត់ ។

**នៅដាច់ពីគេ ប៉ុន្តែពុំត្រូវបានបំភ្លេចចោលឡើយ**

នៅឆ្នាំ ១៨៨៩ គឺ ១០ ឆ្នាំបន្ទាប់ពីដំណឹងល្អដែលបានស្តារឡើងវិញមកដល់ប្រទេសម៉ិកស៊ិកភាគកណ្តាល នោះថ្នាក់ដឹកនាំសាសនាចក្រទទួលអារម្មណ៍បំផុសគំនិតឲ្យផ្លាស់ប្តូរ ធនធានដែលមានតិចតួចរបស់សាសនាចក្រ ដោយបង្កើតក្រុមនានានៅក្នុងប្រទេសម៉ិកស៊ិកភាគខាងជើង ។ សមាជិកនៅជិតទីក្រុងម៉ិកស៊ីកូ ដែលមានចម្ងាយផ្លូវប្រហែល ១៦០០ គីឡូម៉ែត្រ ពីក្រុមទាំងនោះ មានអារម្មណ៍ដូចជាសត្វចៀមដែលគ្មានអ្នកគង្វាល នៅពេលអ្នកផ្សព្វផ្សាយសាសនាបានចាកចេញទៅភាគខាងជើង ។ ដោយមានក្រុមគ្រួសារនៅក្បែរ ដេសីឌើរៀ បានដឹងថាពួកគេនឹងត្រូវអនុវត្តតាមដំណឹងល្អនៅកន្លែងដាច់ឆ្ងាយពីគេ ។ នេះមានន័យថា គាត់នឹងពុំអាចចូលរួមថ្នាក់សមាគមសង្គ្រោះ ឬទទួលពរជ័យនៃព្រះវិហារបរិសុទ្ធអំឡុងពេលនៅមានជីវិតនោះឡើយ ។



ប៉ុន្តែគាត់បានទទួលស្គាល់ថា ព្រះអម្ចាស់បានស្គាល់គាត់ ។ តាមរយៈអ្នកបម្រើរបស់ទ្រង់ ព្រះអម្ចាស់បានបើកសម្ដែងព្រះទ័យរបស់ទ្រង់ ដើម្បីបម្រើហ្វូងចៀមរបស់ទ្រង់ម្នាក់ម្ដងៗ ។ ដោយសារសុបិនរបស់គាត់ ពរជ័យនៃបព្វជិតភាព និង ព្រះគម្ពីរមរមន នោះដេស៊ីឌើរៀ អាចថ្លែងទីបន្ទាល់អំពីការបញ្ជាក់ដ៏ច្បាស់លាស់របស់គាត់ថា ព្រះខ្វល់ខ្វាយអំពីសេចក្ដីត្រូវការរបស់គាត់ទាំងខាងវិញ្ញាណ និងខាងសាច់ឈាម ។ ទោះបីជាចំណេះដឹងនេះពុំអាចរារាំងការសាកល្បង និងឧបសគ្គនានាកុំឲ្យកើតមានឡើងក្នុងជីវិតគាត់ក្ដី ក៏វាបានផ្ដល់នូវទំនុកចិត្តដល់គាត់ថា ព្រះអម្ចាស់នឹងសម្រាលបន្ទុករបស់គាត់ ។

### មរតកនៃការកាន់ខ្ជាប់

ក្នុងឆ្នាំ ១៩០៣ អ្នកផ្សព្វផ្សាយសាសនាបានត្រឡប់ទៅប្រទេស ម៉ិកស៊ិកភាគខាងត្បូងវិញជាលើកដំបូង ចាប់តាំងពីឆ្នាំ ១៨៨៦ មក ។ ពួកគេបានជួប ហូសេ ដែលសង្ខេបអំពីការកាន់ខ្ជាប់ដរាបដល់ចុងបំផុត និងមរតកនៃសេចក្ដីជំនឿ ដោយនិយាយថាទាំងភរិយា និងម្ដាយរបស់គាត់ « បានចែកឋានទៅទាំងមានសេចក្ដីជំនឿទាំងស្រុងលើនិកាយមរមន » ហើយថាគាត់ « រំពឹងថានឹងស្លាប់ក្នុងជំនឿនៃពួកមរមន » ។[៧]

បន្ទាប់ពីបានសុបិនអំពីរឿងនោះមក ដេស៊ីឌើរៀ បានចាប់ផ្ដើមដើរលើមាគ៌ានៃដំណឹងល្អ ដោយក្លាយជាអ្នកត្រួសត្រាយជនជាតិឡាតាំងនៃសាសនាចក្រ ។ គ្រាប់ពូជនៃសេចក្ដីជំនឿបានដុះឡើង តាមរយៈសុបិននៅក្នុងឆ្នាំ ១៨៨០ នោះពុំឥតប្រយោជន៍ឡើយ វាបានដុះពន្លកឡើងនៅពេល ដេស៊ីឌើរៀ បានចុះសេចក្ដីសញ្ញានៃបុណ្យជ្រមុជទឹក ហើយស៊ូទ្រាំនឹងការសាកល្បងគាត់ដោយសេចក្ដីជំនឿ ។ ដេស៊ីឌើរៀ នឹងពុំងាយចុះខ្សោយខាងវិញ្ញាណឡើយ នៅពេលគាត់ និងគ្រួសារគាត់អនុវត្តតាមដំណឹងល្អដែលនៅដាច់គេពីព្រះវិហារទាំងអស់នោះ ប៉ុន្តែគាត់បានបន្តកាន់ខ្ជាប់ ។ គាត់បានដឹងថាព្រះខ្វល់ខ្វាយ ហើយមើលថែរូបគាត់ក្នុងផ្នែកដ៏តូចនៃពិភពលោក ។

ទោះបីជាគាត់ពុំអាចចេញពីផ្ទះរួចក្ដី គាត់ក្លាយជាគំរូមួយនៃសេចក្ដីជំនឿ ភាពឧស្សាហ៍ព្យាយាម ការគោរពប្រតិបត្តិ និងជាកម្លាំងមិនត្រឹមតែសម្រាប់គ្រួសាររបស់គាត់ប៉ុណ្ណោះនោះទេ ថែមទាំងដល់ពួកយើងម្នាក់ៗផងដែរ នៅពេលយើងព្យាយាមបន្តនូវស្មារតីនៃអ្នកត្រួសត្រាយនេះ ។ ■

កំណត់ចំណាំ

១. សូមមើល Alonzo L. Taylor Mission Papers ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩០៣ និង Mexican Mission Manuscript History and Historical Reports ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៩០៣ Church History Library Salt Lake City ។

២. សូមមើល Taylor Mission Papers ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩០៣ និង James Z. Stewart Papers ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៨៨០ Church History Library ។

៣. សូមមើល Stewart Papers ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៨៨០ ។

៤. សូមមើល Moses Thatcher Journal ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៨៧៩ និង Stewart Papers ថ្ងៃទី ២៦ ខែ មេសា និង ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៨៨០ Church History Library ។ ដេស៊ីឌើរៀ គឺជាមនុស្សដំបូងគេដែលបានទទួលបុណ្យជ្រមុជទឹក បន្ទាប់ពីបេសកកម្មម៉ិកស៊ិក បានបើកនៅក្នុងឆ្នាំ ១៨៧៩ នៅក្នុងទីក្រុងម៉ិកស៊ីកូ ។ ប៉ុន្តែ បេសកកម្មខ្លីមួយទៅទីក្រុង ហើរម៉ូស៊ីលយ៉ូភាគខាងជើងក្នុងឆ្នាំ ១៨៧៧ បាននាំឲ្យមានបុណ្យជ្រមុជទឹកចំនួនប្រាំនាក់នៅភូមិក្បែរនោះ រួមមាន ម៉ារៀ ឡាគ្រូស ប៉ារ៉ូស ដែលត្រូវបានស្គាល់ថាជាស្ត្រីជនជាតិម៉ិកស៊ិកដំបូងគេដែលបានប្រែចិត្តជឿ ។ កំណត់ត្រាជាផ្លូវការនៃបេសកកម្ម ម៉ិកស៊ិក ដែលបានបង្កើតឡើងដោយ ម៉ូសេ ថាឆើរ ដាក់ថា ដេស៊ីឌើរៀ យ៉ាញេស្ស គឺជាស្ត្រីដំបូងគេដែលបានប្រែចិត្តជឿ ដែលការពិតនោះគាត់គឺជាអ្នកទីពីរ ។ សូមមើលផងដែរ Louis Garff Reminiscences គ្មានកាលបរិច្ឆេទ Church History Library ។

៥. សូមមើល Horace H. Cummings Papers ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៨៨៦ Church History Library ។

៦. Cummings Papers ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៨៨៦ ។

៧. Taylor Mission Papers ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩០៣ ។







# ការចិញ្ចឹមបីបាច់កូនប្រុសរបស់យើងក្នុងភាពជាដៃគូជាមួយព្រះ

ដោយ ខាមី គ្រូកស្តុន

ការយល់ដឹងមួយរបស់ខ្ញុំក្នុងនាមជាឪពុកម្ដាយនោះ គឺការឲ្យកូនៗរបស់ខ្ញុំស្លៀកពាក់ឲ្យបានស្អាតបាតជានិច្ច ហើយពុំកខ្វក់ឡើយ ។ ភ្លាមៗនោះខ្ញុំដឹងថា ការយល់ដឹងដែលខ្ញុំចង់បាននោះគឺជាគំនិតរវើរវាយមួយ ។ ខ្ញុំបានសុខចិត្តទទួលយកភាពរញ៉េរញ៉ៃដែលមាននៅក្នុងផ្ទះរបស់ខ្ញុំ និងការហៀរសំបោររបស់កូនៗ ដោយសារខ្ញុំដឹងថា រឿងទាំងនេះបានកើតឡើងជាពរជ័យដ៏អស្ចារ្យបំផុត ដែលខ្ញុំពុំធ្លាប់មានពីមុនមក ។ ប៉ុន្តែអ្វីដែលខ្ញុំពុំធ្លាប់គិតឃើញនោះ គឺជាការលំបាកដែលខ្ញុំបានជួបអំឡុងពេលចិញ្ចឹមបីបាច់កូនៗរបស់ខ្ញុំ ជាពិសេស ប្រាដ កូនប្រុសរបស់ខ្ញុំ ។

ប្រាដ បានកើតមកជាក្មេងគ្មានកំហុសដូចជាក្មេងៗដទៃទៀតដែរ ប៉ុន្តែមិនយូរប៉ុន្មានក្រោយមកយើងបានដឹងថាគាត់មានភាពខុសប្លែកពីក្មេងដទៃ ។ គាត់ពុំអាចទៅថ្នាក់ទារកដ្ឋានដោយគ្មានស្វាមីខ្ញុំ ឬរូបខ្ញុំឡើយ ដោយសារគាត់រករឿងគេខ្លាំងណាស់ ។ នៅពេលគាត់ធំឡើង និងពេលគាត់លេងជាមួយក្មេងដទៃទៀត គាត់ត្រូវតែមានការមើលគ្រប់គ្រងជាប់ជានិច្ច ។ នៅពេលយើងស្វែងរកជំនួយ នោះគេបានប្រាប់យើងថា យើងត្រូវនៅឲ្យកាន់តែកៀកនឹងគាត់ ។ យើងបានធ្វើកិច្ចការគ្រប់យ៉ាងដែលយើងគិតឃើញ ៖ យើងបានស្រាវជ្រាវតាមអ៊ិនធើរណែត អានសៀវភៅផ្សេងៗអំពីភាពជាឪពុកម្ដាយ ហើយសួរយោបល់ពីវេជ្ជបណ្ឌិត និងសមាជិកគ្រួសារ ។ ទីបំផុតនៅពេល ប្រាដ ចាប់ផ្ដើមចូលរៀន គាត់ត្រូវបានធ្វើរោគវិនិច្ឆ័យថាកើតជំងឺវិបត្តិមានសកម្មភាពហួសហេតុដែលខ្វះការប្រុងស្មារតី ឬ ADHD ព្រមទាំងមានបញ្ហាជាច្រើនផ្សេងទៀត ។

នៅគ្រាដំបូងយើងមានអារម្មណ៍ថាយើងមានសេចក្ដីសង្ឃឹម ។ ឥឡូវនេះយើងមានរោគវិនិច្ឆ័យ យើងអាចចាប់ផ្ដើមផែនការព្យាបាល ។ យើងមានសង្ឃឹមថា ថ្នាំដែលដាក់ឲ្យ ប្រាដ ផឹកនោះមានប្រសិទ្ធភាពព្រោះថ្នាំនោះបានជួយមនុស្សជាច្រើនផ្សេងទៀត ។ ជាអកុសល ឥរិយាបថរបស់ ប្រាដ នៅពេលប្រើថ្នាំគឺកាន់តែអាក្រក់ជាងពេលពុំបានប្រើថ្នាំទៅទៀត ដូច្នេះគាត់ត្រូវឈប់ផឹកថ្នាំនោះ ។ ខ្ញុំមានអារម្មណ៍ថាសេចក្ដីសង្ឃឹមចុងក្រោយបន្តិចបន្តួចរបស់ខ្ញុំបានរលាយបាត់អស់ ។

ថ្ងៃមួយពេល ប្រាដ មានអាយុប្រាំមួយឆ្នាំ ខ្ញុំបានប្រឈមមុខនឹងការផ្ទុះកំហឹងដែលគាត់មានជាប្រចាំ ។ ខ្ញុំចង់ចុះចាញ់ហើយ ។ ខ្ញុំបានទៅបន្ទប់របស់ខ្ញុំមួយសន្ទុះតែម្នាក់ឯង ហើយខ្ញុំបានយំ ។ ខ្ញុំបានអធិស្ឋានទូលសូមកម្លាំង ដើម្បីអាចដេកលក់នៅពេលដល់ម៉ោងសម្រាក ។ តើខ្ញុំអាចបន្តធ្វើកិច្ចការនេះពីមួយថ្ងៃទៅមួយថ្ងៃបានយ៉ាងដូចម្ដេច ? ខ្ញុំមានអារម្មណ៍ថា ខ្ញុំគ្មានសមត្ថភាពនឹងស៊ូទ្រាំនឹងការណ៍នោះបានឡើយ ។ តើព្រះវរបិតាសួគ៌ជ្រាបដឹងថាវាពិបាកខ្លាំងប៉ុណ្ណាទេ ? ប្រសិនបើទ្រង់ពិតជាស្រឡាញ់ខ្ញុំ

*នៅពេលខ្ញុំរៀនប្រើប្រាស់ធនធានខាងវិញ្ញាណដែលមានសម្រាប់ខ្ញុំ នោះខ្ញុំមានយោបល់ជាច្រើនអំពីរបៀបជួយកូនប្រុសរបស់ខ្ញុំ ហើយជួយខ្ញុំឲ្យប្រឈមមុខនឹងការសាកល្បងរបស់ខ្លួនខ្ញុំផ្ទាល់បានកាន់តែប្រសើរឡើង ។*



*ស្វាមីខ្ញុំ និងខ្ញុំបាន ស្រាវជ្រាវ និងបាន រកឃើញធនធាន ជាច្រើនដើម្បីជួយ ពួកយើង ប៉ុន្តែយើង ភ្លេចកិច្ចការមួយដ៏ សំខាន់បំផុតគឺ ៖ ការអធិស្ឋាន ។*

មែន ខ្ញុំគិតថា ទ្រង់នឹងដកយកបន្ទុកនេះចេញពីខ្ញុំ ហើយ ប្រទានជីវិតសាមញ្ញដូចគេឯងដល់កូនប្រុសរបស់ខ្ញុំវិញ ។ គំនិត និងអារម្មណ៍ទាំងនោះបានកើតមានឡើងក្នុងចិត្តខ្ញុំ នៅពេលការសាកល្បងដែលខ្ញុំជួបប្រទះហាក់បីដូចជាកាន់តែ ធ្ងន់ធ្ងរទៅៗ មិនប្រសើរឡើងសោះ ។

**លក្ខណៈពិតប្រាកដនៃការសាកល្បង**

ខ្ញុំគិតថា ខ្ញុំបានយល់អំពីការសាកល្បង ។ យើងត្រូវឆ្លងកាត់ ការសាកល្បងទាំងនោះ ដូចជាឆ្នាំងដែលត្រូវបានដុតនៅក្នុង ឡភ្លើងដែរ ។ យើងនឹងត្រូវលត់ដោយភ្លើងទៅមកៗ បន្ទាប់មក ជីវិតនេះនឹងត្រឡប់ទៅរកភាពធម្មតាវិញ រហូតដល់ការលត់នឹង កម្តៅលើកក្រោយទៀត ។ ប៉ុន្តែខ្ញុំបានជួបការសាកល្បងនេះអស់ រយៈពេលជាច្រើនឆ្នាំ ហើយវាមិនបានដកចេញទៅណាឡើយ ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំរងសម្ពាធយ៉ាងធ្ងន់ ហើយអារម្មណ៍នៃ ភាពគ្មានសង្ឃឹម បាននាំឲ្យខ្ញុំលុតជង្គង់ចុះអធិស្ឋាន ។

ក្រោយមកខ្ញុំបានដឹងថា កន្លែងដែលខ្ញុំត្រូវទៅដើម្បីទទួល បានការលួងលោមនោះ និងការយល់ចិត្តនោះគឺព្រះវិហារ បរិសុទ្ធ ។ តាមរយៈការបំផុសគំនិតនោះ ខ្ញុំបានដឹងថាយើងពុំ មែនជាអ្នករើសយកការសាកល្បងណាមួយដែលយើងនឹងមាន ក្នុងជីវិតនេះ ឬរើសយករយៈពេលនៃការសាកល្បងនោះឡើយ ។ អ្វីដែលយើងអាចគ្រប់គ្រងបាននោះគឺជារបៀបដែលយើងគិត និងប្រព្រឹត្ត នៅពេលដែលការសាកល្បងនោះកើតមានឡើង ។

ខ្ញុំបានដឹងថា ហេតុផលដែលខ្ញុំមានអារម្មណ៍តូចចិត្តចំពោះ ខ្លួនខ្ញុំនោះ គឺដោយសារខ្ញុំមានចិត្តអាណិតខ្លួនឯងខ្លាំងពេក ។ រឿងដំបូងដែលខ្ញុំត្រូវធ្វើនោះ គឺខ្ញុំត្រូវសម្រេចចិត្តឈប់មានគំនិត អវិជ្ជមានដែលមាននៅក្នុងចិត្តខ្ញុំ ដូចជា « រឿងនេះអយុត្តិធម៌ ណាស់ ខ្ញុំពុំអាចធ្វើរឿងនេះបានទេ ហេតុអ្វី ប្រាដ មិនអាចជា មនុស្សធម្មតា ? ឬ ប្រភពដែលធ្វើឲ្យមានគំនិតអវិជ្ជមាន « ខ្ញុំគឺ ជាម្តាយដែលអន់ » ។ ខ្ញុំបានខិតខំយ៉ាងខ្លាំងដើម្បីបញ្ឈប់គំនិត អវិជ្ជមានដែលមានក្នុងចិត្តរបស់ខ្ញុំ ហើយខ្ញុំបានឃើញថា គំនិត ដ៏ពិតប្រាកដរបស់ខ្ញុំ បានប្រែជាកាន់តែមានចិត្ត អំណត់ ហើយស្រឡាញ់ នៅពេលខ្ញុំដោះស្រាយ បញ្ហាជាមួយកូនរបស់ខ្ញុំទាំងអស់ ។



ខ្ញុំក៏បានលើកទឹកចិត្តឲ្យគិតអ្វីដែល វិជ្ជមាន ។ ខ្ញុំបានចាប់ផ្តើមគិតថា « អ្នក បានធ្វើល្អហើយ » ហើយខ្ញុំបានសរសើរខ្លួនខ្ញុំ ដូចជា « អ្នក ត្រូវនិយាយដោយស្រទន់ ហើយកុំស្រែក ។ នេះជារឿងត្រឹមត្រូវ ដែលត្រូវធ្វើ ! »

**ពឹងផ្អែកទៅលើព្រះ**

បន្ទាប់ពីថ្ងៃដ៏លំបាកនោះមកខ្ញុំបានសូមឲ្យស្វាមីរបស់ខ្ញុំ ផ្តល់ការប្រសិទ្ធពរដល់ខ្ញុំ ។ អំឡុងពេលប្រសិទ្ធពរ ខ្ញុំត្រូវបាន រំឭកថា ខ្ញុំជាបុត្រីរបស់ព្រះ ថាទ្រង់ជ្រាបដឹងពីខ្ញុំ និងតម្រូវការ ខ្ញុំ ហើយថាកូនប្រុសរបស់ខ្ញុំគឺជាបុត្រានៃព្រះ ។ ប្រាដ គឺជា បុត្ររបស់ព្រះ ហើយស្វាមីខ្ញុំ និងខ្ញុំមានភាពជាដៃគូជាមួយ ព្រះមើលថែ ប្រាដ ។ ខ្ញុំបានដឹងថា ខ្ញុំពុំទាន់បានប្រើប្រាស់ ឧបករណ៍ទាំងអស់ដែលទ្រង់បានប្រទានដល់ខ្ញុំនោះទេ ។ ស្វាមីខ្ញុំ និងខ្ញុំបានស្រាវជ្រាវ និងបានរកឃើញធនធានជាច្រើន ដើម្បីជួយពួកយើង ប៉ុន្តែយើងភ្លេចកិច្ចការមួយដ៏សំខាន់បំផុត គឺ ៖ ការអធិស្ឋាន ។

ខ្ញុំបានចាប់ផ្តើមអធិស្ឋានរៀងរាល់ថ្ងៃ អំពីរបៀបដែលខ្ញុំ អាចជួយ ប្រាដ ។ នៅពេលគាត់មានកំហឹងឆួវចិត្តខ្លាំងនោះ ខ្ញុំបានអធិស្ឋានខ្លីមួយទូលសូមការបំផុសគំនិតពីមុនទៅជួប គាត់ ។ នៅពេលខ្ញុំបានពឹងផ្អែកលើព្រះ ទូលសូមការគាំទ្រ និង ការបំផុសគំនិតសម្រាប់កូនប្រុសខ្ញុំ នោះខ្ញុំបានចាប់ផ្តើមយល់ អំពីសក្តានុពលរបស់ខ្ញុំ និងអ្វីដែលខ្ញុំអាចធ្វើសម្រាប់គាត់ ។ ខ្ញុំបានព្យាយាមធ្វើតាមប្រសាសន៍របស់អាលម៉ា ៖ « ហើយនេះ គឺជាការអួតរបស់ខ្ញុំ ក្រែងខ្ញុំអាចបានទៅជាគ្រឿងឧបករណ៍មួយ នៅក្នុងព្រះហស្តនៃព្រះ » ( អាលម៉ា ២៩:៩ ) ។

ការផ្លាស់ប្តូរបានកើតមានឡើងភ្លាមៗ ។ ខ្ញុំមានគំនិត និងវិធីសាស្ត្រជាច្រើនដើម្បីជួយ ប្រាដ ។ ខ្ញុំបានប្រើប្រាស់ រាត្រីជួបជុំក្រុមគ្រួសារធ្វើជាឧបករណ៍មួយ ហើយបានអធិស្ឋាន ទូលសូមយោបល់នានាអំពីអ្វីដែលត្រូវបង្រៀន ។ ខ្ញុំក៏បានអាន ព្រះគម្ពីរដោយមានចិត្តស្មោះសរកាន់តែខ្លាំងឡើង ហើយទទួល ស្គាល់នូវការទូន្មាននៃភាពជាឪពុកម្តាយដ៏អស្ចារ្យដែលមាន នៅក្នុងគម្ពីរ ។ ខ្ញុំបានចាប់ផ្តើមពោរពេញដោយសេចក្តីសង្ឃឹម និងការលួងលោម ។

នៅពេលខ្ញុំបន្តអនុវត្តតាមគំនិតដែលថា ស្វាមីខ្ញុំ និងខ្ញុំមាន ព្រះជាដៃគូ ក្នុងការធ្វើជាឪពុកម្តាយចំពោះកូនៗរបស់យើង ហើយប្រើប្រាស់ឧបករណ៍ដែលទ្រង់បានប្រទានដល់យើង នោះ

ខ្ញុំបានចាប់ផ្ដើមពឹងផ្អែកលើព្រះកាន់តែច្រើនឡើង ។ ខ្ញុំបានដឹងថា ចំណេះដឹងរបស់ខ្ញុំអំពីភាពជាឪពុកម្ដាយ អាចឈានមកដល់ចំណុចនេះ ដោយសារតែព្រះវរបិតាសួគ៌ដែលពោរពេញដោយក្ដីស្រឡាញ់ ដែលជ្រាបដឹងរឿងគ្រប់យ៉ាង ហើយស្រឡាញ់កូនប្រុសរបស់ខ្ញុំច្រើនជាងខ្ញុំស្រឡាញ់គាត់ទៅទៀត នោះការយល់ដឹងនេះអាចជួយខ្ញុំឲ្យក្លាយទៅជាម្ដាយកាន់តែប្រសើរឡើង និងរឹងមាំឡើង ។ ទោះជាយ៉ាងណាក្ដី ជួនកាលខ្ញុំនៅតែមានការលំបាក ប៉ុន្តែខ្ញុំដឹងពីកន្លែងដែលខ្ញុំត្រូវស្វែងរកជំនួយ ។ ឥឡូវនេះខ្ញុំយល់ថា ការសាកល្បងមួយចំនួនអាចគ្មានពេលកំណត់ថាឈប់នៅពេលណាឡើយ ប៉ុន្តែប្រសិនបើខ្ញុំផ្ដោតទៅលើភាពអស់កល្បជានិច្ចនោះព្រះនឹងជួយខ្ញុំ ។

**មានអំណរនៅក្នុងរឿងល្អៗដែលកើតមាន**

នៅពេលមានគ្រាលំបាកនានា ខ្ញុំបានរៀនចំណាយពេលទទួលអំណរចំពោះរឿងល្អៗដែលកើតមាន ទោះបីវាតូចតាចក្ដី — វាជាអំណោយ — ដែលបានប្រទានដល់យើង ។ នៅពេលកូនប្រុសរបស់ខ្ញុំថើបខ្ញុំ នោះខ្ញុំមានអំណរគុណណាស់ ។ នៅពេលខ្ញុំបានមើលកូនប្រុសរបស់ខ្ញុំជិះឡានក្រុងតែឯងបាន នោះខ្ញុំមានពរដោយមានខគម្ពីរនេះបានផុសឡើងក្នុងចិត្តរបស់ខ្ញុំ ៖ « យើងនឹងទៅពីមុខអ្នក ។ យើងនឹងនៅខាងស្ដាំដៃអ្នក ហើយខាងឆ្វេងដៃអ្នក ហើយព្រះវិញ្ញាណរបស់យើងនឹងសណ្ឋិតនៅក្នុងដួងចិត្តរបស់អ្នក ហើយពួកទេវតារបស់យើងនៅព័ទ្ធជុំវិញអ្នក ដើម្បីទ្រអ្នកឡើង » ( គ. និង ស. ៨៤:៨៨ ) ។ ខ្ញុំបានដឹងថា ប្រាដ មិននៅឯកោ ហើយនឹងពុំឯកោឡើយ ។

យើងគឺជាគ្រួសារអស់កល្បជានិច្ច ហើយដោយមានជំនួយពីមនុស្សដែលស្រឡាញ់ពួកយើង និងព្រះវរបិតាសួគ៌ដែលពេញដោយក្ដីស្រឡាញ់របស់យើង មើលថែយើង នោះខ្ញុំមានអំណរគុណចំពោះអំណោយតូចតាចនានា ដែលបានប្រទានឲ្យខ្ញុំរាល់ថ្ងៃ និងអារម្មណ៍នៃអំណរ ព្រមទាំងសុភមង្គលដែលយើងចង់បាន ។ ហើយដោយមានពរជ័យតូចៗទាំងនោះ និងជំនួយពីព្រះអម្ចាស់ នោះខ្ញុំអាចប្រែក្លាយដូចជាមនុស្សដែលខ្ញុំចង់ប្រែក្លាយ ទោះវាត្រូវចំណាយពេលយូរប៉ុណ្ណាក្ដី ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*



*នៅពេល មើរីឡូ បានទទួលបុណ្យជ្រមុជទឹកនៅអាយុ ១៦ ឆ្នាំ គ្រួសារទាំងមូលរបស់គាត់បានប្រឆាំងនឹងរឿងនោះ ។ ពេលគាត់ទទួលការហៅបម្រើបេសកកម្ម ឪពុកម្ដាយរបស់គាត់បានបោះសម្លៀកបំពាក់ទៅព្រះវិហាររបស់គាត់ចោល ហើយបញ្ឈប់គាត់មិនឲ្យបម្រើបេសកកម្ម ។ ទីបំផុតគាត់បានជួយនាំគ្រួសារគាត់មកព្រះវិហារ ប៉ុន្តែគាត់នៅតែមានអារម្មណ៍ថាពុំសក្តិសមដែលពុំបានបម្រើបេសកកម្ម ។*

**ខូឌី បែល ជាងថតរូប**

# មើរីឡូ វីសិនធេ លីធេ រីបៀរ៉ូ

*ហ្គុយយ៉ាណៀ ប្រទេសប្រេស៊ីល*



វាមានការលំបាកសម្រាប់ខ្ញុំដែលជាយុវជនម្នាក់ ហើយមិនបម្រើបេសកកម្ម ។ ខ្ញុំមានអារម្មណ៍ថាអន់ជាងមិត្តភក្តិរបស់ខ្ញុំ ដែលបានទៅបម្រើបេសកកម្ម ហើយខ្ញុំមានអារម្មណ៍ថាឯកោនៅព្រះវិហារ ។ មនុស្សមួយចំនួនគិតថា ខ្ញុំពុំអាចទៅបម្រើបានទេ ដោយសារខ្ញុំគ្មានភាពសក្តិសម ។ ប៉ុន្តែខ្ញុំបានប្រឹងអស់ពីសមត្ថភាពរបស់ខ្ញុំ ដើម្បីបន្តរឹងមាំនៅក្នុងសេចក្តីជំនឿ ។

ប៉ុន្មានឆ្នាំក្រោយមក ខ្ញុំបានជួបអែលឌើរ ចៃរ៉ូ ម៉ាស្សាហ្គាឌី ក្នុងពួកចិតសិបនាក់ នៅពេលលោកបានមករៀបចំស្តេករបស់យើងឡើងវិញ ។ លោកបានសួរខ្ញុំអំពីការបម្រើបេសកកម្មរបស់ខ្ញុំ ។

ខ្ញុំបាននិយាយទាំងទឹកភ្នែកថា « ខ្ញុំពុំបានបម្រើបេសកកម្មទេ ។

លោកបានមានប្រសាសន៍ថា « ប្អូនប្រុសមើរីឡូ ចូរកុំគិតអំពីរឿងកន្លងទៅធ្វើអ្វី ចូរបន្តឆ្ពោះទៅមុខ ។ អស់អ្នកដែលក្រឡេកមើលក្រោយនឹងដើរថយក្រោយ ហើយអស់អ្នកដែលសម្លឹងទៅមុខនោះនឹងរីកចម្រើនឡើង ។ ប្អូនប្រុសមានភាពស្អាតស្អំហើយ » ។

អារម្មណ៍នោះគឺដូចជាការដកចេញនូវសម្ពាយដ៏ធ្ងន់ពីខ្នងរបស់ខ្ញុំ ។

លោកបានប្រាប់ខ្ញុំនិងភរិយាឲ្យទៅជួបលោក ហើយបានហៅខ្ញុំបម្រើជាប្រធានស្តេក ។

អានអំពីរឿងរបស់មើរីឡូបន្ថែមទៀតនៅក្នុង *លីអាហូណា* នៅលើអ៊ិនធើរណែតតាមគេហទំព័រ **lds.org/go/71738** ។





**ខ្ញុំ** បានចាប់ផ្ដើមបើកបរឡានដឹកអ្នកដំណើរ ហើយធ្វើការជាភ្នាក់ងារលក់ ដើម្បីផ្គត់ផ្គង់ដល់សេចក្ដីត្រូវការចាំបាច់របស់យើង ។

# បាតដៃទទេ ប៉ុន្តែពេញដោយសេចក្ដីជំនឿ

បន្ទាប់ពីបម្រើនៅក្នុងបេសកកម្ម ខាហ្គាយ៉ាន ឌើ អូរ៉ូ ហ្វីលីពីន មក ខ្ញុំបានសម្រេចចិត្តធ្វើតាមការទូន្មានរបស់ព្យាការី និងពួកសាវកដើម្បីរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ។ សាច់ញាតិ និង មិត្តភក្តិរបស់ខ្ញុំដែលពុំមែនជាសមាជិកស្ទើរតែគ្រប់រូប និងសូម្បីតែសមាជិកមួយចំនួន បាននិយាយថា ខ្ញុំគួរតែរៀនឲ្យចប់កម្រិតមហាវិទ្យាល័យសិន ឬមានការងារល្អសិនពីមុនគិតអំពីរឿងរៀបការ ។ ខ្ញុំពុំបានគិតអំពីរឿងទាំងពីរនោះឡើយ ប៉ុន្តែខ្ញុំបានភ្ជាប់ពាក្យ ។

ខ្ញុំមានចិត្តច្របូកច្របល់ ប៉ុន្តែខ្ញុំចាំអំពីរឿងមួយអំពីប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ១៩១០–២០០៨ ) នៅពេលលោកបានទទួលការហៅបម្រើបេសកកម្មទៅប្រទេសអង់គ្លេស ។ លោកកំពុងរៀបចំខ្លួនចេញទៅបេសកកម្មអំឡុងពេលដែលសេដ្ឋកិច្ចធ្លាក់ចុះ និងមានវិបត្តិ ដែលរំខានដល់លោក ។ ពីមុនលោកបានចាកចេញទៅ ឪពុករបស់លោកបានប្រគល់កាតមួយទៅលោកដោយមានសរសេរពាក្យទាំងនេះ ៖ « កុំខ្លាចអី ឲ្យគ្រាន់តែជឿប៉ុណ្ណោះ » ( ម៉ាកុស ៥:៣៦ ) ។ ខ្ញុំក៏បានចាំអំពីប្រសាសន៍របស់ប៊ីស្សពខ្ញុំ ៖ « ចូរមានជំនឿចុះ ។ ព្រះនឹងប្រទានឲ្យ » ។ ពាក្យទាំងនោះបានផ្ដល់ភាពក្លាហាន និងកម្លាំងឲ្យខ្ញុំដើម្បីបន្តបោះជំហានទៅមុខទៀត ។

ទោះបីជាខ្ញុំមានតែបាតដៃទទេក្ដី ខ្ញុំបានរៀបអាពិហ៍ពិពាហ៍ជាមួយគូដណ្ដឹងជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងព្រះវិហារបរិសុទ្ធ ម៉ានីល ហ្វីលីពីន ។ មិនយូរប៉ុន្មានក្រោយពីរៀបការមក ខ្ញុំចាប់ផ្ដើមធ្វើការឲ្យក្រុមហ៊ុនមួយ ដែលតម្រូវឲ្យខ្ញុំត្រូវធ្វើការនៅថ្ងៃអាទិត្យ ។ ខ្ញុំចង់រក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ដូច្នេះខ្ញុំបានធ្វើការនោះតែមួយរយៈពេលខ្លីប៉ុណ្ណោះ ។ មនុស្សជាច្រើនបានឆ្ងល់ថា ហេតុអ្វីខ្ញុំឈប់ធ្វើការនោះ ប៉ុន្តែខ្ញុំបានបន្តឈានទៅមុខ ដោយនិយាយប្រាប់ខ្លួនខ្ញុំម្ដងហើយម្ដងទៀតថា « ចូរមានជំនឿចុះ ។ ព្រះនឹងប្រទានឲ្យ » ។

ខ្ញុំបានចាប់ផ្ដើមបើកបរឡានដឹកអ្នកដំណើរ ហើយធ្វើការជាភ្នាក់ងារលក់ ដើម្បីផ្គត់ផ្គង់ដល់សេចក្ដីត្រូវការចាំបាច់របស់យើង និងត្រៀមសម្រាប់កំណើតកូនដំបូងរបស់ពួកយើង ។ ភរិយារបស់ខ្ញុំបានឃើញថា ខ្ញុំបានព្យាយាមយ៉ាងខ្លាំងដើម្បីផ្គត់ផ្គង់គ្រួសាររបស់យើង ។ គាត់បានប្រាប់ខ្ញុំថា ខ្ញុំត្រូវត្រឡប់ទៅរៀនវិញ ប៉ុន្តែខ្ញុំគិតថាវានឹងមានការលំបាកដើម្បីធ្វើការផង បម្រើក្នុងសាសនាចក្រផង ព្រមទាំងត្រូវទៅរៀនទៀត ។

ប្រាកដណាស់ វា *ពិតជា* ពិបាកណាស់ ។ ប៉ុន្តែយើងបានកាន់តាមព្រះបញ្ញត្តិទាំងឡាយដោយអស់ពីចិត្តរបស់យើង ។ ជារឿយៗ យើងមានថវិកាតិចតួច ប៉ុន្តែដោយមានជំនួយមកពីមូលនិធិដែលមានជាបន្តបន្ទាប់របស់សាសនាចក្រ នោះខ្ញុំអាចបញ្ចប់ការអប់រំរបស់ខ្ញុំ ពីមុនកូនទីពីររបស់ខ្ញុំកើតមក ។ ខ្ញុំបានធ្វើជាគ្រូបង្រៀននៅវិទ្យាល័យ ហើយទីបំផុតក្លាយជាអ្នកសម្របសម្រួលថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន ។

ការធ្វើតាមដំបូន្មានរបស់ពួកព្យាការី និងថ្នាក់ដឹកនាំផ្សេងទៀតរបស់សាសនាចក្រ បានជួយខ្ញុំឲ្យដឹងថា អាពាហ៍ពិពាហ៍ផ្ដល់ឱកាសដ៏អស្ចារ្យសម្រាប់ការរីកចម្រើនខាងវិញ្ញាណ និងភាពចាស់ទុំ ។ ខ្ញុំមានពរដោយសារអាពាហ៍ពិពាហ៍របស់ខ្ញុំ និងដំណឹងល្អ ។

យើងពុំត្រូវភ័យខ្លាចឡើយ ទោះជាស្ថិតនៅក្នុងកាលៈទេសៈដ៏លំបាកបំផុតក្ដី ។ យើងត្រូវតែធ្វើឲ្យអស់ពីសមត្ថភាពរបស់យើង ហើយចងចាំពាក្យទាំងនេះ ៖ « ចូរមានជំនឿចុះ ។ ព្រះនឹងប្រទានឲ្យ » ។ ■

រីឆាដ អូ អ៊ីស្ពីណូសា ទីក្រុង ថាលីក ប្រទេសហ្វីលីពីន

រូបគំនូរ ដោយ ឆារ៉ូន វីបើក

# បានទទួលការលួងលោម បន្ទាប់ពីរលូតកូន

នៅសប្ដាហ៍ទីដប់ប្រាំបីនៅក្នុងការពរពោះលើកទីបួនរបស់ខ្ញុំ ខ្ញុំបានក្រោកពីដេកដោយមានធ្លាក់ឈាមតិចតួច ។ ខ្ញុំមានអារម្មណ៍ភិតភ័យនៅពេលឈាមនោះហូរពុំឈប់សោះ ដូច្នេះខ្ញុំបានសម្រេចចិត្តទៅបន្ទប់សង្គ្រោះបន្ទាន់ ។

អំឡុងពេលជិះឡានដ៏យូរទៅកាន់មន្ទីរពេទ្យ នោះខ្ញុំបានសង្ឃឹម និងអធិស្ឋានទូលសូមឲ្យអ្វីៗគ្រប់យ៉ាងនឹងគ្មានបញ្ហាអ្វីឡើយ ។ ខ្ញុំបានគិតថា រឿងអាក្រក់បំផុតដែលវេជ្ជបណ្ឌិតនឹងប្រាប់ខ្ញុំនោះគឺឲ្យខ្ញុំសម្រាកនៅលើគ្រែបួនប្រាំថ្ងៃ ។

នៅពេលខ្ញុំត្រូវបានបញ្ជូនទៅដល់មន្ទីរពេទ្យ បុគ្គលិកនៅទីនោះបានធ្វើតេស្តមួយចំនួន ។ ពួកគេបានរកឃើញថា ទារកពុំមានចង្វាក់បេះដូងឡើយ ។ ពួកគេបានធ្វើរោគវិនិច្ឆ័យថា « ទារកស្លាប់ក្នុងផ្ទៃ » ។ មកដល់ចំណុចនេះ វេជ្ជបណ្ឌិតពុំអាចធ្វើអ្វីផ្សេងទៀតបានឡើយ ដូច្នេះគាត់បានឲ្យខ្ញុំចេញពីមន្ទីរពេទ្យវិញ ។

ខ្ញុំបានត្រឡប់ទៅផ្ទះវិញដោយក្រៀមក្រំ និងភ័យខ្លាច ។ ខ្ញុំដេកពុំលក់ឡើយនាយប់នោះ ។ ពេលខ្ញុំភ្ញាក់ពីដំណេកនៅព្រឹកបន្ទាប់ ខ្ញុំទទួលការបំផុសគំនិតឲ្យទៅពិធីអំណោយទានពិសិដ្ឋនៅព្រះវិហារបរិសុទ្ធវគ្គពេលព្រឹកព្រលឹម ។

នៅពេលជិតចុងបញ្ចប់នៃវគ្គនោះ ខ្ញុំបានសម្លឹងមើលដោយយកចិត្តទុកដាក់លើចិញ្ចៀនអាពាហ៍ពិពាហ៍ និងចិញ្ចៀនភ្ជាប់ពាក្យដែលពាក់នៅដៃនាងរបស់ខ្ញុំ ។ វាគឺជាចិញ្ចៀនរបស់ជីដូនទួតរបស់ខ្ញុំ ដែលខ្ញុំដាក់ឈ្មោះដូចគាត់ ។ គាត់បានចែកឋានទៅកាលខ្ញុំអាយុប្រាំឆ្នាំ ហើយថ្មីៗនេះខ្ញុំបានអានរឿងរបស់គាត់ ។ ខ្ញុំចាំថា គាត់បានធ្លាប់ជួបនូវការរលូតកូនជាច្រើនដង កាលគាត់មានអាយុខ្ទង់ ២០ ឆ្នាំជាង ។

ពេញមួយព្រឹក ខ្ញុំអត់ទ្រាំពុំយំ ដោយសារតែភាពក្រៀមក្រំ និងក្ដីភ័យខ្លាចនោះ ប៉ុន្តែនៅក្នុងគ្រានោះ ខ្ញុំមានអារម្មណ៍នៃភាពសុខសាន្តយ៉ាងខ្លាំង ។ ខ្ញុំទទួលអារម្មណ៍នៃការលួងលោម ។ ជីដូនទួតខ្ញុំបានចែកឋានទៅដោយជួបនូវការសាកល្បងស្រដៀងគ្នានេះនៅក្នុងជីវិតគាត់ ហើយព្រះអង្គសង្គ្រោះបានជួយគាត់ ។ ខ្ញុំទទួលអារម្មណ៍បញ្ជាក់ថា ទ្រង់នឹងជួយខ្ញុំផងដែរ ។

« ទ្រង់នឹងដាក់លើរូបអង្គទ្រង់នូវជំងឺឈឺចាប់របស់ពួកគេ ដើម្បីឲ្យព្រះហឫទ័យទ្រង់បានពោរពេញទៅដោយសេចក្ដីមេត្តាករុណាស្របតាមសាច់ឈាម ដើម្បីទ្រង់អាចដឹងស្របតាមសាច់ឈាមថាតើត្រូវជួយរាស្ត្រទ្រង់បែបណាតាមជំងឺរបស់គេ » ( អាលម៉ា ៧:១២ ) ។

ខ្ញុំមានអំណរគុណយ៉ាងជ្រាលជ្រៅ សម្រាប់ភាពសុខសាន្តដែលកើតមានមកពីការចូលរួមព្រះវិហារបរិសុទ្ធ សម្រាប់កេរដំណែលនៃដូនតាដ៏ស្មោះត្រង់ និងកាន់តែសំខាន់បំផុតនោះគឺមានអំណរគុណសម្រាប់ពលិកម្មដ៏ធួនរបស់ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ។ ■

អ៊ីមីលី មីលើ រដ្ឋ តិចសាស ស.រ.អា.

ចិញ្ចៀនអាពាហ៍ពិពាហ៍ និងចិញ្ចៀនភ្ជាប់ពាក្យរបស់ខ្ញុំគឺជារបស់ជីដូនទួតខ្ញុំ ។ ខ្ញុំចាំថា គាត់បានធ្លាប់ជួបនូវការរលូតកូនជាច្រើនដង ។



រូបគំនូរដោយ អេលែន ហ្គាសដ៍

# ការផ្ដល់ជំនិះ និងការចែកចាយដំណឹងល្អ

ការបើកឡានឆ្លងកាត់ទីជនបទនៅក្នុងប្រទេសអង់គ្លេសមានភាពស្ងប់ស្ងាត់ និងសុខសាន្ត ពេលខ្ញុំបើកឡានទៅព្រះវិហារនាព្រឹកថ្ងៃអាទិត្យមួយ ។ នៅតាមផ្លូវខ្ញុំបានឃើញស្ត្រីចំណាស់ម្នាក់នៅលើចិញ្ចើមផ្លូវ ។ ខ្ញុំត្រូវសម្រេចចិត្តភ្លាមៗថាត្រូវឈប់ឡានឬអត់ ហើយចង់ដឹងថាតើគាត់ត្រូវការយានជំនិះដែរឬអត់ ។

ខ្ញុំមានអារម្មណ៍ថាខ្ញុំគួរតែឈប់ឡាន ។ គាត់បានប្រាប់ខ្ញុំថា គាត់ឈ្មោះម៉ារី ហើយគាត់ទើបតែមកដល់ទីនោះ ។ ខ្ញុំបានដឹងថា ប្រសិនបើគាត់មកយឺតជាងនេះបន្តិច ឬបើខ្ញុំមកលឿនជាងនោះបន្តិចនោះ យើងពុំបានជួបគ្នាឡើយ ។ វាចំពេលគ្នាតែម្ដង ។

គាត់បានប្រាប់ខ្ញុំពីកន្លែងដែលគាត់ត្រូវទៅ ហើយវានៅជិតសាលាជំនុំ ។ ខ្ញុំបាននិយាយថា ខ្ញុំកំពុងធ្វើដំណើរទៅព្រះវិហារ ហើយបានសួរគាត់ប្រសិនបើគាត់ធ្លាប់ឮពីព្រះវិហារ ។ គាត់បាននិយាយថា គាត់មានសេចក្ដីជំនឿលើព្រះអង្គសង្គ្រោះ ប៉ុន្តែគាត់បានដឹងតិចតួចណាស់អំពីពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ នៅតាមផ្លូវខ្ញុំបានចែកចាយដំណឹងល្អជាមួយគាត់ ។

នៅពេលខ្ញុំដាក់ម៉ារីចុះ ខ្ញុំបាននិយាយថា ខ្ញុំអាចដឹកគាត់ម្ដងទៀតបាននៅពេលព្រះវិហារចប់ ។ គាត់បានទទួលយកការស្នើសុំនោះ ហើយយើងបានណាត់ជួបគ្នានៅសាលាជំនុំ ។ នៅពេលខ្ញុំដើរចូលទៅព្រះវិហារ ខ្ញុំបានជួបអ្នកផ្សព្វផ្សាយសាសនា ហើយបានសូមព្រះគម្ពីរមរមនមួយក្បាលពីពួកគេ ឲ្យទៅមិត្តភក្ដិថ្មីរបស់ខ្ញុំនោះ ។ ក្រោយមក ពេលគាត់មកដល់សាលាប្រជុំ សមាជិកមានភាពរួសរាយរាក់ទាក់ ហើយបានចែកចាយទីបន្ទាល់ពួកគេជាមួយគាត់ ។

នៅពេលជិះឡានត្រឡប់ទៅវិញ ខ្ញុំបានប្រាប់ម៉ារីថា គាត់អាចរៀនបន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទតាមរយៈការអានព្រះគម្ពីរមរមន ។ ខ្ញុំក៏បានប្រាប់គាត់អំពីកន្លែងដែលគាត់ អាចអានដំណើររឿងនៃការបង្ហាញព្រះកាយរបស់អង្គសង្គ្រោះដល់ពួកសាសន៍នីហ្វៃ ។ ទោះបីជាបទពិសោធន៍ដែលគាត់មានជាមួយពួកបរិសុទ្ធថ្ងៃចុងក្រោយមានរយៈពេលខ្លីក្ដី ខ្ញុំដឹងថាគាត់បានទទួលអារម្មណ៍អំពីអ្វីមួយ ។ ខ្ញុំបានដាក់ម៉ារីចុះនៅកន្លែងដដែលដែលយើងជួបគ្នា ។ ខ្ញុំមិនរំពឹងថាជួបគាត់ម្ដងទៀតឡើយ ។

ពេលខ្ញុំកំពុងបើកឡានចេញពីធ្វើការត្រឡប់ទៅផ្ទះវិញនាថ្ងៃបន្ទាប់ ខ្ញុំត្រូវបើកលើផ្លូវវាងមួយដែលខ្ញុំពុំធ្លាប់ធ្វើដំណើរពីមុន ។ ខ្ញុំភ្ញាក់ផ្អើលណាស់ ដោយបានឃើញម៉ារីម្ដងទៀត ! ពេលគាត់បានឃើញខ្ញុំ គាត់បានញញឹមដាក់ខ្ញុំ ។ ខ្ញុំរីករាយនឹងដឹកគាត់ម្ដងទៀត ។

ខ្ញុំលែងបានជួបម៉ារីតាំងពីពេលនោះមក ប៉ុន្តែពេលខ្ញុំចាំអំពីបទពិសោធន៍នោះ ខ្ញុំមានអំណរគុណចំពោះព្រះអម្ចាស់ដែលបានប្រទានឱកាសដល់ខ្ញុំ ឲ្យចែកចាយដំណឹងល្អ ។ ខ្ញុំដឹងថាព្រះអម្ចាស់ប្រទានពរដល់ពួកយើង ទៅតាមពេលវេលាដ៏ឥតខ្ចោះរបស់ទ្រង់ ។ ■

ម៉ៃយែល យើរ៉ាន់ ទីក្រុង ហ្វូធៃស្មើរ ប្រទេសអង់គ្លេស

ខ្ញុំបានដឹងថា ប្រសិនបើគាត់មកយឺតជាងនេះបន្តិច ឬបើខ្ញុំមកលឿនជាងនោះបន្តិចនោះ យើងពុំបានជួបគ្នាឡើយ ។




រចនារូបភាពដោយ អាឡែន ប៉ែកយើរ ។

# ទេវតាបាននាំពន្លឺមកកាន់ផ្ទះរបស់ខ្ញុំ

នាព្រឹកថ្ងៃអាទិត្យមួយ ខ្ញុំត្រូវបានសួរប្រសិនបើខ្ញុំចង់ឲ្យគ្រូបង្រៀនតាមផ្ទះមកជួបខ្ញុំឬទេ ។ ថ្មីៗនេះ ខ្ញុំទើបតែលែងលះគ្នា ហើយមានការលំបាកក្នុងការប្រឈមមុខនឹងជីវិតថ្មីរបស់ខ្ញុំ ក្នុងនាមជាម្ដាយទោលដែលមានកូនតូចៗពីរនាក់ ។ ខ្ញុំបាននិយាយថា ខ្ញុំនឹងមានអំណរគុណប្រសិនបើមានគេមកសួរសុខទុក្ខ ។ នៅពេលនោះ ខ្ញុំកំពុងមានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំងអំពីស្ថានភាពរបស់ខ្ញុំ ហើយមានអារម្មណ៍ឯកោនៅក្នុងការពុះពាររបស់ខ្ញុំ ។

នៅសប្ដាហ៍បន្ទាប់មក បងប្អូនប្រុសដ៏ល្អពីរនាក់បានមកផ្ទះរបស់ខ្ញុំ ។ អំឡុងពេលនៃការសួរសុខទុក្ខនោះ ពួកគេបានសួរសំណួរសាមញ្ញៗ ហើយចែកចាយសារលិខិតដំណឹងល្អខ្លីមួយជាមួយគ្រួសារខ្ញុំ ។

ក្រោយមកបងប្អូនប្រុសដ៏ល្អទាំងនេះបានសួរថា « បងស្រី នើរៀដា តើមានអ្វីដែលពួកខ្ញុំអាចជួយបងបានទេ ? »

ដោយពុំបានគិតច្រើនអំពីសំណួរនោះ ខ្ញុំបានប្រាប់ពួកគេអំពីអំពូលភ្លើងដាច់នៅខាងលើជណ្ដើរដែលឡើងទៅជាន់ទីរពីរ ។ ខ្ញុំមានអំពូលភ្លើងនោះហើយ ប៉ុន្តែខ្ញុំពុំអាចឈោងដៃដល់ដើម្បីប្ដូរវាបានឡើយ ហើយខ្ញុំបារម្ភក្នុងការប្រើជណ្ដើរបត់ដាក់ពីលើកាំជណ្ដើរ ។ ខ្ញុំក៏បានប្រាប់ពួកគេថា នៅរានហាលខាងក្រោយផ្ទះគ្មានអំពូលភ្លើងទេ ។

ពួកគេបានទៅភ្លាម ។ មានបងប្រុសម្នាក់បានចេញទៅកាន់ឡានរបស់គាត់ ហើយត្រឡប់មកវិញដោយមានកាន់ប្រអប់ឧបករណ៍មកជាមួយ ។ គាត់មានកម្ពស់ជិត ១.៩ ម៉ែត្រ ដូច្នេះគាត់បានឡើងជណ្ដើរ ហើយប្ដូរអំពូលភ្លើងដោយគ្មានបញ្ហាអ្វីឡើយ ។ នៅក្នុងពេលដំណាលគ្នានោះ ដៃគូរបស់គាត់បានទៅរានហាលខាងក្រោយផ្ទះ ហើយបានឃើញថាខ្សែភ្លើងបានតផ្ដុំយគ្នា ។ គាត់បានជួសជុលវាក្នុងរយៈពេលដ៏ខ្លីបំផុត ។

ច្រើនឆ្នាំមកនេះ ខ្ញុំមានអំណរគុណយ៉ាងខ្លាំងដល់គ្រូបង្រៀនតាមផ្ទះរបស់ខ្ញុំ ចំពោះទង្វើសាមញ្ញៗរបស់ពួកគេ ដូចជាសេចក្ដីសប្បុរស សេចក្ដីស្រឡាញ់ និងការលះបង់ និងមេរៀនដ៏អស្ចារ្យដែលពួកគេបានបង្រៀនខ្ញុំ ។ គ្រូបង្រៀនតាមផ្ទះរបស់ខ្ញុំគឺជាទេវតាពិតៗ ដែលពុំគ្រាន់តែនាំពន្លឺមកកាន់ផ្ទះរបស់ខ្ញុំប៉ុណ្ណោះទេ តែថែមទាំងបាននាំភាពសុខសាន្តសេចក្ដីសង្ឃឹម និងសុវត្ថិភាពនៃដំណឹងល្អ ដែលនាំពន្លឺមកកាន់ទីងងឹតគ្រប់បែបយ៉ាងផងដែរ ។ ■

នើរៀដា សាន់តាហ្វេ ហ្រ្គេន ការ៉ាកាស ប្រទេសវ៉េនេហ្ស៊ូអេឡា



# ដំណឹងតែមួយគត់ដែលបាន
# សង្គ្រោះខ្ញុំ

**ដោយ ស្សឹហូ តាកាយ៉ាម៉ា បានប្រាប់ដល់ អាណាលីសា ក្លាក ម៉ូឡិន**

> **មិត្តភាពដែលពុំបានរំពឹងទុកមួយ បានជួយខ្ញុំឲ្យផ្លាស់ប្តូរជីវិតខ្ញុំពីភាពអន្ធការមកឯពន្លឺ ។**

កីឡាវាយកូនហ្គោលគឺជាកីឡាពេញនិយមនៅក្នុងប្រទេសជប៉ុន ដូច្នេះខ្ញុំបានចាប់ផ្តើមលេងវាតាំងពីខ្ញុំអាយុ ១៤ ឆ្នាំ ដែលជារបៀបមួយដើម្បីចំណាយពេលជាមួយឪពុករបស់ខ្ញុំ ។ វាសប្បាយណាស់តាំងពីចាប់ផ្តើមដំបូង ហើយទីបំផុតខ្ញុំបានចាប់ផ្តើមអនុវត្តដោយខ្លួនឯងផ្ទាល់ ហើយលេងនៅក្នុងក្រុមកីឡាវាយកូនហ្គោលនៅវិទ្យាល័យរបស់ខ្ញុំ ។ ខ្ញុំបានក្លាយជាមិត្តជាមួយកីឡាកររួមក្រុម និងគ្រូបង្វឹករបស់ខ្ញុំ ដែលពួកគេបានលើកទឹកចិត្តខ្ញុំឲ្យចាប់យកក្តីសុបិនរបស់ខ្ញុំក្នុងការក្លាយជាកីឡាករវាយកូនហ្គោលអាជីព ។

ខ្ញុំបានខិតខំយ៉ាងខ្លាំង ដែលពុំគ្រាន់តែខំក្នុងការលេងកីឡារបស់ខ្ញុំនោះទេ ថែមទាំងខំនៅក្នុងការសិក្សារបស់ខ្ញុំផងដែរ ខ្ញុំបានបញ្ចប់ការសិក្សាជាសិស្សឆ្នើមក្នុងវិទ្យាល័យ ។

ពេលដំបូងដែលខ្ញុំចូលរៀនមហាវិទ្យាល័យ ខ្ញុំមានទំនាក់ទំនងយ៉ាងល្អជាមួយគ្រូបង្វឹកកីឡាវាយកូនហ្គោល និងកីឡាកររួមក្រុមរបស់ខ្ញុំ ។ ពួកគេលេងបានល្អជាងខ្ញុំ ដូច្នេះខ្ញុំខិតខំគ្រប់បែបយ៉ាងដើម្បីលេងឲ្យបានពូកែដូចពួកគេ ។ សមាជិកក្រុមមួយចំនួនបានរិះគន់ជាពិសេសអំពីឈ្មោះ ស្សឹហូ ដែលជាឈ្មោះរបស់ខ្ញុំ ។ ខ្ញុំបានប្រាប់ពួកគេថា ជីដូនខាងម្តាយខ្ញុំជនជាតិកូរ៉េ បានដាក់ឈ្មោះនេះឲ្យខ្ញុំ ហើយជាភាសាកូរ៉េ វាមានន័យថា « ភ្នំដ៏ស្រស់ស្អាត » ។ ចាប់តាំងពីពេលនោះមក ខ្ញុំមានអារម្មណ៍ថា ឥរិយាបថរបស់ពួកគេមកលើរូបខ្ញុំបានផ្លាស់ប្តូរ ដែលវាជះឥទ្ធិពលមកពីសម្ពាធដ៏យូរអង្វែងរវាងប្រជាជនជប៉ុន និងកូរ៉េ ។

ពួកគេបានចាប់ផ្តើមហៅខ្ញុំថា « អាក្មេងកូរ៉េ » ហើយពួកគេបាននិយាយថាខ្ញុំនឹងធ្វើឲ្យកេរ្តិ៍ឈ្មោះដ៏ល្អរបស់សាកលវិទ្យាល័យអាប់ឱន ។ ពួកគេបានឲ្យខ្ញុំសម្អាតបង្គន់ដោយមិនឲ្យខ្ញុំហាត់សមវាយកូនហ្គោលជាមួយពួកគេឡើយ ។

ខ្ញុំកាន់តែមានអារម្មណ៍តានតឹងដើម្បីនៅក្នុងក្រុមនោះ ។ ការនៅឆ្ងាយពីផ្ទះ ធ្វើឲ្យខ្ញុំមានអារម្មណ៍ថាខ្ញុំនៅឯកោ ។ ខ្ញុំបានព្យាយាមបន្តចាប់យកក្តីសុបិនខ្ញុំ ហើយបានធ្វើឲ្យគ្រូបង្វឹក និងក្រុមរបស់ខ្ញុំពេញចិត្តខ្ញុំឡើងវិញ ប៉ុន្តែពីរឆ្នាំក្រោយមក ខ្ញុំពុំអាចអត់ធ្មត់នឹងការប្រព្រឹត្តិដ៏ឃោរឃៅរបស់ពួកគេតទៅទៀតឡើយ ដូច្នេះខ្ញុំបានត្រឡប់ទៅផ្ទះវិញ ។

នេះជាគ្រាដ៏អាប់អួរមួយសម្រាប់ខ្ញុំ ។ ភាពតានតឹងផ្លូវចិត្តនោះបានជះឥទ្ធិពលលើសតិអារម្មណ៍ និងរូបកាយរបស់ខ្ញុំ ។ ការបំបាក់តម្លៃខ្លួនឯងអស់រយៈពេលពីរឆ្នាំ ។ ក្តីសុបិនរបស់ខ្ញុំក្នុងការក្លាយជាកីឡាករវាយកូនហ្គោលអាជីពនោះបានបញ្ចប់ហើយ ។ ខ្ញុំពុំដឹងថាត្រូវធ្វើអ្វីនោះឡើយ ។ ហើយខ្ញុំមានកំហឹង ។ ខ្ញុំខឹងនឹងមនុស្សគ្រប់គ្នា ៖ គ្រូបង្វឹក កីឡាកររួមក្រុម និងឪពុកម្តាយខ្ញុំ ។ ខ្ញុំបានខឹងយ៉ាងខ្លាំង គំនិតនានាក្នុងខ្លួនខ្ញុំបានធ្វើឲ្យខ្ញុំភ័យខ្លាចនឹងខ្លួនឯង ។ ខ្ញុំគ្មានមិត្តភក្តិឡើយ ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំពុំអាចទុកចិត្ត ឬទាក់ទងជាមួយមនុស្សផ្សេងឡើយ ។ អស់រយៈពេលប្រាំមួយខែ ខ្ញុំគ្រាន់តែចេញពីផ្ទះដើម្បីហាត់ប្រាណនៅក្លឹបហាត់ប្រាណប៉ុណ្ណោះ ។

អំឡុងពេលដ៏អាប់អួរក្នុងជីវិតខ្ញុំនេះ ខ្ញុំបានរាប់អាន ចាស្ទីន គ្រីស្ទី ជាអ្នកដែលខ្ញុំជួបនៅក្លឹបហាត់ប្រាណ ។ គ្រាដំបូងដែលខ្ញុំបានជួបគាត់ ខ្ញុំបានគិតថាគាត់គឺជានិស្សិតបរទេសដែលចុះកម្មសិក្សា ។ ខ្ញុំស្ទាក់ស្ទើរមិនហ៊ាននិយាយជាមួយគាត់ឡើយ រហូតដល់ខ្ញុំបានឃើញគាត់និយាយជាមួយគេនៅក្លឹបហាត់ប្រាណនោះ ហើយដោយក្តីភ្ញាក់ផ្អើលគឺថាគាត់ចេះនិយាយភាសាជប៉ុន ។ ខ្ញុំនៅតែមានអារម្មណ៍ថាពុំអាចទុកចិត្តមនុស្សផ្សេងឡើយ ប៉ុន្តែ



គាត់បានផ្ដល់យោបល់ថា យើងហ្វឹកហ្វាត់ជាមួយគ្នា ។ មានអ្វីមួយដែលចម្លែកអំពីគាត់ដែលខ្ញុំពុំយល់នៅគ្រានោះឡើយ ។ ខ្ញុំមានអារម្មណ៍ស្ងប់ចិត្ត នៅពេលខ្ញុំនៅជិតគាត់ ។ ខ្ញុំបានចាប់ផ្ដើមទន្ទឹងចាំដល់ម៉ោងហ្វឹកហ្វាត់ជាមួយគ្នា ។ ខ្ញុំបានរកឃើញមនុស្សម្នាក់ដែលខ្ញុំមានអារម្មណ៍ថាអាចទុកចិត្តធ្វើជាមិត្តភក្ដិម្នាក់ ។

បន្ទាប់ពីការហ្វឹកហ្វាត់ជាមួយគ្នាអស់ពេលជាច្រើនខែមក ចាស្ទីន បានអញ្ជើញខ្ញុំឲ្យទៅទទួលទានអាហារពេលល្ងាចជាក្រុម ដែលគាត់តែងតែទៅជាប្រចាំ ។ ខ្ញុំមានការស្ទាក់ស្ទើរនឹងទៅ ប៉ុន្តែបន្ទាប់ពីការអញ្ជើញបួនប្រាំដងមក ខ្ញុំបានសម្រេចចិត្តទៅទទួលទានអាហារពេលល្ងាចជាមួយយុវមជ្ឈិមវ័យនៅលីវ នៅផ្ទះរបស់ រីឆាដ និងខរីណា ក្លាក ។ ពួកគេបានទទួលស្វាគមន៍ខ្ញុំដោយក្ដីកក់ក្ដៅពេលខ្ញុំចូលទៅក្នុងផ្ទះរបស់ពួកគេ បងប្រុស ក្លាក ស្វាគមន៍ជាភាសាជប៉ុន ហើយបងស្រី ក្លាក ស្វាគមន៍ជាភាសាអង់គ្លេស ។ ខ្ញុំពុំយល់អ្វីដែលបងស្រី ក្លាក និយាយឡើយ ប៉ុន្តែខ្ញុំព្យាយាមឆ្លើយទៅកាន់គាត់ ។ ទោះបីជាមនុស្សមួយចំនួននៅទីនោះពុំនិយាយភាសាជប៉ុនក្ដី ពួកគេគឺជាក្រុមដែលពេញដោយក្ដីស្រឡាញ់ និងរីករាយ ដែលមានភាពកក់ក្ដៅ និងរួសរាយរាក់ទាក់ ។ ពួកយើងសើចរហូត ។

ខ្ញុំបានចាប់ផ្ដើមចូលរួមសកម្មភាពនានារបស់យុវមជ្ឈិមវ័យនៅលីវផ្សេងទៀត ហើយមានភាពសប្បាយរីករាយយ៉ាងខ្លាំង ដែលពុំធ្លាប់មានពីមុនមកក្នុងជីវិតខ្ញុំឡើយ ។ ខ្ញុំឆ្ងល់ថា តើមានអ្វីទៅដែលធ្វើឲ្យមនុស្សទាំងនេះមានចិត្តល្អ ហើយរួសរាយបែបនេះ ។

អំឡុងពេលនោះ ចាស្ទីនបានសួរខ្ញុំថា តើខ្ញុំគិតចង់ធ្វើអ្វីបន្តទៀតនៅក្នុងជីវិតខ្ញុំ ។ ខ្ញុំភ្ញាក់ផ្អើលណាស់ដោយឃើញថា គោលដៅរបស់ខ្ញុំបានចាប់ផ្ដើមផ្លាស់ប្ដូរ ។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំចង់រៀនឲ្យចេះនិយាយភាសាអង់គ្លេស ហើយខ្ញុំចង់ធ្វើជាមិត្តនឹង

**ខ្ញុំបានសម្រេចចិត្តថា ខ្ញុំចង់ជួយសង្គ្រោះមនុស្ស ដែលស្ថិតនៅក្នុងស្ថានភាពដូចជារូបខ្ញុំ ។**

មនុស្សគ្រប់គ្នា ដូចជាគាត់បានធ្វើ ។ គាត់បានប្រាប់ខ្ញុំអំពីថ្នាក់រៀនភាសាអង់គ្លេសនៅព្រះវិហារដែលរៀនពុំគិតថ្លៃ ។ ខ្ញុំបានទៅរៀនភាសាអង់គ្លេស ហើយបានជួបអ្នកផ្សព្វផ្សាយសាសនា ។ ទោះបីជាខ្ញុំពុំធ្លាប់គិតអំពីព្រះក្ដី ក៏ខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរតែស្ដាប់អ្នកផ្សព្វផ្សាយសាសនា ។ ពួកគេបានបង្រៀនខ្ញុំអំពីមូលដ្ឋានគ្រឹះនៃដំណឹងល្អ ហើយបានទូរសព្ទមករកខ្ញុំស្ទើរតែរាល់ថ្ងៃ ។ ពួកគេបានក្លាយជាមិត្តល្អរបស់ខ្ញុំដែលធ្វើឲ្យខ្ញុំរីករាយយ៉ាងខ្លាំង ដោយសារខ្ញុំពុំទាន់មានមិត្តភក្ដិច្រើននៅឡើយ ។

ខ្ញុំបានចាប់ផ្ដើមជួបសមាជិកជាច្រើននៃសាសនាចក្រ ដែលបានទៅបង្រៀនខ្ញុំជាមួយអ្នកផ្សព្វផ្សាយសាសនា ហើយពួកគេក្លាយជាមិត្តល្អរបស់ខ្ញុំ ។ ពួកគេបានបង្រៀនខ្ញុំអំពីដំណឹងល្អ ហើយបានធ្វើជាគំរូដល់ខ្ញុំ ។ ចាស្ទីនបាននិយាយជាមួយខ្ញុំអំពីព្រះគម្ពីរមរមន ហើយបានប្រាប់ខ្ញុំអំពីរឿងនានាដែលមាននៅក្នុងនោះ ដូច្នេះគាត់ធ្វើឲ្យខ្ញុំចង់អានគម្ពីរនោះដោយខ្លួនឯង ។ មិត្តម្នាក់ឈ្មោះ ស៊្មីនហ្គូ ជាអ្នកដែលពូកែពន្យល់យ៉ាងល្អិតល្អន់ បានពិភាក្សាគោលលទ្ធិនានាជាមួយខ្ញុំ តាមរបៀបមួយដែលធ្វើឲ្យខ្ញុំងាយយល់ ។ គាត់តែងតែថ្លែងទីបន្ទាល់របស់គាត់នៅពេលយើងពិភាក្សាគ្នាចប់ ។

ខ្ញុំបានរកឃើញអ្វីដែលខ្ញុំបានជឿ និងកន្លែងដែលខ្ញុំមានអារម្មណ៍ថា ជាកន្លែងរបស់ខ្ញុំ ។ បន្ទាប់ពីខ្ញុំបានទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់មក ខ្ញុំបានចាប់ផ្ដើមគិតអំពីការបម្រើបេសកកម្ម ប៉ុន្តែខ្ញុំបារម្ភអំពីការលះបង់សម្រាប់រយៈពេលពីរឆ្នាំនោះ ។ ខ្ញុំបាននិយាយជាមួយមនុស្សជាច្រើន អំពីការបម្រើបេសកកម្ម ជាពិសេសជាមួយមិត្តភក្ដិរបស់ខ្ញុំ ដែលជាអ្នកត្រឡប់មកពីបេសកកម្ម ។ ខ្ញុំបានគិតច្រើនអំពីរឿងនោះ ហើយខ្ញុំបានដឹងថា ដំណឹងល្អគឺជាដំណឹងតែមួយគត់ដែលអាចសង្គ្រោះខ្ញុំបាន ។

ខ្ញុំដឹងថា ព្រះបានប្រទានអ្វីៗគ្រប់យ៉ាងដល់ខ្ញុំ ៖ ក្ដីសុបិន ក្ដីសង្ឃឹម មិត្តភក្ដិ ហើយជាពិសេសគឺសេចក្ដីស្រឡាញ់ ។ ដំណឹងល្អបានជួយខ្ញុំចេញពីភាពអន្ធការទៅរកពន្លឺ ។ ■

*ជាអ្នកនិពន្ធរស់នៅក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន ។*



**ធ្វើជាគំរូ**

« យើងម្នាក់ៗមកកាន់ផែនដីនេះ ដោយត្រូវបានផ្ដល់ឲ្យនូវពន្លឺព្រះគ្រីស្ទ ។ នៅពេលយើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ហើយរស់នៅដូចដែលទ្រង់បានរស់នៅ និងដូចដែលទ្រង់បានបង្រៀន ពន្លឺនោះនឹងបំភ្លឺក្នុងខ្លួនយើង ហើយនឹងបំភ្លឺផ្លូវអ្នកដទៃ ។ . . .

ខ្ញុំជឿថាអ្នកដែលទទួលឥទ្ធិពលរបស់យើង គឺជាអ្នកដែលឯកោ អ្នកឈឺ និងអ្នកដែលមានអារម្មណ៍បាក់ទឹកចិត្ត ។ យើងមានឱកាសដើម្បីជួយពួកគេ ហើយលើកវិញ្ញាណគេឡើង » ។

ប្រធាន ថូម៉ាស អេស ម៉នសុន « **Be an Example and a Light** » ***Liahona,*** ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៨៦ ។



## របៀបដែលខ្ញុំចែកចាយដំណឹងល្អជាមួយស្ស៊ូហូ

ដោយ ចាស្ទីន គ្រីស្ទី

នៅពេលខ្ញុំបានជួបស្ស៊ូហូនៅក្លឹបហាត់ប្រាណ គាត់បាននិយាយថា គាត់ចង់រៀនភាសាអង់គ្លេស ហើយនឹងទៅកម្មវិធីកីឡាវាយកូនហ្គោលនៅក្រៅប្រទេស ។ ខ្ញុំបានប្រាប់គាត់អំពីថ្នាក់ភាសាអង់គ្លេសនៅព្រះវិហារ ប៉ុន្តែវាចំណាយពេលជាច្រើនសប្ដាហ៍ពីមុនយើងអាចចូលរៀនថ្នាក់នោះបាន ។ ក្នុងពេលដំណាលគ្នានោះ នៅពេលយើងហាត់ប្រាណជាមួយគ្នា នោះយើងបានពិភាក្សាគ្នាយ៉ាងច្រើន អំពីប្រធានបទនានានៃដំណឹងល្អ អំពីព្រះគម្ពីរមរមន និងអំពីភាពទូទៅនៃជីវិត ។

មិត្តភាព និងគំរូល្អៗរបស់សមាជិកគ្រួសារដែលគាត់បានជួប បានធ្វើឲ្យគាត់ចាប់អារម្មណ៍ ហើយបានជួយគាត់រៀនដំណឹងល្អ ។ ព្រះវិញ្ញាណបានដឹកនាំឲ្យមានការប្រែចិត្តជឿ អ្វីដែលយើងត្រូវធ្វើនោះគឺត្រូវចែកចាយសារលិខិត ហើយគាំទ្រមនុស្ស នៅពេលពួកគេជ្រើសរើសដោយខ្លួនពួកគេ ។

ខ្ញុំធ្លាប់មានភាពតានតឹងក្នុងចិត្ត នៅពេលគិតអំពីការចែកចាយដំណឹងល្អ ។ ប៉ុន្តែខ្ញុំបានឃើញថា ប្រសិនបើយើងគ្រាន់តែបើកមាត់នៅចំពេលដែលត្រឹមត្រូវ នោះយើងនឹងមានឱកាសផ្សព្វផ្សាយសាសនាបាន ។ អ្វីដែលយើងត្រូវធ្វើនោះគឺត្រូវអញ្ជើញមនុស្សឲ្យមកសកម្មភាព ឬ ការប្រជុំនៅព្រះវិហារ ។ ប្រសិនបើយើងបើកដួងចិត្តរបស់យើង នោះនឹងមានឱកាសជាច្រើនដើម្បីចែកចាយដំណឹងល្អ ។ ■

# ការដើរតួក្នុង ឈុតដ៏សំខាន់បំផុត

ដោយ អាននី ម៉ាក់ខរមីក បូននើរ

ការសម្ដែងដោយផ្ទាល់គឺជាបំណងប្រាថ្នារបស់ខ្ញុំ ! ក្នុងនាមជាយុវមជ្ឈិមវ័យ ខ្ញុំមានចិត្តរំភើបក្នុងការសម្ដែង និងច្រៀងនៅលើឆាក ។ ខ្ញុំបានទទួលពរដោយមានទេពកោសល្យ ហើយសង្ឃឹមថាបង្កើតមុខរបរជាអ្នកសម្ដែងអាជីព ។ ខ្ញុំមានជោគជ័យលើការដើរតួសម្ដែងរឿងដែលលំបាកៗបំផុត ហើយខ្ញុំតែងតែកាន់យកកិរិយាមាយាទដែលមានវិជ្ជាជីវៈ ដើម្បីទទួលបានការគោរពពីបងប្អូនសិល្បៈករ ។

ខ្ញុំមានចិត្តរំភើបយ៉ាងខ្លាំង ពេលចាងហ្វាងផលិតកម្មដ៏មានឥទ្ធិពលនៅក្នុងតំបន់របស់យើងបានប្រាប់ខ្ញុំថា គាត់នឹងមានការរើសសិល្បៈករម្នាក់ ហើយគាត់ចង់ឲ្យខ្ញុំសាកល្បងសម្ដែង ។ ការសម្ដែងនោះនឹងត្រូវបានធ្វើឡើងនៅក្នុងទីតាំងដ៏មានកិត្យានុភាពបំផុតនៅក្នុងតំបន់របស់យើង ហើយថាមិត្តភក្តិចាងហ្វាងផលិតកម្មរបស់ខ្ញុំហាក់ដូចជាបានគិតរើសយកខ្ញុំរួចទៅហើយនៅក្នុងចិត្តគាត់ ដើម្បីឲ្យខ្ញុំធ្វើជាតួសម្ដែងសំខាន់ ។

គ្មានអត្ថបទសាច់រឿងដើម្បីអានពីមុនការសម្ដែងរើសសិល្បៈករឡើយ ប៉ុន្តែល្ខោននោះផ្អែកលើរឿងប្រលោមលោកមួយដែលនិពន្ធដោយទស្សនវិទូកាលសតវត្សរ៍ទី ១៨ ដែលខ្ញុំបានអាន ។ ខ្ញុំក៏បានស្គាល់ច្បាស់នូវតន្ត្រីនៃការសម្ដែងនោះ ដែលវាជាតន្ត្រីដ៏ពីរោះអស្ចារ្យ និងគួរឲ្យរំភើប ។

ការសម្ដែងបានប្រព្រឹត្តទៅយ៉ាងល្អ ហើយភ្លាមនោះខ្ញុំត្រូវបានប្រាប់ឲ្យដឹងថានឹងត្រូវសម្ដែងជាតួសំខាន់ — គឺឈុតដ៏សំខាន់បំផុត — នោះ ! ខ្ញុំបានជឿជាក់ថាតួសម្ដែងនេះគឺជាឱកាសដ៏ធំធេងមួយ ។

ខ្ញុំមានចិត្តរំភើបពន់ពេក — រហូតដល់ទទួលបានអត្ថបទសាច់រឿងនោះ ។ នៅពេលខ្ញុំអានអត្ថបទសាច់រឿងនោះ ក្ដីរីករាយរបស់ខ្ញុំបានរលាយបាត់អស់មួយរំពេច ។ រឿងប្រលោមលោក និងតន្ត្រីមានភាពសមរម្យ ប៉ុន្តែអត្ថបទសាច់រឿងនោះមិនគួរឲ្យគោរព ហើយមាននូវការផ្ដល់យោបល់ និងការដឹកនាំឲ្យសម្ដែងនៅលើឆាកដែលមិនសមរម្យ ។ ខ្ញុំបានដឹងថា ខ្ញុំពុំគួរចូលរួមនឹងផលិតកម្មនេះទេ ។ វាជាការខកចិត្តដ៏ខ្លាំងបំផុត ។

រំពេចនោះ ខ្ញុំខ្វល់ខ្វាយក្នុងចិត្តយ៉ាងខ្លាំង ។ វិន័យរបស់រោងភាពយន្តចែងថា បន្ទាប់ពីទទួលយកតួហើយ នោះតួសម្ដែងពុំត្រូវឈប់ ដោយសារតែកាលវិភាគរបស់ផលិតកម្ម ពុំផ្ដល់ពេលវេលាផ្លាស់ប្ដូរនានានៅក្នុងក្រុមសម្ដែងឡើយ ។ ការឈប់ក្នុងពេលនេះនឹងត្រូវបានចាត់ទុកថាគ្មានវិជ្ជាជីវៈឡើយ ។ ខ្ញុំខ្លាចថាបាត់បង់ការទុកចិត្តពីក្រុមហ៊ុនល្ខោន ធ្វើឲ្យចាងហ្វាងផលិតកម្មអាក់អន់ចិត្ត ហើយថែមទាំងបាត់បង់ឱកាសបន្តសម្ដែងនៅកន្លែងផ្សេងៗទៀត ។

ប្រាកដណាស់ខ្ញុំត្រូវបានល្បួងឲ្យដោះសារ ! មានសំឡេងមួយបន្លឺមកក្នុងចិត្តខ្ញុំថា « អ្នកមិនត្រូវឈប់ក្នុងពេលនេះឡើយ ។ អត្ថបទសាច់រឿងនោះពុំអាក្រក់ណាស់ណាទេ ។ ឈុតដែលល្អនៅក្នុងល្ខោននោះនឹងប៉ះប៉ូវឈុតដែលមិនសូវល្អនោះហើយ » ។ ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធតែងមានឥទ្ធិពលលើដួងចិត្តខ្ញុំជានិច្ច — ដោយរឹងប៉ឹង អត់ធ្មត់ ជំរុញខ្ញុំយ៉ាងខ្ជាប់ខ្ជួនថា ខ្ញុំត្រូវចាកចេញពីការសម្ដែងល្ខោននេះ ។

**ខ្ញុំទើបតែបានទទួលភារៈកិច្ចដ៏ធំបំផុតនៅក្នុងជីវិតខ្ញុំ ។ ខ្ញុំមានចិត្តរំភើប — រហូតដល់ពេលទទួលបានប្រប៉ូលអត្ថបទសាច់រឿង ។**

រូបថតអាគី GETTY IMAGES

ខ្ញុំបានដឹងនូវអ្វីដែលខ្ញុំត្រូវធ្វើ ។ ដោយក្ដីញាប់ញ័រ ខ្ញុំបានចាប់យកទូរសព្ទ ហើយវាយលេខទូរសព្ទទៅលោកចាងហ្វាងផលិតកម្ម ។

នៅពេលលោកបានឆ្លើយទូរសព្ទ ខ្ញុំបាននិយាយថា « ជំរាបសួរ លោក ខ្ញុំគឺអាននី » ។

« អាននី ! ខ្ញុំរីករាយចិត្តចំពោះការសម្ដែងណាស់ ។ តើអ្នកបានទទួលអត្ថបទសាច់រឿងហើយឬនៅ ? »

« ចាស ខ្ញុំបានទទួលហើយ ហើយខ្ញុំ . . . ខ្ញុំ . . . »

ខ្ញុំបានចាប់ផ្ដើមយំ ។ និយាយអំពីភាពពុំមែនជាអ្នកមានវិជ្ជាជីវៈ !

ទោះជាយ៉ាងណាក្ដី ខ្ញុំបានរៀបរាប់ពន្យល់ដល់លោកចាងហ្វាងផលិតកម្មអំពីមូលហេតុដែលខ្ញុំពុំអាចចូលរួមសម្ដែងក្នុងល្ខោនរបស់គាត់ទាំងទឹកភ្នែក ។ ហើយក្រោយមកខ្ញុំបានរង់ចាំទទួលលទ្ធផលអាក្រក់ដែលនឹងអាចកើតឡើង ។

លោកចាងហ្វាងនោះបានសើច ។ គាត់បានគោរពដល់ជម្រើសរបស់ខ្ញុំ ។ ដំបូងគាត់បានព្យាយាមនិយាយជាមួយខ្ញុំ ឲ្យបន្តសម្ដែងទៀត ប៉ុន្តែគាត់បានឈប់ព្យាយាមវិញ ។ គាត់បាននិយាយថា គាត់នៅតែចូលចិត្តខ្ញុំទោះបីជាខ្ញុំពុំចង់ចូលរួមសម្ដែងក្នុងល្ខោនរបស់គាត់ក្ដី ។ ហើយគាត់បានសូមឲ្យខ្ញុំយកអត្ថបទសាច់រឿងនោះទៅឲ្យគាត់វិញ ដើម្បីគាត់អាចយកវាទៅឲ្យអ្នកផ្សេងទៀត ។ ខ្ញុំបានដាក់ទូរសព្ទចុះ ទាំងមានអារម្មណ៍ខ្មាសអៀនចំពោះការទួញយំរបស់ខ្ញុំ ប៉ុន្តែមានអំណរគុណចំពោះសេចក្ដីសណ្ដោស ចម្លើយដែលមានការយល់ចិត្តរបស់លោកចាងហ្វាង ។

ខ្ញុំបានជូតទឹកភ្នែកចេញ ហើយចាប់យកអត្ថបទសាច់រឿងនោះ ប្រញាប់ចូលក្នុងឡានរបស់ខ្ញុំ ។ នៅពេលម៉ាស៊ីនឡានដំណើរការ វិទ្យុក៏បានបើកផងដែរ ។ វិទ្យុនោះបើកចំប៉ុស្តិ៍ស្ថានីយ៍តន្ត្រីបុរាណក្នុងតំបន់ ហើយដោយក្ដីភ្ញាក់ផ្អើល តន្ត្រីដែលកំពុងលេងនោះគឺជាការស្នើសុំ ដែលវាជាតន្ត្រីល្ខោនដដែលនោះ ។ ខ្ញុំពុំដែលធ្លាប់ឮតន្ត្រីនោះចាក់ផ្សាយតាមវិទ្យុពីមុនឡើយ ។

ខ្ញុំមានអារម្មណ៍ថា ព្រះវរបិតាសួគ៌កំពុងប្រគុំតន្ត្រីសម្រាប់ខ្ញុំ ។ ទ្រង់ចង់ឲ្យខ្ញុំយល់ថា ទ្រង់ស្រឡាញ់ខ្ញុំ ហើយទ្រង់យល់ស្របនឹងជម្រើសរបស់ខ្ញុំ ។ តន្ត្រីនោះបានចាក់ផ្សាយតាមវិទ្យុគឺជាសេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់មួយរបស់ព្រះ ។ តាមរយៈតន្ត្រីនេះខ្ញុំបានទទួលការលួងលោមអំពីសេចក្ដីស្រឡាញ់របស់ទ្រង់ ។

ខ្ញុំបានបន្តសិក្សាអំពីល្ខោននៅសាកលវិទ្យាល័យ ។ ខ្ញុំបានឃើញថា ខ្ញុំស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នាជាច្រើនដង ។ មានគ្រាជាច្រើនដែលវាចាំបាច់ត្រូវតែចាកចេញពីគម្រោងជាក់លាក់នានាដែលយើងសហការគ្នា ដោយសារមកពីការមានមាតិកាដែលពុំសមរម្យនោះ ។ ស្ថានភាពទាំងនេះពុំងាយស្រួល ឬគាប់ចិត្តឡើយ ប៉ុន្តែខ្ញុំអាចទប់ទល់នឹងស្ថានភាពទាំងនោះដោយព្រះគុណកាន់តែច្រើនឡើងៗ ដោយពុំយំទៀឡើយ ។ ប្រហែលជាបទពិសោធន៍កាលពីមុនៗរបស់ខ្ញុំបានរៀបចំសម្រាប់ឱកាសទាំងនោះ ។ ប្រហែលវាជួយខ្ញុំឲ្យយល់កាន់តែប្រសើរអំពីខ្លួនខ្ញុំ និងអ្វីដែលខ្ញុំចង់ប្រែក្លាយខ្លាំងបំផុត ។

វិល្លាម ស្ស៊ិកស្ពៀរ បានសរសេរថា ៖

*ពិភពលោកទាំងអស់គឺជាឆាកសម្ដែងមួយ*
*ហើយទាំងបុរស និងស្ត្រីគ្រប់រូប គ្រាន់តែ*
*អធិស្ឋាន ៖*
*ពួកគេមានច្រកចេញ និងច្រកចូលរបស់ពួកគេ*
*ហើយមនុស្សម្នាក់ប្រើពេលវេលារបស់ខ្លួនសម្ដែង*
*ក្នុងផ្នែកជាច្រើន ។*[១]

ខ្ញុំរៀនថាមានឈុតមួយដែលត្រូវសម្ដែងដែលវាជាឈុតសំខាន់ជាងឈុតណាៗទាំងអស់ ។ នោះគឺជាការធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ ។ ការទទួលបានការសាទរពីមិត្តភក្ដិរបស់យើង អាចជារឿងដែលគួរឲ្យរំភើប និងពេញចិត្ត ប៉ុន្តែមានតែការអនុម័តរបស់ព្រះទេ ដែលសំខាន់នោះ ។ ការសម្ដែងដ៏ប្រសើរបំផុតរបស់យើងកើតឡើងបាន នៅពេលយើងរៀនធ្វើតាមលោកចៅហ្វាយ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ វ៉ាស៊ីងតោន ស.រ.អា. ។*



កំណត់ចំណាំ
១. William Shakespeare *As You Like It* ការសម្ដែងទី ២ ឈុតទី ៧ ទំព័រ ១៤១–៤៤ ។

# រឹងប៉ឹង
## ពេញមួយសប្ដាហ៍









*យុវវ័យទាំងនេះចែកចាយអំពីរបៀបដែលព្រះអម្ចាស់ប្រទានពរដល់ពួកគេ នៅពេលពួកគេទទួលទានសាក្រាម៉ង់ ហើយចងចាំសេចក្ដីសញ្ញារបស់ខ្លួនពេញមួយសប្ដាហ៍ ។*

វាជាយប់ថ្ងៃអាទិត្យ ។ នោះមានន័យថាថ្ងៃស្អែកគឺជាថ្ងៃចន្ទ — ត្រូវត្រឡប់ទៅធ្វើកិច្ចការសាលា ធ្វើការងារ ហាត់សមបាល់ឱប រៀនលេងព្យាណូ និងកិច្ចការផ្សេងៗទៀត ។ មានកិច្ចការដាក់លាក់ជាច្រើនដែលត្រូវធ្វើក្នុងសប្ដាហ៍នេះ ! ប៉ុន្តែអ្នកអាចធ្វើកិច្ចការទាំងនោះបាន ។ អ្នកអាចសម្រេចកិច្ចការជាច្រើនដែលអ្នកគ្រោងចង់ធ្វើសប្ដាហ៍នេះ ។

តើអ្នកចង់ដឹងថាធ្វើបែបណាដែរឬទេ ?

អ្នកមានភាពរឹងមាំខាងវិញ្ញាណជួយដល់អ្នក ។ ជារៀងរាល់ថ្ងៃអាទិត្យ អ្នកអាចទទួលទានសាក្រាម៉ង់ ហើយរំឭកសេចក្ដីសញ្ញាដែលអ្នកបានចុះ ។ នៅពេលអ្នកធ្វើបែបនោះ អ្នកត្រូវបានសន្យាថា ប្រសិនបើអ្នកលើកដាក់មកលើខ្លួនអ្នកនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ចងចាំទ្រង់ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះអ្នកនឹងមានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយអ្នក *ជាដរាប* ( សូមមើល គ. និង ស. ២០:៧៧, ៧៩ ) ។ នោះមានន័យថា អ្នកអាចទទួលអារម្មណ៍ថាត្រូវបានពង្រឹងខាងវិញ្ញាណ ទោះបីអ្នកជួបនឹងរឿងអ្វីក៏ដោយក្នុងសប្ដាហ៍នេះ ។

យើងបានសូមឲ្យយុវវ័យមួយចំនួនចែកចាយអំពីបទពិសោធន៍របស់ពួកគេជាមួយពិធីសាក្រាម៉ង់ និងរបៀបដែលពិធីនេះបានពង្រឹងដល់ពួកគេ នៅពេលពួកគេចងចាំសេចក្ដីសញ្ញារបស់ខ្លួនពេញមួយសប្ដាហ៍នោះ ។ សូមអានអំពីរឿងមួយចំនួនរបស់ពួកគេ ។ ប្រហែលជាអ្នកធ្លាប់ជួបនឹងរឿងស្រដៀងគ្នានេះផងដែរ !

រូបថតខាងក្រោយ និងខាងលើ ៖ រូបថតមកពី GETTY IMAGES



ការចងចាំព្រះអង្គសង្គ្រោះជានិច្ចជួយខ្ញុំឲ្យមានភាពក្លាហាននៅក្នុងការប្រឈមមុខនឹងការសាកល្បងលំបាកៗ ។ កាលរៀននៅវិទ្យាល័យបានពាក់កណ្ដាលឆ្នាំ គ្រួសារខ្ញុំបានប្ដូរទីលំនៅទៅសហរដ្ឋវិញ ប៉ុន្តែខ្ញុំបន្តនៅប្រទេសអូស្ត្រាលីតែម្នាក់ឯង ដើម្បីរៀនបញ្ចប់ថ្នាក់នោះសិន ។ បន្ទាប់ពីខ្ញុំទៅលេងពួកគេអំឡុងពេលវិស្សមកាល ខ្ញុំបានជិះយន្តហោះត្រឡប់មកប្រទេសអូស្ត្រាលីវិញ ហើយខ្ញុំមានអារម្មណ៍ថាឯកោខ្លាំងណាស់ ។ ប៉ុន្តែភ្លាមនោះខ្ញុំបានដឹងថា ខ្ញុំពុំនៅឯកោឡើយ ខ្ញុំពុំធ្លាប់នៅឯកោ ឬនឹងនៅឯកោឡើយ ដោយសារព្រះវិញ្ញាណរបស់ព្រះអង្គសង្គ្រោះនឹងគង់នៅជាមួយខ្ញុំជាដរាប នៅពេលខ្ញុំព្យាយាមធ្វើតាមទ្រង់ ។ នោះគឺជាការល្បួងលោមដ៏អស្ចារ្យបំផុតដែលខ្ញុំបានទទួលនាគ្រានោះ ។

***ស្យារ៉ុន អេស អាយុ ១៩ ឆ្នាំ ទីក្រុងស៊ីឌនី ប្រទេសអូស្ត្រាលី***



ពេលខ្ញុំស្ដាប់ឮការអធិស្ឋានសាក្រាម៉ង់ ខ្ញុំរំឭកខ្លួនខ្ញុំថា ប្រសិនបើខ្ញុំធ្វើនូវចំណែករបស់ខ្ញុំក្នុងសេចក្ដីសញ្ញាបុណ្យជ្រមុជទឹក នោះខ្ញុំអាចឲ្យព្រះវិញ្ញាណគង់នៅជាមួយខ្ញុំ ។ ពេលវេលាពេញមួយសប្ដាហ៍នោះ កាន់តែងាយស្រួលនៅពេលខ្ញុំរក្សាឲ្យព្រះវិញ្ញាណគង់នៅក្បែរ ។ ឧទាហរណ៍ សិស្សជាច្រើននៅសាលារៀនខ្ញុំនិយាយពាក្យអសុរស ហើយនិយាយតាមរបៀបមួយដែលពុំសមរម្យ ។ ការចងចាំអំពីសេចក្ដីសញ្ញារបស់ខ្ញុំ ជួយខ្ញុំកុំឲ្យខ្វល់នឹងអ្វីដែលខ្ញុំស្ដាប់ឮ ហើយវាថែមទាំងមានឥទ្ធិពលទៅលើយុវវ័យទាំងនោះឲ្យឈប់និយាយអសុរសបែបនោះទៀត ។

***ជេកុប ប៊ី អាយុ ១៤ ឆ្នាំ រដ្ឋ ខូឡូរ៉ាដូ ស.រ.អា.***



សម្រាប់ខ្ញុំ ការលើកដាក់មកលើខ្លួនខ្ញុំនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ មានន័យថាចងចាំថា ព្រះវិញ្ញាណរបស់ទ្រង់អាចគង់នៅជាមួយពួកយើងជានិច្ច ហើយថាយើងត្រូវតែជ្រើសរើសធ្វើអ្វីដែលត្រូវ ។ មានគ្រាមួយនៅក្នុងពិធីជប់លៀងថ្ងៃខួបកំណើត មិត្តភក្ដិរបស់ខ្ញុំបានផឹកគ្រឿងស្រវឹង ហើយពួកគេបានឲ្យខ្ញុំផឹកគ្រឿងស្រវឹងនោះផងដែរ ។ ខ្ញុំបានបដិសេធពុំផឹកវាឡើយ ។ ក្រោយមកមានមិត្តភក្ដិម្នាក់របស់ខ្ញុំដែលជាសមាជិកនៅសាសនាចក្រ បានមកហើយប្រាប់ពួកគេថា យើងពុំផឹកគ្រឿងស្រវឹងឡើយ ដោយសារវាជាច្បាប់ហាមឃាត់ក្នុងសាសនារបស់យើង ។ ការចងចាំព្រះអង្គសង្គ្រោះជានិច្ចនាំឲ្យមានព្រះវិញ្ញាណគង់នៅជិតខ្ញុំជានិច្ច ហើយរារាំងរឿងអាក្រក់ឲ្យចេញឆ្ងាយពីខ្ញុំ ។

***ម៉ៃហ្កែល ស៊ី អាយុ ១៦ ឆ្នាំ ទីក្រុងប៉ារ៉ាណា ប្រទេសប្រេស៊ីល ។***



នៅសាលារៀនមានក្មេងស្រីពិការម្នាក់ ។ សិស្សជាច្រើនបានយកការណ៍នោះជាការដោះសារបន្ថែមដើម្បីសើចចំអកដាក់នាង ។ មានតែមិត្តខ្ញុំ និងខ្ញុំប៉ុណ្ណោះដែលព្យាយាមជួយនាង ។ ថ្ងៃខ្លះ វាហាក់បីដូចជាសិស្សនៅក្នុងថ្នាក់ទាំងមូលបានរួមគ្នាទាស់នឹងនាង ។ វាលំបាកណាស់ក្នុងការដឹងអំពីរបៀបដែលត្រូវប្រតិកម្មចំពោះរឿងនោះ ។ ខ្ញុំគ្រាន់តែចង់ដើរចេញ ប៉ុន្តែខ្ញុំបានជ្រើសដើម្បីចងចាំថា នាងគឺជាបុត្ររបស់ព្រះ ហើយខ្ញុំគិតអំពីរបៀបដែលព្រះយេស៊ូវនឹងប្រព្រឹត្តដល់នាង ។ ខ្ញុំទទួលអារម្មណ៍ពីឥទ្ធិពលដ៏ស្ងប់នៃព្រះវិញ្ញាណបរិសុទ្ធ ។ ខ្ញុំចាំថា ខ្ញុំអាចធ្វើឲ្យមានការផ្លាស់ប្ដូរបាន ។ ការធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះបានជួយខ្ញុំយ៉ាងច្រើន ហើយខ្ញុំបានដឹងថា អ្វីៗគ្រប់យ៉ាងនឹងគ្មានបញ្ហាអ្វីឡើយ ។

នៅក្នុងសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំ ខ្ញុំត្រូវបានសន្យាថា មានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយខ្ញុំ ប្រសិនបើខ្ញុំធ្វើដូចអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើ ។ ខ្ញុំមានអំណរគុណចំពោះអារម្មណ៍ដែលល្បួងលោម និងភាពរឹងមាំមកពីព្រះវិញ្ញាណបរិសុទ្ធ ។

***អាឡិចស៊ី អិល អាយុ ១៣ ឆ្នាំ រដ្ឋ ខាន់សាស ស.រ.អា.***

អំឡុងពេលពិធីសាក្រាម៉ង់ ខ្ញុំធ្លាប់គិតអំពីកិច្ចការនានាដូចជាកិច្ចការដែលខ្ញុំត្រូវធ្វើនៅក្នុងសប្ដាហ៍បន្ទាប់ កិច្ចការនៅសាលា ឬគិតអំពីមិត្តភក្តិរបស់ខ្ញុំ ។ ប៉ុន្តែក្រោយមកតាមរយៈថ្នាក់សាលាថ្ងៃអាទិត្យ និងសារលិខិតមកពីព្យាការីរបស់យើង ខ្ញុំបានចាប់ផ្ដើមយល់អំពីអត្ថន័យនៃពិធីសាក្រាម៉ង់ ។ ឥឡូវនេះខ្ញុំគិតអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ថាទ្រង់បានថ្វាយព្រះជន្មទ្រង់សម្រាប់ពួកយើង បានបង់ថ្លៃសម្រាប់អំពើបាបរបស់យើង ហើយបានរងទុក្ខចំពោះរឿងគ្រប់យ៉ាង ។ ការណ៍នេះផ្ដល់ការជំរុញទឹកចិត្តខ្ញុំរៀងរាល់ថ្ងៃឲ្យខ្ញុំនិយាយថា ខ្ញុំអាចព្យាយាមប្រែក្លាយដូចជាទ្រង់ ហើយបង្ហាញសេចក្ដីស្រឡាញ់ដូចដែលទ្រង់បានបង្ហាញដល់អ្នកដទៃ ។ ខ្ញុំអាចចែកចាយដំណឹងល្អជាមួយអ្នកដទៃ ។ ខ្ញុំអាចធ្វើកិច្ចការនានាដើម្បីឲ្យបានកាន់តែសក្តិសមដើម្បីចូលទៅក្នុងព្រះវិហារបរិសុទ្ធ ហើយទទួលទានសាក្រាម៉ង់ ។

***អាឡេសសាន់ត្រា ប៊ី អាយុ ១៧ ឆ្នាំ ទីក្រុងសាន់ទីអាហ្គោ ប្រទេសឈីលី***



ការទទួលទានសាក្រាម៉ង់ផ្ដល់អារម្មណ៍ និងគំនិតសុខសាន្តដល់ខ្ញុំ ដែលនាំឲ្យខ្ញុំអាចទប់ទល់នឹងរឿងរ៉ាវដែលកើតឡើងក្នុងជីវិតខ្ញុំ ។ កាលពីខែមិថុនាឆ្នាំមុន ខ្ញុំមានគ្រាដ៏លំបាកក្នុងជីវិតខ្ញុំ ។ មិត្តភក្តិស្និទ្ធស្នាលរបស់ខ្ញុំម្នាក់បានប្ដូរទីលំនៅទៅរស់នៅឆ្ងាយ ខ្ញុំមានការលំបាកនឹងជំងឺបាក់ទឹកចិត្ត ហើយខ្ញុំមានគំនិតពុំប្រាកដប្រជាអំពីរូបកាយនេះឡើយ ។ ថ្ងៃអាទិត្យមួយ ខ្ញុំកំពុងទទួលទានសាក្រាម៉ង់ ស្រាប់តែអារម្មណ៍នៃភាពសុខសាន្តដ៏ខ្លាំងបានកើតមានក្នុងចិត្តខ្ញុំ ។ ខ្ញុំមានអារម្មណ៍ថា ពិតជារីករាយណាស់ ។

***អូលីវៀ ធី អាយុ ១៤ ឆ្នាំ រដ្ឋវើរជីញ៉ា ស.រ.អា.***



ពិធីសាក្រាម៉ង់គឺជាការលើកស្ទួយខាងវិញ្ញាណសម្រាប់មួយសប្ដាហ៍ទាំងមូល ។ ពិធីនេះរំឭកខ្ញុំអំពីសេចក្ដីសញ្ញាដែលខ្ញុំបានចុះជាមួយព្រះវរបិតាសួគ៌ខ្ញុំ ដែលគង់នៅស្ថានសួគ៌ ហើយពិធីនេះដឹកនាំខ្ញុំពេញមួយសប្ដាហ៍ទាំងមូល ។ វាធ្វើឲ្យខ្ញុំគិតអំពីការពលិកម្មរបស់ព្រះយេស៊ូវគ្រីស្ទសម្រាប់ពួកយើង ហើយរៀបចំខ្លួនខាងវិញ្ញាណសម្រាប់សប្ដាហ៍ក្រោយទៀត ។

មានគ្រាមួយខ្ញុំមានការតានតឹងក្នុងចិត្ត និងមានការលំបាកជាខ្លាំង ប៉ុន្តែនៅពេលខ្ញុំទទួលទានសាក្រាម៉ង់ ហើយអានទំនុកតម្កើងសាក្រាម៉ង់ នោះខ្ញុំពោរពេញដោយព្រះវិញ្ញាណ ។ ខ្ញុំបានភ្លេចពីភាពតានតឹងផ្លូវចិត្តរបស់ខ្ញុំ ហើយផ្ដោតលើព្រះអង្គសង្គ្រោះវិញ ។

***ប្រែដ ប៊ី អាយុ ១៧ ឆ្នាំ រដ្ឋខូឡូរ៉ាដូ ស.រ.អា.***



ការដឹងថាខ្ញុំបានចុះសេចក្ដីសញ្ញាដើម្បីលើកដាក់មកលើខ្លួនខ្ញុំនូវព្រះនាមនៃព្រះគ្រីស្ទ វាផ្ដល់នូវការយល់ដឹងដល់ខ្ញុំអំពីកាតព្វកិច្ចដើម្បីធ្វើតាមទ្រង់ ប៉ុន្តែវាពុំងាយស្រួលរហូតនោះឡើយ ។ នាគ្រាមួយនៅក្នុងសកម្មភាពក្រុម ខ្ញុំបានឃើញក្មេងម្នាក់ដែលគ្មាននរណានិយាយជាមួយឡើយ ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរតែទៅនិយាយរកគាត់ ។ ដំបូង ខ្ញុំពុំចង់ធ្វើឡើយ ។ ខ្ញុំពុំសូវពូកែក្នុងការរួសរាយរាប់អានមិត្តភក្តិឡើយ ។ ប៉ុន្តែដោយការចងចាំអំពីអ្វីដែលព្រះគ្រីស្ទបានធ្វើ នោះខ្ញុំបានរកឃើញភាពរឹងប៉ឹងដើម្បីរាប់អានមិត្តភក្តិថ្មី ។ នៅពេលខ្ញុំនិយាយរកគាត់ ខ្ញុំមានអារម្មណ៍ពីព្រះវិញ្ញាណបំផុសគំនិតខ្ញុំ ឲ្យសួរសំណួរគាត់ ហើយមានភាពរីករាយ ។

***អ៊ីវ៉ាន អេ អាយុ ១៦ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា.***





**ដោយអែលឌើរ ដាល្លិន អេក អូក**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# របៀប ទទួលបានទីបន្ទាល់

ជំហានទីមួយក្នុងការទទួលបានចំណេះដឹងណាក៏ដោយគឺ ការមានប្រាថ្នាចង់ដឹងដោយពិតប្រាកដ ។ នៅក្នុងករណីនៃចំណេះដឹងខាងវិញ្ញាណ ជំហានបន្ទាប់គឺ ទូលសួរដល់ព្រះនៅក្នុងការអធិស្ឋានដ៏ស្មោះសរ ។ ដូចយើងអាននៅក្នុងវិវរណៈសម័យទំនើបនេះថា « បើសិនជាអ្នកសូម នោះអ្នកនឹងបានទទួលវិវរណៈថែមទៅលើវិវរណៈ តម្រិះថែមទៅលើតម្រិះ ដើម្បីឲ្យអ្នកអាចបានស្គាល់សេចក្ដីអាថ៌កំបាំងទាំងឡាយ និងរបស់ទាំងឡាយដ៏ប្រកបដោយសេចក្ដីសុខសាន្ត — ដែលនឹងនាំឲ្យមានសេចក្ដីអំណរជាអ្វីដែលនាំឲ្យមានជីវិតដ៏នៅអស់កល្បជានិច្ច » ( គ. និង ស. ៤២:៦១ ) ។

នេះជាអ្វីដែលអាលម៉ាបានសរសេរអំពីអ្វីដែលគាត់បានធ្វើ ៖ « មើលចុះ ខ្ញុំបានតមអាហារ ហើយបានអធិស្ឋានជាច្រើនថ្ងៃដើម្បីខ្ញុំអាចដឹងនូវរឿងទាំងនេះដោយខ្លួនខ្ញុំ ។ ហើយឥឡូវនេះ ខ្ញុំដឹងរឿងទាំងនោះដោយខ្លួនខ្ញុំថាជារឿងពិត ព្រោះព្រះអម្ចាស់ដ៏ជាព្រះទ្រង់បានសម្ដែងប្រាប់ខ្ញុំ ដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ » ( អាលម៉ា ៥:៤៦ ) ។

នៅពេលយើងមានបំណងប្រាថ្នា ហើយស្វែងរកនោះយើងគប្បីចាំថា ការទទួលបានទីបន្ទាល់ពុំមែនជារឿងអកម្មឡើយ ប៉ុន្តែវាជាដំណើរការមួយដែលរំពឹងឲ្យយើង *ធ្វើ* កិច្ចការអ្វីមួយ ។ ព្រះយេស៊ូវបានបង្រៀនថា « បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងសេចក្ដីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ » ( យ៉ូហាន ៧:១៧ ) ។

របៀបមួយទៀតដើម្បីស្វែងរកទីបន្ទាល់ ហាក់បីដូចជាអស្ចារ្យណាស់ បើប្រៀបធៀបទៅនឹងវិធីនានាក្នុងការទទួលបានចំណេះដឹងដទៃទៀត ។ យើងទទួលបាន ឬ ពង្រឹងទីបន្ទាល់តាមរយៈការថ្លែងទីបន្ទាល់នោះ ។ មានមនុស្សមួយចំនួនព្រមទាំងបានផ្ដល់យោបល់ថា ទីបន្ទាល់ខ្លះអាចទទួលបាននៅពេលពួកគេថ្លែងទីបន្ទាល់នោះ ជាជាងការលុតជង្គង់ទូលសូមទីបន្ទាល់នោះ ។

ទីបន្ទាល់ផ្ទាល់ខ្លួនគឺជាគ្រឹះសម្រាប់សេចក្ដីជំនឿរបស់យើង ។ ដូច្នេះហើយ អ្វីៗដែលយើងត្រូវធ្វើដើម្បីទទួលបាន ដើម្បីពង្រឹង និងរក្សាទីបន្ទាល់ទុកគឺចាំបាច់សម្រាប់ជីវិតខាងវិញ្ញាណរបស់យើង ។ ក្រៅពីអ្វីដែលបាននិយាយមកហើយនេះ យើងត្រូវតែ ទទួលទានសាក្រាម៉ង់រៀងរាល់សប្ដាហ៍ ( សូមមើល គ. និង ស. ៥៩:៩) ដើម្បីសក្ដិសមនឹងការសន្យាដ៏មានតម្លៃថាយើងនឹង « មានព្រះវិញ្ញាណរបស់ទ្រង់ គង់នៅជាមួយនឹង [ ពួកយើង ] ជាដរាប » ( គ. និង ស. ២០:៧៧ ) ។ ប្រាកដណាស់ ព្រះវិញ្ញាណគឺជាប្រភពនៃទីបន្ទាល់របស់យើង ។ ■

*ដកស្រង់ចេញពីសុន្ទរកថាសន្និសីទទូទៅ ខែ មេសា ឆ្នាំ ២០០៨ ។*



## តើអ្នកបានអនុវត្តគោលការណ៍នេះដោយរបៀបណា ?

ខ្ញុំមានទីបន្ទាល់អំពីសាសនាចក្រនេះ ។ វាបានកើតឡើងតាមរយៈការបំផុសគំនិត និងការពលិកម្ម និងការអានព្រះគម្ពីរជាប្រចាំថ្ងៃ ។ ហើយនៅពេលអ្នកមានទីបន្ទាល់ផ្ទាល់ខ្លួន នោះអ្នកនឹងយល់ឃើញ ហើយស្ដាប់ឮរឿងនានាកាន់តែអស្ចារ្យ ។

ស្សានណាន់ មើរៀ អិម រដ្ឋខូឡូរ៉ាដូ ស.រ.អា

# ចំទៅនឹងគោលដៅ



## តើខ្ញុំអាចថ្លឹងថ្លែងរវាង ការមិនវិនិច្ឆ័យអ្នកដទៃ និងការមិនអនុគ្រោះចំពោះអំពើបាបតាមរបៀបណា ?

យើងត្រូវបានត្រាស់បញ្ជាឲ្យអភ័យទោសអ្នកដទៃ ហើយទុកឲ្យការវិនិច្ឆ័យចុងក្រោយទៅលើព្រះ ( សូមមើល គ. និង ស. ៦៤:៩–១១ ) ប៉ុន្តែវាពុំមែនមានន័យថាជាការអនុគ្រោះចំពោះអំពើបាបឡើយ ។ ប្រសិនបើយើងនៅក្បែរអ្នកដែលកំពុងពាក់ព័ន្ធនឹងឥរិយាបថដែលពោរពេញដោយអំពើបាប នោះយើងគប្បីធ្វើជាពន្លឺដល់ពួកគេ ហើយឈរយ៉ាងរឹងប៉ឹងចំពោះអ្វីដែលត្រូវ ។ យ៉ាងហោចណាស់ ការណ៍នេះមានន័យថាធ្វើជាគំរូល្អដោយពុំពាក់ព័ន្ធខ្លួនយើងទៅក្នុងអំពើបាប ហើយពុំបណ្តោយខ្លួនយើងឲ្យស្ថិតក្នុងស្ថានភាព ឬក្រុមមនុស្សដែលមានចិត្តសង្ស័យ ។ ប៉ុន្តែតើយើងគប្បីចង្អុលប្រាប់អំពីឥរិយាបថអាក្រក់របស់មនុស្ស ដើម្បីឲ្យពួកគេដឹងអំពីក្រឹត្យវិន័យរបស់ព្រះ និងគោលជំហររបស់យើងចំពោះក្រឹត្យវិន័យទាំងនោះដែរឬទេ ? ប្រសិនបើយើងគួរប្រាប់មែន តើយើងគួរធ្វើវានៅពេលណា និងរបៀបណា ?

ចម្លើយនោះប្រហែលវាអាស្រ័យតាមស្ថានភាព អាស្រ័យលើទំនាក់ទំនងដែលយើងមានជាមួយមនុស្សដែលយើងទាក់ទង និងចំណេះដឹងរបស់ពួកគេអំពីក្រឹត្យវិន័យរបស់ព្រះ ។ ឧទាហរណ៍ ការនិយាយមួយទល់នឹងមួយជាមួយសមាជិកគ្រួសារ និងមិត្តភក្តិស្និទ្ធស្នាលវាប្រសើរជាងការប្រាប់មនុស្សនៅក្នុងបន្ទប់ទាំងអស់អំពីបុគ្គលដែលត្រូវតែប្រែចិត្ត ។ សូមស្វែងរកការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។ ទ្រង់អាចដឹកនាំពាក្យសម្តី និងទង្វើរបស់អ្នក ប្រយោជន៍ឲ្យអ្នកអាចបង្ហាញនូវតុល្យភាពត្រឹមត្រូវនៃសេចក្តីស្រឡាញ់ ការអត់ឱន និងការតាំងចិត្តខ្ជាប់ខ្ជួនទៅនឹងបទដ្ឋានរបស់ព្រះអម្ចាស់ ។ ■

## ប្រសិនបើខ្ញុំឈប់មើលការណ៍អាសគ្រាមដោយខ្លួនឯងហើយ តើខ្ញុំនៅតែត្រូវនិយាយរឿងនោះប្រាប់ប៊ីស្សពរបស់ខ្ញុំទៀតឬ ?

ប្រសិនបើអ្នកធ្លាប់មើលការណ៍អាសគ្រាម អ្នកត្រូវបានលើកទឹកចិត្តឲ្យ « ស្វែងរកជំនួយដែលអ្នកត្រូវការ ។ ឪពុកម្តាយ និងប៊ីស្សពរបស់អ្នកអាចជួយអ្នកឆ្លងកាត់ជំហានដ៏ចាំបាច់ ដើម្បីប្រែចិត្ត និងនាំអ្នកចេញពីទម្លាប់ដ៏បំផ្លិចបំផ្លាញនេះ » ( *ដើម្បីកម្លាំងនៃយុវជន* [ ឆ្នាំ ២០១១ ] ទំព័រ ១២ ) ។

ប្រសិនបើអ្នកឈប់មើលការណ៍អាសគ្រាមដោយខ្លួនអ្នកហើយ សំណួរគឺពុំមែនថាតើអ្នកនៅតែ ឬមិននៅតែ « តម្រូវឲ្យ » និយាយជាមួយប៊ីស្សពរបស់អ្នកអំពីរឿងនោះទេ ។ សំណួរដែលត្រូវសួរនោះគឺថា « ហេតុអ្វីខ្ញុំ *មិន* និយាយអំពីរឿងនេះជាមួយប៊ីស្សពរបស់ខ្ញុំ ? » វាពិតជាគ្មានគុណវិបត្តិចំពោះរឿងនោះឡើយ ។ គាត់នឹងយល់ ហើយលើកទឹកចិត្ត ហើយគាត់នឹងពេញចិត្តចំពោះការខិតខំដែលអ្នកបានធ្វើ ដើម្បីបោះបង់អំពើបាបកាលពីអតីតកាលរបស់អ្នក ។ ប៊ីស្សពអាចជួយអ្នកដោះស្រាយនូវចម្ងល់នានា ដែលអ្នកធ្លាប់មានពីមុនៗទាក់ទងនឹងភាពសក្តិសមរបស់អ្នក ហើយខ្វល់ខ្វាយយ៉ាងខ្លាំងអំពីការប្រែចិត្តរបស់អ្នក ។ ហើយគាត់អាចជួយអ្នកឲ្យពង្រឹងសេចក្តីជំនឿ ព្រមទាំងទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ និងពលិកម្មធួនរបស់ទ្រង់ ។ សម្រាប់ហេតុផលស្រដៀងគ្នានេះ អ្នកក៏គួរតែគិតអំពីការពិភាក្សាជាមួយឪពុកម្តាយរបស់អ្នកផងដែរ ។ ■


WILLIE HANDCART COMPANY
RESCUE SITE

ដើម្បីធ្វើជាពួកបរិសុទ្ធថ្ងៃចុងក្រោយគឺ
ត្រូវតែធ្វើជាអ្នកត្រួសត្រាយ ។

# ដំណើរត្រួសត្រាយរបស់អ្នក —

## ដំណើរពិតប្រាកដ ពុំមែនប្រឌិតឡើយ

**ដោយ អ៊ើរ៉ុន អិល វ៉ែស**
ការិយាល័យប្រវត្តិសាស្ត្ររបស់សាសនាចក្រ

កាលពីខ្ញុំនៅក្មេង ជួនកាលខ្ញុំបានធ្វើលេងថាខ្ញុំជាតារាកីឡាករ ។ ខ្ញុំធ្វើពុតថាអាចហោះហើរបាន ។ ខ្ញុំធ្វើលេងថាខ្ញុំជាយក្ស ។ ខ្ញុំរីករាយនឹងជីវិតរបស់ខ្ញុំទោះបីខ្ញុំទាប ពុំអាចហោះហើរបាន ហើយមានសមត្ថភាពលេងកីឡាបានតែបន្តិចបន្តួចក្ដី ។ ប៉ុន្តែការធ្វើលេងទាំងនេះពិតជាសប្បាយណាស់ ។ ខ្ញុំរីករាយនឹងបទពិសោធន៍ផ្សេងៗ ទោះបីវាគ្រាន់តែជាការស្រមើលស្រមៃរបស់ខ្ញុំក្ដី ។ ខ្ញុំគិតថា នោះហើយជាមូលហេតុដែលមនុស្សជាច្រើនចូលចិត្តពុតធ្វើលេង ។

និយាយអំពីការពុតធ្វើលេងនេះ យើងជាពួកបរិសុទ្ធថ្ងៃចុងក្រោយចូលចិត្តចូលរួមក្នុងសកម្មភាពដើរត្រួសត្រាយណាស់ ។ យើងពាក់សម្លៀកបំពាក់ពួកអ្នកត្រួសត្រាយ ( ប្រហែល ) យើងអូសរទេះរបស់ពួកអ្នកត្រួសត្រាយ ( ប្រហែល ) យើងបរិភោគអាហាររបស់អ្នកពួកអ្នកត្រួសត្រាយ ( ប្រហែលជាមិនដូចទាំងស្រុងទេ ) ។ យើងបានខិតខំយ៉ាងខ្លាំង ដើម្បីធ្វើពុតជាពួកអ្នកត្រួសត្រាយ ។ រឿងដែលអស្ចារ្យនោះគឺថា យើងពុំចាំបាច់ធ្វើពុតឡើយ ។ *យើងគឺជាពួកអ្នកត្រួសត្រាយរួចទៅហើយ* ។

ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា « ដើម្បីធ្វើជាពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺត្រូវធ្វើជាអ្នកត្រួសត្រាយ ដ្បិតនិយមន័យនៃពាក្យថាអ្នកត្រួសត្រាយគឺជា ‹ មនុស្សដែលដើរទៅមុន ដើម្បីរៀបចំ ឬ បើកផ្លូវសម្រាប់មនុស្សដទៃទៀតឲ្យដើរតាម › » ។[១] ប្រធាន ម៉នសុន បានបង្រៀនពួកយើងតាមរយៈប្រសាសន៍ និងទង្វើរបស់លោក អំពីរបៀបធ្វើជាអ្នកត្រួសត្រាយដ៏ពិត ៖

« យើងដើរតាមដាននៃអ្នកត្រួសត្រាយដ៏អស្ចារ្យបំផុត — គឺព្រះអង្គសង្គ្រោះ — ដែលទ្រង់បានយាងមុនគេ ដោយបង្ហាញដល់យើងនូវមាគ៌ាដើម្បីដើរតាម ។

ទ្រង់បានអញ្ជើញថា ‹ ចូរមកតាមខ្ញុំ › » ។[២]

*ចូរមក . . . តាម . . . ខ្ញុំ* ។ ព្រះបន្ទូលដ៏សាមញ្ញនេះអាចជួយយើងឲ្យក្លាយជាអ្នកត្រួសត្រាយពិតប្រាកដ ។

ចូរមើលព្រះបន្ទូលទាំងនេះក្នុងទស្សនវិស័យមួយអំពីពួកអ្នកត្រួសត្រាយមួយចំនួននាសម័យទំនើប ដែលថ្មីៗនេះពួកគេបានចូលរួមក្នុងសកម្មភាពដើរអ្នកត្រួសត្រាយរបស់ស្តេក ។



ចេញរូបភាពដោយ ប្រ៊េត ស្វាត
រូបថតសកម្មភាពការធ្វើដំណើរទទួលបានសិទ្ធិអនុញ្ញាតពី អ៊ើរ៉ុន វ៉ែស










## « ចូរមកតាមខ្ញុំ »

ពាក្យថា *ចូរមក* គឺជាការអញ្ជើញមួយ ។ ពាក្យនេះផ្ដល់យោបល់ឲ្យប្ដូរពីកន្លែងមួយទៅកន្លែងមួយទៀត ។ ថេលើរ អេ ស្គាល់យ៉ាងច្បាស់អំពីអត្ថន័យនៃពាក្យនេះ ។

ថេលើរ សប្បាយចិត្ត មានអំណរ ហើយពោរពេញដោយព្រះវិញ្ញាណ ប៉ុន្តែគាត់នឹងប្រាប់អ្នកយ៉ាងលឿនថា ពាក្យទាំងនោះពុំបានធ្វើឲ្យគាត់យល់ឡើយកាលពីពីរឆ្នាំកន្លងទៅ ។ ឥឡូវនេះគាត់បានប្ដូរទៅកន្លែងមួយផ្សេងទៀតទាំងខាងវិញ្ញាណ និងខាងរូបកាយ ។ គាត់គឺជាអ្នកត្រួសត្រាយ ។

គាត់និយាយថា « ខ្ញុំធ្លាប់ធ្វើជាអ្នកត្រួសត្រាយក្នុងជីវិតខ្ញុំ ដោយសារខ្ញុំគឺជាអ្នកប្រែចិត្តជឿថ្មី ។ ហើយដំណើររបស់ខ្ញុំគឺជាដំណើរមួយដ៏អស្ចារ្យ ។ ខ្ញុំមានអារម្មណ៍ថាវាគឺដំណើរក្នុងជីវិតថ្មីមួយទាំងស្រុង ។ ហើយនៅពេលយើងចាប់យកជំហាននោះ នៅក្នុងដំណើររបស់យើង នោះអព្ភូតហេតុនឹងកើតឡើង » ។

ថេលើរ ពុំគ្រាន់តែយល់ដឹងអំពីការអញ្ជើញឲ្យមកប៉ុណ្ណោះទេ — គាត់ថែមទាំងដឹងអំពីប្រភពនៃការអញ្ជើញនោះផងដែរ ។ គាត់បានសង្កេតឃើញថា « នៅក្នុងពិភពលោកយើងនេះ យើងពុំបានយកចិត្តទុកដាក់អំពីអ្វីដែលនាំយើងមកកាន់ផែនដីនេះឡើយ មែនទេ ? យើងផ្ដោតចិត្តទុកដាក់នៅក្នុងមុខរបររបស់យើង និងបច្ចេកវិទ្យា ហើយសារលិខិតមួយដែលហាក់ដូចជាសំខាន់ចំពោះខ្ញុំនោះគឺ ការដាក់ព្រះគ្រីស្ទជាអាទិភាពទីមួយ ។ យើងគប្បីធ្វើតាមគំរូរបស់ពួកអ្នកត្រួសត្រាយដែលពួកគេបានធ្វើគឺ — [ ពួកគេ ] បានផ្ដោតសំខាន់លើព្រះគ្រីស្ទ » ។

*តាម* គឺជាការអញ្ជើញមួយផ្សេងទៀត ។ នៅក្នុងសកម្មភាពដើរត្រួសត្រាយ អ៊ីធិន ជី បានទទួលការយល់ដឹងកាន់តែច្បាស់អំពីពាក្យនេះ ។ គាត់បានថ្លែងថា « ជួនកាលខ្ញុំគ្មានអារម្មណ៍ល្អឡើយនៅក្នុងសកម្មភាពដើរត្រួសត្រាយ ឬខ្ញុំមានអារម្មណ៍ហាក់ដូចជាបាក់ទឹកចិត្ត » ។ ប៉ុន្តែខ្ញុំក៏បានដឹងថាអ្នកត្រួសត្រាយក៏មានអារម្មណ៍បែបនោះផងដែរ » ។

អ៊ីធិន ធ្លាប់ឆ្ងល់ពីមូលហេតុដែលពួកអ្នកត្រួសត្រាយពីជំនាន់ដើម មានឆន្ទៈធ្វើអ្វីដែលពួកគេបានធ្វើ ។ គាត់និយាយថា « ខ្ញុំមានអារម្មណ៍ថាខ្ញុំអាចនឹងចុះចាញ់ ។ ប៉ុន្តែពេលខ្ញុំគិតអំពីរឿងនោះ ខ្ញុំហាក់ដូចជាដឹងថា ដោយសារពួកគេស្រឡាញ់ព្រះអង្គសង្គ្រោះ ហើយពួកគេមានសេចក្ដីសង្ឃឹមថាពួកគេអាចប្រែកាន់តែប្រសើរឡើងតាមរយៈទ្រង់ ។ ខ្ញុំក៏ចង់សាកល្បងធ្វើបែបនោះដែរ » ។

ពីមុនអ៊ីធិនចូលរួមសកម្មភាពការធ្វើដំណើរនេះ គាត់បានអានរឿងអំពីពួកអ្នកត្រួសត្រាយកាលពីជំនាន់ដើម មានអារម្មណ៍ថាមានទំនាក់ទំនងជាមួយពួកគេ ហើយត្រូវបានបំផុសគំនិតដោយសារសេចក្ដីជំនឿរបស់ពួកគេក្នុងការធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។ ហើយឥឡូវនេះតើអ៊ីធិនកំពុងធ្វើអ្វី ? គាត់កំពុងរៀបចំខ្លួនទទួលការហៅបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។ ដោយគោរពតាមការទូន្មានរបស់ប្រធាន ម៉នសុន គាត់កំពុងត្រៀមខ្លួនបង្ហាញអ្នកដទៃអំពីមាគ៌ាដែលត្រូវដើរតាម ។

តើយើងគួរតែមកពីណា ? តើនរណាដែលយើងគួរតែដើរតាម ? ព្រះអង្គសង្គ្រោះប្រាប់យើងថា ៖ « ចូរមកតាម *ខ្ញុំ* » ( លូកា ១៨:២២ ការគូសបញ្ជាក់បានបន្ថែម ) ។ នៅពេល ហាម៉ូនី បានចេញពីផ្ទះដើម្បីចូលរួមការធ្វើដំណើរនោះ នាងបានឃើញជំនួយរបស់ព្រះអម្ចាស់នៅក្នុងបទពិសោធន៍របស់នាង ។ នាងបានដឹងថា នាងកំពុងដើរតាមទ្រង់ ។

ផ្លូវធ្វើដំណើររបស់ ហាម៉ូនីទៅកាន់សកម្មភាពធ្វើដំណើររបស់ស្តេក ខុសពីផ្លូវធ្វើដំណើររបស់អ្នកដទៃទៀត ។ ក្នុងវ័យ ១៥ ឆ្នាំនាងបានដឹងថា ខ្លួនមានជំងឺមហារីកស្បែកក្នុងសណ្ឋានដ៏កម្រកើតមានមួយ ។ នាងពុំអាចចូលរួមក្នុងសកម្មភាពធ្វើដំណើររបស់ស្តេកនាងបានឡើយ ។ នាងបាននិយាយថា « ខ្ញុំពិតជាស្ដាយខ្លាំងណាស់ » ។

បួនឆ្នាំក្រោយមកនៅពេល ស្តេករបស់នាងបានប្រកាសអំពីសកម្មភាពធ្វើដំណើរមួយទៀត នោះហាម៉ូនី បានជាសះស្បើយពីជំងឺមហារីកនោះ ។ ប៉ុន្តែកាលនាងអាយុ ១៩ ឆ្នាំ នាងបានគិតថានាងពុំអាចចូលរួមសកម្មភាពនោះបានឡើយ ។ ក្រោយមកនាងទទួលការហៅឲ្យចូលរួមដោយធ្វើជាអ្នកដឹកនាំសកម្មភាពនោះ ។ នាងបាននិយាយថា « វាគឺជាទីបន្ទាល់មួយសម្រាប់ខ្ញុំថា ព្រះអម្ចាស់ជ្រាបដឹងថាពួកយើងជានរណា ហើយទ្រង់ជ្រាបដឹងអំពីបំណងប្រាថ្នានៃដួងចិត្តរបស់យើង ហើយប្រសិនបើបំណងនោះសុចរិតហើយល្អ នោះទ្រង់នឹងប្រទានពរដល់យើង » ។

ហាម៉ូនី បានផ្ដល់ការទូន្មានដើម្បីជួយពួកយើងនៅពេលយើងជួបនឹងការសាកល្បង ៖ « ចំពោះអស់អ្នកដែលកំពុងជួបការលំបាក ខ្ញុំសូមនិយាយថា ចូរពឹងផ្អែកលើព្រះអម្ចាស់ចុះ ។ ទ្រង់គង់នៅទីនោះដើម្បីជួយអ្នក ។ ទ្រង់ស្រឡាញ់យើង ហើយទ្រង់នឹងពុំឲ្យយើងបរាជ័យឡើយ ។ យើងត្រូវឈោងដៃយើងទៅរកទ្រង់ ហើយទ្រង់នឹងជួយយើងនៅក្នុងដំណើរត្រួសត្រាយរបស់យើង » ។






### អ្នកត្រួសត្រាយ — ដូនតាខាងវិញ្ញាណរបស់យើង

« ខ្ញុំគ្មានដូនតានៅក្នុងចំណោមអ្នកត្រួសត្រាយសតវត្សរ៍ទី ១៩ ឡើយ ។ ប៉ុន្តែចាប់តាំងពីថ្ងៃដំបូងដែលខ្ញុំក្លាយជាសមាជិកសាសនាចក្រនេះ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងអ្នកត្រួសត្រាយពីជំនាន់ដើមនោះ ដែលបានឆ្លងកាត់វាលទំនាប ។ ពួកគេគឺជាដូនតាខាងវិញ្ញាណរបស់ខ្ញុំ ហើយពួកគេក៏ជាដូនតាខាងវិញ្ញាណសម្រាប់សមាជិកម្នាក់ៗ និងគ្រប់រូបនៃសាសនាចក្រផងដែរ » ។

ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ « **The Global Church Blessed by the Voice of the Prophets** » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០២ ទំព័រ ១០ ។

## អ្នកអាចក្លាយជាអ្នកត្រួសត្រាយ

ប្រសិនបើអ្នកពុំធ្លាប់ចូលរួមសកម្មភាពដើរត្រួសត្រាយទេ អ្នកនៅតែអាចធ្វើជាអ្នកត្រួសត្រាយ ។ អ្នកពុំចាំបាច់ត្រូវពាក់មួក ឬអូសរទេះរុញឡើយ ។ អ្នកគ្រាន់តែធ្វើតាមព្រះយេស៊ូវគ្រីស្ទ ដូចពួកអ្នកត្រួសត្រាយកាលពីជំនាន់ដើមបានធ្វើ ។ ដូចប្រធាន ម៉នសុន បានមានប្រសាសន៍ថា ការធ្វើបែបនោះ អ្នកនឹងក្លាយជា « មនុស្សដែលដើរទៅមុនដើម្បីរៀបចំ ឬបើកផ្លូវសម្រាប់មនុស្សដទៃទៀតឲ្យដើរតាម » ។

ប្រសិនបើអ្នកមានឱកាសចូលរួមសកម្មភាពដើរត្រួសត្រាយ សូមរីករាយនឹងសកម្មភាពនោះចុះ ! ហើយនៅពេលសកម្មភាពនោះចប់ ហើយអ្នកទុករទេះរបស់អ្នកនៅមួយកន្លែង ចូរកុំភ្លេចទីបន្ទាល់អំពីការត្រួសត្រាយរបស់អ្នកដែលមានក្នុងសកម្មភាពនោះឡើយ ។ សូមនាំយកទីបន្ទាល់នោះមកជាមួយអ្នក ។

អ្នកគឺជាអ្នកត្រួសត្រាយដ៏ពិតប្រាកដ អ្នកត្រួសត្រាយនាសម័យទំនើបនេះ ។ ជាមួយនឹងអ្នកត្រួសត្រាយដ៏អស្ចារ្យបំផុតគឺ — ព្រះអង្គសង្គ្រោះ — ជាមគ្គុទ្ទេសក៍របស់អ្នក នោះអ្នកនឹងទទួលបានជោគជ័យជាប្រាកដ ! ■

កំណត់ចំណាំ
1. ថូម៉ាស អេស ម៉នសុន « True to the Faith of Our Forefathers » *Liahona,* ខែ កក្កដា ឆ្នាំ ២០១៦ ទំព័រ ៤ ការដកស្រង់ *The Compact Edition of the Oxford English Dictionary* ( ឆ្នាំ ១៩៧១ ) « pioneer » ។
2. ថូម៉ាស អេស ម៉នសុន « True to the Faith of Our Forefathers » ទំព័រ ៤–៥ ។

ដើម្បីជួបថេលើ, អ៊ីធិន និង ហាម៉ូនី និងអ្នកត្រួសត្រាយដទៃទៀតក្នុងសម័យទំនើបនេះ សូមមើលវីដេអូនេះនៅគេហទំព័រ **lds.org/go/pioneer717.**

អ្នកអាចអានរឿងរបស់ពួកអ្នកត្រួសត្រាយនៅគេហទំព័រ **lds.org/go/handcart717.**



# មួយបទសម្រាប់ ចម្រៀង ម៉ាណុន

*ឱនេះជាសកម្មភាពមួយដែលពោរពេញដោយការកម្សាន្ត ប្រកបដោយការបង្ហាញនូវសេចក្ដីស្រឡាញ់ដ៏ខ្លាំងចំពោះយុវនារីម្នាក់ ។*

**ដោយ វីធោឌ អិម រ៉មនី**
ទស្សនាវដ្ដីសាសនាចក្រ

ក្រុមយុវនារីមានចិត្តរំភើបជាខ្លាំង ។ តាមពិតទៅ សមាជិកនៅទូទាំងវួដក្នុងប្រទេសបារាំងភាគខាងត្បូងមានចិត្តរំភើបជាខ្លាំង ។ ដើម្បីលើកកម្ពស់ឲ្យមានសាមគ្គីភាពកាន់តែប្រសើរឡើង នោះថ្នាក់ដឹកនាំបានគ្រោងសកម្មភាពសង្គមវួដមួយ ដោយមានទទួលទានអាហារ និងការកម្សាន្ត ។ ដោយដឹងថាក្រុមប៊ីហៃ ម៉ែម៉េត និង ឡូរ៉ល បានរៀនច្រៀងចម្រៀង និងរាំរួចជាស្រេចអំឡុងពេលនៃសកម្មភាពរបស់ពួកគេ នោះថ្នាក់ដឹកនាំបានអញ្ជើញពួកគេឲ្យផ្ដល់ការសម្ដែងនាពេលល្ងាចមួយ ។

ដូច្នោះហើយ យុវនារីនៅក្នុងវួដនោះបានចាប់ផ្ដើមខំប្រឹងប្រែងហាត់ — គឺគ្រប់គ្នាទាំងអស់ លើកលែងតែម្នាក់ប៉ុណ្ណោះ ។ ម៉ាណុនពុំអាចសម្ដែងបានឡើយ ។ គាត់កំពុងទទួលការព្យាបាលជំងឺមហារីកអស់រយៈពេលជាងពីរឆ្នាំហើយ ។

ម៉ាណុន ស៊ី អាយុ ១៦ ឆ្នាំ នៅតែអាចចូលរួមប្រជុំ និងសកម្មភាពនានាតាមលទ្ធភាពដែលនាងអាចធ្វើបាន ហើយនាងតែងតែចែកចាយស្នាមញញឹមដ៏រួសរាយទោះបីជានាងកំពុងជួបនូវឧបសគ្គក្ដី ។ ប៉ុន្តែអំឡុងពេលទទួលការព្យាបាលដោយចាក់គីមី ជួនកាលគាត់ខ្សោយពុំអាចធ្វើអ្វីបានឡើយ ក្រៅតែពីដេកប៉ុណ្ណោះ ។ សមាជិកវួដបានតមអាហារ និងអធិស្ឋានជាច្រើនដងសម្រាប់គាត់ ។ គ្មាននរណាម្នាក់រំពឹងថា គាត់មកហាត់សម ឬរាំបានឡើយ ។

ប៉ុន្តែគាត់ *អាច* ចូលរួមទទួលទានអាហារពេលល្ងាច ។ ដូច្នេះតើហេតុអ្វីពុំអាចធ្វើសកម្មភាពនាល្ងាចនោះសម្រាប់ ម៉ាណុនទៅ ?

## ល្ងាចដ៏មានភក្ដីភាព

សមាជិកគ្រប់គ្នាមានក្ដីរំភើបចំពោះយោបល់នោះ ។

អិមម៉ា អេស អាយុ ១៦ ឆ្នាំ ពន្យល់ថា « យើងចង់ឲ្យ ម៉ាណុន ទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ពីវួដ និងការគាំទ្រដល់នាង ។ ប្រសិនបើវួដរបស់យើងចង់មានសាមគ្គីភាពកាន់តែច្រើន តើមានវិធីណាដែលប្រសើរជាងការធ្វើការជាមួយគ្នាដើម្បីបង្ហាញសេចក្ដីស្រឡាញ់ចំពោះម៉ាណុននោះ ? »

សមាជិកវួដទាំងមូលបានចូលរួមនៅក្នុងការរៀបចំ ។ ក្រុមគ្រួសារនានាបានទទួលការចាត់តាំង ឲ្យនាំយកអាហារសម្រាប់ពេលល្ងាច សមាគមសង្គ្រោះបានជួយដេរសម្លៀកបំពាក់សម្ដែងសម្រាប់យុវនារី យុវមជ្ឈិមវ័យបានផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស ( អគ្គីសនី សំឡេង និងវីដេអូ ) សម្រាប់ការហាត់សម និងការសម្ដែងលើកចុងក្រោយ ហើយពួកបងប្អូនប្រុសខាងបព្វជិតភាពបានជួយរៀបចំតុ និងកៅអី ។

កិច្ចការទាំងនេះបានធ្វើរួចជាស្រេចដោយសមាជិកវួដ ដែលពួកគេរស់នៅឆ្ងាយៗពីគ្នានៅក្នុងតំបន់ដ៏ធំនោះ ។ អាវអ៊ីអូឡា វី អាយុ ១៦ ឆ្នាំ និយាយថា « យុវវ័យនៅក្នុង

រចនារូបភាពដោយ អេលីស្សាបែត ថៃឡ័រ



*ចាប់ពីខាងឆ្វេង ៖ អិមម៉ា បាននិពន្ធចម្រៀង យុវនារីសម្ដែង ម៉ាណុនចូលរួមជាភ្ញៀវកិត្តិយស ហើយយុវវ័យ និងថ្នាក់ដឹកនាំទាំងអស់បានជួយគ្នា ។*

រួដមានភាពជិតស្និទ្ធគ្នាខាងវិញ្ញាណ ប៉ុន្តែពួកយើងរស់នៅដាច់ឆ្ងាយពីគ្នាណាស់ ។ យើងពុំឃើញគ្នានៅសាលារៀនឡើយ ដោយសារពួកយើងរស់នៅក្នុងទីក្រុងផ្សេងគ្នា ដូច្នេះពួកយើងបានខិតខំយ៉ាងខ្លាំងដើម្បីប្រាកដថាគ្មានពួកយើងណាម្នាក់ត្រូវបានពុំរាប់រកគ្នាឡើយ » ។

អ៊ីនកា អេស អាយុ ១៥ ឆ្នាំ និយាយថា « យើងក៏បន្តទាក់ទងគ្នាគ្រប់ពេល យើងមានអំណរគុណចំពោះទូរសព្ទដៃណាស់ ។ យើងបង្រៀនគ្នាទៅវិញទៅមកដោយការចែកចាយនូវបទពិសោធន៍ផ្សេងៗគ្នារបស់ពួកយើង ។ យើងដឹងថាយើងអាចពឹងពាក់គ្នាបាន ហើយយើងព្យាយាមធ្វើជាគំរូល្អដល់គ្នាទៅវិញទៅមក » ។ យុវនារីទាំងនេះចូលចិត្តនៅជាមួយគ្នាគ្រប់ពេលដែលពួកគេអាចធ្វើបាន បានរកឃើញថាការហាត់សមសម្រាប់ការសម្ដែង សម្រាប់អាហារពេលល្ងាចនោះ បានផ្ដល់នូវឱកាសបន្ថែមទៀតក្នុងការពង្រឹងមិត្តភាពកាន់តែជិតស្និទ្ធឡើង ។

អ៊ីនកា ពន្យល់ថា « ពីមុនយើងចាប់ផ្ដើមហាត់សម ខ្ញុំមានការខ្មាសអៀន ។ ខ្ញុំខ្លាចថាខ្ញុំធ្វើខុស ។ ប៉ុន្តែនៅពេលយើងរាំជាក្រុម ខ្ញុំបានទុកការខ្មាសអៀននោះមួយអន្លើរ ។ ខ្ញុំបានដឹងថា វាគឺជាពេលមួយដើម្បីបង្ហាញសមាជិករួដថា យើងបានខិតខំខ្លាំងប៉ុណ្ណា » ។

សម្រាប់ ម៉ាណុន វិញមានទាំងការបន្ទាបខ្លួន និងការអណិតអាសូរ ។ នាងនិយាយថា « នៅពេលពួកគេបានប្រាប់ខ្ញុំអំពីកម្មវិធីអាហារពេលល្ងាច និងការសម្ដែងនោះ ហើយថាខ្ញុំគឺជាភ្ញៀវកិត្តិយស ខ្ញុំបានគិតថាខ្ញុំនឹងមិនត្រូវរំខានគេឡើយ ដោយសារពួកគេខិតខំជាខ្លាំងសម្រាប់ខ្ញុំ ។ ហើយម្យ៉ាងវិញទៀតខ្ញុំមានចិត្តរំភើបដើម្បីទៅចូលរួមកម្មវិធីនោះ ! »

## ការសម្ដែងដែលពោរពេញដោយក្ដីស្រឡាញ់ និងការគាំទ្រ

មិនយូរប៉ុន្មាន កម្មវិធីនាល្ងាចនោះបានមកដល់ ហើយវាគឺជាឱកាសដ៏អស្ចារ្យដើម្បីផ្ដល់សេចក្ដីស្រឡាញ់ និងការគាំទ្រដល់ម៉ាណុន ។ អាវអ៊ីអូឡា និយាយថា « ប្រាកដណាស់ អាហារមានរសជាតិឆ្ងាញ់ណាស់ ។ នេះហើយជាប្រទេសបារាំង ! »

បន្ទាប់មកការសម្ដែង — ដែលហៅថា *spectacle* ជាភាសាបារាំង — គឺអស្ចារ្យណាស់ ។ ល្បែងកម្សាន្ត ចម្រៀង និងការរាំបានធ្វើឲ្យទស្សនិកជនមានភាពរីករាយ ។ បន្ទាប់មកយុវនារីដែលរួមគ្នាជាក្រុមចម្រៀងបានផ្ដល់នូវការសម្ដែងមួយដ៏អស្ចារ្យ ។ ពួកគេបានផ្ញើចម្រៀងនោះដល់ម៉ាណុន ជាចម្រៀងដែលអិមម៉ា បាននិពន្ធ និងតែងដោយខ្លួននាង ។ ទំនុកបទនៅក្នុងវគ្គបន្ទរបានបង្ហាញសេចក្ដីស្រឡាញ់ និងការគាំទ្ររបស់មនុស្សគ្រប់គ្នាដែលចង់ឲ្យម៉ាណុនដឹង ៖

*សូមកុំចុះចាញ់ឡើយ*
*ព្រោះយើងជឿជាក់លើអ្នក*
*ហើយកុំភ្លេចថាខ្លួនអ្នកជានរណា*
*ព្រោះយើងជឿជាក់លើអ្នក ។*

នៅពេលក្រុមយុវនារីបានច្រៀងចម្រៀងនោះ វាហាក់បីដូចជាសមាជិកគ្រប់គ្នានៅក្នុងរួដបានច្រៀងតាម យ៉ាងហោចណាស់បានច្រៀងនៅក្នុងចិត្តរបស់ពួកគេ ។ វាហាក់បីដូចជាចម្រៀងដ៏សាមញ្ញរបស់អិមម៉ា បានបង្ហាញអំពីមនោសញ្ចេតនាដ៏ជ្រាលជ្រៅនៅក្នុងដួងចិត្តរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយទោះជាពួកគេរស់នៅទីណាក្ដី — ដែលជាចម្រៀងស្ដីពីភាពក្លាហាន និងការអាណិតអាសូរ គ្រួសារ និងមិត្តភក្តិ សាមគ្គីភាព សេចក្ដីជំនឿ និងសេចក្ដីសង្ឃឹម និងការអធិស្ឋានឥតឈប់បានឮដល់ស្ថានសួគ៌ ។

គោលបំណងរបស់ថ្នាក់ដឹកនាំនៅក្នុងការរៀបចំសកម្មភាពសង្គមនេះ គឺដើម្បីមានសាមគ្គីភាពនៅក្នុងរួដ ។ ការប្រារព្ធកម្មវិធីនាល្ងាចនោះសម្រាប់ម៉ាណុន ពុំគ្រាន់តែជួយឲ្យសម្រេចបានគោលដៅនោះប៉ុណ្ណោះទេ វាថែមទាំងបង្កើតឲ្យមានស្មារតីដ៏រឹងប៉ឹង ក្នុងការគាំទ្រដល់ម៉ាណុន និងគ្រួសារគាត់ ព្រមទាំងការយល់ដឹងថា បុត្រគ្រប់រូបរបស់ព្រះសំខាន់ ។ អាវអ៊ីអូឡានិយាយថា « វាគឺជាគោលបំណងរបស់សាសនាចក្រ ក្នុងការជួយពួកយើងឲ្យខិតកាន់តែជិតនឹងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។ យើងដឹងថាពួកទ្រង់ស្រឡាញ់ពួកយើង ហើយថាពួកយើងពុំនៅឯកោឡើយ » ។ ■

រូបថតដោយ អែរឿន ម៉ារេ វ៉េទ្វូ


ចូរឡើងឲ្យកាន់តែខ្ពស់
« ព្រះវិញ្ញាណបន្តអញ្ជើញឲ្យយើងមានភាពកាន់តែប្រសើរ ហើយឡើងបានកាន់តែខ្ពស់ » ។
អែលឌើរ លែរី អរ ឡូរិន ក្នុងពួកចិត្តសិបនាក់ សន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៥ ។
រចនារូបថតដោយ ដាវីឌ ស្ដូឃើ

# ផ្លូវទៅកាន់ស៊ីយ៉ូន

ដោយ ជេស៊ីកា ឡូសិន

ផ្អែកទៅលើដំណើររឿងពិត

**ទីក្រុង រិចម៉ន្ត រដ្ឋ មិសសួរី ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៨៦២**

« ម៉ារី តើកូនមើលឃើញអ្វីខ្លះ ? » ម្ដាយចុងរបស់ម៉ារី បាននិយាយដោយស្រទន់ពីលើគ្រែដោយកំពុងដេកឈឺ ។

ម៉ារី និយាយដោយមើលទៅក្រៅតាមបង្អួចថា « ការប្រយុទ្ធគ្នានោះហាក់បីដូចជាមកកាន់តែជិតហើយ » ។ សង្គ្រាមស៊ីវិលអាមេរិកកំពុងប្រយុទ្ធគ្នានៅចម្ងាយពីរបីគីឡូម៉ែត្រពីទីនោះប៉ុណ្ណោះ ។ សំឡេងបាញ់គ្នាឮកងរំពងពេញអាកាសតាំងពីព្រឹក ។ ម៉ារី បានងាកមើលទៅម្ដាយចុងរបស់នាងវិញ ។ « កូនសូមទោស ។ កូនគិតថា យើងពុំអាចចេញពីផ្ទះដើម្បីទៅរកវេជ្ជបណ្ឌិតឡើយ » ។

« ខិតឲ្យជិតមក » ។ ម៉ារី បានអង្គុយនៅក្បែរគ្រែ ហើយបានចាប់ដៃរបស់ម្ដាយចុងនាង ។ ម្ដាយចុងរបស់ម៉ារីបាននិយាយដោយស្ងាត់ៗថា « ម៉ាក់ដឹងថា ឪពុករបស់កូនពុំទាន់មានសុខភាពល្អនៅឡើយទេ ប៉ុន្តែកូនត្រូវនាំយកគ្រួសារយើងទៅស៊ីយ៉ូន — ប្អូនប្រុសប្អូនស្រីរបស់កូន និងកូនភ្លោះ ។ ចូរកុំបណ្ដោយឲ្យឪពុកកូនស្លាប់ឡើយ រហូតគាត់ទៅដល់ភ្នំរ៉ុកគីសិន ! សូមសន្យានឹងម៉ាក់មក ! »

ម៉ារីបានដឹងថាគ្រួសាររបស់នាងចង់ទៅទីក្រុង សលត៍ លេកយ៉ាងខ្លាំង ។ បន្ទាប់ពីពួកគេបានឮអំពីដំណឹងល្អ ហើយទទួលបុណ្យជ្រមុជទឹកមក ពួកគេបានចាកចេញពីប្រទេសអង់គ្លេសទៅចូលរួមពួកបរិសុទ្ធនៅទីក្រុងស៊ីយ៉ូន ។ ប៉ុន្តែតើវាអាចធ្វើទៅបានដែរឬទេ ? នាងបានក្រឡេកមើលទៅឪពុកនាង កំពុងអង្គុយដោយស្ងាត់ស្ងៀមនៅលើកៅអីរបស់គាត់ ។ បីឆ្នាំកន្លងមកនេះ ឪពុកនាងបានរងទុក្ខដោយការដាច់សរសៃឈាមក្នុងខួរក្បាលយ៉ាងធ្ងន់ធ្ងរ ដែលធ្វើឲ្យគាត់ពិការមួយចំហៀងខ្លួនខាងឆ្វេង ។

ម៉ារីបានដកដង្ហើមវែង ។ នាងបានខ្សឹបថា « កូនសូមសន្យា » ។

មិនយូរប៉ុន្មាន ម្ដាយចុងរបស់ម៉ារីបានស្លាប់ ។

នាព្រឹកបន្ទាប់មក ម៉ារីបានសម្រេចចិត្តថា វាដល់ពេលដែលត្រូវប្រាប់ឪពុកនាងអំពីការសន្យានោះ ។ នាងបានថ្លែងថា « កូនដឹងថាកូនមានអាយុតែ ១៤ ឆ្នាំប៉ុណ្ណោះ ប៉ុន្តែកូនត្រូវតែនាំគ្រួសាររបស់យើងទៅស៊ីយ៉ូនឲ្យបាន » ។ នាងបានឮសំឡេងកូនភ្លោះភ្ញាក់ឡើង ។ នាងបាននិយាយថា « កូនត្រូវទៅចំអិនអាហារពេលព្រឹកហើយ ។ ប៉ុន្តែសូមគិតអំពីរឿងនេះ » ។

ពីរបីថ្ងៃក្រោយមក ឪពុកបានហៅឈ្មោះរបស់ម៉ារី ។ គាត់បាននិយាយថា « អ្វីៗទាំងអស់បានរៀបចំរួចស្រេចហើយ » ។ សំឡេងរបស់គាត់នៅតែឮទ្បុលៗនៅឡើយ ដោយសារការដាច់សរសៃឈាមក្នុងខួរក្បាលនោះ ។ « ប៉ាបានលក់ដីរបស់យើង និងរ៉ែធ្យូងថ្មរបស់យើង ដើម្បីឲ្យយើងអាចទិញរទេះមួយ គោឈ្មោល គោញី និងគ្រឿងសម្ភារមួយចំនួន ។ ក្រុមរទេះនឹងចាកចេញដំណើរយ៉ាងឆាប់នេះទៅទិសខាងលិច ។ ពួកគេពុំមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយទេ ប៉ុន្តែពួកយើងអាចធ្វើដំណើរជាមួយពួកគេទៅដល់រដ្ឋអៃអូវ៉ា ។ នៅពេលយើងទៅដល់ទីនោះ យើងអាចចូលរួមជាមួយក្រុមពួកបរិសុទ្ធ ដែលធ្វើដំណើរទៅជ្រលងភ្នំសលត៍ លេក » ។



ម៉ារីបានឱបឪពុកនាង ។ « អរគុណប៉ា » ។ មិនយូរប៉ុន្មាន ពួកគេនឹងទៅស៊ីយ៉ូន !

ពេលវេលាដើរយ៉ាងលឿន ពេលម៉ារីបានជួយរៀបចំក្រុមគ្រួសារនាងដើម្បីធ្វើដំណើរ ។ នាងបានប្រាប់ខ្លួនឯងថា « អ្វីគ្រប់យ៉ាងនឹងដំណើរការយ៉ាងល្អ ។ មិនយូរប៉ុន្មានទេពួកយើងនឹងរស់នៅក្នុងស៊ីយ៉ូន » ។

ប៉ុន្តែក្រោយមកឪពុកនាងបានឈឺ ។ មាត់របស់គាត់ធ្លាក់ស្រយុងចុះម្ខាង ម៉ារីបារម្ភថាមានការដាច់សសៃឈាមក្នុងខួរក្បាលមួយផ្សេងទៀត ។

នាងបានប្រាប់អ្នកដឹកនាំក្រុមរទេះថា « គាត់ឈឺខ្លាំងណាស់ពុំអាចធ្វើដំណើរបានឡើយ ។ យើងត្រូវការពេលពីរបីថ្ងៃដើម្បីឲ្យគាត់បានធូរស្បើយសិន » ។

បុរសនោះបាននិយាយភ្លាមថា « យើងពុំអាចរង់ចាំបានឡើយ » ។ ដោយមើលមុខរបស់ម៉ារី បុរសនោះបានបន្ទន់សំឡេងរបស់គាត់ ។ « ក្មួយអាចនៅទីនេះរហូតដល់គាត់អាចធ្វើដំណើរបាន ហើយក្រោយមកក្មួយអាចទៅទាន់ពួកយើងហើយ » ។ ដោយគ្មានជម្រើសអ្វីផ្សេងទៀត ម៉ារីបានយល់ព្រម ។

មួយសប្ដាហ៍ក្រោយមក ម៉ារីបានរៀបចំគ្រួសារនាងដើម្បីធ្វើដំណើរបន្តទៅទៀត ។ នាងនិយាយប្រាប់ ដែកសិន ប្អូនប្រុសអាយុប្រាំបួនឆ្នាំរបស់នាងថា « កូនភ្លោះ និងសារ៉ាអាចជិះលើគោបាន ។ ប៉ាអាចជិះលើរទេះ ហើយឯងអាចជួយបងបណ្ដើរគោ » ។

សារ៉ាបាននិយាយដោយសំឡេងតិចៗថា « ខ្ញុំខ្លាចណាស់ » ។ នាងទើបតែមានអាយុប្រាំមួយឆ្នាំ ហើយនាងមើលទៅមានមាឌតូច កំពុងតែអង្គុយនៅលើខ្នងដ៏ធំរបស់គោ ។ កូនភ្លោះអាយុបួនឆ្នាំនោះបានមើលម៉ារីទាំងបើកភ្នែកធំៗ ។

« យើងនឹងធ្វើដំណើរឲ្យលឿន ហើយទៅទាន់ក្រុមរបស់យើង ! » ម៉ារីបានបង្ខំចិត្តនិយាយទាំងក្ដីរីករាយ ។

គ្រួសាររបស់ម៉ារីបានធ្វើដំណើរយ៉ាងឆ្ងាយអស់ជាច្រើនគីឡូម៉ែត្រ និងអស់ជាច្រើនថ្ងៃ ។ ទីបំផុត សូម្បីតែម៉ារីក៏សារភាពអំពីរឿងហេតុពិតផងដែរ ។

ក្រុមរទេះទាំងនោះពុំបានរង់ចាំពួកគេឡើយ ។ ម៉ារី និងគ្រួសារនាងត្រូវធ្វើដំណើរទៅស៊ីយ៉ូនតែឯងហើយ ។



**ទន្លេ ប្លេត រដ្ឋ ណេប្រាស្កា ឆ្នាំ ១៨៦៣**

« មើលណ៎ ! » ម៉ារីបានទាញខ្លុះគោ ហើយគោបានបន្ថយល្បឿន ។ « តើប្អូនៗគ្មានបញ្ហាអ្វីទេឬ ? » នាងបានមើលទៅប្អូនៗតូចជាងគេទាំងបីរបស់នាង ដែលកំពុងជិះនៅលើខ្នងគោ ។ ពួកគេបានងក់ក្បាល ។

ទន្លេ ប្លេត លាតសន្ធឹងនៅពីមុខពួកគេ យ៉ាងធំទូលាយហើយមានភក់ ។ ជែកសិន ប្អូនប្រុសរបស់នាងបានសួរថា « តើយើងត្រូវធ្វើអ្វីទៀត ? » គាត់មានអាយុតែប្រាំបួនឆ្នាំប៉ុណ្ណោះ ប៉ុន្តែគាត់កំពុងជួយម៉ារីបណ្ដើរគោ ។ ឪពុកទម្រេតខ្លួនលើរទេះ នៅតែឈឺដោយសារជំងឺដាច់សសៃឈាមក្នុងខួរក្បាលនៅឡើយ ។

ម៉ារីបាននិយាយថា « យើងពុំចាំបាច់ឆ្លងទន្លេនេះឡើយ ។ ប៉ុន្តែយើងអាចធ្វើដំណើរតាមដងទន្លេនេះ » ។ គ្មានផ្លូវទៅកាន់ស៊ីយ៉ូនឡើយ ប៉ុន្តែទន្លេនេះគួរតែនាំផ្លូវពួកគេឆ្ពោះទៅភាគខាងលិច ។ « ហ៊ុយៗ ម៉ារីដេញគោឲ្យទៅមុខ ! »

ម៉ារីពុំដឹងថាពួកអ្នកត្រួសត្រាយមរមនធ្វើដំណើរតាមត្រើយម្ខាងទៀតនៃទន្លេប្លេត ហើយបានទៅតាមផ្លូវមួយផ្សេងទៀតទេ ។ ដោយពុំបានឆ្លងទន្លេ នោះពួកគេបានចូលទៅក្នុងដែនដីពួកឥណ្ឌាអាមេរិកាំងដើម ។ ពួកគេពុំបានជួបរទេះផ្សេងទៀតឡើយនៅពេលពួកគេបន្តធ្វើដំណើរនោះ ។

ពួកគេចេះតែបន្តដំណើរទៅមុខ ។ ជាច្រើនសប្ដាហ៍ក្រោយមក ម៉ារីបានឃើញធូលីដីដ៏ក្រាស់បានហុយមក ។ នាងបានខ្សឹបប្រាប់គោ និងខ្លួននាងថា « ចូររឹងប៉ឹងឡើង ។ ចូររឹងប៉ឹងឡើង » ។

ពេលធូលីដីនោះឈប់ហុយពួកគេបានឃើញពួកឥណ្ឌាអាមេរិកាំងដើមមួយក្រុមតូចកំពុងជិះសេះមក ។ មានម្នាក់បានជិះសេះមកក្បែរខ្នងរទេះជាកន្លែងដែលប៉ារបស់នាងកំពុងដេក ។

ទឹកមុខរបស់អ្នកជិះសេះនោះមើលទៅមានចិត្តសប្បុរស ។ គាត់បានសួរដោយចង្អុលទៅឪពុកនាងថា « តើគាត់ឈឺឬ ? »

ម៉ារីបាននិយាយតិចៗថា « ចាស៎ » ។ បុរសនោះបានស្រែកដោយនិយាយជាភាសារបស់គាត់ ហើយមានបុរសមួយចំនួនបានជិះសេះមកយ៉ាងលឿន ។

ម៉ារីបានសម្លឹងមើលទៅលើមេឃ ។ នាងបានប្រាប់ជែកសិន ថា « យើងនឹងឈប់នៅទីនេះ » ។ នាងបានលើកសារ៉ា និងកូនភ្លោះចុះក្រោម ។

ជែកសិនបាននិយាយថា « ម៉ារីមកមើលនេះ ! » បុរសដែលមានទឹកមុខសប្បុរសនោះបានជិះសេះមករកពួកគេ ដោយយួរអ្វីមួយធូន់នៅក្នុងដៃគាត់ ។

បុរសនោះនិយាយថានេះជា « ទាព្រៃ និងទន្សាយ ។ សម្រាប់អ្នកទាំងអស់គ្នា » ។ ម៉ារីគ្រាន់តែឈរសម្លឹង ដោយពុំអាចថ្លែងរួច នៅពេលបុរសនោះទម្លាក់



សត្វដែលគាត់បានសម្លាប់ទាំងនោះមកក្នុងដៃនាង ។ គាត់បានងក់ក្បាល ហើយជិះសេះទៅវិញខណៈដែលពន្លឺព្រះអាទិត្យកំពុងភ្លឺចែងចាំង ។

ម៉ារីបានបន្លឺសំឡេងថា « អាហារ ! ។ សាច់ ! » ។ អំណោយរបស់បុរសនោះពិតជាអព្ភូតហេតុមួយ ។

មានអព្ភូតហេតុជាច្រើនទៀតបានកើតមាននៅក្នុងដំណើររបស់ពួកគេ ។ គោព្រៃមួយហ្វូងបានមកក្បែរពួកគេ ប៉ុន្តែក្រោយមកបានវាងចេញពីរទេះ ដោយទៅតាមផ្លូវរៀងៗខ្លួន ។ ព្យុះដីហុយបានបក់បោកនាំយកកូនភ្លោះម្នាក់ធ្លាក់ចូលក្នុងទន្លេ ប៉ុន្តែម៉ារីបានសង្គ្រោះនាងបានមកវិញ ។

ប៉ុន្តែ ការធ្វើដំណើរនោះនៅតែមានការលំបាក ។ រទេះគោមានសភាពចាស់ទ្រុឌទ្រោមរាល់ថ្ងៃ ហើយមើលទៅគោកាន់តែខ្សោយទៅៗ ។ ចំណែកឯដីវិញជាដីចំណោត ហើយមានសុទ្ធតែថ្ម ។ ភ្នំនានាពិបាកឆ្លងកាត់ ។ ប៉ុន្តែម៉ារី និងគ្រួសារនាងបន្តធ្វើដំណើរទៅមុខដោយសន្សឹមៗ ។

ពួកគេទើបតែចុះមកពីកំពូលភ្នំដ៏ខ្ពស់មួយ ពេលម៉ារីបានឃើញបុរសម្នាក់កំពុងបររទេះមករកពួកគេ ។

នាងបាននិយាយទៅជែកសិន ថា « ប្រហែលជាគាត់អាចប្រាប់ផ្លូវពួកយើងទៅទីក្រុងលីហៃ ! » ។ ពួកគាត់មានឪពុកមាម្នាក់រស់នៅទីនោះ ។

នៅពេលនាងបានសួរតើពួកនាងកំពុងនៅទីណា បុរសនោះបាននិយាយថា « ក្មួយកំពុងនៅជ្រលងជ្រោះ អេខូ នៅមិនឆ្ងាយប៉ុន្មានពីជ្រលងភ្នំ សលត៍ លេកឡើយ ។ ប៉ុន្តែតើមនុស្សទាំងអស់នៅក្នុងក្រុមរបស់ក្មួយនៅឯណា ? »

នាងបានប្រាប់រឿងទាំងអស់ដល់បុរសនោះ ហើយគាត់បានស្ដាប់នាងដោយក្ដីភ្ញាក់ផ្អើល ។ « ក្មួយបានធ្វើដំណើរដោយខ្លួនឯងចម្ងាយ ១៦០៩ គីឡូម៉ែត្រឬ ? » គាត់បានគ្រវីក្បាលដោយការកោតសរសើរ ។ « ក្មួយជាក្មេងស្រីម្នាក់ដ៏ក្លាហាន ។ ពូសូមប្រាប់ផ្លូវក្មួយទៅកាន់ទីក្រុងលីហៃ ។ ក្មួយជិតទៅដល់ទីនោះហើយ » ។

ខណៈដែលបុរសនោះបានដកយកផែនទីសាមញ្ញមួយដែលប្រឡាក់ដីចេញមក ម៉ារីបាននិយាយតិចៗដាក់ខ្លួននាងថា « ជិតដល់ទីនោះហើយ ។ ជិតដល់ស៊ីយ៉ូនហើយ ។ ខ្ញុំគិតថាទីបំផុត យើងអាចធ្វើដំណើរទៅដល់ទីនោះហើយ » ។

ម៉ារី និងគ្រួសារនាងបានធ្វើដំណើរទៅដល់ទីក្រុងលីហៃរដ្ឋយូថាហ៍ ។ ក្រោយមកនាងបានរៀបអាពាហ៍ពិពាហ៍ ហើយមានគ្រួសារផ្ទាល់ខ្លួននាងដ៏ធំមួយ ។ គំរូនៃសេចក្ដីជំនឿ និងភាពក្លាហានរបស់នាងបានផ្ដល់ពរដល់មនុស្សជាច្រើន ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ តិចសាស ស.រ.អា ។*



# តមអាហារ សម្រាប់ ព្យាការី

*ស៊ីលីអូទីស្រឡាញ់ប្រធានឃីមបឺល ។ នាងចង់ឲ្យលោកបានធូរស្បើយ ។*



ចេនារូបភាពដោយ យ៉ារេឌ បេិកស្រ្តេន

**ដោយ រ៉េបេកា ជេ ខាលសុន**
ផ្អែកទៅលើដំណើររឿងពិត

« *Feed thou our souls, fill thou our hearts, and bless our fast, we pray* » ( ទំនុកតម្កើង *លេខ ១៣៨* ) ។

*រឿងនេះបានកើតឡើងនៅក្នុងប្រទេសតុងហ្គាក្នុងឆ្នាំ ១៩៨១ ។*

ស៊ីលីអូទី បានដើរពីសាលារៀនទៅផ្ទះដោយដើរកាត់ដើមល្ហុង និងស្វាយដែលមានផ្លែទុំក្រហមស្រស់ ។ នៅពេលនាងបានឃើញផ្លែឈើទាំងនោះ នាងចាំថានាងឃ្លានយ៉ាងខ្លាំង ។ នាងក៏បានចាំផងដែរថា ថ្ងៃនេះគឺជាថ្ងៃពិសេស ។ ថ្ងៃនេះសមាជិកគ្រប់រូបនៅក្នុងស្តេករបស់នាង នៅក្នុងប្រទេសតុងហ្គាកំពុងតមអាហារសម្រាប់ព្យាការី ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃីមបឺល ។ ព្យាការីឈឺ ហើយលោកត្រូវទទួលការវះកាត់ ។ យប់នេះសមាជិកគ្រប់រូបនឹងជួបគ្នានៅក្នុងស្តេកដើម្បីអធិស្ឋាន ហើយបញ្ចប់ការតមអាហាររបស់ពួកគេជាមួយគ្នា ។

នៅពេលស៊ីលីអូទី បានទៅដល់ផ្ទះរបស់នាង នាងបានឆ្ងុយក្លិនម្ហូបដែលកំពុងចម្អិននៅក្នុង ‘umu ( *អ៊ូមូ* ) នៅលើចង្ក្រាន ។ ពោះរបស់នាងបានកូរ ។ ស៊ីលីអូទី រីករាយណាស់ដែលនាងមានអាយុគ្រប់គ្រាន់ល្មមដើម្បីតមអាហារបាន ប៉ុន្តែការតមអាហារនៅថ្ងៃទៅរៀនគឺពិបាកខ្លាំងជាងការតមអាហារនៅថ្ងៃអាទិត្យ ។

ស៊ីលីអូទីព្យាយាមបំភ្លេចថានាងឃ្លានខ្លាំងណាស់ ។ នាងបានរកអុស ហើយបានបោសសម្អាតស្លឹកឈើដែលបានធ្លាក់មកពីដើមចំប៉ាដក់ខ្ពស់ៗដ៏ស្រស់ស្អាតដែលផ្តល់ម្លប់នៅរានហាលរបស់នាង ។

ស៊ីលីអូទី បានគិតនៅពេលនាងបានលាងដៃរបស់នាងបន្ទាប់ពីការបោសសម្អាតនោះថា « ព្រះវរបិតាសួគ៌នឹងយល់ប្រសិនបើខ្ញុំគ្រាន់តែចឹបទឹកបន្តិច » ។ ក្រោយមកនាងបានគិត



អំពីសេចក្ដីស្រឡាញ់ដ៏ខ្លាំងដែលនាងមានចំពោះប្រធាន ឃឹមប៊ល ។ នាងចង់ឲ្យលោកបានធូរស្បើយឡើងវិញ ។ នាងបានសម្រេចចិត្តថានាងនឹងរង់ចាំ ។

ស៊ីលីអូទី បានអង្គុយនៅលើមាត់ទ្វារ ហើយកើយក្បាលនាងនៅលើភ្លៅរបស់ម្ដាយនាង ។ នាងអស់កម្លាំងខ្លាំងណាស់ ។

ម៉ាក់នាងបាននិយាយថា « កូនអាចបញ្ចប់ការតមអាហារបានប្រសិនបើកូនចង់ » ។

ស៊ីលីអូទី បាននិយាយថា « ប៉ុន្តែកូនចង់តមអាហារ ។ កូនអាចធ្វើវាបាន » ។

នៅពេលឪពុកនាងបានមកពីធ្វើការវិញ មនុស្សគ្រប់គ្នានៅក្នុងគ្រួសារបានជួយបើកគម្រប់ *'umu* (អ៊ូមូ) នៅលើចង្ក្រាន ។ ពួកគេបានដកយកចង្វាយសាច់ជ្រូកជាចំណិតៗ ត្រី និងផ្លែចំប៉ាដក់ដែលបានដុតនៅក្នុងខ្ទះដូង ។ ក្រោយមកពួកគេបានខ្ចប់អាហារនៅក្នុងបង្វិច ហើយយួរវាចេញទៅផ្លូវដើម្បីរង់ចាំរថយន្តក្រុង ។

ពួកគេបានជួបគ្រួសារផ្សេងទៀតនៅតាមផ្លូវ មនុស្សទាំងអស់មានម្ហូបរៀងៗខ្លួនរបស់ពួកគេ ។ ពួកគេទាំងអស់បានញញឹម ហើយបាននិយាយនៅពេលពួកគេបានឡើងជិះឡានក្រុងជាមួយគ្នា ។ ស៊ីលីអូទីឃើញកន្ត្រងទំនេរតូចមួយនៅក្បែរម្ដាយនាង ។ នាងស្រង់ក្លិនអាហារដ៏ឆ្ងុយឆ្ងាញ់នោះនៅពេលឡានក្រុងកំពុងធ្វើដំណើរ ។



មេឃងងឹតហើយនៅពេលឡានក្រុងទៅដល់សាលាជំនុំ ។ នៅក្នុងអគារ ស៊ីលីអូទីបានលុតជង្គង់ ជាមួយឪពុកម្ដាយបងប្អូនប្រុសស្រីរបស់នាង និងសមាជិករាប់រយនាក់ផ្សេងទៀតនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

អំឡុងពេលអធិស្ឋាន ស៊ីលីអូទី បានអធិស្ឋានក្នុងចិត្តនាងថា « សូមទ្រង់ជួយឲ្យប្រធាន ឃឹមប៊ល បានធូរស្បើយឡើងវិញ » ។ នាងបានដឹងថាមនុស្សគ្រប់គ្នានៅក្នុងបន្ទប់កំពុងអធិស្ឋានសម្រាប់រឿងដូចគ្នា ។ អារម្មណ៍ដ៏ស្ងប់បានផុសឡើងក្នុងចិត្តនាងថា ប្រធាន ឃឹមប៊លនឹងបានធូរស្បើយ ។

នៅពេលនាងបើកភ្នែកវិញ នាងបានឃើញមនុស្សនៅជុំវិញខ្លួននាងស្រក់ទឹកភ្នែក ។ សមាជិកទាំងនេះបានតមអាហារ ហើយនាងបានតមអាហារជាមួយពួកគេ ។ វាមានការលំបាក ប៉ុន្តែនាងបានធ្វើវា !

*ប្រធាន ឃឹមប៊ល បានមានជីវិតរស់នៅបន្ទាប់ពីការវះកាត់របស់លោក ហើយបានបម្រើជាព្យាការីអស់រយៈពេលបួនឆ្នាំទៀត ។* ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ហាវ៉ៃ ស.រ.អា. ។*

**ហេតុអ្វីយើងតមអាហារ និងអធិស្ឋាន ?**

ការតមអាហារ និងការអធិស្ឋានធ្វើទៅព្រមគ្នា ។ នៅពេលយើងតមអាហារ និងអធិស្ឋានដោយសេចក្ដីជំនឿ នោះយើងកាន់តែងាយទទួលយកចម្លើយចំពោះការអធិស្ឋាន និងពរជ័យរបស់យើងមកពីព្រះអម្ចាស់ » ។

*ប្រកាសដំណឹងល្អរបស់យើង ៖ មគ្គុទេសក៍ចំពោះការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* ( ឆ្នាំ ២០០៤ ) ទំព័រ ៨១ ។

ផ្នែកមួយនៃសំណួរ

# តើខ្ញុំដឹងថា ខ្ញុំធំល្មមនឹងចាប់ផ្ដើមតមអាហារបានដោយរបៀបណា ?



នៅថ្ងៃអាទិត្យតមអាហារ យើងតែងតែមិនបរិភោគ ឬផឹកសម្រាប់អាហារពីរពេល ។ យើងក៏បង់វិភាគទានរបស់យើងសម្រាប់អាហារពីរពេលនោះ ដើម្បីជួយដល់មនុស្សដែលត្រូវការវា ។ គេហៅវាថា « ដង្វាយតមអាហារ » ។ អំឡុងពេលយើងតមអាហារ យើងអាចចងចាំអំពីពរជ័យរបស់យើង អធិស្ឋានសម្រាប់អ្នកដទៃ ហើយមានអារម្មណ៍ខិតជិតព្រះវរបិតាសួគ៌ ។ អ្នកអាចចាប់ផ្ដើមតមអាហារ នៅពេលអ្នកនឹងឪពុកម្ដាយអ្នកមានអារម្មណ៍ថាអ្នកត្រៀមខ្លួនរួចរាល់ ។ ប្រសិនបើអ្នកពុំអាចតមអាហារបាន ដោយសារបញ្ហាសុខភាព នោះអ្នកអាចនៅតែអធិស្ឋាន ហើយទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ខណៈដែលអ្នកដទៃទៀតតមអាហារ ។



វាមិនជាថ្មីទេដើម្បីតមអាហារ នៅពេលអ្នកចង់ជួយផ្ដល់ពរជ័យដល់អ្នកដទៃ ហើយទទួលអារម្មណ៍ពីព្រះវិញ្ញាណនោះ ។ វាគឺជាពេលមួយដ៏ប្រពៃដើម្បីតមអាហារ បន្ទាប់ពីអ្នកជ្រមុជទឹក ។

**អេឌី អូ អាយុ ៩ ឆ្នាំ រដ្ឋ កាលីហ្វូញ៉ា ស.រ.អា.**



ខ្ញុំបានដឹងថាខ្ញុំធំល្មមដើម្បីចាប់ផ្ដើមតមអាហារ នៅពេលខ្ញុំមានអារម្មណ៍ថា ខ្ញុំចង់ធ្វើវា ហើយព្រះវិញ្ញាណបរិសុទ្ធបានប្រាប់ខ្ញុំថា ខ្ញុំធ្វើរឿងត្រឹមត្រូវ ។ នៅពេលខ្ញុំចាប់ផ្ដើមតមអាហារខ្ញុំបានធ្វើវាដោយសន្សឹមៗ ។ ដំបូងខ្ញុំតមអាហារក្នុងរយៈពេលតែអាហារមួយពេលប៉ុណ្ណោះ ។ ក្រោយមកខ្ញុំសាកល្បងព្យាយាមតមសម្រាប់រយៈពេលពីរពេល ។

**អាន ឌី អាយុ ៩ ឆ្នាំ រដ្ឋនីវ៉ាដា ស.រ.អា.**



ខ្ញុំនឹងដឹងថាខ្ញុំធំល្មម ដោយសារខ្ញុំនឹងទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធប្រាប់ខ្ញុំថា វាគឺជាពេលវេលាសមស្របដើម្បីតមអាហារហើយ ។ ហើយខ្ញុំនឹងសួរម្ដាយ និងឪពុកខ្ញុំថា តើអារម្មណ៍នោះត្រឹមត្រូវឬទេ ។

**ប្រូក្លីន អ័រ អាយុ ៧ ឆ្នាំ អូកលែន ប្រទេស នូវែលសេឡង់ ។**



អ្នកអាចអធិស្ឋានទៅព្រះវរបិតាសួគ៌ដើម្បីដឹងថាពេលណាអ្នកគួរតែចាប់ផ្ដើមតមអាហារ ។ ខ្ញុំដឹងថាព្រះវរបិតាសួគ៌អាចឆ្លើយតបការអធិស្ឋានរបស់អ្នក ។

**លៀម ភី អាយុ ៧ ឆ្នាំ រដ្ឋ យូថាហ៍ ស.រ.អា.**



នៅពេលខ្ញុំទទួលបុណ្យជ្រមុជទឹក ខ្ញុំគិតថាខ្ញុំនឹងទទួលអារម្មណ៍ថា ត្រៀមខ្លួនរួចរាល់ដើម្បីចាប់ផ្ដើមតមអាហារ ។ ខ្ញុំអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ទូលសូមជំនួយ ហើយទូលសួរទ្រង់ឲ្យដឹងពីពេលវេលា និងរបៀបដែលខ្ញុំគួរតែចាប់ផ្ដើមតមអាហារ ។

**ប្រែន ខេ អាយុ ៧ ឆ្នាំ រដ្ឋ វ៉ាស៊ីងតោន ស.រ.អា.**

រចនារូបភាពដោយ ឡូអែល ហែនឌើរសុន



**ដោយ អែលឌើរ**
**ឡារី អេស ខាឆើរ**
ក្នុងពួកចិតសិបនាក់



# ការបញ្ចាំងពន្លឺរបស់អ្នក

ខ្ញុំចង់ប្រាប់ប្អូនៗអំពីក្មេងស្រីពីរនាក់ដែលខ្ញុំស្គាល់ ដែលបានបង្ហាញគំរូក្នុងការចែកចាយដំណឹងល្អ ។ ពេលកូនស្រីរបស់ខ្ញុំ នៀលលីជិតគ្រប់អាយុប្រាំបីឆ្នាំ ក្រុមគ្រួសាររបស់យើងរស់នៅស្វីស ។ នៀលលីមានចិត្តរីករាយដោយបានទទួលបុណ្យជ្រមុជទឹក ។ ពីមុនថ្ងៃខួបកំណើតរបស់នាង យើងបានធ្វើរាត្រីជួបជុំក្រុមគ្រួសារជាមួយមិត្តរបស់យើងឈ្មោះធីណា ។ អ្នកផ្សព្វផ្សាយសាសនាបានបង្រៀនធីណា ។ ប៉ុន្តែនាងពុំដឹងប្រាកដថា តើនាងចង់ជ្រមុជទឹកដែរឬអត់នោះទេ ។

បន្ទាប់ពីយើងបានបង្រៀនហើយយើងបានសូមឲ្យធីណាអធិស្ឋាន ។ ធីណាពុំសូវចេះនិយាយភាសាអង់គ្លេសច្រើនទេ ដូច្នេះនាងបានអធិស្ឋានជាភាសាចិន ។ យើងពុំយល់ពាក្យដែលនាងអធិស្ឋានទ្បើយ ប៉ុន្តែយើងមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធនៅពេលពេលនាងអធិស្ឋាន ។

ក្រោយមកនៅយប់នោះ នៀលលី បានសួរប្រសិនបើនាង និងធីណាអាចជ្រមុជទឹកនៅថ្ងៃជាមួយគ្នា ។ យើងពុំដឹងថាតើធីណាមានអារម្មណ៍យ៉ាងណាអំពីយោបល់នោះទ្បើយ ។ ប៉ុន្តែយើងទាំងអស់គ្នាបានសម្រេចចិត្តថា នៀលលី គួរតែទូរសព្ទទៅធីណា ហើយសួរនាងអំពីរឿងនោះ ។ យើងមានការភ្ញាក់ផ្អើលណាស់ដែលធីណាបានយល់ព្រម !

នៀលលី និងធីណាបានទទួលបុណ្យជ្រមុជទឹកនៅចុងសប្ដាហ៍នោះ ។ ក្រោយមក ធីណាបានប្រាប់ពួកយើងអំពីរឿងដ៏អស្ចារ្យមួយ ។ នាងបានរំឭកពួកយើងអំពីការអធិស្ឋានរបស់នាងនៅក្នុងរាត្រីជួបជុំគ្រួសាររបស់យើង ។ នៅក្នុងការអធិស្ឋានរបស់នាង នាងបានទូលសូមឲ្យព្រះវរបិតាសួគ៌ អនុញ្ញាតឲ្យនាងដឹងថាតើនាងគួរតែជ្រមុជទឹកដែរឬទេ ។ ក្រោយមកនៅពេល នៀលលីបានទូរសព្ទទៅនាយប់នោះ ធីណាបានដឹងថាព្រះវរបិតាសួគ៌បានស្ដាប់ឮការអធិស្ឋានរបស់នាង ។

មិត្តភក្ដិរបស់យើង ចាសស្មីន គឺជាគំរូល្អដល់ពួកយើងផងដែរ ។ ចាសស្មីនមានអាយុ ១២ ឆ្នាំ ។ គ្រួសាររបស់នាងបានក្លាយជាកល្យាណមិត្តរបស់យើង នៅពេលយើងនៅក្នុងប្រទេសអាស៊ីបូព៌ា ។ នៅក្នុងប្រទេសរបស់នាង សមាជិកសាសនាចក្រពុំអាចនិយាយអំពីដំណឹងល្អជាមួយអ្នកដទៃទ្បើយ ។ ការធ្វើបែបនោះគឺប្រឆាំងនឹងច្បាប់ ។ ប៉ុន្តែចាសស្មីនបានសម្រេចចិត្តថា នាងអាចចែកចាយដំណឹងល្អដោយការធ្វើតាមអ្វីដែលព្រះយេស៊ូវបានធ្វើ ។ នាងបានបង្ហាញសេចក្ដីស្រឡាញ់ និងចិត្តសប្បុរសដល់អ្នកដទៃ ។ គ្រប់កន្លែងដែលនាងទៅ ឬគ្រប់អ្វីទាំងអស់ដែលនាងធ្វើ នាងបានព្យាយាមប្រែក្លាយដូចជាព្រះយេស៊ូវ ។ នាងគឺជាគំរូដ៏ល្អបំផុតសម្រាប់អ្នកដទៃ ។

នៀលលី និងចាសស្មីន បង្ហាញពួកយើងអំពីរបៀបដែលពួកយើងអាចធ្វើជាគំរូអំពីព្រះយេស៊ូវគ្រីស្ទ ។ យើងអាចធ្វើកិច្ចការនេះបានមិនថាយើងមានអាយុប៉ុន្មាន ឬយើងរស់នៅទីណានោះទ្បើយ ។ ■


កាបូបលុយ
វេទមន្ត

ដោយ អាម៉ានដា រៃតធើរ

ផ្អែកទៅលើដំណើររឿងពិត

« *ជ្រើសរើសផ្លូវត្រូវ ហើយចូររីករាយ ។ ខ្ញុំត្រូវជ្រើសផ្លូវត្រូវជានិច្ច* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ៨២* ) ។

មែនឌី បាននិយាយថា « ខ្ញុំចាប់ឯងបានហើយ ! » នាងបានប៉ះប្អូនប្រុសរបស់នាង ហើយនាងបានហែលទឹកចេញទៅ ។ គ្រួសាររបស់មែនឌីបានស្នាក់នៅក្នុងសណ្ឋាគារ រហូតដល់ពេលពួកគេប្ដូរទីលំនៅទៅផ្ទះថ្មីរបស់ខ្លួន ។ វារីករាយណាស់ក្នុងការញ៉ាំអាហារវ៉ាហ្វើលីកម្ដៅក្ដៅឧណ្ហៗនៅក្នុងម៉ាស៊ីនកម្ដៅអាហារសម្រាប់អាហារថ្ងៃត្រង់ ។ ហើយពួកគេហែលទឹកលេងនៅក្នុងសណ្ឋាគារនោះស្ទើរតែរាល់ថ្ងៃ ។

ប៉ុន្តែមានអ្វីមួយដែលពុំសូវជាល្អនៅក្នុងការរស់នៅសណ្ឋាគារនោះ ។ ការិយាល័យរបស់អ្នកគ្រប់គ្រងសណ្ឋាគារនោះនៅជាន់ក្រោមបន្ទប់របស់ពួកគេ ហើយអ្នកគ្រប់គ្រងនោះគិតថា មែនឌី និងបងប្អូនប្រុសស្រីរបស់នាងឡូឡាណាស់ ។ គាត់បានសួរប៉ារបស់ពួកគេថា « តើខ្ញុំអាចដូលបន្ទប់ឲ្យអ្នកបានយ៉ាងដូចម្តេចទៅ នៅពេលវាឮសូរសំឡេងដូចដំរីចុះប្រេងនៅហឹងនឹងត្រចៀកបែបនេះ ? » ។

បន្ទាប់ពីបរិភោគអាហារពេលថ្ងៃហើយ ប្អូនប្រុសរបស់មែនឌី អើរ៉ុនបានលោតចេញពីគ្រែ ហើយទន្ទ្រាំលើកម្រាលឥដ្ឋឮសូរ *គ្រាំៗ* ។ មែនឌីបានគ្រវីក្បាល ហើយមើលទៅម៉ាក់ ។

ម៉ាក់បាននិយាយថា « សូមកុំលោត សូមដើរថ្នមៗ » ។

ប៉ុន្តែវាយឺតពេលទៅហើយ ។ ទូរសព្ទបានរោទិ៍ឡើង ។

មែនឌីបានគិតថា « អ៊ូ នោះ » ។

ម៉ាក់បានទទួលទូរសព្ទ ។ មែនឌីអាចស្ដាប់ឮម្ដាយរបស់នាងនិយាយសូមទោសអ្នកគ្រប់គ្រងនោះ ។

ម្ដាយនាងបានញាក់ស្មាដោយបាក់ទឹកចិត្ត ពេលគាត់ដាក់ទូរសព្ទចុះវិញ ។ គាត់បាននិយាយថា « អេដវើដ និងមែនឌី ម៉ាក់ត្រូវឲ្យអើរ៉ុន និងអ៊ីមីលីគេង ។ តើកូនអាចយក គ្រីស្ទីន និង ដានីយ៉ែលទៅដើរលេងបានទេ ? »

នៅពេលពួកគេបានចាប់ផ្ដើមដើរកាត់កន្លែងចតឡានសណ្ឋាគារនោះ មែនឌីបានឃើញអ្វីមួយតូច មានពណ៌ត្នោតនៅលើដី ។

វាគឺជាកាបូបលុយ ។ ហើយមានលុយនៅក្នុងកាបូបនោះ !

នាងបាននិយាយពេលលើកកាបូបនោះឡើងថា « នេះនែ៎ អេដវើដ ! » ។

អេដវើដ បាននិយាយថា « យើងត្រូវយកកាបូបនេះទៅការិយាល័យអ្នកគ្រប់គ្រងភ្លាម » ។

មែនឌីមានអារម្មណ៍បុកពោះ ។ ហេតុអ្វីបានជាពួកគេត្រូវយកកាបូបនោះទៅឥឡូវនេះ ? តើម៉ាក់ ឬប៉ារបស់ពួកគេមិនអាចយកទៅឲ្យគាត់នៅពេលក្រោយបានទេឬ ?

ប៉ុន្តែ មែនឌីបានដឹងភ្លាមអំពីរឿងត្រឹមត្រូវដែលត្រូវតែធ្វើ ។

ក្មេងៗបានបើកទ្វារការិយាល័យ ហើយបានដើរចូលទៅក្នុងបន្ទប់ដោយភ័យខ្លាច ។ អ្នកគ្រប់គ្រងនោះបានធ្វើមុខក្រញ៉ូវ ។ មែនឌីបាននិយាយថា « ចាស ពួកខ្ញុំបានឃើញកាបូបលុយនេះនៅកន្លែងចតឡាន » ។ ដៃរបស់នាងញ័រនៅពេលនាងដាក់កាបូបលុយនោះនៅលើតុបញ្ជា ។

បុរសម្នាក់ដែលកំពុងឈរនៅតុបញ្ជានោះបានសម្លឹងមើលមក ។ គាត់បានថ្លែងថា « នោះជាកាបូបរបស់ខ្ញុំ » ។ គាត់បានប្រញាប់មើលក្នុងកាបូបនោះ ។ « អ្វីគ្រប់យ៉ាងគឺនៅក្នុងនេះទាំងអស់ ។ អរគុណក្មួយ ! »

មែនឌីបានក្រឡេកមើលទៅអ្នកគ្រប់គ្រងនោះ ។ មុខក្រញ៉ូវរបស់គាត់បានរសាយបាត់ទៅ ហើយទឹកមុខរបស់គាត់មើលទៅគួរឲ្យរីករាយ ។

ពេលពួកគេបានចេញពីការិយាល័យនោះ ដានីយ៉ែលបានសួរថា « តើនោះពុំមែនជាកាបូបលុយវេទមន្តទេឬ ? »

អេដវើដបានសួរ « ហេតុអ្វីបងគិតថាវាជាកាបូបលុយវេទមន្ត ? »

អេដវើដបានគ្រវីក្បាល ហើយនិយាយថា

« ដោយសារកាបូបលុយនោះធ្វើឲ្យមនុស្សដែលមួរម៉ៅសប្បាយចិត្ត ! តើវាពុំមែនជាកាបូបលុយវេទមន្តទេឬ ។ គាត់សប្បាយចិត្តដោយសារយើងបានធ្វើរឿងត្រឹមត្រូវ » ។

មែនឌីបានមានអារម្មណ៍យ៉ាងពិសេសក្នុងចិត្តនាង ។ នាងពុំធ្លាប់ដឹងសោះថា ការជ្រើសរើសធ្វើទង្វើត្រឹមត្រូវធ្វើឲ្យមនុស្សរីករាយជាខ្លាំង ។

ប៉ុន្មានថ្ងៃក្រោយមក មែនឌី និងប៉ារបស់នាងបានទៅបង់ថ្លៃបន្ទប់ក្នុងសប្ដាហ៍នោះ ។ អ្នកគ្រប់គ្រងបានញញឹមដាក់មែនឌី ។ គាត់បានទូរសព្ទទៅតែម្តងគត់ ចាប់តាំងពីពេលដែលពួកគេឃើញកាបូបលុយនោះមក ហើយគាត់គ្រាន់តែទូរសព្ទទៅអរគុណចំពោះភាពទៀងត្រង់របស់ពួកគេ ។ មែនឌី មានអារម្មណ៍ថានាងបានរាប់អានមិត្តភក្ដិថ្មី ។

មែនឌីបានគិតថា « ការជ្រើសរើសត្រូវគឺជារឿងអស្ចារ្យណាស់ » ។ នាងបានលើដៃគ្រវីលា ហើយអ្នកគ្រប់គ្រងនោះបានលើកដៃគ្រវីលាដាក់នាងវិញ ។ « ហើយគាត់ពិតជាមិនមួរម៉ៅទៀតឡើយ តាំងពីពេលនោះមក » ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ណេវ៉ាដា ស.រ.អា. ។*



**ការមានចិត្តទៀងត្រង់**

ថ្ងៃមួយពេលម៉ោងចេញលេង មានអ្នកជ្រុះកាក់ម្ភៃប្រាំសេននៅលើដី ។ ខ្ញុំបានរើសវាមក ហើយទោះបីជាខ្ញុំចង់ទុកកាក់នោះក្តី ខ្ញុំបានយកវាទៅឲ្យគ្រូរបស់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍ល្អ ដោយសារខ្ញុំបានជ្រើសរើសធ្វើរឿងត្រឹមត្រូវ ។ ខ្ញុំបានរៀនថា ប្រសិនបើអ្នកឃើញអ្វីមួយដែលពុំមែនជារបស់អ្នក ហើយសូម្បីតែអ្នកចូលចិត្តវាក៏ដោយ សូមកុំយកវា ដោយសារនោះគឺដូចជាការលួចហើយ ។

ថាយលើ ប៊ី អាយុ ៧ ឆ្នាំ អ៊ូវ៉ាហ៊្គិន ស.រ.អា.

**ចម្លើយមកពីសាវក**



**ដោយ អែលឌើរ**
**អិម រ័សុល បាឡឺដ**
ក្នុងកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

# តើក្រុមប្រឹក្សាគ្រួសារជាអ្វី ?

ក្រុមប្រឹក្សាគ្រួសារ គឺជាការប្រជុំមួយនៅថ្ងៃណាក៏បានក្នុងសប្ដាហ៍ ។ វាអាចជាការប្រជុំរវាងអ្នក និងឪពុកឬម្ដាយអ្នក ឬ ជាមួយគ្រួសារទាំងមូល ។ វាគឺជាពេលដែលអ្នកអាច . . .



បិទឧបករណ៍អេឡិចត្រូនិច ហើយមើលនិងស្ដាប់គ្នាទៅវិញទៅមក ។



ប្រាប់ឪពុកម្ដាយរបស់អ្នកអំពីក្ដីបារម្ភ ឬ ការភ័យខ្លាចរបស់អ្នក ។



ដាក់គោលដៅ ហើយ សរសេរគោលដៅនោះទុក ។



ផ្ដល់ជំនួយដល់បងប្អូនខ្លួន អំឡុងពេលលំបាក ។

ក្រុមប្រឹក្សាគ្រួសារដែលមានបញ្ចូលនូវការអធិស្ឋាន អាចអញ្ជើញឲ្យមានវត្តមានរបស់ព្រះអង្គសង្គ្រោះមកក្នុងផ្ទះរបស់អ្នក ។ វាអាចជួយគ្រួសាររបស់អ្នកឲ្យសប្បាយរីករាយ ។

*ដកស្រង់ចេញពី « ក្រុមប្រឹក្សាគ្រួសារ »* Liahona, *ខែ ឧសភា ឆ្នាំ ២០១៦ ទំព័រ ៦៣–៦៥ ។*

រចនារូបភាពដោយ ស្សែជា អាបវ៉ាប៊ី

# ទីក្រុង ខឺតឡង់ និងច្បាប់ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ

*សូមកាត់រូបភាពទាំងនេះ ដើម្បីជួយអ្នកចែកចាយរឿងនានាអំពីប្រវត្តិសាសនាចក្រ !*







*អំឡុងពេលពួកបរិសុទ្ធជំនាន់មុនរស់នៅក្នុងទីក្រុង ខឺតឡង់ រដ្ឋអូហៃអូ ព្រះអម្ចាស់បានប្រាប់ពួកគេឲ្យសាងសង់ព្រះវិហារបរិសុទ្ធ ។ ( សូមអានអំពីអ្វីដែលបានកើតឡើងបន្ទាប់ពីព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លងហើយនៅក្នុង គ. និង ស. ១១០ ) ។ ព្រះអម្ចាស់ក៏បានប្រាប់ យ៉ូសែប ស្ម៊ីធ ឲ្យចាប់ផ្ដើមបង្កើតសាលាមួយ ដើម្បីបង្រៀនថ្នាក់ដឹកនាំសាសនាចក្រអំពីដំណឹងល្អ ។ បុរសៗជាច្រើននៅសាលានោះបានជក់បារី ឬចុកថ្នាំជក់ ។ យ៉ូសែប និងអិមម៉ា ពុំចូលចិត្តការជក់បារី ភាពរាយប៉ាយនៃថ្នាំជក់នោះទេ ។ នៅពេលយ៉ូសែប បានទូលសួរព្រះអម្ចាស់អំពីអ្វីដែលត្រូវធ្វើចំពោះរឿងនោះ លោកបានទទួលវិវរណៈមួយ ដែលឥឡូវនេះយើងហៅថាពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។ អ្នកអាចអានវានៅក្នុង គ. និង ស. ៨៩ ។*

អ្នកអាចស្វែងរករូបភាពអំពីប្រវត្តិសាសនាចក្របន្ថែមទៀតនៅគេហទំព័រ liahona.lds.org ។

រចនារូបភាពដោយ បេត អឹម វ៉ាយថេកឃើរ

# ព្រះយេស៊ូវបានប្រទានអាហារដល់មនុស្សជាច្រើន

ដោយ គីម វេប រៀង



ថ្ងៃមួយព្រះយេស៊ូវមានព្រះទ័យចង់នៅតែអង្គឯង ។ ទ្រង់បានឡើងជិះទូក ហើយបានបើកក្ដោងទូកយាងទៅកន្លែងស្ងប់ស្ងាត់មួយ ។ មិនយូរប៉ុន្មានក្រោយមក មានមនុស្សជាច្រើនបានតាមទ្រង់ទៅទីនោះដែរ ។



ព្រះយេស៊ូវបានបង្រៀនពួកគេ ហើយបានព្យាបាលពួកអ្នកឈឺ ។ នាល្ងាចនោះ មនុស្សទាំងនោះបានចាប់ផ្ដើមឃ្លានអាហារ ។ ពួកសិស្សរបស់ព្រះយេស៊ូវចង់ឲ្យទ្រង់ប្រាប់មនុស្សទាំងនោះឲ្យទៅទិញអាហារនៅក្នុងទីក្រុង ។

គំនូរគូរដោយ អាប៊ែល ស្គុត

ព្រះយេស៊ូវបានមានបន្ទូលប្រាប់ទៅពួកសិស្សរបស់ទ្រង់ថាឲ្យផ្ដល់អាហារដល់ពួកគេ ដើម្បីកុំឲ្យពួកគេចាកចេញទៅ ។ ប៉ុន្តែពួកសិស្សមានតែនំបុ័ងប្រាំដុំ និង ត្រីពីរប៉ុណ្ណោះ ។ វាពុំគ្រប់គ្រាន់ដើម្បីចម្អែតមនុស្សគ្រប់គ្នាបានឡើយ ។





ព្រះយេស៊ូវបានប្រទានពរដល់នំបុ័ង ហើយបេះវាជាចំណិតៗ ។ បន្ទាប់មក ពួកសិស្សបានហុចនំបុ័ងនោះទៅឲ្យមនុស្សទាំងនោះ ។ តើនឹងមានអាហារគ្រប់គ្រាន់ដែរឬទេ ?



កូនក្មេង ស្រ្តី និងបុរសរាប់ពាន់នាក់បានបរិភោគនំប៉័ង និងត្រីនោះទាំងអស់គ្នា ។ បន្ទាប់ពីពួកគេបានបរិភោគហើយ នោះនៅសល់នំប៉័ង ១២ កន្ត្រក ! វាជាអព្ភូតហេតុមួយ ។ អព្ភូតហេតុនៅតែកើតមាននៅលើផែនដីសព្វថ្ងៃនេះ ! ■

*ដកស្រង់មកពី ម៉ាថាយ ១៤:១៣–២១*

# ខ្ញុំចូលចិត្តអានព្រះគម្ពីរ



រចនារូបភាពដោយ អាប៊ីល ស្មុីត



ដោយប្រធាន ជេ រ៉ូបឺន ក្លាក ជុញ្ញ័រ
( ១៨៧១–១៩៦១ )
ទីប្រឹក្សាទីមួយក្នុង
គណៈប្រធានទីមួយ

# ពួកគេគឺជាក្រុមរទេះចុងក្រោយគេ

*នៅក្នុងក្រុមរទេះចុងក្រោយនោះមានមនុស្សដែលមានការប្តេជ្ញា មានភក្តីភាព និងភាពថ្លៃថ្នូរ ហើយលើសពីអ្វីទាំងអស់នោះគឺជាសេចក្តីជំនឿទៅលើពួកបងប្អូនប្រុស ព្រមទាំងព្រះចេស្តារបស់ព្រះ ។*



ខ្ញុំចង់និយាយអ្វីមួយអំពីក្រុមរទេះចុងក្រោយ អំពីរទេះនីមួយៗដែលបានធ្វើដំណើរដោយសន្សឹមៗនៅលើវាលទំនាប ។ . . .

. . . នៅក្នុងក្រុមរទេះចុងក្រោយនោះ ពួកគេពុំអាចមើលឃើញពួកបងប្អូនប្រុសនៅខាងមុខពួកគេជានិច្ចឡើយ ពួកគេក៏ពុំអាចឃើញផ្ទៃមេឃខៀវស្រងាត់ដែរ ដោយសារដីហុយមកពីការធ្វើដំណើរនោះ ។ ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេដែលនៅក្នុងក្រុមរទេះចុងក្រោយនោះបានបន្តឆ្ពោះទៅមុខ ទាំងអស់កម្លាំង និងហត់នឿយ ដោយមានដំបៅជើង ជួនកាលស្ទើរតែបាក់ទឹកចិត្តអស់ ប៉ុន្តែដោយសារសេចក្តីជំនឿរបស់ពួកគេថា ព្រះស្រឡាញ់ពួកគេ ថាដំណឹងល្អដែលបានស្តារឡើងវិញគឺជាការពិត ហើយថាព្រះអម្ចាស់បានដឹកនាំ និងនាំផ្លូវពួកបងប្អូនប្រុសដែលដឹកនាំនៅខាងមុខនោះ ។ នៅពេលសេចក្តីជំនឿរបស់ពួកគេបានកើនឡើង ជួនកាលពួកអ្នកដែលនៅក្នុងក្រុមរទេះចុងក្រោយនោះបានឃើញសិរីល្អនៃពិភពសេឡេស្ទាលមួយភ្លែត ដែលវាហាក់ដូចជានៅសែនឆ្ងាយ ហើយការនិមិត្តដ៏លឿននោះបានលោយបាត់ទៅ ដោយសារតែសេចក្តីត្រូវការ និងការនឿយហត់ ព្រមទាំងការឈឺចិត្ត ហើយជួនកាលជាការខកចិត្តដែលពួកគេបន្តប្រឈមមុខ ។

នៅពេលការនិមិត្តបានលោយបាត់ទៅ ចិត្តរបស់ពួកគេបានកើតទុក្ខ ។ ប៉ុន្តែពួកគេបានអធិស្ឋានម្តងទៀត ហើយបន្តឆ្ពោះទៅមុខ ដោយមានការលើកស្ទួយបន្តិចបន្តួចពីអ្នកដទៃ ដែលពុំមែនជាការលើកទឹកចិត្តច្រើននោះទេ ហើយក៏ពុំមែនដោយការលើកតម្កើងដែរ ។ . . . ប៉ុន្តែនៅក្នុងក្រុមរទេះចុងក្រោយនោះ មានមនុស្សដែលមានការប្តេជ្ញា ភក្តីភាព និងភាពថ្លៃថ្នូរ ហើយលើសពីអ្វីទាំងអស់នោះគឺជាសេចក្តីជំនឿទៅលើពួកបងប្អូនប្រុស ព្រមទាំងព្រះចេស្តារបស់ព្រះ និងភាពល្អទាំងនោះ ។ . . .

ដោយឆ្លងកាត់ដីហុយ និងធូលីដី . . . ពួកគេបានបន្តដើរទៅមុខរហូតដល់ពួកគេបានឆ្លងផុតពីជងជ្រោះនោះ ទៅដល់ជ្រលងភ្នំជាទីដែលផ្តល់កន្លែងសម្រាក និងផ្ទះដល់ពួកគេ ។ . . .

ប៉ុន្តែមនុស្សដ៏ក្លាហានរាប់រយនាក់ដែលមានសេចក្តីជំនឿដោយឥតសង្ស័យ និងមានជំនាញដ៏អស្ចារ្យនោះពុំទាន់បញ្ចប់ការធ្វើដំណើររបស់ពួកគេនៅឡើយទេ ។

បងប្រុស ព្រិកហាំ [ យ៉ង់ ] បានហៅពួកគេម្តងទៀតដើម្បីបម្រើនគរព្រះ ហើយបានបញ្ជូនពួកគេទៅតាំងលំនៅនៅក្នុងជ្រលងភ្នំ ទាំងជិត និងឆ្ងាយនៅក្នុងតំបន់ដ៏ធំធេងនៃភ្នំនោះដែលពួកគេអាចស្វែងរកទីជម្រក ។ ដូច្នេះពួកគេបានពាក់នឹមឲ្យគោរបស់ខ្លួន ហើយទឹមគោទាំងនោះ . . . រួចធ្វើដំណើរដោយសន្សឹមៗទៅកាន់ជ្រលងភ្នំថ្មីនោះ ដោយមានទំនុកចិត្ត និងសេចក្តីជំនឿទាំងស្រុងនៅក្នុងប្រាជ្ញា និងការដឹកនាំពីព្រះនៃពួកអ្នកដឹកនាំរបស់ពួកគេ ។ . . .

ហើយតាំងពីពេលនោះមកដល់ឥឡូវនេះ ពួកអ្នកត្រួសត្រាយរាប់ពាន់នាក់នេះ ជាពួកអ្នកដែលព្រះបានរើសតាំងឡើង បានបំពេញការហៅបម្រើ និងគោលដៅរបស់ពួកគេដោយរាបសា ដូចអ្វីដែលបងប្រុស ព្រិកហាំ យ៉ង់ និងអ្នកដទៃទៀតបានធ្វើចំពោះកាតព្វកិច្ចរបស់ពួកគេ ហើយព្រះនឹងប្រទានរង្វាន់ដល់ពួកគេ ។ ពួកគេគឺជាពួកអ្នកត្រួសត្រាយទាំងពាក្យសម្តី និងគំនិត ព្រមទាំងទង្វើ និងសេចក្តីជំនឿ គឺដូចជាពួកអ្នកដែលមានមុខងារលេចធ្លោទាំងនោះផងដែរ ។ ការបង្កបង្កើតនៃអាណាចក្រនៅក្នុងចន្លោះភ្នំនោះ ពុំមែនកើតឡើងដោយលាក់កំបាំងពីមនុស្សជម្រើសតែពីរបីនាក់ប៉ុណ្ណោះនោះទេ ប៉ុន្តែដោយមនុស្សជាច្រើនដែលបានមកពីប្រជាជាតិជាច្រើន ដែលបានមកហើយធ្វើកិច្ចការ ព្រមទាំងស្ថាបនា ដោយធ្វើតាមអ្នកដឹកនាំពួកគេដែលហៅដោយព្រះ ។ . . .

ដូច្នេះចំពោះមនុស្សដ៏រាបសា និងអស្ចារ្យទាំងនេះ . . . ខ្ញុំសូមបង្ហាញដោយចិត្តរាបទាបនូវសេចក្តីស្រឡាញ់ ការគោរព និងការកោតសរសើរដ៏រាបសារបស់ខ្ញុំ ។ ■

*ដកស្រង់ចេញពីសុន្ទរកថាក្នុងសន្និសីទទូទៅខែ តុលា ឆ្នាំ ១៩៤៧ « To Them of the Last Wagon » ។*

រូបថតពី GETTY IMAGES

រូបថតទទួលបានសិទ្ធិអនុញ្ញាតពីសារៈមន្ទីរសិល្បៈនៃសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ អំណោយរបស់ ជេ រ៉ូប៊ីន ក្លាក




***ពួកគេគឺជាក្រុមរទេះចុងក្រោយគេ***
**( កាលីហ្វ័រញ៉ា ឆ្នាំ ១៩៥៤ ) លីន ហ្វោសែត**

*ដោយសេចក្ដីជំនឿរបស់ពួកគេ នោះពួកអ្នកត្រួសត្រាយផ្លូវបានស្ថាបនាផ្លូវដោយក្លាហាន ដែលត្រូវបានហៅថា ការធ្វើដំណើររបស់ពួកមរមន លើចម្ងាយផ្លូវ ១៦០០ គីឡូម៉ែត្រ ទៅកាន់ជ្រលងភ្នំ សលត៍ លេក ។ ពួកអ្នកដែលនៅខាងក្រោយគេនៃក្រុមរទេះនោះពុំអាចមើលឃើញថ្នាក់ដឹកនាំរបស់ពួកគេជានិច្ចទេ ប៉ុន្តែពួកគេបានឈានទៅមុខដោយខ្ជាប់ខ្ជួន ។*

# មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ

ដំណឹងតែមួយគត់ដែលបាន

### សង្គ្រោះខ្ញុំ

ស្សឹហូបានជួបនឹងការប្រកាន់ពូជសាសន៍ និងការបដិសេធ ប៉ុន្តែគាត់បានជួបដំណឹងល្អ ហើយរៀនទុកចិត្តមនុស្សសារជាថ្មីម្ដងទៀត ។



ទំព័រ ៤៤

## សម្រាប់យុវវ័យ

ទំព័រ ៥០



### រឹងប៉ឹង

ពេញមួយសប្ដាហ៍

របៀបដែលពិធីសាក្រាម៉ង់អាចជួយអ្នកឲ្យរឹងប៉ឹងពេញមួយសប្ដាហ៍ ។

## សម្រាប់កុមារ

### ជ្រុងមួយនៃសំណួរ

តើពេលណាទើបកុមារគួរចាប់ផ្ដើមតមអាហារ ?



ទំព័រ ៧០

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02144 47258 1